# ពុទ្ធប្បវត្តិ



ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុផាត

ថ្ងៃ ១៥ កើត ខែអាសាឍ ព.ស ២៥៥៣

# ពុទ្ធប្បវត្តិ




ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា
អាត្មាភាព **យង់ សុផាត**

សម្រាប់ជាធម្មទាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ២២៥ សជណ

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា
## ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

__កម្មវត្ថុ__ : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

__យោង__ : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***ចម្លងជូន :***
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

សៀវភៅពុទ្ធប្បវត្តិនេះ ខ្ញុំព្រះករុណា អាត្មាភាព បានដកស្រង់ចេញអំពីបិដកខ្មែរ លេខ ៧៧ អដ្ឋកថាលេខ ៥៥ ដែលមានសេចក្តីគួរឲ្យជ្រះថ្លា ចំពោះព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានសន្សំបុណ្យបារមី ដើម្បីឲ្យបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដឹកនាំចម្លងសត្វលោក ឲ្យរួចផុតអំពីសេចក្តីទុក្ខក្នុងសង្សារវដ្តនេះ ការដកស្រង់មកនេះក៏មិនបានសេចក្តីពិស្តារពេកដែរ គ្រាន់តែដើម្បីឲ្យព្រះករុណាព្រះគុណម្ចាស់ និងពុទ្ធបរិស័ទបានជ្រាបថា ពុទ្ធប្បវត្តិដែលយើងធ្លាប់បានឮមកនោះ មានសម្តែងនៅក្នុងព្រះត្រៃបិដក និងអដ្ឋកថា ដែលរៀបរាប់ជារបៀប **ទូរេនិទាន អវិទូរេនិទាន** និង **សន្តិកេនិទាន** បានដល់ការពណ៌នាអំពីចរិយាវត្តរបស់ព្រះអង្គ កាលដែលព្រះអង្គនៅជាព្រះបរមពោធិសត្វ រហូតដល់បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។

សៀវភៅពុទ្ធប្បវត្តិនេះ ខ្ញុំព្រះករុណា អាត្មាភាព មិនអាចដាក់ភាសាបាលីផងបានទេ ព្រោះថា មានសេចក្តីពិស្តារពេក បើអ្នកសិក្សាត្រូវការភាសាបាលី ចូរតាមរកមើលក្នុង **គម្ពីរព្រះត្រៃបិដក** និង **អដ្ឋកថា**

ក្នុងចំណុចដែលលើកឡើងមកនីមួយៗ ចុះ ព្រោះគ្រប់ចំណុចដែលលើកឡើងមកនោះ សុទ្ធតែបានប្រាប់ពី **គម្ពីរ** ឬច្បាប់ដើម ជាមូលដ្ឋានរួចអស់ហើយ ។

ខ្ញុំព្រះករុណា អាត្មាភាព សង្ឃឹមថា សៀវភៅពុទ្ធប្បវត្តិនេះនឹងបានជាប្រយោជន៍ចំពោះបុគ្គល អ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែង ក៏ប្រសើជាងអត់ផងដែរ ខ្ញុំព្រះករុណា អាត្មាភាព និងសព្រហ្មចារី បានខំប្រឹងប្រែងអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់នៅមានខុសមិនខាន ជួនដោយចេះមិនដល់ ជួនដោយការភ្លេចភ្លាំង ជាពិសេសនោះគឺអក្ខរាវិរុទ្ធ ដូច្នេះ ខ្ញុំព្រះករុណា អាត្មាភាព សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិត ជាសប្បុរស ជួយកែលម្អ ឲ្យដល់ខ្ញុំព្រះករុណា អាត្មាភាពផងដើម្បីជាប្រយោជន៍ដល់ជាតិ សាសនារបស់យើងទាំងអស់គ្នា ។

សូមអស់មិត្តអ្នកអាន បានទទួលនូវការចេះដឹង ជាក្តៅមិត្តិកផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់ព្រះនិព្វាន ដែលជាបរិយោសាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា អាត្មាភាព បានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស **២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ ៦៤៥ ដុល្លារសហរដ្ឋអាមេរិក ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទនៅប្រមាណ ៦៥ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ១០ ព្រះអង្គផងដែរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅ **ថ្វាយបង្គំបាន ៥១ កន្លែង** បានការឧបត្ថម្ភមកអំពីឧបាសក **ឡាយ សុខុម** និងឧបាសិកា **ឌិម លក្ខណា** នៅក្នុង ព.ស **២៥៥០** ( ១០.០២.២០០៧ ) ។

ឃ

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្ដា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្ដា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះកគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស.២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស **២៥៥១** ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស **២៥៥០** ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស **២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល)** និង **ប្រាក់ដុល្លារ ៨៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសស្រីលង្កា** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១២១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៤ ព្រះអង្គផងដែរ**

ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ិម ចណ្ណា នៅក្នុង ព.ស ២៥៥១ ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

នឹកឃើញលង្កា　　នឹកឃើញកាលណា　ជ្រះថ្លាក្រៃលែង
នៅពុទ្ធស្ថាន　　១៩ កន្លែង　　ដែលខ្ញុំបានស្វែង
　　　　ទៅថ្វាយបង្គំ ។
១២១ អង្គា　　គាល់ព្រះបាទា　នាស្ថានមនោរម
លើសុមនកូដ　　ជេស្ដាឧត្ដម　　ជាកំពូលភ្នំ
　　　　ក្នុងប្រវត្តិពុទ្ធ ។
ទឹកដីលង្កា　　ទឹកដីអស្ចារ្យ　　ពេញពោរដោយឫទ្ធិ
នឹកឃើញកាលណា　ជ្រះថ្លាក្រៃពិត　ធម្មយាត្រាប្រណីត
　　　　ក្នុង ព.ស.២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស ២៥៥២ ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស ២៥៥១ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស

**២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល ) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទីពីរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គផងដែរ** បានការឧបត្ថម្ភមកអំពីឧបាសក **យឹត ស្វូណាត** ឧបាសិកា **ហ៊ុន ម៉ារ៉ានី** M. SU SOKUNORA et MmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **អ៊ុង រិទ្ធារី** ឧបាសិកា **ស្ងួន គល្យាណ** ឧបាសិកា **ស្ងួន ចរណៃ** នៅក្នុង **ព.ស ២៥៥២** ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ! ព្រះសាសនា ។

នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទីពីរ** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះដែលមានពុទ្ធបរិស័ទទៅប្រមាណ **៣៦ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៣ ព្រះអង្គផងដែរ** បានការឧបត្ថម្ភមកអំពីឧបាសក **ឆាយ អ៊ីចស៊ាង** ឧបាសិកា **ហុង គឹមសែ** ក្រោមការជ្រោមជ្រែងរបស់ឧបាសក **យន្ត សួន** នៅក្នុង **ព.ស ២៥៥២** ( ១១. ០៣. ២០០៩ ) ។

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យង់ សុង** ( ស្លាប់ ) និងញោមស្រី **ឈឹម ហាយ** ( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូន

ចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីច** ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគតកុំបីខានឡើយ សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអាសាឍ ព.ស ២៥៥៣

**ដោយសមាគមធម្មទានអរិយវង្ស យង់ សុផាត**

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

ឧបាសក សន ឈៀត ជួយប្រែ

លោកគ្រូធម្មាចារ្យ គាំ អ៊ុច ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឌិម ឌំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក អ៊ឹម វីរយ៉ា ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រឹម សុមេធ ជួយពិនិត្យអក្ខរាវិរុទ្ធ

# មាតិការឿង


| ល.រ | | ទំព័រ |
|---|---|---|
| ១ | និទានមាន ៣ | ១ |
| ២ | ទូរេនិទាន | ២ |
| ៣ | ទោសរបស់ទីចង្ក្រមមាន ៥ យ៉ាង | ១០ |
| ៤ | សំពត់សាដកដែលប្រកបដោយទោស ៩ ប្រការ | ១៤ |
| ៥ | សំពត់សម្បកឈើមានអានិសង្ស ១២ ប្រការ | ១៥ |
| ៦ | បណ្ណសាលាមានទោស ៨ ប្រការ | ១៨ |
| ៧ | គល់ឈើដែលប្រកបដោយគុណ ១០ ប្រការ | ២០ |
| ៨ | បានជាព្រះពុទ្ធប្រកបដោយធម៌ ៨ ប្រការ | ២៦ |
| ៩ | ទីបង្ករពុទ្ធវង្សទី ១ | ៤៧ |
| ១០ | កោណ្ឌញ្ញពុទ្ធវង្សទី ២ | ៥២ |
| ១១ | មង្គលពុទ្ធវង្សទី ៣ | ៥៨ |
| ១២ | សុមនពុទ្ធវង្សទី ៤ | ៦៤ |
| ១៣ | រេវតពុទ្ធវង្សទី ៥ | ៧០ |

១៤ សោកិតពុទ្ធវង្សទី ៦ .................................... ៧៦

១៥ អនោមទស្សីពុទ្ធវង្សទី ៧ .................................... ៨២

១៦ បទុមពុទ្ធវង្សទី ៨ .................................... ៨៨

១៧ នារទពុទ្ធវង្សទី ៩ .................................... ៩៤

១៨ បទុមុត្តរពុទ្ធវង្សទី ១០ .................................... ១០១

១៩ សុមេធពុទ្ធវង្សទី ១១ .................................... ១០៧

២០ សុជាតពុទ្ធវង្សទី ១២ .................................... ១១៣

២១ បិយទស្សីពុទ្ធវង្សទី ១៣ .................................... ១២០

២២ អត្ថទស្សីពុទ្ធវង្សទី ១៤ .................................... ១២៥

២៣ ធម្មទស្សីពុទ្ធវង្សទី ១៥ .................................... ១៣០

២៤ សិទ្ធត្ថពុទ្ធវង្សទី ១៦ .................................... ១៣៥

២៥ តិស្សពុទ្ធវង្សទី ១៧ .................................... ១៤០

២៦ បុស្សពុទ្ធវង្សទី ១៨ .................................... ១៤៦

២៧ វិបស្សីពុទ្ធវង្សទី ១៩ .................................... ១៥១

២៨ សិខីពុទ្ធវង្សទី ២០ .................................... ១៥៦

២៩ វេស្សភូពុទ្ធវង្សទី ២១ .................................... ១៦២

៣០ កកុសន្ធពុទ្ធវង្សទី ២២ .................................... ១៦៧

៣១ កោនាគមនពុទ្ធវង្សទី ២៣ .................................... ១៧៣

៣២ កស្សបពុទ្ធវង្សទី ២៤ .................................... ១៧៨

៣៣ ដល់ព្រមដោយសម្បត្តិទាំង ៨ ប្រការ .................... ១៨៦

៣៤ អវិទូរេនិទាន .................................... ១៩៥

៣៥ កោលាហលមាន ៣ យ៉ាង .................................... ១៩៥

៣៦ បុព្វនិមិត្ត ៤ ប្រការ .................................... ២២៤

៣៧ បរិក្ខារទាំង ៨ .................................... ២៤៩

៣៨ សន្តិកេនិទាន .................................... ២៨២

# ពុទ្ធប្បវត្តិកថា

*ពុទ្ធប្បវត្តិ* តំណាលពីប្រវត្តិ គឺដំណើរដែលប្រព្រឹត្តទៅ ឬពីរឿងរ៉ាវរបស់ព្រះមានព្រះភាគ ដរាបដល់បរិនិព្វានជាទីបំផុត ។

ពុទ្ធប្បវត្តិនេះ បានដកស្រង់សេចក្តីមកអំពីក្នុង **អដ្ឋកថាជាតក ឯកនិបាត** មានសម្តែងនិទាន ៣ យ៉ាងគឺ **១- ទូរេនិទាន** ការពណ៌នាអំពីព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង កាលនៅជាព្រះពោធិសត្វ ឈ្មោះ **សុមេធបណ្ឌិត** ដែលកើតនៅក្នុងត្រកូលព្រាហ្មណ៍ ដរាបមកដល់កើតជា **សន្តុសិតទេវបុត្រ** ដែលស្ថិតនៅនាឯស្ថានតុសិតទេវលោក ។ **២- អវិទូរេនិទាន** ការពណ៌នាអំពីព្រះពោធិសត្វ ច្យុតចាកស្ថានតុសិតទេវលោកមកកើតជាព្រះសិទ្ធត្ថកុមារ នៅក្នុងសក្យត្រកូលដរាបដល់បានត្រាស់ដឹងជាព្រះសម្ពុទ្ធនៅលើរតនបល្ល័ង្ក ក្រោមមណ្ឌលពោធិព្រឹក្ស ។ **៣- សន្តិកេនិទាន** ការពណ៌នាក្រោយអំពីព្រះសាស្តា បានត្រាស់ដឹងជាព្រះពុទ្ធ ហើយព្រះលោកនាថ បានស្តេចយាងចារិកទៅប្រោសដល់សព្វសត្វទាំងឡាយ ក្នុងទីកន្លែងផ្សេងៗ មាននិគម ជនបទជាដើម

ដរាបដល់ព្រះអង្គរំលត់ខន្ធបរិនិព្វាន ។

# ទូរេនិទាន

ក្នុងនិទាននេះមានដូចតទៅនេះ បានឮមកថា ក្នុងទីបំផុត ៤ អសង្ខេយ្យ និងមួយសែនកប្បនោះ មាននគរមួយឈ្មោះថា **អមរវតី** ក្នុងនគរនោះ មានព្រាហ្មណ៍មួយឈ្មោះសុមេធអាស្រ័យនៅ គេមានកំណើតល្អ មានគតិដ៏បរិសុទ្ធទាំងខាងចំណែកមាតា និងចំណែកបិតារាប់បាន ៧ ជួរត្រកូល នរណាមិនអាចមើលស្រាលបាន ពុំមានអ្នកតិះដៀល ដែលទាក់ទងជាមួយនឹងជាតិឡើយ មានរូបស្អាត គួរឲ្យពិតពិលរមិលមើល គួរឲ្យជ្រះថ្លា ប្រកបដោយពណ៌សម្បុរដ៏ស្រស់ផូរផង់ក្រៃលែង គេមិនប្រកបការងារអ្វីឡើយ គិតសិក្សាតែសិល្បៈរបស់ព្រាហ្មណ៍ មាតាបិតារបស់គេធ្វើកាលកិរិយា តាំងអំពីគេនៅក្នុងវ័យកំលោះម្ល៉េះ តមកមេការអ្នកចាត់ចែងផលប្រយោជន៍ បាននាំយកបញ្ជីទ្រព្យមកឲ្យមើល ថែមទាំងបានបើកឃ្លាំងមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម ជម្រាបឲ្យជ្រាបដល់ទ្រព្យសម្បត្តិ តាំងពី ៧ ជួរត្រកូលមកថា បពិត្រកុមារ ទ្រព្យមានប៉ុណ្ណេះជារបស់មាតា ប៉ុណ្ណេះ

ជារបស់បិតា ប៉ុណ្ណោះជារបស់ជីតា និងប៉ុណ្ណោះជារបស់ជីទួតជាដើម ហើយជម្រាបថា សូមកុមារចាត់ចែងកិច្ចការងារនេះចុះ សុមេធគិតថា ជីតាជាដើមរបស់យើង បានសន្សំទ្រព្យសម្បត្តិទាំងនេះទុក កាលបើសេចក្តីស្លាប់មកដល់ហើយ មិនអាចនឹងកាន់យកនូវទ្រព្យសម្បត្តិទាំងអស់នេះ សូម្បីត្រឹមតែមួយកហាបណៈទៅជាមួយខ្លួនបានឡើយ ដូច្នេះយើងនឹងធ្វើហេតុ ដែលអាចនាំយកនូវទ្រព្យសម្បត្តិទាំងអស់នេះទៅឲ្យទាល់តែបាន គេគិតឃើញដូច្នេះហើយ បានក្រាបទូលដល់ព្រះរាជាឲ្យវាយស្គរបង្ហូកប្រកាសក្នុងព្រះនគរ ឲ្យទានដល់មហាជន ហើយគេចេញបួសជាតាបស ( ដើម្បីនឹងឲ្យសេចក្តីនេះជាក់ច្បាស់ សូមពោលសុមេធកថា ក្នុងទីនេះដូចតទៅ សុមេធកថានេះ មានសម្តែងនៅក្នុងគម្ពីរពុទ្ធវង្សថា

ក្នុង ៤ អសង្ខ្យេយ្យ និងមួយសែនកប្បនោះ មាននគរឈ្មោះ **អមរវតី** ជានគរគួរពិតពិលរមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូណ៌ទៅដោយបាយ និងទឹក ទាំងមិនស្ងាត់ទៅដោយសំឡេង ១០ យ៉ាង គឺសំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងសង្ខ និង សំឡេងរថជាដើម ។

បណ្ដាបទទាំងនោះ បទថា **ទសហិ សទ្ទេហិ អវិវិត្តំ** មានសេចក្ដីថា មិនស្ងាត់ទៅដោយសំឡេងទាំងនោះ គឺមានសំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងស័ង្ខ សំឡេងរថជាដើមថា ចូរស៊ី ចូរផឹក ជានគរសម្បូរដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួង បរិបូណ៌ ដោយការងារគ្រប់យ៉ាង ។ បរិបូណ៌ដោយកែវ ៧ ប្រការ កុះករដោយជនជាតិផ្សេងៗ សម្រេច ( ដោយគ្រឿងបរិភោគ និងឧបករណ៍ទាំង-ពួង ) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ ។ វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវជាច្រើន ។ ជាអ្នករៀនមន្ត ចងចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមីក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ។

កាលនោះ តថាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្ដីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្ដីទុក្ខដូចគ្នា ( ការស្លាប់ប្រកបទៅដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន

ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។ បើដូច្នោះ អាត្មាអញ គួរតែលះបង់នូវកាយស្អុយនេះ ដែលពេញទៅដោយសាកសពផ្សេងៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្ដីត្រូវការ ហើយនឹងចៀសចេញទៅ ។ ផ្លូវនោះនឹងមានពិត ផ្លូវនោះមិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកនូវផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។ កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមានការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្ដៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះដែរ ។ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមាន ព្រះនិព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នា ក៏មានយ៉ាងនោះដែរ ។ បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹក ហើយមិនស្វែងរកស្រះ ទោសនោះមិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមានហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាងនូវកិលេសជាមន្ទិលចេញទេ ទោសនោះ មិនមែនជាទោសនៃស្រះ គឺព្រះនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ។ បុរសដែលត្រូវសត្រូវទាំងឡាយ

ចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ចេញទៅមាន តែបុរសនោះ មិនរត់ទៅ ទោសនោះមិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវ កិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោស នៃផ្លូវព្រះនិព្វានទេ គឺជាទោសរបស់ បុគ្គលនោះឯង យ៉ាងនោះដែរ ។ បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះព្យាបាលជំងឺនោះទេ ទោសនោះ មិនមែនជាទោស នៃពេទ្យនោះទេ យ៉ាងណាមិញ បុគ្គលត្រូវជំងឺ គឺកិលេសទាំងឡាយ បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកលោកគ្រូអាចារ្យ ទោសនោះ មិនមែនជាទោសនៃលោកគ្រូអាចារ្យទេ គឺជាទោសរបស់ បុគ្គលនោះឯង យ៉ាងនោះដែរ ។ (បើដូច្នោះ) គួរតែអាត្មាអញលះបង់ កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញ គប្បីជាអ្នក មិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការដោយរូប ហើយចេញទៅ ។ បុរសបានស្រាយសាកសពដ៏គួរខ្ពើមរអើម ដែល ជាប់ព្ទដ៏.ក គប្បីជាអ្នកមានសេចក្តីសុខនៅតាមទំនើងខ្លួន មានអំណាច ខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញគួរតែលះបង់នូវកាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗ ចេញ ហើយគប្បីជាអ្នក

មិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការចេញទៅយ៉ាងនោះដែរ ។ បុរស ឬស្ត្រីទាំងឡាយទៅបន្ទោបង់នូវករីសក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញនឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញទៅ ដូចបុរស ឬស្ត្រីទាំងឡាយ ដែលបន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។ ម្ចាស់ទូកទាំងឡាយ តែងតែលះបង់នូវទូកចាស់ដែលពុកផុយលិចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញយ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកទាំងឡាយ តែងតែលះបង់ចោលនូវទូកចាស់ ដូច្នោះឯង ។ បុរសកាលបើដើរទៅជាមួយនឹងពួកចោរយកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅ យ៉ាងណា កាយនេះក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹងលះបង់នូវកាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌យ៉ាងនោះដែរ ។

លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូល

ទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ ។ និម្មិតនូវទីចង្រ្កម ដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ នាំមកនូវ អភិញ្ញាពលៈ ដែលប្រកបដោយគុណ ៨ ប្រការ ។ លះបង់សំពត់ សាដក ដែលប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២ ប្រការវិញ ។ លះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ ចូលទៅ កាន់គល់ឈើ ដែលប្រកបដោយគុណ ១០ យ៉ាង ។ លះបង់ស្រូវ ដែលគេព្រោះ គេដាំ ដោយមិនសេសសល់ កាន់យកផ្លែឈើដែល ជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ តថាគតបានផ្គងនូវសេចក្តី ព្យាយាម ក្នុងអាស្រមបទនោះ ( ញុំាងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្រ្កម បានលុះ ( សម្រេច ) អភិញ្ញាពលៈ ក្នុងរវាង ៧ ថ្ងៃ ។ កាលតថាគតសម្រេចអភិញ្ញាហើយ ជាអ្នកមាន វសីក្នុងសាសនានៃតាបស កាលនោះ ទើបពោលវាចាឡើងថា

នៅក្នុងព្រះបាលីនៃព្រះគាថានេះថា **អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា** លោកពោលដល់បណ្ណសាលា និងទីចង្រ្កម

ហាក់បីដូចជា សុមេធបណ្ឌិតកសាងឡើង ដោយដៃរបស់ខ្លួនឯង ។ ប៉ុន្តែនៅក្នុងព្រះគាថានេះ មានសេចក្តីដូចតទៅនេះ សក្កទេវរាជទ្រង់ឃើញថា ព្រះមហាសត្វនឹងចូលទៅកាន់ព្រៃហិមពាន្តហើយ ថ្ងៃនេះនឹងដល់ភ្នំធម្មិក ទើបត្រាស់ហៅវិស្សុកម្មទេវបុត្រថា នែបា សុមេធបណ្ឌិតចេញមកដោយគិតថា យើងនឹងបួស អ្នកចូរទៅនិម្មិតទីនៅ ឲ្យដល់មហាសត្វនោះ វិស្សុកម្មទេវបុត្រនោះ បានទទួលព្រះតម្រាស់របស់សក្កទេវរាជហើយ ទើបនិម្មិតអាស្រមគួរជាទីរីករាយ បណ្ណសាលាយ៉ាងល្អ ទីចង្ក្រមគួរជាទីរីករាយ តែសុមេធបណ្ឌិតអាស្រ័យនៅអាស្រមបទនោះ ដែលសម្រេចដោយអានុភាព ដោយបុណ្យរបស់លោក ( ព្រះសម្ពុទ្ធទើបត្រាស់ថា ) ម្នាលសារីបុត្រ នៅភ្នំធម្មិកនោះ អាស្រមតថាគតបានសាងឡើងយ៉ាងល្អ និម្មិតបណ្ណសាលាយ៉ាងល្អនេះ ក៏ទាំងបាននិម្មិតទីចង្ក្រម ដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមនោះដែរ ដូចនេះ ។

បណ្តាបទទាំងនោះ បទថា **សុកតោ មយ្ហំ** ប្រែថា តថាគតសាងអាស្រមនោះយ៉ាងល្អហើយ ។ បទថា **បណ្ណសាលា សុមាបិតា** មានសេចក្តីថា សូម្បីបណ្ណសាលាដែលប្រក់ដោយស្លឹកឈើ តថាគត

កសាងល្អហើយ ។ បទថា **បញ្ចទោសវិវជ្ជិតំ** មានសេចក្តីថា ឈ្មោះថា ទោសរបស់ទីចង្ក្រមមាន ៥ យ៉ាង គឺរឹង និងរដាក់រដុប មានដើមឈើ ខាងក្នុងដុះរាត់រាយ ទីប្រក់បាំងរាត់រាយ ទីចង្អៀតពេក ទីធំទូលាយពេក ដោយសេចក្តីពិត កាលបើបុគ្គលដើរចង្ក្រមនៅក្នុងទីចង្ក្រមមានផ្ទៃដីរឹង និងរដាក់រដុប ជើងទាំងពីរក៏ឈឺ មានពងបាតជើងជាដើមកើតឡើង ទើបចិត្តមិនតាំងមាំ កម្មដ្ឋានក៏វិបត្តិ តែកម្មដ្ឋាននឹងដល់ព្រម ព្រោះ អាស្រ័យការនៅសប្បាយ ក្នុងផ្ទៃដីដែលទន់ និងរាបស្មើ ព្រោះដូច្នោះ គប្បីជ្រាបថា ផ្ទៃដីដែលរឹង និងរដាក់រដុប ជាទោសប្រការទី ១ ។ កាលបើមានដើមឈើដុះនៅខាងក្នុង ឬកណ្តាល ឬទីបំផុតនៃទីចង្ក្រម កាលបើអាស្រ័យការប្រមាទក្នុងការដើរចង្ក្រម ថ្ងាស ឬក្បាលក៏នឹងទង្គិច ព្រោះដូច្នោះ មានដើមឈើនៅខាងក្នុង ទើបជាទោសប្រការទី ២ ។ កាលបើដើរចង្ក្រមក្នុងទីប្រក់បិទបាំងដោយស្មៅ និងវល្លិ៍របូតរាត់រាយ ជាដើម ក្នុងវេលាយប់ ក៏នឹងជាន់សត្វ មានសត្វពស់...ធ្វើឲ្យវាស្លាប់ ឬនឹងត្រូវវាចឹកបានទទួលនូវការវិនាសអន្តរាយ ព្រោះដូច្នោះ ទីប្រក់ បិទបាំងរាត់រាយ ទើបចាត់ជាទោសប្រការទី ៣ ។ កាលបើទីចង្ក្រម នៅក្នុងទីកន្លែងដែលចង្អៀតពេក ដែលមានកំណត់ ត្រឹមតែមួយហត្ថ

ឬកន្លះហត្ថ ក្រចកខ្លះ ម្រាមដៃខ្លះ នឹងប៉ះទង្គិច ហើយបែក ( មានរបួស ) ព្រោះដូច្នោះ ការចង្អៀតពេកនេះ ទើបជាទោសប្រការទី ៤ ។ កាលបើដើរចង្ក្រមនៅទីប្រកបដោយទូលាយពេក ចិត្តក៏រមែងរត់ច្រេចូ្រ និងមិនមានអារម្មណ៍តាំងមាំ ព្រោះដូច្នោះ ការដែលទីកន្លែងជំទូលាយពេក ទើបជាទោសប្រការទី ៥ ។ ដើរចង្ក្រមដោយចំណែកទទឹង មានកន្លះហត្ថ ( ក្នុងសងខាង មានប្រមាណពាក់កណ្ដាលហត្ថ ) កន្លែងដើរចង្ក្រម មានប្រមាណ ៦០ ហត្ថ មានផ្ទៃដីទន់ មានដីខ្សាច់រោយរាយរាបស្មើ ក៏ប្រើប្រាស់បានដូចទីចង្ក្រមរបស់ព្រះមហិន្ទត្ថេរ អ្នកបណ្ដុះបណ្ដាលសេចក្ដីជ្រះថ្លា ឲ្យអ្នកកោះលង្កា ក្នុងចេតិយគិរីវិហារ ក៏បានមានដូចនេះ ព្រោះហេតុនោះ ទើបលោកពោលថា តថាគតបានកសាងកន្លែងដើរចង្ក្រមនេះ ក្នុងអាស្រមនោះ ដែលប្រាសចាកទោស ៥ ប្រការ ។

បទថា **អដ្ឋគុណសមុបេតំ** គឺប្រកបដោយសេចក្ដីសុខរបស់សមណៈ ៨ ប្រការ ឈ្មោះថា សុខរបស់សមណៈ ៨ ប្រការនោះ មានដូចនេះ គឺឥតមានការហួងហែងទ្រព្យសម្បត្តិ និងបាយ ស្វែងរកតែបិណ្ឌបាតដែលឥតមានទោស បរិភោគតែបិណ្ឌបាតដែលត្រជាក់ ឥតមានការបង្កាប់តម្រូវ ប្រាសចាកតម្រេក ដោយអំណាចការពេញចិត្ត

ក្នុងឧបករណ៍ទាំងឡាយ មិនមានការភ័យខ្លាច ក្នុងរឿងចោរប្លន់ មិនត្រូវនៅស្និទ្ធស្នាលនឹងព្រះរាជា ឬរាជអាមាត្យ មិនត្រូវប៉ះទង្គិច ក្នុងទិសទាំង ៤ ។ លោកអធិប្បាយថា អ្នកនៅក្នុងអាស្រមនោះ អាចប្រសព្វសុខរបស់សមណៈ ៨ យ៉ាងទាំងនេះបាន យ៉ាងណា តថាគតកសាងអាស្រមនោះ ប្រកបដោយគុណ ៨ យ៉ាង ដូច្នេះដែរ ។ បទថា **អភិញ្ញាពលមាហរឹ** មានសេចក្តីថា បន្ទាប់ពីនោះមក កាលបើ តថាគតនៅក្នុងអាស្រមនោះ ធ្វើបរិកម្មក្នុងកសិណហើយ ទើបផ្តើម បម្រើនវិបស្សនា ដោយសភាពជារបស់មិនទៀង និងដោយភាពជាទុក្ខ ដើម្បីត្រូវការ ការកើតឡើងនៃអភិញ្ញា និងសមាបត្តិ ហើយក៏បាន កម្លាំងនៃវិបស្សនា ដែលទ្រទ្រង់រាងកាយ ។ មានពាក្យអធិប្បាយថា កាលបើតថាគតនៅក្នុងអាស្រមនោះ អាចនាំមកនូវកម្លាំងបាន យ៉ាង ណាមិញ តថាគតបានកសាងអាស្រមនោះ ធ្វើឲ្យសមគួរដល់កម្លាំង នៃវិបស្សនានោះ ដើម្បីប្រយោជន៍ដល់អភិញ្ញា ។

ក្នុងព្រះគាថានេះថា **សាដកំ បជហឹ តត្ថ នវទោសមុបាគតំ** ដូចមានពាក្យពោលតទៅនេះ បានឮមកថា ក្នុងកាលនោះ វិស្សកម្ម-ទេវបុត្រនិម្មិតអាស្រម បណ្ណសាលា និងទីចង្ក្រមដេរដាសទៅដោយ

ដើមឈើ មានផ្កា និងផ្លែ ទឹកមានរសឆ្ងាញ់ គួររីករាយ ប្រាសចាក សត្វកាច និងបក្សី ដែលមានសំឡេងស្រែក គួរឲ្យភ័យខ្លាចផ្សេងៗ គួរដល់ការស្ងប់ស្ងាត់ រៀបចំរកគ្រឿងបង្អែក សម្រាប់អង្គុយផ្អែក ទីបំផុតសងខាងផ្លូវចង្ក្រម ដែលស្អិតស្អាងល្អហើយ តម្កល់ផ្ទាំងថ្ម មានពណ៌ដូចសណ្តែកខៀវ មានផ្ទៃរាបស្មើ នៅត្រង់ទីកណ្តាលកន្លែង ចង្ក្រម ខាងក្នុងបណ្ណសាលា និម្មិតវត្ថុគ្រប់យ៉ាងដែលនឹងប្រព្រឹត្តទៅ ដើម្បីជាឧបការៈដល់បព្វជិតយ៉ាងនេះ គឺជដាមណ្ឌល (ជដាដែល មានទ្រង់ទ្រាយមូល) សំពត់សម្បកឈើ បរិក្ខាររបស់តាបស មាន ឈើច្រត់ចម្ពាម ៣ ជាដើម នៅទីក្បែរទ្វារ មានតម្កល់ថ្នាំងសម្រាប់ ដាក់ទឹកផឹក ស័ង្ខដងទឹកផឹក កន្លែងរោងភ្លើង មានឧសជាដើម ។ នៅជញ្ជាំងបណ្ណសាលាសរសេរអក្សរថា នរណាៗ មានបំណងនឹងបួស ចូរកាន់យកបរិក្ខារទាំងនេះបួសចុះ ហើយទៅកាន់ទេវលោកវិញ ។

សុមេធបណ្ឌិតទៅកាន់ព្រៃហិមពាន្តតាមផ្លូវនៃច្រកភ្នំ រកមើលទីកន្លែង ជាទីសប្បាយ គួរនឹងអាស្រ័យនៅរបស់ខ្លួន បានមើលឃើញអាស្រម គួរជាទីរីករាយ ដែលវិស្សកម្មទេវបុត្រនិម្មិតទុកនោះហើយ ទើបដើរ ទៅខាងចុងទីចង្ក្រម មិនបានឃើញស្នាមជើង ទើបគិតថា បព្វជិត

ស្វែងរកបរិក្ខារក្នុងស្រុកឆ្ងាយ ហើយហត់នឿយ នឹងចូលមកកាន់បណ្ណសាលា លុះចូលទៅដល់ហើយ ក៏បានអង្គុយចាំមួយសន្ទុះមក ទើបគិតថា បព្វជិតនឹងយឺតយូរក្រែនិមន្តម៉្លេះ យើងចង់ដឹងណាស់ ទើបបើកទ្វារបណ្ណសាលា ចូលទៅខាងក្នុង ពិនិត្យមើលខាងនេះ ខាងនោះ អានអក្សរនៅត្រង់ជញ្ជាំងហើយគិតថា កប្បិយបរិក្ខារនេះជារបស់យើង យើងនឹងកាន់យកបរិក្ខារទាំងនេះបួស ទើបផ្លាស់សំពត់សាដក ក្នុងបណ្ណសាលានោះ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងថា ម្នាលសារីបុត្រ តថាគតចូលទៅយ៉ាងនេះហើយ បានផ្លាស់ចេញនូវសំពត់សាដកដែលប្រកបដោយទោស ៩ ប្រការ ទុកក្នុងបណ្ណសាលានោះ ព្រោះដូច្នោះ តថាគតកាលបើផ្លាស់សំពត់សាដកចេញ ព្រោះបានឃើញទោស ៩ ប្រការ ។ ពិតណាស់ សម្រាប់អ្នកដែលបួសជាតាបស ទោស ៩ ប្រការរមែងប្រាកដក្នុងសំពត់សាដក គឺមានតម្លៃច្រើន ជាទោសប្រការ ១ ។ កើតឡើងព្រោះជាប់ទាក់ទងនឹងមនុស្សដទៃប្រការ ១ ។ ឆាប់សៅហ្មងព្រោះប្រើប្រាស់ប្រការ ១ ។ សៅហ្មងហើយនឹងត្រូវបោក និងត្រូវជ្រលក់ការដែលចាស់ទៅ ព្រោះការប្រើប្រាស់ជាទោសប្រការ ១ ។ ក៏ចំពោះសំពត់ដែលចាស់ហើយ នឹងត្រូវធ្វើការជួសជុល ឬប៉ះជាបំណះ

ការដែលនឹងបានទទួល ដោយការស្វែងរកទៀតក៏លំបាក ជាទោសប្រការ ១ ។ មិនសមរម្យនឹងការបួសជាតាបស ជាទោសប្រការ ១ ។ ជារបស់ទូទៅដល់សត្រូវ ជាទោសប្រការ ១ ។ ព្រោះនឹងត្រូវគ្រប់គ្រងដោយអាការដែលសត្រូវកាន់យកមិនបាន ជាគ្រឿងប្រដាប់ប្រដារបស់អ្នកប្រើប្រាស់ ជាទោសប្រការ ១ ។ចំពោះអ្នកកាន់យកហើយត្រាច់ទៅជាអ្នកប្រាថ្នាច្រើន ក្នុងវត្ថុដែលជារបស់ប្រើប្រាស់ប្រចាំខ្លួន ជាទោសប្រការ ១ ។ បទថា **វាកចីរំ និវាសេសឹ** មានសេចក្ដីថា ម្នាលសារីបុត្រ គ្រានោះ តថាគតឃើញទោស ៩ ប្រការនេះ ទើបផ្លាស់សំពត់សាដកស្លៀកសំពត់សម្បកឈើវិញ គឺប្រើសំពត់សម្បកឈើ ( ក្រង ឬ ត្បាញដោយស្មៅ ) ប្រយោជន៍ដើម្បីស្លៀក និងដណ្ដប់ ។ បទថា **ទ្វាទសគុណមុបាគតំ** គឺប្រកបដោយអានិសង្ស ១២ ប្រការ ។ ក្នុងសំពត់សម្បកឈើមានអានិសង្ស ១២ ប្រការគឺ តម្លៃថោក នេះជាអានិសង្សទី ១, អាចធ្វើដោយដៃខ្លួនឯង នេះជាអានិសង្សទី ២, និងមិនសូវប្រឡាក់ដោយការប្រើប្រាស់ សូម្បីបោកក៏មិនយូរ នេះជាអានិសង្សទី ៣, សូម្បីនឹងចាស់ទៅព្រោះការប្រើប្រាស់ក៏មិនចាំបាច់ដេរ នេះជាអានិសង្សទី ៤, កាលស្វែងរកថ្មី ក៏ធ្វើបានងាយ នេះជាអានិសង្សទី

៥, សមរម្យនឹងការបួសជាតាបស នេះជាអានិសង្សទី ៦, អ្នកជាសត្រូវ មិនប្រើប្រាស់ នេះជាអានិសង្សទី ៧, កាលបើនៅប្រើប្រាស់ ក៏មិនជាទីតាំងនៃការស្អិតស្អាង នេះជាអានិសង្សទី ៨, នឹងស្លៀកដណ្តប់ក៏ស្រោល នេះជាអានិសង្សទី ៩, សម្តែងថា ប្រាថ្នាតិចក្នុងបច្ច័យ គឺចីវរ នេះជាអានិសង្សទី ១០, ការកើតឡើងនៃសម្បកឈើ ជារបស់ប្រកបដោយធម៌ និងមិនមានទោស នេះជាអានិសង្សទី ១១, កាលបើសំពត់សម្បកឈើ នឹងបាត់សូន្យទៅ ក៏ឥតអាល័យ នេះជាអានិសង្សទី ១២ ។

បទថា អដ្ឋទោសសមាកិណ្ណំ បជហិំ បណ្ណសាលកំ មានសេចក្តីថា តថាគតលះបង់ធ្វើអ្វី បានឮមកថា សុមេធបណ្ឌិតនោះផ្លាស់សំពត់សាដកសាច់ម៉ដ្ឋទាំងគូចេញហើយ កាន់យកសំពត់សម្បកឈើពណ៌លឿង ដូចជាផ្កានទោងព្រៃ ដែលពាក់ដូចចីវរ ហើយស្លៀកដណ្តប់សំពត់សម្បកឈើ ពណ៌ដូចមាសមួយផ្ទាំងទៀត ពាក់ចៀងលើស្មា ដោយស្បែកខ្លា ដូចគ្នានឹងសណ្ឋានរបស់ផ្កាបុន្នាគ បង្រួមជដាមណ្ឌល ហើយសៀតកៀបសក់ ធ្វើដោយឈើ និងចូលទៅសង្កត់នឹងផ្នួងសក់ ដើម្បីធ្វើមិនឲ្យប្រហោង ដាក់ក្អមទឹក មានពណ៌ដូចកែវ

ប្រពាឡក្នុងសង្រែក ដូចគ្នានឹងកម្រងកែវមុក្តា កាន់យកដងវែកកោង ក្នុងទី ៣ កន្លែង ព្យួរក្អមទឹកខាងចុងអំវែក តម្កក់នឹងកន្ត្រក ឈើប្រត់ ចម្លាម ៣ តាបសយកអំវែកបរិក្ខារដាក់លើស្មា ដៃស្តាំកាន់ឈើប្រត់ ចេញចាកបណ្ណសាលា ដើរចង្ក្រមទៅមកក្នុងទីចង្ក្រម មានប្រមាណ ៦០ ហត្ថ មើលភេទរបស់ខ្លួនហើយ គិតថា មនោរថរបស់យើងដល់ ទីបំផុតហើយ ការបព្វជ្ជារបស់យើង ប្រពៃពិតណាស់ហ្ន៎ ឈ្មោះថា បព្វជ្ជានេះ អ្នកដែលជាធីរបុរសទាំងពួង មានព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ ស្ញើចសរសើរ គ្រឿងចងរបស់គ្រហស្ថ យើងលះបង់ហើយ យើង កំពុងចេញបួស យើងចេញបួសហើយ បានបព្វជ្ជាដ៏ខ្ពង់ខ្ពស់បំផុត យើងនឹងធ្វើសមណធម៌ យើងនឹងបានសុខ ដែលកើតអំពីមគ្គផល ដូចនេះហើយ កើតការឧស្សាហ៍ តាបសដាក់អំវែកបរិក្ខារចុះ អង្គុយ លើផ្ទាំងថ្ម មានពណ៌ដូចសណ្តែកខៀវ ដូចរូបសូនអំពីមាសដូច្នោះ ឲ្យវេលាថ្ងៃអស់ទៅ ចូលទៅកាន់បណ្ណសាលាក្នុងវេលាល្ងាច ដេកលើ ដំណេក ដែលក្រាលដោយកន្ទេលផ្តៅ បានទទួលអាកាសជាទីសប្បាយ ហើយភ្ញាក់នៅពេលជិតភ្លឺ នឹកដល់ការមករបស់ខ្លួនថា យើងឃើញ ទោសនៅក្នុងភេទជាឃរាវាសហើយ លះបង់ភោគទ្រព្យរាប់មិនអស់

យសដែលរកទីបំផុតមិនបាន ចូលទៅកាន់ព្រៃស្វែងរកនេក្ខម្មៈ ចាប់ផ្តើមអំពីនោះទៅ យើងនឹងប្រព្រឹត្តដោយការមិនប្រមាទ ព្រោះសត្វរុយគឺមិច្ឆាវិតក្ក តែងតែទំពាស៊ី អ្នកដែលលះបង់នូវសេចក្តីស្ងប់ស្ងាត់ត្រាច់ទៅ ឥឡូវនេះ យើងគួរនឹងបង្កើតទ្វេឡើងនូវសេចក្តីស្ងប់ស្ងាត់ដោយសេចក្តីថា យើងមើលឃើញការនៅគ្រប់គ្រងផ្ទះ ដោយមានតែកង្វល់ ទើបចេញមក បណ្ណសាលាគួរជាទីពេញចិត្តនេះ មានផ្ទៃដីដ៏រាបស្មើ ហើយមានពណ៌ដូចផ្លែព្នៅទុំ ជញ្ជាំងពណ៌.ស ដូចជាពណ៌ប្រាក់ ដំបូលស្លឹកពណ៌ដូចជើងសត្វព្រាប ដំណេកមានកម្រាលដ៏ល្អស្អាត លំនៅល្មមអាស្រ័យនៅបានយ៉ាងផាសុក រីឯប្រាសាទរបស់យើងពុំមានប្រាកដក្រៃលែងជាងនេះ ដូចនេះក៏សម្លឹងឃើញទោសនៃបណ្ណ-សាលា ក៏បានឃើញទោស ៨ ប្រការ ៗ ការពិត ក្នុងការប្រើប្រាស់បណ្ណសាលា មានទោស ៨ ប្រការ គឺនឹងត្រូវស្វែងរក ដោយការប្រមូលទព្វសម្ភារៈ ដ៏ធ្ងន់យកមកធ្វើ ជាទោសប្រការ ១, នឹងត្រូវជួសជុលឲ្យល្អជានិច្ច ព្រោះកាលបើស្មៅក្តី ស្លឹកឈើក្តី ដីស្អិតធ្លាក់ជ្រុះចុះមក យើងក៏ត្រូវជួសជុលឲ្យល្អឡើងវិញ ជាទោសប្រការទី ២, ធម្មតាសេនាសនៈ នឹងត្រូវតែចាស់ទ្រុឌទ្រោម តែមនុស្សចាស់មុន

កាលបើមានគេចូលមក ឲ្យយើងក្រោកឡើងក្នុងវេលាដែលមិនសមរម្យ ការតាំងមាំនៃចិត្តក៏នឹងមានមិនបាន ព្រោះដូច្នោះ ការដែលត្រូវក្រោកឲ្យក្រោកឡើង ទើបជាទោសប្រការទី ៣, ព្រោះកម្ចាត់បាននូវត្រជាក់និងក្តៅ ក៏នឹងធ្វើឲ្យរាងកាយទ្រុឌទ្រោមខ្ចះ ( មិនមាំមួន ) ជាទោសប្រការទី ៤, មនុស្សចូលទៅកាន់ផ្ទះ អាចធ្វើអំពើអាក្រក់យ៉ាងណានីមួយ ព្រោះដូច្នោះ ការដែលមិនបិទបាំងកិច្ច ( អំពើ ) គួរតិះដៀលជាទោសប្រការទី ៥, ការហួងហែង ដោយគិតថា ជារបស់យើងជាទោសប្រការទី ៦, ធម្មតា ការមានផ្ទះបង្ហាញថា ត្រូវមានករិយាជាទោសប្រការទី ៧, ជារបស់ទូទៅដល់មនុស្សពួកច្រើន ព្រោះជាសាធារណៈដល់សត្វ មានសត្វសុច សត្វសង្កើច សត្វតុកកែជាដើមជាទោសប្រការទី ៨ ។ បទថា **ឥមេ** មានសេចក្តីថា ព្រះមហាសត្វឃើញទោស ៨ ប្រការនេះហើយ ទើបលះបង់នូវបណ្ណសាលា ។ ព្រោះហេតុនោះ ទើបលោកពោលថា យើងលះបង់នូវបណ្ណសាលាដែលពោរពេញទៅដោយទោស ៨ ប្រការ ។

បទថា **ឧបាគមឹ រុក្ខមូលំ គុណេហិ ទសហុបាគតំ** មានសេចក្តីថា ព្រះមហាសត្វពោលថា យើងហាមទីប្រក់បិទបាំង ចូលទៅកាន់គល់ឈើ

ដែលប្រកបដោយគុណ ១០ ប្រការ មានដូចតទៅនេះ មានសេចក្ដីស្ទុគស្មាញតិច ជាគុណប្រការទី ១, ព្រោះត្រឹមតែចូលទៅកាន់ទីនោះប៉ុណ្ណោះ ក៏នៅទីនុ៎ះបាន ព្រោះដូច្នោះ ទើបមិនត្រូវមើលថែរក្សា ជាគុណប្រការទី ២, ក៏ទីនោះនឹងបោសសម្អាតក៏ដោយ មិនបោសសម្អាតក៏ដោយ ក៏ប្រើប្រាស់បានយ៉ាងសប្បាយដូចគ្នា ការដែលមិនត្រូវព្យាយាមពេក ជាគុណប្រការទី ៣, ទីនោះបិទបាំងការនិន្ទាមិនបាន ព្រោះកាលបើមនុស្សធ្វើអំពើអាក្រក់ក្នុងទីនោះ រមែងអៀនខ្មាស ព្រោះដូច្នោះ ការបិទបាំងការនិន្ទាមិនបាន ជាគុណប្រការទី ៤, គល់ឈើដូចគ្នាក្នុងទីវាល រមែងមិនញុំាងរាងកាយឲ្យលំបាក ព្រោះដូច្នោះ ការដែលរាងកាយមិនលំបាក ទើបជាគុណប្រការទី ៥, ឥតមានការត្រូវហួងហែង ជាគុណប្រការទី ៦, ហាមឃាត់បាននូវសេចក្ដីអាល័យក្នុងផ្ទះសម្បែង ជាគុណប្រការទី ៧, ឥតមានត្រូវការនិយាយថា យើងនឹងបោសសម្អាត ជូតដុសលាង ពួកអ្នកចូរចេញទៅ ហើយក៏ដេញចេញទៅដូចក្នុងផ្ទះដែលទូទៅដល់មនុស្សពួកច្រើន ជាគុណប្រការទី ៨, អ្នករស់នៅបានទទួលការត្រេកអរសប្បាយចិត្ត ជាគុណប្រការទី ៩, មិនអាល័យព្រោះសេនាសនៈ គឺគល់ឈើស្វែងរកបានងាយ មិនថានឹងទៅនៅទីណា

ជាគុណប្រការទី ១០ ព្រះមហាសត្វឃើញគុណ ១០ យ៉ាងនេះ ទើបពោលថា យើងចូលអាស្រ័យគល់ឈើដូចនេះ ។ ព្រះមហាសត្វកំណត់ហេតុមានប្រមាណប៉ុណ្ណេះហើយ ស្អែកឡើងក៏ចូលទៅដើម្បីស្វែងរកភិក្ខា ។ គ្រានោះ ពួកមនុស្សក្នុងស្រុកដែលលោកទៅដល់បានថ្វាយភិក្ខាដោយការឧស្សាហ៍ធំ លោកធ្វើភត្តកិច្ចស្រេចហើយ មកកាន់អាស្រមលុះអង្គុយរួចហើយ គិតថា យើងបួស ដោយគិតថា យើងនឹងមិនបានអាហារក៏គ្មានទេ ធម្មតាអាហារដែលមានរសឆ្ងាញ់នេះ រមែងញុំាងនូវការស្រវឹង ដោយអំណាចមានះ និងការស្រវឹងក្នុងភាពជាបុរសដ៏ចម្រើន ឯទីបំផុតនៃទុក្ខ ដែលមានអាហារជាមូលមិនមាន ប្រសិនបើយើងគប្បីលះបង់អាហារ ដែលកើតពីស្រូវ ដែលគេព្រោះ គេដាំ កាន់យកតែផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ តថាគតផ្គងព្យាយាមក្នុងអាស្រមបទនេះ ( ញុំាងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្រ្កម បានលុះអភិញ្ញាពលៈក្នុងរវាង ៧ ថ្ងៃ ។

កាលតថាគតបានសម្រេចអភិញ្ញាហើយ ជាអ្នកមានវសី ក្នុងសាសនានៃតាបស កាលនោះព្រះជិនស្រី ព្រះនាមទីបង្ករ ជានាយកនៃលោកទ្រង់កើតឡើង ។ កាលព្រះសម្មាសម្ពុទ្ធទ្រង់ចាប់បដិសន្ធិផង

ប្រសូតផង ត្រាស់ដឹងផង សម្តែងព្រះធម្មចក្រផង តថាគតជាអ្នកផ្អែតស្កប់ស្កល់ ដោយសេចក្តីត្រេកអរនៅក្នុងឈាន ( លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រ ) ប៉ុន្តែមិនបានឃើញនូវនិមិត្តទាំង ៤ នោះឡើយ ។

ក្នុងកាលនោះ ព្រះជិនស្រី ព្រះនាមទីបង្ករ ជានាយកនៃលោកមានព្រះខីណាស្រព ៤ សែនរូប សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិគុណប្រាសចាកមន្ទិលហែហម ស្តេចចារិកទៅតាមលំដាប់ ដល់នគរឈ្មោះរម្មកៈ ស្តេចគង់ប្រថាប់នៅសុទស្សនមហាវិហារ ។ ពួកអ្នករម្មកនគរបានដំណឹងថា បានឮមកថា ព្រះពុទ្ធអង្គទ្រង់ព្រះនាមទីបង្ករ ទ្រង់ជាធំជាងពួកសមណៈ ទ្រង់សម្រេចអភិសម្ពោធិដ៏យ៉ាងក្រៃលែង ទ្រង់ប្រកាសធម្មចក្រដ៏បវរ ស្តេចចារិកទៅដោយលំដាប់ មកដល់រម្មកនគរហើយស្តេចគង់ប្រថាប់នៅសុទស្សនមហាវិហារ ម្នាក់ៗ នាំគ្នាកាន់ភេសជ្ជៈមានទឹកដោះថ្លា ទឹកដោះខាប់ ត្រៃចីវរ គ្រឿងក្រអូប និងផ្កាជាដើម ។ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនៅទីណា ក៏នាំគ្នាជាប់តាមទៅទីនោះៗ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំ បូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ហើយអង្គុយក្នុងទីដ៏សមគួរ លុះអង្គុយក្នុងទីដ៏សមគួរហើយក៏ស្តាប់ព្រះធម៌ទេសនា ហើយទូលនិមន្តដើម្បីទទួលភត្តាហារនៅក្នុង

ថ្ងៃស្អែក ហើយក៏ចៀសចេញទៅ ។ លុះព្រឹកឡើង ម្នាក់ៗ បាននាំគ្នាត្រៀមមហាទាន តុបតែងព្រះនគរ បាននាំគ្នាជម្រះផ្លូវជាទីមកនៃព្រះសម្មាសម្ពុទ្ធ ក្នុងទីដែលមានទឹកប្រោះ ឬទឹកជក់ ក៏យកដីមកបំពេញធ្វើផែនដីឲ្យរាបស្មើ រោយដីខ្សាច់មានពណ៌ប្រាក់ រោយរាយដោយលាជនិងផ្កា ដោតទង់ និងទង់ក្រណាត់មានពណ៌ផ្សេងៗ ចងដើមចេក និងតម្កល់ក្អមទឹក មានទឹកពេញដាក់រៀងជាជួរ ។

សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះទៅឰដ៏អាកាស តថាគតឃើញមហាជនកំពុងតែពេញចិត្ត ត្រេកអរស្រស់ស្រាយរីករាយ ក៏ចុះអំពីអាកាសហើយសួរមនុស្សទាំងឡាយ ក្នុងខណៈនោះថា មហាជនត្រេកអរស្រស់ស្រាយរីករាយពេញចិត្តជម្រះផ្លូវគន្ទុក ប្រឡាយ ដើម្បីអ្នកណា ? ពួកជនទាំងនោះ ដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា ព្រះសម្ពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រី ព្រះនាមទីបង្ករ ជាលោកនាយកទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវគន្ទុក ប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ ។ បីតិកើតឡើងដល់តថាគតក្នុងខណៈនោះ ព្រោះតែឮពាក្យថា ព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះហើយ

ក៏បាននូវសោមនស្ស ។ គ្រានោះ តថាគតស្ថិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្តុះពូជកុសលក្នុង បុញ្ញក្ខេត្តនេះ កុំឲ្យខណៈកន្លងទៅទទេឡើយ ។ (លុះគិតដូច្នេះហើយ ក៏និយាយទៅរកមហាជនថា) បើអ្នកទាំងឡាយ ជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវប្រឡាយដែរ ។ កាលនោះ ពួកជនទាំងនោះ ក៏ឲ្យឱកាសមួយដល់តថាគតដើម្បីជម្រះផ្លូវ តថាគតគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ជម្រះផ្លូវបណ្តើរក្នុងឱកាសនោះ ។ កាលដែលឱកាស (ផ្លូវ) របស់តថាគត ធ្វើមិនទាន់ស្រេចនៅឡើយ ស្រាប់តែព្រះជិនស្រី ជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្តេចយាងមក តាមផ្លូវជាមួយនឹងព្រះខីណាស្រព ៤ សែនរូប សុទ្ធតែជាអ្នកបាន អភិញ្ញា ៦ ជាតាទិគុណ ប្រាសចាកមន្ទិល ។ ការក្រោកទទួល (ព្រះសាស្តា) ក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយជាច្រើន ក៏លាន់ឮឡើង គគ្រឹកគគ្រេង ពួកមនុស្ស និងទេវតា ក៏ត្រេកអរ ញ៉ាំងសាធុការឲ្យ ប្រព្រឹត្តទៅ ។ ពួកទេវតាឃើញពួកមនុស្ស ឯពួកមនុស្សក៏ឃើញពួក ទេវតា ទេវតា និងមនុស្សទាំងពីរពួកនេះ បានផ្គងអញ្ជលី ដើរដង្ហែ ព្រះតថាគត ។ ពួកទេវតាប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្ស

ក៏ប្រគំតូរ្យតន្ត្រីរបស់មនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតាដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្ស ផ្កាឈូក ផ្កាបារិច្ឆត្តព្រឹក្សជាទិព្វឰដ៏អាកាសអំពីទិសតូចទិសធំ ។ ពួកទេវតាដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយលម្អិតខ្លឹមចន្ទន៍ទិព្វផង គ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូចទិសធំឰដ៏អាកាស ។ ពួកមនុស្សដែលស្ថិតនៅលើផែនដី ក៏រោយរាយផ្កាចម្ប៉ា ផ្កាស្រស់ ផ្កាកុម្ព ផ្កាខ្ទឹង ផ្កាបុសនាគ និងផ្កាកែស អំពីទិសតូចទិសធំ ។ តថាគតរំសាយសក់ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងក្រណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ ( អធិដ្ឋានថា ) សូមព្រះពុទ្ធ ព្រមទាំងពួកសិស្សជាន់អាត្មាអញយាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ។ កាលតថាគតដេកលើផែនដី ក៏មានសេចក្ដីត្រិះរិះដោយចិត្តយ៉ាងនេះថា បើអាត្មាអញប្រាថ្នាដុតកិលេសទាំងឡាយរបស់អញ ក្នុងថ្ងៃនេះក៏បាន ។ តែជាប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ដោយភេទ ដែលគេមិនស្គាល់នៅក្នុងទីនេះ អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោក ព្រមទាំង

ទេវលោកឲ្យរួចផុតចាកសង្សារ ។ ប្រយោជន៍អ្វី អាត្មាអញជាបុរសសម្តែងកម្លាំងថ្លងទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញនឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះសាស្តា ជាបុរសខ្ពង់ខ្ពស់ ។ តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់កពទាំងបី ឡើងជិះលើនាវា គឺធម៌ និងចម្លងមនុស្សលោក ព្រមទាំងទេវលោក ។

កាលបុគ្គលប្រាថ្នាភាពជាព្រះពុទ្ធ ការប្រាថ្នាដ៏ធំក្រៃលែងនឹងសម្រេចបាន ព្រោះប្រមូលមកនូវធម៌ ៨ ប្រការគឺ ១- ភាពជាមនុស្ស ២- ដល់ព្រមដោយភេទ ៣- ហេតុ ៤- ការឃើញព្រះបរមសាស្តា ៥- ការបព្វជ្ជា ៦- ការបរិបូណ៌ទៅដោយគុណ ៧- ការធ្វើអំពើដ៏ធំក្រៃលែង ៨- ការពេញចិត្ត ។

ពិតណាស់ កាលបុគ្គលស្ថិតនៅក្នុងភាវៈ ជាមនុស្សនោះឯង ប្រាថ្នាភាពជាព្រះពុទ្ធ ការប្រាថ្នារមែងសម្រេច ការប្រាថ្នារបស់នាគ គ្រុឌ ឬទេវតា គ្មានបានសម្រេចទេ សូម្បីក្នុងភាវៈជាមនុស្ស កាលគេស្ថិតនៅក្នុងភេទបុរសប៉ុណ្ណោះ ទើបការប្រាថ្នានឹងបានសម្រេច ការប្រាថ្នា

របស់ស្ត្រី ឬមនុស្សខ្ទើយ និងឧកតោព្យញ្ជនកៈ ក៏ឥតបានសម្រេចឡើយ ចំពោះបុរស សេចក្តីប្រាថ្នារបស់អ្នកបរិបូណ៌ទៅដោយហេតុ ដែលអាចសម្រេចព្រះអរហត្ត ក្នុងអត្តភាពនោះប៉ុណ្ណោះ ទើបនឹងបានសម្រេច ក្រៅអំពីនោះ ឥតបានសម្រេចទេ ចំពោះអ្នកដែលបរិបូណ៌ដោយហេតុ បើប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធប៉ុណ្ណោះ ទើបការប្រាថ្នាបានសម្រេច កាលព្រះពុទ្ធបរិនិព្វានទៅហើយ ការប្រាថ្នានៅក្នុងទីជិតព្រះចេតិយ ឬជិតគល់ព្រះពោធិព្រឹក្ស ក៏ពុំសម្រេចដែរ សូម្បីការប្រាថ្នាក្នុងសម្នាក់នៃព្រះពុទ្ធ ការប្រាថ្នារបស់អ្នកដែលតាំងនៅក្នុងភេទបព្វជិតប៉ុណ្ណោះ ទើបនឹងបានសម្រេច អ្នកដែលស្ថិតនៅក្នុងភេទជាគ្រហស្ថ មិនបានសម្រេចទេ ។ សូម្បីអ្នកជាបព្វជិត ការប្រាថ្នារបស់អ្នកដែលបានអភិញ្ញា ៥ និងសមាបត្តិ ៨ ប៉ុណ្ណោះ ទើបនឹងបានសម្រេច អ្នកដែលប្រាសចាកគុណសម្បត្តិនេះ ក្រៅអំពីនេះមិនបានសម្រេចទេ សូម្បីអ្នកដែលបរិបូណ៌ដោយគុណហើយក៏ដោយ ការប្រាថ្នារបស់អ្នកដែលបានធ្វើការបរិច្ចាគជីវិតរបស់ខ្លួនចំពោះព្រះសាស្តា សឹងជាអ្នកបរិបូណ៌ដោយការធ្វើដ៏ធំក្រៃលែងនេះប៉ុណ្ណោះ ទើបនឹងបានសម្រេច ក្រៅអំពីនេះមិនបានសម្រេចឡើយ សូម្បីអ្នកដែលនឹងបរិបូណ៌ ដោយការធ្វើដ៏ធំក្រៃលែងហើយ

ក៏នឹងត្រូវមានឆន្ទៈដ៏ធំក្រៃលែង ឧស្សាហ៍ព្យាយាម និងការស្វែងរក ដ៏ធំ ដើម្បីប្រយោជន៍ដល់ធម៌ ដែលធ្វើឲ្យជាព្រះពុទ្ធទៀត ការប្រាថ្នា ទើបនឹងបានសម្រេច មនុស្សដទៃក្រៅអំពីនេះមិនបានសម្រេចទេ ។

ក្នុងប្រការដែលឆន្ទៈត្រូវតែឲ្យក្រៃលែងនោះ មានសេចក្តីឧបមា ដូចតទៅនេះ ក៏ប្រសិនបើនឹងគប្បីប្រព្រឹត្តយ៉ាងនេះថា អ្នកណាអាច នឹងប្រើកម្លាំងដៃរបស់ខ្លួន ឆ្លងអន្លង់ចក្រវាឡទាំងអស់ ដែលជាផ្ទៃទឹក ទាំងអស់ ហើយឆ្លងដល់ត្រើយបាន អ្នកនោះរមែងសម្រេចជាព្រះពុទ្ធបាន ឬថា អ្នកណាដើរទៅដោយជើង អាចនឹងជាន់ញាំញីអន្លង់នៃចក្រវាឡ ទាំងអស់ដែលរួបរឹត ដោយគុម្ពឫស្សី ហើយដល់ត្រើយបាន អ្នកនោះ រមែងសម្រេចជាព្រះពុទ្ធបាន ឬថា បុគ្គលណាដោតដាវទាំងឡាយ ហើយយកជើងជាន់អន្លង់នៃចក្រវាឡទាំងអស់ ដែលពេញទៅដោយ មុខដាវ អាចទៅដល់ត្រើយបាន បុគ្គលនោះរមែងសម្រេចជាព្រះពុទ្ធបាន ឬថា បុគ្គលណាយកជើងជាន់លើអន្លង់នៃចក្រវាឡទាំងអស់ ដែល ពេញទៅដោយរងើកភ្លើងឆេះសន្ធោសន្ធៅ អាចនឹងទៅដល់ត្រើយបាន បុគ្គលនោះ រមែងអាចបានសម្រេចជាព្រះពុទ្ធបាន ។ បុគ្គលណា មិនសម្គាល់ហេតុទាំងនោះ សូម្បីហេតុតែមួយថា ជារបស់ដែលខ្លួន

ធ្វើបានដោយលំបាក គិតថា យើងនឹងធ្វូង ឬនឹងទៅកាន់ត្រើយម្ខាង ទាល់តែបានដូចនេះ គេនោះចាត់ថា ជាអ្នកប្រកបដោយធនុះ ឧស្សាហ៍ ព្យាយាម និងការស្វែងរកគុណដ៏ធំ ការប្រាថ្នារបស់គេរមែងសម្រេច មនុស្សក្រៅអំពីនេះ គ្មានសម្រេចទេ ។ សុមេធតាបស សូម្បីនឹង ប្រមូលធម៌ទាំង ៨ ប្រការទាំងនេះបានហើយ ក៏ធ្វើនូវសេចក្តីប្រាថ្នា យ៉ាងក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ហើយសម្រាកសម្រាន្តនៅ ។ ចំណែកព្រះសាស្តា ទ្រង់ព្រះនាមថាទីបង្ករ ស្តេចមកប្រថាប់ឈរក្បែរ សីសៈរបស់សុមេធតាបស ត្រាស់ពាក្យនេះថា (ម្នាលភិក្ខុទាំងឡាយ) អ្នកទាំងឡាយ ចូរមើលនូវតាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ សត្វនេះនឹងចេញចាកក្រុងឈ្មោះកបិលវត្ថុ ជាទី រីករាយ តម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះអង្គុយទៀបគល់ អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតាថ្វាយក្នុងទីនោះ នឹង ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ព្រះមុនីនោះ បានទទួលបាយាសទៀបឆ្នេរ ស្ទឹងនេរញ្ជរា ហើយនឹងត្រឡប់មកតាមផ្លូវដែលគេតាក់តែងយ៉ាងល្អ ប្រសើរ ( អង្គុយ ) ទៀបគល់ពោធិព្រឹក្ស ។ លំដាប់នោះ តាបសមាន

យសធំ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបានត្រាស់ដឹងនូវអនុត្តរ-សម្មាសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ( ដើមពោធិ៍ ) ។ ព្រះជនេត្តិកាមាតារបស់តាបសនោះ នឹងមាននាមថា ព្រះនាងមាយាទេវី ព្រះបិតាព្រះនាម សុទ្ធោទនៈ ឯតាបសនេះ នឹងមានឈ្មោះថា ព្រះគោតម អគ្គសាវកទាំងពីររូប គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះសម្ពុទ្ធនោះ។ អគ្គសាវិកាពីររូប គឺនាងខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ដើមឈើជាទីត្រាស់ដឹងនៃព្រះសាស្តានោះ ហៅថា អស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺចិត្តៈ ១ ហត្ថាឡវកៈ ១ ។ នាងនន្ទមាតា ១ និងនាងឧត្តរា ១ ជាឧបដ្ឋាយិកាដ៏ប្រសើរ ព្រះគោតមមានយសនោះមានព្រះជន្ម ១០០ វស្សា ។ ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាកររបស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយក៏រីករាយដោយគិតថា សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហៅទាំងឡាយក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក

ទាំងមួយម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ។ ពួកមនុស្ស កាលឆ្លងស្ទឹងបើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថា ឆ្លងស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនោះ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទីបង្ករទ្រង់ជ្រាបច្បាស់នូវលោកគួរទទួលនូវគ្រឿងបូជា ទ្រង់បានសរសើរអំពើរបស់តថាគត ហើយទ្រង់លើកព្រះបាទខាងស្តាំ ។ សាវកទាំងឡាយណា ជាបុត្រនៃព្រះមុនីក្នុងទីនោះ ពួកសាវកទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអាសុរ ពួកយក្ខ ក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ ។ កាលព្រះសាស្តា ព្រមទាំងព្រះសង្ឃ កន្លងនូវការឃើញរបស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ។ តថាគតជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខរីករាយទៅដោយបាមោជ្ជ ផ្សព្វផ្សាយទៅដោយបីតិ អង្គុយពែនភ្នែន

ក្នុងកាលនោះ ។ តថាគតអង្គុយពែនភ្នែនគិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញជាអ្នកស្ងាត់នៅក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ។ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសី ស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើ ក្នុងឥទ្ធិធម៌ទាំងឡាយ អាត្មាអញបាននូវសេចក្តីសុខបែបនេះ ។ ក្នុងកាលដែលតថាគត អង្គុយពែនភ្នែនគិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញុំាងសំឡេងខ្លាំងឲ្យលាន់ឮឡើងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែន នៃពោធិសត្វទាំងឡាយប្រាកដក្នុងកាលមុន និមិត្តទាំងនោះក៏ប្រាកដ ក្នុងថ្ងៃនេះ ។ ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រំងាប់ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

ក្នុងគ្រានោះ លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេង ឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ដឹងជាព្រះពុទ្ធប្រាកដ ខ្យល់ធំទាំងឡាយក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ផ្កាទាំងពួង ដែលកើតលើគោក កើតក្នុងទឹក

ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ វល្លិ៍ទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែ ក្នុងខណៈនោះ វល្លិ៍ និងឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ កែវទាំងឡាយដែលស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្វ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ដឹងជាព្រះពុទ្ធប្រាកដ ។ ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាស ក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ មហាសមុទ្រក៏ស្រកចុះ លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រ ក្នុងខណៈនោះ មហាសមុទ្រ និងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពង ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ភ្លើងក្នុងនរកទាំងមួយម៉ឺនក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ព្រះអាទិត្យប្រាសចាកមន្ទិល ផ្កាយ

ទាំងពួងក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដី ក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដី ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកផ្កាយទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្តឫក្សទាំងឡាយ ប្រកបដោយព្រះច័ន្ទនៃវិសាខ (ក៏រុងរឿង) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោល ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ សេចក្តីអផ្សុកមិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយជាអ្នកត្រេកអរ ក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគទាំងឡាយដ៏ស្រាលៗ ក៏ស្ងប់រំងាប់ទៅ ទាំងសេចក្តីស្រេកឃ្លាន ក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រាគៈក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ ក៏បាត់បង់ទៅ ក្នុងកាលនោះ រាគៈ និងកិលេសទាំងអស់នោះ ក៏ប្រាសចេញទៅ

ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

គ្រានោះ ធូលីក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលីក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្លិនស្អុយ ក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរាំងមិនមានឡើយ កំពែងសន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអាកាសប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចុតិ និងឧបបត្តិមិនមានក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុង

ថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងនេះក៏ប្រាកដ ដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ (ពួកសត្វពោលថា បពិត្រសុមេធតាបស) សូមលោកផ្គងព្យាយាម ឲ្យមាំមួនឡើង កុំត្រឡប់ កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់ នូវហេតុនោះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ តថាគត លុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតា ទាំងមួយម៉ឺន ចក្រវាឡហើយ ក៏ត្រេកអរ ស្រស់ស្រាយរីករាយ គិតក្នុងកាលនោះ យ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែក ជាពីរទេ ព្រះជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញ នឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដីដែលគេចោលទៅឮដ៏អាកាស ទៀងតែធ្លាក់មកលើផែនដីវិញយ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរ ទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធ ទាំងឡាយ មិនចេះឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ ប្រាកដ សេចក្តីស្លាប់របស់សព្វសត្វទៀតទាត់ប្រាកដ យ៉ាងណា ព្រះបន្ទូលរបស់ព្រះលោកនាថដ៏ប្រសើរទាំងឡាយ ទៀងទាត់ប្រាកដ

ដូច្នោះដែរ ។ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ សីហៈដែលចេញអំពីដំណេក តែងបន្លឺសំឡេងយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ ការសម្រាលគភ៌នៃស្រី ដែលមានគភ៌ធ្ងន់ជារបស់ទៀងទាត់ យ៉ាងណា ព្រះបន្ទូលរបស់ព្រះសាស្ដាដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។

កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវទានបារមី ជាដំបូងនេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះ ចាក់មិនឲ្យសល់ទឹក ទឹកមិនជក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទាន

កុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញសីលបារមីទីពីរ ដែលពោធិសត្វ ទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មាន ខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកឯងចូរសមាទាន ធ្វើសីលបារមី ទីពីរនេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីល-បារមីចុះ ។ សត្វចាមរី (កាលឃើញ ) រោមកន្ទុយជំពាក់នឹងរបស់ អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណា អ្នកចូរបំពេញនូវសីលទាំងឡាយចុះ ក្នុងភូមិទាំង ៤ ចូររក្សាសីល សព្វកាល ឲ្យដូចជាសត្វចាមរីរក្សាកន្ទុយយ៉ាងនោះចុះ ។ ពុទ្ធធម៌ ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរក ពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរកពុទ្ធធម៌ ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន

ធ្វើនេក្ខម្មបារមីទី ៣ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់នៅក្នុងគុកអស់កាលយូរ ត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្ដីត្រេកអរ ឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណាមិញ អ្នកចូរឃើញនូវភពទាំងអស់ ដូចជាគុកចុះ ចូរបែរមុខ ទៅរកនេក្ខម្មៈ ដើម្បីរួចចាកភព ក៏យ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរកពុទ្ធធម៌ ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវបញ្ញាបារមីទី ៤ នេះ ឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនរំលង នូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបាន ចង្ហាន់ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរ ជនជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវ

ពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងតែជ្រើសរើសរកពុទ្ធធម៌ ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាមឲ្យមាំមួន ក្នុងកពទាំងពួងយ៉ាងនោះចុះ លុះដល់នូវវីរិយបារមីហើយ នឹងបានសម្រេចនូវពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។

កាលនោះ តថាគតកំពុងជ្រើសរើសរកពុទ្ធធម៌ ក៏បានឃើញនូវខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរ

សមាទាន ចូរធ្វើនូវខន្តិបារមីទី ៦ នេះឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ ក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយរបស់ពួកជនទាំងពួង យ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវសច្ចបារមីទី ៧ នេះឲ្យមាំមួន កុំមានពាក្យបែកជាពីរ ក្នុងសច្ចបារមីនោះ នឹងបានសម្រេចនូវសម្ពោធិញ្ញាណមិនខានឡើយ ។ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថិ ក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាត

ចាកវិថិ ក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរកពុទ្ធធម៌ ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ភ្នំថ្មឥតកម្រើក តាំង នៅស៊ប់មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួន ដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមី សព្វកាលយ៉ាង នោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំង ពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ពុទ្ធធម៌ ក៏បានឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយអំពី

បុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាល សុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គលដទៃស្មើបាន ដោយមេត្តា បើអ្នកចង់លុះនូវ ពោធិញ្ញាណ ។ ធម្មតាទឹករមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជន ទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិល យ៉ាងណា ។ អ្នកចូរចម្រើនមេត្តាឲ្យស្មើ ចំពោះមិត្រ និងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខាន ឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យ សម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរកពុទ្ធធម៌ ក៏ឃើញ ឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើឧបេក្ខាបារមីទី ១០ នេះឲ្យមាំមួន អ្នកគួរជាបុគ្គល ដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី តែងព្រងើយកន្តើយចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែល គេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ

ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីងចំពោះសុខ និងទុក្ខសព្វកាល យ៉ាងនោះដែរ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចពោធិញ្ញាណពុំខាន ។ ធម៌ទាំងឡាយណា ជាគ្រឿងញុំាងពោធិញ្ញាណឲ្យសម្រេច ធម៌ទាំងនោះមានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃ ក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីទាំង ១០ នោះឲ្យមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីទាំងនេះ ព្រមទាំងកិច្ច និងលក្ខណៈ ។ ផែនដីទាំងមួយម៉ឺនលោកធាតុ ក៏ញាប់ញ័រដោយតេជះនៃធម៌ ។ ផែនដីកម្រើកបន្ទឺឡើងដូចជាឃ្នាបអំពៅដែលត្រូវគេគាប ឬចក្រយន្ត ប្រេងត្រូវគេគាបហើយ ( វិមែងវិលញ័រ ) យ៉ាងណា ផែនដីក៏ញាប់ញ័រ យ៉ាងនោះដែរ ។ បរិស័ទរបស់ព្រះពុទ្ធមានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាសបរិស័ទនោះ ក៏ញាប់ញ័រ ដេកជ្រប់លើផែនដី ក្នុងទីអង្គាសនោះ ។ ឆ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចគ្នាបែកខ្ទេចខ្ទីអស់ក្នុងទីនោះ ។

គ្រានោះ ពួកមហាជនមានចិត្តរន្ធត់តក់ស្លុត ភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយ ចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់

ដូចម្ដេច នឹងមានដល់មនុស្សលោក លោកទាំងមូលត្រូវសេចក្ដីអន្តរាយបៀតបៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោស បន្ទោបង់សេចក្ដីអន្តរាយនោះចេញ ។ គ្រានោះ ព្រះមហាមុនីទីបង្ករ ទ្រង់ញ៉ាំងមហាជនទាំងនោះឲ្យយល់ច្បាស់ថា អ្នកទាំងឡាយ ចូរកុំមានសេចក្ដីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។ ដ្បិតតថាគតបានព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ( ក្នុងកាលជាអនាគត ) សុមេធបណ្ឌិតនោះ កំពុងពិចារណាធម៌ ដែលព្រះភគវាអំពីបុរាណធ្លាប់សេពមកហើយ ។ កាលសុមេធបណ្ឌិតពិចារណាធម៌ គឺពុទ្ធភូមិ ដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោក ព្រមទាំងទេវលោក ញាប់ញ័រ ។ ចិត្ត ( នៃមហាជន ) ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះបានស្ដាប់ព្រះបន្ទូលរបស់ព្រះសាស្ដា ពួកមហាជនទាំងអស់គ្នា ក៏ចូលមករកតថាគត ហើយក្រាបថ្វាយបង្គំម្ដងទៀត ។ គ្រានោះ តថាគត សមាទាននូវពុទ្ធគុណ ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ ។ ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្ស ចំពោះសុមេធបណ្ឌិតដែល

ក្រោកចាកអាសនៈ ។ ពួកទេវតា និងពួកមនុស្សទាំងពីរពួកនោះ បាននូវសួស្តី ( ពោលថា ) តំណែងដ៏ធំដែលលោកប្រាថ្នាហើយ សូមលោកបាននូវតំណែងនោះ សមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួងចូរបវៀសចៀសចេញទៅ សេចក្តីសោក និងរោគ ក៏ចូរចៀសវាងចេញទៅ សេចក្តីអន្តរាយ កុំបីមានដល់លោកឡើយ សូមលោកបានលុះនូវសព្វញ្ញុតញ្ញាណដ៏ខ្ពង់ខ្ពស់ឆាប់ៗ ចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែងបញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កាដោយពុទ្ធញ្ញាណ យ៉ាងនោះដែរ ។ ព្រះសាស្តាទាំងឡាយណាមួយ ទ្រង់បំពេញហើយនូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកបំពេញបារមីទាំង១០យ៉ាងនោះចុះ ។ ព្រះទសពលទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀបគល់ពោធិមណ្ឌល យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកត្រាស់ដឹងទៀបគល់ពោធិមណ្ឌលនៃព្រះភគវាយ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅយ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់ រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា

លោកក៏មានចិត្តពេញ ចូររុងរឿងក្នុងលោកធាតុទាំងមួយម៉ឺនយ៉ាងនោះ ។ ព្រះអាទិត្យដែលរួចផុតអំពីរាហូ រមែងរុងរឿងដោយកម្តៅ យ៉ាងណា សូមលោករួចចាកលោកធម៌ សូមរុងរឿងដោយពុទ្ធសិរីយ៉ាងនោះ ។ ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណា ពួកលោក ព្រមទាំងទេវលោក ក៏រមែងប្រជុំក្នុងសម្នាក់របស់លោក យ៉ាងនោះដែរ ។ គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតា និង មនុស្សទាំងនោះស្ញើចសរសើរហើយ ក៏សមាទាននូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ហើយចូលទៅកាន់ព្រៃធំ ។

## ចប់ សុមេធកថា

គ្រានោះ ពួកឧបាសក ឧបាសិកាទាំងនោះ ញុំាងព្រះសាស្តា ព្រមទាំងព្រះសង្ឃ ឲ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្តាទីបង្ករនោះ ជាទីពឹង ។ ព្រះតថាគតទ្រង់ញុំាងបុគ្គលខ្លះ ឲ្យតម្កល់នៅក្នុងសរណគមន៍ ញុំាងបុគ្គលខ្លះឲ្យតាំងនៅក្នុងសីល ៥ ញុំាងបុគ្គលដទៃទៀតឲ្យតម្កល់ នៅក្នុងសីល ១០ ។ ព្រះអង្គទ្រង់ប្រទានមគ្គដល់បុគ្គលខ្លះ ប្រទានផល ដ៏ឧត្តមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើ ដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរ ជាឯនរជន ទ្រង់ប្រទានសមាបត្តិ

៨ ដ៏ប្រសើរដល់បុគ្គលខ្លះ ប្រទានវិជ្ជា ៣ ដល់បុគ្គលខ្លះ ប្រទានអភិញ្ញា ៦ ដល់បុគ្គលខ្លះ ។ ព្រះភគវាទ្រង់ទូន្មានពួកជន ដោយន័យជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនានៃព្រះសម្ពុទ្ធ ជាគុណជាតដ៏ធំទូលាយ ។ ព្រះពុទ្ធទីបង្ករ មានព្រះហនុកា ( ដូចព្រះច័ន្ទក្នុងថ្ងៃ ១២ កើត ) មានដងខ្លួនមូលក្លំដូចគោឧសភៈ ទ្រង់ចម្លងពួកជនច្រើនឲ្យរួចចាកទុគ្គតិ ។ ព្រះមហាមុនីទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹងស្ថិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិតហើយ ញ៉ាំងពួកជននោះឲ្យត្រាស់ដឹងក្នុងខណៈនោះ ។ ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ញ៉ាំងពួកទេវតា ១០០ កោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ព្រះលោកនាយក ទ្រង់ញ៉ាំងពួកទេវតា និងមនុស្ស ៩០ កោដិឲ្យត្រាស់ដឹង ។ កាលណា ព្រះសម្ពុទ្ធទ្រង់សម្តែងធម៌ក្នុងភពនៃទេវតាកាលនោះ ពួកទេវតា ៩០ ពាន់កោដិ ( បានត្រាស់ដឹង ) នេះជាការត្រាស់ដឹងទី ៣ ។ ព្រះសាស្តាទីបង្ករមានសាវកសន្និបាត ( ការជួបជុំសាវក ) ៣ លើក គឺសន្និបាតលើកទី ១ មានភិក្ខុសង្ឃ ១ សែនកោដិ ។ កាលដែលព្រះទសពល ទ្រង់យាងទៅក្នុងទីស្ងាត់លើកំពូលភ្នំនារទៈ ពួកព្រះខីណាស្រព ប្រាសចាកមន្ទិលចំនួន ១០០ កោដិមកប្រជុំគ្នា

( នេះជាសន្និបាតលើកទី ២ ) ។ កាលព្រះមហាមុនី មានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ ៩០ កោដិ ពួដ៏ក្នុំសុទស្សនៈ ( នេះជាសន្និបាតលើកទី ៣ ) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅពួដ៏អាកាស ជាអ្នក បានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ។ ពួកសត្វចំនួន ៣ ម៉ឺនបាន ត្រាស់ដឹងនូវសច្ចៈ ការត្រាស់ដឹងរបស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់ មិនអស់ឡើយ ។ សាសនារបស់ព្រះទីបង្ករមានព្រះភាគជាគុណជាត ធំទូលាយ មានជនច្រើនស្តុកស្តម្ភ សាយភាយ គឺព្រះអង្គទ្រង់ជម្រះ ល្អហើយ ក្នុងកាលនោះ ។ ពួកព្រះខីណាស្រពចំនួន ៤ សែនរូប បានលុះអភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករ ដែលទ្រង់ ជ្រាបច្បាស់នូវលោកសព្វកាល ។ ក្នុងសម័យនោះ ពួកជនណាមួយ ដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខបុគ្គល លះបង់នូវការកើត ជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។ សាសនារបស់ព្រះ ពុទ្ធទីបង្ករនោះ រីកសាយល្អ រុងរឿងដោយពួកព្រះអរហន្តខីណាស្រព ជាតាទិគុណ ប្រាសចាកមន្ទិលសព្វកាល ។ នគររបស់ព្រះសាស្តា ព្រះនាមទីបង្ករឈ្មោះ រម្មាវតី ក្សត្រព្រះនាមសុទេវៈ ( ជាព្រះបិតា )

ព្រះជនិកាព្រះនាមសុមេធា ។ ព្រះមុនីនៅគ្រប់គ្រងផ្ទះអស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ខ្ពង់ខ្ពស់ មាន ៣ ខ្នង គឺហង្សប្រាសាទ ១ កោញ្ចប្រាសាទ ១ មយុរប្រាសាទ ១ ។ ពួកនារី ៣ សែននាក់ សុទ្ធតែតាក់តែងយ៉ាងល្អ នារីឈ្មោះបទុមានោះ ( ជាមហេសី ) ព្រះឱរសព្រះនាមឧសភក្ខន្ធ ។ ព្រះជិនស្រីឃើញនិមិត្តទាំង ៤ ទ្រង់ចេញទៅបួសដោយយាន គឺដំរី ទ្រង់ផ្គងព្យាយាមអស់ ១០ ខែឥតខ្វះ ។ លុះព្រះសាស្តាមានព្រះទ័យ ប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ដឹងជាព្រះពុទ្ធ ព្រះសាស្តាទីបង្ករ ត្រូវព្រហ្មអារាធនាហើយ ។ ព្រះជិនស្រីមានព្យាយាមធំ ទ្រង់ញ៉ាំង ធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងវត្តនន្ទ: ទ្រង់គង់ទៀបគល់ព្រេស ធ្វើនូវការ ញ៉ាំញីតិរ្ថិយ ។

គ្រានោះ ព្រះសុមង្គលៈ និងព្រះតិស្សៈ ជាអគ្គសាវក ព្រះ សាគតៈជាឧបដ្ឋាក របស់ព្រះសាស្តាទីបង្ករ ។ នាងនន្ទា និងសុនន្ទា ជាអគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា ដើមល្ងៀប ។ ឧបាសកឈ្មោះតបុស្សៈ និងភល្លិកៈ ជាឧបដ្ឋាកដ៏ប្រសើរ នាងសិរិមា និងនាងសោណា ជាឧបដ្ឋាយិការបស់ព្រះសាស្តាទីបង្ករ ។ ព្រះមហាមុនីទីបង្ករ មានកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬ

ដូចដើមសាលរាជព្រឹក្ស មានផ្ការីកស្គុសស្គាយ ។ រស្មីរបស់ព្រះអង្គផ្សាយទៅចម្ងាយ ១០ យោជន៍ជុំវិញ ព្រះមហេសីនោះមានព្រះជន្មាយុ ១ សែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញុំាងព្រះសទ្ធម្មឲ្យរុងរឿង ចម្លងមហាជន ញុំាងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារវដ្ត ។ ព្រះទីបង្ករនោះ ព្រមទាំងសាវកនិព្វានទៅ ដូចគំនរភ្លើងដែលរុងរឿងរលត់ទៅដូច្នោះ ឫទ្ធិនោះក្តី យសនោះក្តី ទាំងចក្ករតនៈ ពួដ៏ព្រះបាទានោះក្តីក៏រលត់ទៅ សម្បត្តិទាំងអស់ ក៏អន្តរធានទៅ ឱហ្ន៎! សង្ខារទាំងពួងជារបស់សោះសូន្យទទេ ព្រះជិនស្រីជាសាស្តាចារ្យ ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ ។ ព្រះស្តូបរបស់ព្រះជិនស្រីនោះកម្ពស់ ៣៦ យោជន៍ ( គេសាងទុក ) ក្នុងវត្តនន្ទៈនោះឯង ។ គ្រានោះ ( ពួកជនកសាង ) ព្រះស្តូបកម្ពស់ ៣ យោជន៍ទៀបគល់ពោធិព្រឹក្ស ( សម្រាប់បញ្ចុះ ) បាត្រ និងចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់របស់ព្រះសាស្តា ។

**ចប់ ទីបង្ករពុទ្ធវង្សទី ១**

# កោណ្ឌញ្ញពុទ្ធវង្សទី ២

សម័យខាងក្រោយអំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោកនាយក ព្រះនាមកោណ្ឌញ្ញៈ ទ្រង់មានតេជៈរកទីបំផុតគ្មាន មានយសរាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយបុគ្គលគ្របសង្កត់បាន ។ ព្រះអង្គមានការអត់ធន់ ប្រៀបដោយធរណី មានសីល ប្រៀបដោយសាគរ មានសមាធិប្រៀបដោយភ្នំសិនេរុ មានញាណ ប្រៀបដោយអាកាស ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសហើយ នូវការប្រកាសឥន្ទ្រិយពលៈ ពោជ្ឈង្គ និងមគ្គសច្ច ដើម្បីប្រយោជន៍ ដល់សព្វសត្វទាំងឡាយសព្វកាល ។ កាលព្រះកោណ្ឌញ្ញៈ ជាលោកនាយក ទ្រង់សម្ដែងធម្មចក្រ ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផលលើកទី ១ ។ លំដាប់តអំពីនោះ កាលព្រះពុទ្ធអង្គទ្រង់សម្ដែងធម៌ ក្នុងសមាគមនៃមនុស្ស និងទេវតា ពួកសត្វ ៩០ ពាន់កោដិ បានសម្រេចមគ្គផលលើកទី ២ ។ កាលព្រះសាស្តា ទ្រង់សម្ដែងធម៌ញាំញីពួកតិត្ថិយ ពួកសត្វ ៨០ ពាន់កោដិ បានសម្រេចមគ្គផលលើកទី ៣ ។ ព្រះមហេសី ព្រះនាមកោណ្ឌញ្ញៈ មានសាវកសន្និបាត ៣ លើក គឺសន្និបាតទី ១ មានព្រះខីណាស្រព

ដែលប្រាសចាកមន្ទិល មានចិត្តស្ងប់រំងាប់ មានចិត្តនឹងធឹង ចំនួន ១ សែនកោដិ សន្និបាតទី ២ មានព្រះខីណាស្រព ១ ពាន់កោដិ សន្និបាតទី ៣ មានព្រះខីណាស្រព ៩០ កោដិ ។ ក្នុងសម័យនោះ តថាគតបានកើតជាក្សត្រ មានឈ្មោះថា **វិជិតាវី** បានញ៉ាំងឥស្សរិយយសឲ្យប្រព្រឹត្តទៅ រហូតដល់សមុទ្រជាទីបំផុត ។ តថាគតបាននិមន្តព្រះខីណាស្រពមួយសែនកោដិ ដែលប្រាសចាកមន្ទិល ស្វែងរកគុណដ៏ធំព្រមទាំងព្រះបរមសាស្តា ជាទីពឹងដ៏ប្រសើរ របស់សត្វលោកឲ្យឆ្អែតស្កប់ស្កល់ ដោយម្ហូបចំណីដ៏ថ្លៃថ្លា ។ ព្រះសាស្តា ជានាយកព្រះនាមកោណ្ឌញ្ញៈអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបានអំពីកប្បនេះ បុរសនេះនឹងបានជាព្រះពុទ្ធក្នុងលោក ។ សត្វ (នេះ) នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ ។ តអំពីនោះមក សត្វនេះមានយសច្រើន

ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ( ដើមពោធិ៍ ) ។

ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធនោះ នឹងមានព្រះនាមថា **មាយា** ព្រះបិតាមានព្រះនាមថា **សុទ្ធោទនៈ** ឯព្រះពុទ្ធអង្គនោះ មានព្រះនាម **គោតម** ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ មិនមានអាសវៈប្រាសចាកតម្រេក មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវកព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈប្រាសចាកតម្រេក មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ពោធិព្រឹក្សរបស់ព្រះសម្ពុទ្ធអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកជាឧបដ្ឋាកដ៏ប្រសើរឈ្មោះ ចិត្តៈ ១ ហត្ថាឡវកៈ ១ ។ ឧបាសិកាជាឧបដ្ឋាយិកាដ៏ប្រសើរឈ្មោះនន្ទមាតា ១ ឧត្តរា ១ ព្រះគោតមដ៏ទ្រង់យសអង្គនោះមានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ភាសិតរបស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំនេះហើយ ក៏រីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្សព្រមទាំងទេវតាមួយម៉ឺន មានសំឡេងហ៊ោឡើងផង ទះដៃផង សើចផង

ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនារបស់ព្រះលោកនាថកោណ្ឌញ្ញៈអង្គនេះ គង់នឹងបានជួបចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ពួកមនុស្សកាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា យើងទាំងអស់គ្នា បើលះបង់ព្រះជិនស្រីនេះហើយ គង់នឹងបានជួបចំពោះព្រះភក្ត្រ នៃព្រះបរមសាស្តាអង្គនោះក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់នូវព្រះតម្រាស់របស់ព្រះសម្ពុទ្ធអង្គនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក កាលញ៉ាំងប្រយោជន៍នោះឲ្យសម្រេច បានថ្វាយរាជសម្បត្តិដ៏ធំចំពោះព្រះជិនស្រី លុះថ្វាយរាជសម្បត្តិដ៏ធំហើយ ទើបបួសក្នុងសម្នាក់របស់ព្រះអង្គ ។ តថាគតបានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនាមានអង្គ ៩ ទាំងអស់ ហើយញ៉ាំងព្រះសាសនានៃព្រះមុនីឲ្យរុងរឿង ។ តថាគតមិនប្រមាទ កាលនៅក្នុងទីនោះ បានសម្រេចអភិញ្ញាបារមីក្នុងទីអង្គុយ និងទីចង្ក្រម ក៏បានទៅកើតក្នុងព្រហ្មលោក ។ ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះរម្មវតីមានព្រះបិតាព្រះនាម **សុនន្ទៈ** ព្រះមាតាព្រះនាម **នាងសុជាតាទេវី** ។

ព្រះអង្គគង់នៅក្នុងកណ្តាលផ្ទះអស់មួយម៉ឺនឆ្នាំ ឯប្រាសាទដ៏ប្រសើរសម្រាប់ព្រះអង្គ មាន ៣ គឺរុចិប្រាសាទ ១ សុរុចិប្រាសាទ ១ សុកប្រាសាទ ១ ។ នារី ៣ សែន មានគ្រឿងប្រដាប់សមរម្យ នារីជាកិរិយានោះព្រះនាម **រុចិទេវី** មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាម **ជីវិតសេន** ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាង ទ្រង់ចេញដោយយាន គឺរថ ទៅតាំងសេចក្តីព្យាយាមអស់ ១០ ខែឥតខ្វះ ។ ព្រះសម្ពុទ្ធព្រះនាមកោណ្ឌញ្ញៈ មានព្រះទ័យស្ងប់រំងាប់ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ មានចក្រប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនាក្នុងមហាវ័ន របស់ពួកទេវតា ។ ព្រះថេរៈឈ្មោះភទ្ទៈ ១ សុភទ្ទៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអនុរុទ្ធ ជាឧបដ្ឋាករបស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកគុណដ៏ធំ ។ ភិក្ខុនីឈ្មោះតិស្សា ១ ឧបតិស្សា ១ ជាអគ្គសាវិកា សាលកល្យាណិព្រឹក្សជាពោធិ៍ របស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ឧបាសកឈ្មោះសោណៈ ១ ឧបសោណៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនន្ទា ១ សិរិមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីអង្គនោះ មានកម្ពស់ ៨៨ ហត្ថ ទ្រង់ល្អល្អះដូចព្រះច័ន្ទពុំនោះសោត ដូចព្រះអាទិត្យ ក្នុងវេលាថ្ងៃត្រង់ ។ ព្រះសាស្តាមាន

ព្រះជន្មាយុមួយសែនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកវាលវដ្តសង្សារ ) ។ ផែនដីដ៏វិចិត្រដោយព្រះខីណាស្រពទាំងឡាយ ដែលអស់មន្ទិល ព្រះសម្ពុទ្ធអង្គនោះ ទ្រង់រុងរឿងដូចមេឃ ដែលល្អដោយពួកផ្កាយ ។ព្រះនាគត្ថេរទាំងអម្បាលនោះ មានគុណប្រមាណមិនបាន មានសន្តានមិនកម្រើក បុគ្គលចូលទៅរកបានដោយកម្រ សម្តែងនូវឫទ្ធិ ដូចការធ្លាក់ចុះនៃផ្លេកបន្ទោរ ព្រះអរហន្តដ៏មានយសធំទាំងនោះ និព្វានហើយ ។ចំណែកឫទ្ធិរបស់ព្រះជិនស្រីនោះ ជាគុណឥតប្រឹងថ្លែង បានសមាធិ មានញាណអប់រំហើយ របស់ទាំងអស់ វិនាសសូន្យទៅ សង្ខារទាំង-ពួងជារបស់ទទេពិត ។ ព្រះកោណ្ឌញ្ញសម្ពុទ្ធ ព្រះអង្គទ្រទ្រង់សិរីទ្រង់បរិនិព្វានក្នុងនន្ទារាម ពួកមហាជនបានបញ្ចុះ ( ព្រះអដ្ឋិ ) របស់ព្រះអង្គនោះក្នុងចេតិយ មានកម្ពស់ ៧ យោជន៍ ក្នុងនន្ទារាមនោះឯង ។

**ចប់ កោណ្ឌញ្ញពុទ្ធវង្សទី ២**

# មង្គលពុទ្ធវង្សទី ៣

កាលខាងក្រោយអំពីព្រះសម្ពុទ្ធកោណ្ឌញ្ញៈមក ព្រះលោកនាថ ព្រះនាមមង្គលៈ ទ្រង់កម្ចាត់បង់ងងឹតក្នុងលោក ព្រះពុទ្ធអង្គទ្រទ្រង់នូវគប់ភ្លើង គឺព្រះធម៌ ។ពន្លឺរបស់ព្រះអង្គឥតថ្លឹងបាន ជាពន្លឺលើសលប់ជាងព្រះជិនស្រីដទៃ គ្របសង្កត់ពន្លឺព្រះច័ន្ទ និងព្រះអាទិត្យ រុងរឿងអស់មួយម៉ឺនលោកធាតុ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ប្រកាសសច្ចៈ ៤ ដ៏ប្រសើរ ពួកសត្វនោះៗ បានផឹករសសច្ចៈ ហើយកម្ចាត់ងងឹតធំ គឺមោហៈ ។ ព្រះសាស្ដាអង្គនោះ បានដល់នូវពោធិញ្ញាណ ជាគុណឥតថ្លឹងបាន កាលសម្ដែងធម៌ជាដំបូង ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផលលើកទី ១ ។ ព្រះលោកនាថ ទ្រង់សម្ដែងធម៌ក្នុងសុរិន្ទទេវភព កាលនោះ ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផលលើកទី ២ ។ កាលព្រះបាទសុនន្ទចក្រពត្តិ ទ្រង់ចូលទៅគាល់ព្រះសម្ពុទ្ធ កាលនោះ ព្រះទសពលទ្រង់វាយស្គរ គឺព្រះធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ ។ កាលនោះ ពួកជនដែលតាមហែព្រះបាទសុនន្ទៈ មានចំនួន ៩០ កោដិ ជនទាំងអស់នោះ បានជាឯហិភិក្ខុ ឥតសេសសល់ ( លើកទី ៣ )

ព្រះមង្គលសម្ពុទ្ធ ព្រះអង្គស្វែងរកគុណដ៏ធំ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានព្រះខីណាស្រពមួយកោដិ សន្និបាតលើកទី ២ មានព្រះខីណាស្រពមួយសែនកោដិ សន្និបាតលើកទី ៣ មានព្រះខីណាស្រព ៩០ កោដិ ។ សមាគមក្នុងកាលនោះ សុទ្ធតែព្រះខីណាស្រព ប្រាសចាកមន្ទិល សម័យនោះ តថាគតជាព្រាហ្មណ៍ឈ្មោះសុរុចិ ។ តថាគតអ្នករៀនមន្ត ចងចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ ហើយបានដល់នូវព្រះសាស្តាជាទីពឹង ។ តថាគតបានបូជាព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយគ្រឿងក្រអូប និងផ្កាកម្រង លុះបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងហើយ ក៏ញុំាងកិក្ខុសង្ឃឲ្យឆ្អែតស្កប់ស្កល់ ដោយទឹកដោះគោ ។ ព្រះសម្ពុទ្ធព្រះនាមមង្គលៈនោះ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ទ្រង់ទំនាយតថាគតថា ក្នុងរវាងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ បុរសនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ តាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។សត្វនេះនឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះសាស្តាអង្គនោះ ទ្រង់សោយបាយាស

ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែង ។ លំដាប់អំពីនោះទៅ ព្រះលោកនាយកមានយសច្រើន នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសាស្តាអង្គនោះ ព្រះនាម មាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ ឯបុរសនេះជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹងរបស់ព្រះលោកនាថអង្គនោះ ហៅថា អស្សត្ថព្រឹក្ស (ដើមពោធិ៍) ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ឮព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធមិនមានបុគ្គលស្មើ ស្វែងរកគុណដ៏ធំហើយ

ក៏មានចិត្តរីករាយថា បុគ្គលនេះជាពូជពន្ធុកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយបើឃ្លាងមគ្គផល ក្នុងសាសនា របស់ព្រះលោកនាយកនេះ គង់នឹងបានសម្រេចចំពោះ ព្រះភក្ត្រនៃព្រះបរមសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាង ព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តា អង្គនោះ ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះដែរ ។ តថាគតបាន ស្តាប់ព្រះតម្រាស់របស់ព្រះពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ក្នុងកាលនោះ តថាគត ចម្រើនបីតិ ថ្វាយផ្ទះរបស់តថាគត ចំពោះព្រះសម្មាសម្ពុទ្ធ ហើយបួសក្នុងសម្នាក់ព្រះអង្គ ដើម្បីសម្រេចពោធិញ្ញាណដ៏ប្រសើរ ។ តថាគតបានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនាមានអង្គ ៩ ទាំងអស់ ហើយញ៉ាំងសាសនាព្រះជិនស្រី ឲ្យល្អរុងរឿង ។ តថាគត មិនប្រមាទ កាលនៅក្នុងទីនោះ ចម្រើនព្រហ្មវិហារ បានសម្រេច

អភិញ្ញាបារមី ហើយក៏បានទៅកើតនៅក្នុងព្រហ្មលោក ។ ព្រះមង្គលៈ ទ្រង់ស្វែងរកនូវគុណធំ មាននគរឈ្មោះឧត្តរៈ មហាក្សត្រព្រះនាម ឧត្តរៈ ជាព្រះបិតា ព្រះមាតាព្រះនាម ឧត្តរា ។

ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងរាជជំណាក់អស់ ៩ ពាន់ឆ្នាំ មានប្រាសាទ ៣ ដ៏ល្អឧត្តម គឺយសវប្រាសាទ ១ សុចិមប្រាសាទ ១ សិរិមប្រាសាទ ១ មានពួកនារី ៣ ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ នារីជាភរិយាឈ្មោះ យសវតី មានព្រះរាជបុត្រឈ្មោះ សីវលៈ ។ ព្រះជិនស្រី ទ្រង់ឃើញនិមិត្ត ៤ ហើយទ្រង់ចេញទៅដោយយាន គឺសេះ តាំងសេចក្ដីព្យាយាមអស់ ៨ ខែឥតខ្វះ ។ ព្រះសាស្ដាព្រះនាម មង្គលៈ មានព្រះទ័យស្ងប់រំងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅ មានព្យាយាម ទ្រង់ប្រសើរជាងសត្វទ្វេបាទ ត្រូវមហាព្រហ្មអារាធនាហើយ ទើបស្ដេចត្រាច់ទៅ គឺសម្ដែងធម៌ ។ ព្រះថេរៈឈ្មោះសុទេវៈ ១ ធម្មសេន ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះបាលិតៈ ជាឧបដ្ឋាក របស់ព្រះមង្គលៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះ សីវលា ១ អសោកា ១ ជាអគ្គសាវិកា ដើមឈើត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ ហៅថា នាគព្រឹក្ស ( ដើមខ្លឹង ) ។ ឧបាសក ឈ្មោះនន្ទុៈ ១ វិសាខៈ ១

ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះអនុឡា ១ សុមនា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីទ្រង់មានកម្ពស់ ៨៨ ហត្ថ រស្មីច្រើនសែន ផ្សាយចេញអំពីកាយព្រះសម្ពុទ្ធ ។ ព្រះជន្មាយុរបស់ព្រះអង្គ ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ស្ថិតនៅជរាបនោះ ញ៉ាំងពួកជនច្រើនឲ្យឆ្លង (វដ្តសង្សារ) ។ រលកក្នុងសាគរ គេមិនអាចរាប់បាន យ៉ាងណាមិញ សាវកទាំងឡាយរបស់ព្រះអង្គ ក៏គេមិនអាចរាប់បានយ៉ាងនោះដែរ ។ ព្រះមង្គលសម្ពុទ្ធជានាយក ទ្រង់បានស្ថិតនៅជរាបណា មរណៈប្រកបដោយកិលេសមិនមានក្នុងសាសនានៃព្រះអង្គជរាបនោះ ។ ព្រះសម្ពុទ្ធទ្រង់មានយសច្រើនអង្គនោះ ទ្រទ្រង់នូវគប់ភ្លើង គឺព្រះធម៌ ហើយញ៉ាំងមហាជនឲ្យឆ្លងដ៏រុងរឿង ដូចជាផ្កាយដុះកន្ទុយ ទ្រង់បរិនិព្វាន ។ ព្រះសម្ពុទ្ធទ្រង់សម្តែងនូវភាពប្រែប្រួលនៃសង្ខារដល់ពួកមនុស្ស ព្រមទាំងទេវតារុងរឿងដូចគំនរភ្លើង ពុំនោះសោត ដូចព្រះអាទិត្យ ដែលទើបនឹងអស្តង្គត ។ ព្រះមង្គលសម្ពុទ្ធ ទ្រង់បរិនិព្វានក្នុងឧទ្យានឈ្មោះវេស្សរៈ ព្រះស្តូបរបស់ព្រះលោកនាយកអង្គនោះ មានកម្ពស់ ៣០ យោជន៍ មាននៅក្នុងទីនោះឯង ។

ចប់ មង្គលពុទ្ធវង្សទី ៣

# សុមនពុទ្ធវង្សទី ៤

កាលខាងក្រោយអំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយក ព្រះនាមសុមនៈ រកបុគ្គលស្មើគ្មានដោយធម៌ទាំងពួង ព្រះអង្គឧត្តមជាង សព្វសត្វ ។ កាលនោះព្រះអង្គទ្រង់ទូងស្គរ គឺអមតៈ ប្រកបដោយស័ង្ខ គឺធម៌ ជាសាសនារបស់ព្រះជិនស្រី មានអង្គ ៩ ក្នុងមេខលបុរី ។ ព្រះបរមសាស្ដាអង្គនោះ ទ្រង់ឈ្នះនូវកិលេស ហើយសម្រេចនូវ សម្ពោធិញ្ញាណដ៏ប្រសើរ ទ្រង់សាងនគរជាបុរី គឺព្រះសទ្ធម្មដ៏ប្រសើរ ខ្ពង់ខ្ពស់ ។ ព្រះសាស្ដាទ្រង់សាងផ្លូវធំ មិនមានចន្លោះ ជាផ្លូវមិនវៀច ជាផ្លូវត្រង់ មានទទឹងដ៏ធំទូលាយ គឺសតិប្បដ្ឋានដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះលោកនាថ ទ្រង់លាតសាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ សមាបត្តិ ៨ ក្នុងផ្លូវនោះ ។ ពួកសត្វណា មិនមានសេចក្ដីប្រមាទ មិនរឹងរូស ប្រកបដោយសេចក្ដីខ្មាសបាប និងសេចក្ដីព្យាយាម ពួក សត្វនោះៗ តែងកាន់យកគុណដ៏ប្រសើរទាំងនេះ តាមសប្បាយ ។ ព្រះសាស្ដាទ្រង់ស្រោចស្រង់មហាជន ដោយសេចក្ដីព្យាយាមនោះ យ៉ាងនេះឯង បានញ៉ាំងសត្វមួយសែនកោដិឲ្យត្រាស់ដឹងលើកទី ១ ។

ព្រះភគវាមានព្យាយាមច្រើន ទ្រង់ឲ្យឱវាទដល់ពួកតិរ្ថិយក្នុងកាលណា កាលនោះ សត្វមួយសែនកោដិ ( បានសម្រេចគុណវិសេស ) ក្នុងធម្មទេសនា លើកទី ២ ។ ពួកទេវតា និងមនុស្ស មានសេចក្តីព្រមព្រៀងគ្នា មានចិត្តស្រួលបួល សួរប្រស្នាក្នុងនិរោធផង សេចក្តីសង្ស័យផង សេចក្តីប្រាថ្នាក្នុងចិត្តផង ក្នុងកាលណា កាលនោះ ពួកសត្វ ៩០ ពាន់កោដិ បានសម្រេចមគ្គផលលើកទី ៣ ក្នុងព្រះធម្មទេសនាជាគ្រឿងបំភ្លឺនូវនិរោធ ។ ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវ័កសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រំងាប់ ទាំងមានចិត្តនឹងធឹង ។ កាលព្រះមុនីទ្រង់ចេញវស្សាហើយ កាលភិក្ខុសង្ឃប្រកាសបវារណាហើយ ព្រះតថាគត ទ្រង់បវារណា ដោយភិក្ខុចំនួនមួយសែនកោដិ ( នេះជាសន្និបាតលើកទី ១ ) ។ ក្នុងការប្រជុំដទៃអំពីនោះមក មានសន្និបាតលើកទី ២ នៃព្រះខីណាស្រព ៩០ ពាន់កោដិ លើកញ្ញនបព៌តមិនមានមន្ទិល ។ កាលសក្កទេវរាជចូលមកគាល់ព្រះសម្ពុទ្ធ ជាសន្និបាតលើកទី ៣ នៃព្រះខីណាស្រព ៨០ ពាន់កោដិ ។ ក្នុងសម័យនោះ តថាគតកើតជាស្តេចនាគមានឫទ្ធិច្រើន មានឈ្មោះថា អតុលៈ ជាអ្នក

សន្សំកុសល ។ កាលនោះ តថាគតចេញអំពីភពនាគ ជាមួយនឹងពួកញាតិ បានទៅបម្រើព្រះលោកនាយក ព្រមទាំងភិក្ខុសង្ឃ ដោយតន្ត្រីជាទិព្វ របស់នាគ ។ តថាគតបានញ៉ាំងភិក្ខុសង្ឃមួយសែនកោដិ ឲ្យឆ្អែត ស្កប់ស្កល់ ដោយបាយទឹក ហើយថ្វាយសំពត់មួយគូៗ មួយអង្គ ហើយយកព្រះភិក្ខុសង្ឃ នោះជាទីពឹង ។ ព្រះសម្ពុទ្ធព្រះនាមសុមនៈ ជានាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះ នាគរាជនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញ អំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយទៅតម្កល់សេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួល បាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រី អង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេច ចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដែលគេចាត់ចែងដ៏ប្រសើរ ។ លំដាប់តអំពីនោះមក ព្រះសាស្តា មានយសច្រើនអង្គនោះ ទ្រង់ធ្វើ ប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់ អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនោះ ព្រះនាម មាយា ព្រះបិតា ព្រះនាម សុទ្ធោទនៈ ឯនាគរាជនេះនឹងបានត្រាស់ជាព្រះពុទ្ធ

ព្រះនាម គោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ។ ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះសម្ពុទ្ធអង្គនោះ ហៅថា អស្សត្ថព្រឹក្ស (ដើមពោធិ៍) ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់មានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្ដាប់ព្រះពុទ្ធដីកានេះ របស់ព្រះអង្គមិនមានបុគ្គលស្មើស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា នាគរាជនេះនឹងជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុស្រែកហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះពុទ្ធអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្ដាអង្គនោះ ក្នុងកាល

ជាអនាគតមិនខាន ។ ពួកមនុស្សក្រោលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខានក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះតម្រាស់របស់ព្រះពុទ្ធនោះហើយក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ ព្រះសុមនសម្ពុទ្ធទ្រង់ស្វែងរកគុណដ៏ធំ មានទីក្រុងឈ្មោះមេខលៈ មានមហាក្សត្រព្រះនាមសុទត្តៈ ជាព្រះបិតា ព្រះមាតាព្រះនាមសិរិមា ។ ព្រះអង្គគ្រប់គ្រងព្រះរាជដំណាក់អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺចន្ទប្រាសាទ ១ សុចន្ទប្រាសាទ ១ វដំសប្រាសាទ ១ ។ ពួកនារី ៦៣ សែននាក់ មានរូបប្រដាប់សមរម្យនារី ( ជាអគ្គមហេសី ) ព្រះនាមវដំសកី ព្រះរាជបុត្រព្រះនាមអនូបមៈ ។ ព្រះលោកនាថឃើញនិមិត្ត ៤ ហើយ ទ្រង់ចេញបព្វជ្ជាដោយយានដំរី ទ្រង់តាំងសេចក្តីព្យាយាមអស់ ១០ ខែ ឥតខ្វះ ។ ព្រះលោកនាយកព្រះនាមសុមនៈ មានព្រះទ័យស្ងប់រំងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅមានព្យាយាមធំ ត្រូវព្រហ្មអារាធនា ក្នុងមេខលបុរីដ៏ប្រសើរខ្ពង់ខ្ពស់ ។

ព្រះថេរៈឈ្មោះសរណៈ ១ ភាវិតត្ថៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះឧទេន ជាឧបដ្ឋាករបស់ព្រះសម្ពុទ្ធ ព្រះនាមសុមនៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះសោណា ១ ឧបសោណា ១ ជាអគ្គសាវិកាព្រះទសពលនោះ ស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ទ្រង់បានត្រាស់ដឹង ទៀបគល់នាគព្រឹក្ស ។ ឧបាសកឈ្មោះវរុណៈ ១ សរុណៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះចាលា ១ ឧបចាលា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៩០ ហត្ថមានលម្អនៃព្រះរូបប្រហែលដូចជាគ្រឿងបូជាមាស ទ្រង់រុងរឿងក្នុងមួយម៉ឺនលោកធាតុ ។ ព្រះជន្មាយុ ( របស់ព្រះអង្គ ) ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ស្ថិតនៅដរាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( វដ្តសង្សារ ) ។ ព្រះសម្ពុទ្ធទ្រង់ចម្លងពួកសត្វដែលគួរចម្លង ទ្រង់បានដាស់តឿនពួកសត្វ ដែលគួរដាស់តឿន ហើយទ្រង់បរិនិព្វាន ដូចព្រះច័ន្ទអស្តង្គត ។ ភិក្ខុទាំងឡាយនោះ ជាព្រះខីណាស្រពក្តី ព្រះសម្ពុទ្ធអង្គនោះក្តី ទ្រង់មិនមានបុគ្គលណាស្មើ ទ្រង់បញ្ចេញរស្មីឥតប្រៀបថ្លៃងបានព្រះខីណាស្រពមានយសច្រើនទាំងនោះនិព្វានហើយ ។ ព្រះញាណនោះជាគុណឥតមានអ្វីប្រៀបបានផង រតនៈទាំងនោះ ឥតមានអ្វីប្រៀបបានផង

របស់ទាំងអស់នោះ វិនាសសូន្យទៅ សង្ខារទាំងពួងជារបស់ទទេពិត ។ ព្រះសុមនសម្ពុទ្ធ ទ្រទ្រង់យស ទ្រង់បរិនិព្វានក្នុងអង្គារាម ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកម្ពស់ ៤ យោជន៍ ប្រតិស្ឋានទៅក្នុងអារាមនោះ ។

ចប់ សុមនពុទ្ធវង្សទី ៤

# រេវតពុទ្ធវង្សទី ៥

កាលខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធ ព្រះនាមសុមនៈមក មានព្រះលោកនាយក ព្រះនាមរេវតៈ មិនមានបុគ្គលប្រៀប មិនមានបុគ្គលស្មើ មិនមានបុគ្គលប្ញឹងបាន ព្រះអង្គឧត្តម ទ្រង់ឈ្នះពួកមារ ។ ព្រះសម្ពុទ្ធអង្គនោះ លុះមហាព្រហ្មអារាធនាហើយ ទ្រង់ប្រកាសធម៌ដ៏កំណត់ដោយខន្ធ និងធាតុ ជាធម៌មិនប្រព្រឹត្តទៅ ក្នុងភពតូចភពធំ ។ ក្នុងការសម្តែងធម៌នៃព្រះរេវតសម្ពុទ្ធនោះ មានការត្រាស់ដឹងមគ្គផល ៣ លើក គឺការត្រាស់ដឹងលើកទី ១ មិនគប្បីពោលដោយការរាប់ចំនួនបាន ។ ព្រះមហាមុនីព្រះនាមរេវតៈ ទ្រង់ទូន្មានព្រះបាទអរិន្ទមៈ ក្នុងកាលណា កាលនោះ ពួកសត្វមួយពាន់កោដិ បានត្រាស់ដឹងមគ្គផល

លើកទី ២ ។ ព្រះនរាសភ: ទ្រង់ក្រោកចាកទីពួនសំងំអស់ ៧ ថ្ងៃ ហើយទូន្មានពួកមនុស្ស និងទេវតាមួយរយកោដិ ( ឲ្យតាំងនៅ ) ក្នុងផលដ៏ឧត្តមលើកទី ៣ ។ ព្រះសម្ពុទ្ធ ព្រះនាមរេវត: ទ្រង់ស្វែងរកគុណធំ មានសាវកសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះទ័យរួចស្រឡះដោយប្រពៃ មានចិត្តនឹងធឹង គឺសន្និបាតលើកទី ១ កន្លងផុតផ្លូវនៃការរាប់ ( រាប់ពុំបាន ) សន្និបាតលើកទី ២ មានព្រះអរហន្តមួយសែនកោដិ ។ ព្រះអគ្គសាវកអង្គណារកបុគ្គលស្មើគ្មានដោយប្រាជ្ញា ជាអ្នកប្រព្រឹត្តតាមធម្មចក្រនៃព្រះសម្ពុទ្ធអង្គនោះ កាលនោះព្រះអគ្គសាវកនោះ មានព្យាធិ ដល់នូវការសង្ស័យក្នុងជីវិត ។ កាលនោះ ពួកព្រះអរហន្តចូលទៅគាល់ព្រះភគវា ដើម្បីសាកសួរអាពាធរបស់ព្រះអគ្គសាវកនោះ មានចំនួនមួយសែនកោដិ នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគតកើតជាព្រាហ្មណ៍ឈ្មោះអតិទេវ: បានចូលទៅគាល់ព្រះរេវតសម្ពុទ្ធ ហើយបានយកព្រះអង្គជាទីពឹង ។ តថាគតបានសរសើរសើល សមាធិ បញ្ញា និងគុណដ៏ប្រសើររបស់ព្រះពុទ្ធអង្គ ហើយបានថ្វាយសំពត់ឧត្តរាសង្គ: តាមកម្លាំង ។ ព្រះសម្ពុទ្ធ ព្រះនាមរេវត: ជាលោកនាយកអង្គនោះ

ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ទៅតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះទសពលអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេបានចាត់ចែងដ៏ល្អ ។ លំដាប់អំពីនោះមក ព្រះទ្រង់យសធំ ទ្រង់ធ្វើប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសាស្តាអង្គនោះ ព្រះនាម មាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ ព្រាហ្មណ៍នេះនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះសាស្តាអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹង

បានជាអគ្គសាវិកា ។ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ( ដើមពោធិ៍ ) ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធអង្គ មិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា ព្រាហ្មណ៍នេះនឹងបានជាពូជពន្លកនៃព្រះសម្មាសម្ពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុស្រែកហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា ពួកយើងទាំងឡាយ បើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះសម្ពុទ្ធអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះបរមសាស្តាអង្គនោះក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំយ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានជួបក្នុងទីចំពោះព្រះភក្ត្រ នៃព្រះបរមសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះតម្រាស់

របស់ព្រះពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ កាលនោះ តថាគតនឹកឃើញ ហើយបានអប់រំពុទ្ធការកធម៌នោះ ទាំងបានបំពេញនូវពុទ្ធការកធម៌នោះ តាមគួរដល់សេចក្តីប្រាថ្នានៃតថាគត ។ ព្រះរេវត-សម្ពុទ្ធទ្រង់ស្វែងរកគុណដ៏ធំ មានទីក្រុងឈ្មោះសុធញ្ញកៈ មានមហាក្សត្រព្រះនាម វិបុលៈ ជាព្រះបិតា ព្រះមាតាព្រះនាម វិបុលា ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងព្រះរាជជំណាក់អស់ ៦ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្មមាន ៣ គឺសុទស្សនប្រាសាទ ១ រតនគ្ឃិប្រាសាទ ១ អាវេឡប្រាសាទ ១ ដែលគេស្អិតស្អាងហើយ ។ ពួកនារី ៣៣ សែននាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គមហេសីព្រះនាមសុទស្សនា មានព្រះរាជបុត្រព្រះនាមវរុណៈ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាងហើយ ទ្រង់ចេញបព្វជ្ជាដោយរថជាយានហើយតាំងសេចក្តីព្យាយាមអស់ ៧ ខែឥតខ្វះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមរេវតៈ ជាលោកនាយក មានព្រះទ័យស្ងប់រំងាប់ ទ្រង់ញុំាងចក្រឲ្យប្រព្រឹត្តទៅ ទ្រង់មានព្យាយាមច្រើន ទ្រង់ឈ្នះមារ ត្រូវមហាព្រហ្មអារាធនាហើយ ទ្រង់គង់នៅក្នុងវរុណារាម ។ ព្រះថេរៈ

ឈ្មោះវរុណៈ ១ ព្រហ្មទេវៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះសម្ភវៈ ជាឧបដ្ឋាករបស់ព្រះរេវតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះភទ្ទា ១ សុភទ្ទា ១ ជាអគ្គសាវិកា ឯព្រះសម្ពុទ្ធឥតមានបុគ្គលស្មើអង្គនោះ ទ្រង់បានត្រាស់ដឹង ទៀបដើមខ្ទឹង ។ ឧបាសកឈ្មោះវរុណៈ ១ សរកៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកា ឈ្មោះបាលា ១ ឧបបាលា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៨០ ហត្ថ ទ្រង់ញុំាងទិសទាំងពួង ឲ្យភ្លឺរុងរឿង ដូចទង់ជ័យរបស់ព្រះឥន្ទ្រដ៏ខ្ពង់ខ្ពស់ ។ កម្រងរស្មីដ៏ប្រសើរ កើតនៅក្នុងសរីរៈនៃព្រះមានជោគ ផ្សាយចេញមួយយោជន៍ជុំវិញ ទាំងថ្ងៃទាំងយប់ ។ ព្រះសម្ពុទ្ធអង្គនោះ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់ កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើន ឲ្យឆ្លង ( ចាកវដ្តសង្សារ ) ។ ព្រះសម្ពុទ្ធទ្រង់សម្តែងកម្លាំងនៃព្រះពុទ្ធ ហើយទ្រង់ប្រកាសអមតធម៌ក្នុងលោក ព្រះពុទ្ធអង្គមិនមានសេចក្តីប្រកាន់ ទ្រង់បរិនិព្វាន ព្រោះអស់ឧបាទាន ដូចភ្លើងដែលអស់កំញម ។ ព្រះកាយរបស់ព្រះអង្គនោះ មានពណ៌ដូចកែវ ព្រះធម៌របស់ព្រះអង្គ មិនមានអ្វីស្មើដូចទេ របស់ទាំងអស់ វិនាសសូន្យទៅ សង្ខារទាំងពួងទទេពិត ។

ព្រះរេវតសម្ពុទ្ធ ទ្រង់ទ្រង់យសអង្គនោះ ទ្រង់មានបុណ្យច្រើន ទ្រង់បរិនិព្វានហើយ ព្រះធាតុរបស់ព្រះពុទ្ធអង្គ បានសាយកាយទៅក្នុងប្រទេសនោះ ដោយចំណែកៗ ។

ចប់ រេវតពុទ្ធវង្សទី ៥

# សោភិតពុទ្ធវង្សទី ៦

កាលខាងក្រោយអំពីព្រះសម្មាសម្ពុទ្ធ ព្រះនាមរេវតៈមក មានព្រះលោកនាយកព្រះនាម សោភិតៈ មានព្រះហឫទ័យតម្កល់ខ្ជាប់ មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹម ។ ព្រះជិនស្រីអង្គនោះ ទ្រង់ញ៉ាំងបំណងក្នុងព្រះទ័យឲ្យប្រព្រឹត្តទៅ ក្នុងព្រះដំណាក់របស់ព្រះអង្គ ទ្រង់បានសម្រេចសម្ពោធិញាណ ដោយសព្វគ្រប់ ហើយទ្រង់សម្ដែងព្រះធម្មចក្រ ។ ខាងក្រោម រាប់អំពីអវីចិនរកឡើងមក ខាងលើរាប់អំពីភវគ្គព្រហ្មចុះមក ក្នុងចន្លោះនេះពេញដោយបរិស័ទតែម្យ៉ាង ក្នុងការសម្ដែងព្រះធម្មទេសនា ។ កាលព្រះសម្ពុទ្ធទ្រង់សម្ដែងព្រះធម្មចក្រ ដល់បរិស័ទនោះ ការត្រាស់ដឹងធម៌លើកទី ១ គេមិនគប្បីពោល ដោយការរាប់ចំនួនបានឡើយ ។លំដាប់

អំពីនោះមកទៀត កាលព្រះសម្ពុទ្ធ ទ្រង់សម្ដែងធម៌ ក្នុងទីសមាគម នៃមនុស្ស និងទេវតា មានពួកបរិស័ទ ៩ ម៉ឺនកោដិ ត្រាស់ដឹងធម៌ លើកទី ២ ។ មួយវិញទៀត កាលនោះព្រះរាជបុត្រជាក្សត្រ ព្រះនាម ជ័យសេន ដាំសួនវេរថ្វាយព្រះសម្ពុទ្ធ ។ ព្រះលោកនាថទ្រង់ប្រកាស ការបូជា នៃព្រះបាទជ័យសេននោះ ហើយសម្ដែងព្រះធម្មទេសនា ក្នុងកាលនោះ មានបរិស័ទមួយពាន់កោដិត្រាស់ដឹងធម៌លើកទី ៣ ។ ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានសាវ័កសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រពប្រាសចាកមន្ទិល មានព្រះទ័យ រួចស្រឡះដោយប្រពៃ មានចិត្តនឹងធឹង គឺកាលព្រះរាជា ព្រះនាម ឧគ្គតៈអង្គនោះ ទ្រង់ថ្វាយទានចំពោះព្រះសម្ពុទ្ធថ្លៃថ្លាជាងនរជន ក្នុង វេលាថ្វាយទាននោះ មានព្រះអរហន្តមួយរយកោដិ និមន្តមកប្រជុំគ្នា (នេះសន្និបាតលើកទី ១)។ មួយវិញទៀត មានពួកបរិស័ទថ្វាយទាន ចំពោះព្រះសម្ពុទ្ធថ្លៃថ្លាជាងពួកនរជន ក្នុងកាលនោះ មានពួកបរិស័ទ ៩០ កោដិ (មកប្រជុំគ្នា) នេះជាសន្និបាតលើកទី ២ ។ ព្រះជិនស្រី ទ្រង់គង់ក្នុងទេវលោក ហើយស្ដេចចុះចាកទេវលោក ក្នុងកាលណា កាលនោះ មានពួកបរិស័ទ ៨០ កោដិ (មកប្រជុំគ្នា) នេះជាសន្និបាត

លើកទី ៣ ។ សម័យនោះ តថាគតកើតជាព្រាហ្មណ៍ ឈ្មោះសុជាត កាលនោះ តថាគតនិមន្តព្រះពុទ្ធ ព្រមទាំងសាវកឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ។ព្រះសម្ពុទ្ធព្រះនាមសោភិតៈ ជានាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញអំពីក្រុង កបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស បានទទួលបាយាស នៅក្នុងទីនោះ ហើយក៏បានចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រី អង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅ ជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់តអំពីនោះមក ព្រះសាស្តាមានយសច្រើន ទ្រង់ធ្វើប្រទក្សិណ នូវពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងបានត្រាស់ដឹង ទៀបគល់ នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនោះ ព្រះនាម មាយា ព្រះបិតា ព្រះនាម សុទ្ធោទនៈ ព្រាហ្មណ៍នេះនឹងបានត្រាស់ ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្ត

តម្កល់មាំ នឹងបានជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ។ ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះសម្ពុទ្ធអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះ ចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសោភិតសម្ពុទ្ធ ឥតមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា ព្រាហ្មណ៍នេះជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាក្នុងមួយម៉ឺនលោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនា របស់ព្រះសាស្តានេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំ យ៉ាងណា ។

យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះទៅ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខានក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះតម្រាស់ របស់ព្រះសាស្តានោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក មានចិត្តតក់ស្លុតហើយបានធ្វើនូវប្រាជ្ញាឲ្យខ្ពង់ខ្ពស់ ដើម្បីសម្រេចប្រយោជន៍នោះ ។ ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះសុធម្មៈ មានមហាក្សត្រព្រះនាម សុធម្មៈ ជាព្រះបិតា មានព្រះមាតាព្រះនាម សុធម្មា ។ ព្រះសោភិតសម្ពុទ្ធអង្គនោះ ព្រះអង្គគ្រប់គ្រងព្រះរាជដំណាក់អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្មមាន ៣ គឺកុមុទប្រាសាទ ១ នឡិនីប្រាសាទ ១ បទុមប្រាសាទ ១ ដែលគេស្អិតស្អាងហើយ ។ ពួកនារី ៤ ពាន់នាក់ មានរូបតាក់តែងសមរម្យឯនារីជាអគ្គមហេសី ឈ្មោះកិមិលា មានព្រះរាជបុត្រព្រះនាមសីហៈ ។ ព្រះជិនស្រីខ្ពង់ខ្ពស់ជាងបុរស ទ្រង់ឃើញនិមិត្ត ៤ ហើយ ទ្រង់ចេញបព្វជ្ជាទៅដោយប្រាសាទជាយាន ទៅប្រព្រឹត្តបធានចារៈអស់ ៧ ថ្ងៃ ។ ព្រះសោភិតសម្ពុទ្ធ ជាលោកនាយក មានព្រះទ័យស្ងប់រំងាប់ ទ្រង់ញ៉ាំងចក្រឲ្យប្រព្រឹត្តទៅ ទ្រង់មានព្យាយាមច្រើន ត្រូវមហាព្រហ្ម

អាពាធនាហើយ ក្នុងសុធម្មឧទ្យានដ៏ប្រសើរ ។ព្រះថេរៈឈ្មោះអសមៈ ១ សុនេត្តៈ ១ បានជាអគ្គសាវក ព្រះថេរៈឈ្មោះអនោមៈ ជាឧបដ្ឋាក របស់ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះ នកុលា ១ សុជាតា ១ ជាអគ្គសាវិកា ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់ បានត្រាស់ដឹងទៀបដើមខ្ទឹង ។ ឧបាសកឈ្មោះរម្មៈ ១ សុនេត្តៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនកុលា ១ ចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៥៨ ហត្ថ ទ្រង់ញុំាងទិស ទាំងពួងឲ្យរុងរឿង ដូចព្រះអាទិត្យរះឡើង ។ ព្រៃធំដែលមានផ្កាឈើ រីកល្អ ដែលអប់ដោយក្លិនក្រអូបផ្សេងៗ យ៉ាងណា ពាក្យប្រៀនប្រដៅ របស់ព្រះសម្ពុទ្ធអង្គនោះ តែងអប់ដោយក្លិនក្រអូប គឺសីល ក៏យ៉ាង នោះដែរ ។ធម្មតាសាគរ គេតែងមិនឆ្អែតដោយការរមិលមើល យ៉ាងណា ពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធអង្គនោះ គេមិនឆ្អែតដោយការស្តាប់ ក៏យ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធអង្គនោះ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ជាកំណត់ ទ្រង់ស្ថិតនៅអស់កាលជាបនោះ ទ្រង់ញុំាងប្រជុំជនច្រើន ឲ្យឆ្លង (ចាកវដ្តសង្សារ) ។ ព្រះអង្គព្រមទាំងសាវក ទ្រង់ឲ្យឱវាទ និងការប្រៀនប្រដៅចំពោះជនដ៏សេស ហើយញុំាងជនទាំងនោះ ឲ្យមាន

ព្យាយាមដុតកម្តៅកិលេសដូចភ្លើង រួចបរិនិព្វាន ។ ព្រះសម្ពុទ្ធស្មើដោយព្រះពុទ្ធ ឥតមានបុគ្គលស្មើព្រះអង្គនោះក្តី ពួកសាវកទាំងនោះដែលដល់នូវកម្លាំងក្តី របស់ទាំងអស់នោះ ក៏វិនាសសូន្យទៅ សង្ខារទាំងពួងជារបស់ទទេពិត ។ ព្រះសោភិតសម្ពុទ្ធដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងសីហារាម ព្រះធាតុ ( របស់ព្រះអង្គ ) បានសាយភាយទៅក្នុងប្រទេសនោះ តាមចំណែកៗ ។

ចប់ សោភិតពុទ្ធវង្សទី ៦

# អនោមទស្សីពុទ្ធវង្សទី ៧

កាលខាងក្រោយ អំពីព្រះសោភិតសម្ពុទ្ធមក មានព្រះសម្ពុទ្ធព្រះនាមអនោមទស្សី ព្រះអង្គប្រសើរជាងសត្វទ្វេបាទ ទ្រង់មានយសរាប់មិនបាន ទ្រង់មានតេជះ ទ្រង់កម្របុគ្គលកន្លងបាន ។ ព្រះសម្ពុទ្ធទ្រង់កាត់ចំណងទាំងអស់ កម្ចាត់បង់ភពទាំងបី ហើយសម្តែងផ្លូវសម្រាប់ដើរឆ្ពោះទៅរកនិព្វាន មិនត្រឡប់វិញ ចំពោះទេវតា និងមនុស្ស ។ ព្រះអនោមទស្សីអង្គនោះ ទ្រង់មិនរំភើប ដូចជាសាគរ គេគ្របសង្កត់បានដោយក្រ ដូចជាភ្នំ ទ្រង់មានគុណរកទីបំផុតគ្មាន ដូចជាអាកាស

មានព្រះកាយរីកពេញ ដូចជាស្តេចឈើ ។ ពួកសត្វគ្រាន់តែឃើញព្រះសម្ពុទ្ធអង្គនោះ ក៏មាននូវសេចក្តីត្រេកអរ សត្វទាំងនោះ លុះបានស្តាប់មធុរវាចា ដែលលាន់ឮ ក៏បានដល់នូវអមតនិព្វាន ។ កាលនោះការត្រាស់ដឹងធម៌របស់ព្រះអង្គ ក៏ធំទូលាយផ្សាយទៅ ចំនួនពួកសត្វ ១០០ កោដិ បានត្រាស់ដឹង ក្នុងការសម្តែងធម៌លើកទី ១ ។ លំដាប់អំពីនោះមក កាលព្រះសម្ពុទ្ធបង្អុរចុះនូវភ្លៀង គឺធម៌ ក្នុងអភិសម័យពួកសត្វ ៨០ កោដិបានត្រាស់ដឹង ក្នុងការសម្តែងធម៌លើកទី ២ ។ តអំពីនោះមកទៀត កាលព្រះសម្ពុទ្ធ ទ្រង់បង្អុរចុះគ្រាប់ភ្លៀង គឺធម៌ ទ្រង់ញ៉ាំងពួកសត្វឲ្យឆ្អែតស្កប់ស្កល់ ( ដោយធម៌ ) ពួកសត្វ ៧៨ កោដិ បានសម្រេចមគ្គផល លើកទី ៣ ។ ព្រះអនោមទស្សីអង្គនោះ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះអរហន្ត បានសម្រេចអភិញ្ញាពលៈ រីកពេញដោយវិមុត្តិ គឺ សន្និបាតលើកទី ១ ។ កាលនោះ មានព្រះអរហន្ត ៨ សែន ដែលមានសេចក្តីស្រវឹង និងសេចក្តីវង្វេងលះបង់ហើយ មានសន្តានស្ងប់រំងាប់ទាំងមានចិត្តនឹងធឹង ។ សន្និបាតលើកទី ២ មានព្រះអរហន្ត ៧ សែន ដែលមិនមានទីទួល គឺកិលេស ប្រាសចាកធូលី គឺកិលេស ទាំងមាន

សន្តានស្ងប់រំងាប់ មានចិត្តនឹងធឹង ។ សន្និបាតលើកទី ៣ មានព្រះអរហន្ត ៦សែន ដែលបានសម្រេចអភិញ្ញាពលៈ មានទុក្ខរំលត់ហើយ មានព្យាយាមដុតកម្តៅកិលេស ។ សម័យនោះ តថាគតកើតជាយក្ស មានឫទ្ធិច្រើន ជាធំជាងពួកយក្សច្រើនកោដិ ក្នុងវសវត្តីទេវលោក ។ កាលនោះ តថាគតបានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធប្រសើរអង្គនោះ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយអង្គាសព្រះលោកនាថ ព្រមទាំងភិក្ខុសង្ឃឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ ឯព្រះមុនីអង្គនោះ ទ្រង់មានព្រះនេត្រដ៏បរិសុទ្ធ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ យក្សនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។សត្វនេះនឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយនៅទៀបគល់ នៃអជបាលព្រឹក្ស បានទទួលបាយាសក្នុងទីនោះ រួចហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយក៏ចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់តអំពីនោះមក ព្រះសម្ពុទ្ធ មានយសច្រើន ទ្រង់ធ្វើប្រទក្សិណ នូវពោធិមណ្ឌលដ៏ប្រសើរ ហើយបានត្រាស់ដឹង

ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសាស្តាអង្គនោះ ព្រះនាម មាយា ព្រះបិតា ព្រះនាម សុទ្ធោទនៈ យក្សនេះនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ។ ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះសម្ពុទ្ធអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះ ចិត្តៈ ១ ហត្ថាឡវកៈ ១ បានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះ នន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះអនោមទស្សីសម្ពុទ្ធ មិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា យក្សនេះនឹងជាពូជពន្លកនៃព្រះសម្មាសម្ពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុនាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា

ពួកយើងទាំងឡាយ បើនឹងឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះភគវា អង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាង កំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំ យ៉ាងណា ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹង បានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគត មិនខាន ក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះតម្រាស់ របស់ព្រះអនោមទស្សីអង្គនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក ក៏មានចិត្តតក់ស្លុត បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញ បារមីទាំង ១០ ប្រការ ។ ព្រះសាស្តា ព្រះនាមអនោមទស្សីសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មាននគរឈ្មោះចន្ទវតី មហាក្សត្រព្រះនាម យសវា ជាព្រះបិតា ព្រះមាតា ព្រះនាមយសោធរា ។ ព្រះអនោមទស្សី អង្គនោះ ព្រះអង្គគ្រប់គ្រងព្រះរាជដំណាក់អស់ ១ ម៉ឺនឆ្នាំ មានប្រាសាទ ដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្ម មាន ៣ គឺសិរិប្រាសាទ ១ ឧបសិរិប្រាសាទ ១ វឌ្ឍប្រាសាទ ១ (សម្រាប់ព្រះអង្គ) ។ ពួកនារី ២ ម៉ឺន ៣ ពាន់នាក់ មានរូបប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីនោះ

ព្រះនាមសិរិមា មានព្រះរាជបុត្រព្រះនាមឧបសាលៈ ។ ព្រះជិនស្រី ទ្រង់បានឃើញនូវនិមិត្ត ៤ យ៉ាងហើយ ទ្រង់ចេញទៅបព្វជ្ជាដោយ គ្រែស្នែងជាយាន ហើយទ្រង់តាំងសេចក្ដីព្យាយាម អស់ ១០ ខែ ឥតខ្វះ ។ ព្រះអនោមទស្សីសម្ពុទ្ធ ជាលោកនាយក មានព្រះទ័យ ស្ងប់រំងាប់ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនាហើយ ទ្រង់ សម្ដែងធម្មចក្រ នៅក្នុងសុទស្សនឧទ្យានដ៏ឧត្តម ។ ព្រះថេរៈឈ្មោះ និសភៈ ១ អនោមៈ ១ ជាអគ្គសាវក ឯព្រះថេរៈឈ្មោះវរុណៈ ជាឧបដ្ឋាក របស់ព្រះអនោមទស្សីសម្ពុទ្ធនោះ ។ ព្រះថេរីឈ្មោះសុន្ទរា ១ សុមនា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថាអជ្ជុនព្រឹក្ស ( ដើមអគ្រែង ) ។ ឧបាសកឈ្មោះនន្ទិវឌ្ឍៈ ១ សិរិវឌ្ឍៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះឧបលា ១ បទុមា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៥៨ ហត្ថ ពន្លឺនៃព្រះអង្គផ្សាយចេញទៅ ដូចព្រះអាទិត្យរះឡើង ។ ព្រះអង្គមាន ព្រះជន្មាយុមួយសែនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលជរាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង (វដ្ដសង្សារ) ។ ពាក្យថា ជាប្រធាន គឺ សាសនារីកល្អហើយ ដោយពួកអរហន្តជាតាទិគុណ ប្រាសចាករាគៈ

ប្រាសចាកមន្ទិល សាសនារបស់ព្រះជិនស្រីល្អរុងរឿង ។ ឯព្រះសាស្ដាអង្គនោះ មានយសរាប់មិនបានក្ដី គូនៃសាវ័កទាំងពីរនោះ មានគុណច្រើនមិនបានក្ដី របស់ទាំងនោះ វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។ ព្រះជិនស្រី ជាសាស្ដា ព្រះនាមអនោមទស្សី ទ្រង់បរិនិព្វានក្នុងធម្មារាម ឯព្រះស្ដូបបញ្ចុះព្រះធាតុរបស់ព្រះលោកនាយកអង្គនោះ មានកម្ពស់ ២០ យោជន៍ ប្រតិស្ឋាននៅក្នុងអារាមនោះ ។

ចប់ អនោមទស្សីពុទ្ធវង្សទី ៧

# បទុមពុទ្ធវង្សទី ៨

ក្នុងកាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមអនោមទស្សីមក មានព្រះសម្ពុទ្ធ ព្រះនាមបទុមៈ ទ្រង់ឧត្ដមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ សីលនៃព្រះអង្គ ឥតមានសីលនៃបុគ្គលដទៃស្មើ ទាំងសមាធិក៏រកទីបំផុតគ្មាន ព្រះញាណដ៏ប្រសើរនឹងរាប់ពុំបាន ទាំងវិមុត្តិក៏មិនមានឧបមា ។ កាលដែលព្រះពុទ្ធ ព្រះនាមបទុមៈ ព្រះអង្គនោះ មានតេជៈច្រើនមិនបាន ទ្រង់ញុំាងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅ មានការត្រាស់ដឹងនូវធម៌ ៣ លើក ដែលជាគ្រឿង

បន្សាត់បង់នូវធនឹតដ៏ធំ ។ គឺព្រះពុទ្ធ ទ្រង់ញុំាងសត្វ ១០០ កោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ញុំាងសត្វ ៩០ កោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ។ មួយទៀត ព្រះពុទ្ធព្រះនាមបទុមៈ ទ្រង់ទូន្មានព្រះឱរសរបស់ព្រះអង្គ ក្នុងកាលណាកាលនោះ ពួកសត្វ ៨០ កោដិត្រាស់ដឹងលើកទី ៣ ។ ព្រះពុទ្ធព្រះនាមបទុមៈ ជាមហេសី មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានភិក្ខុមួយសែនកោដិ ។ កាលកឋិនចីវរកើតឡើងហើយ ក្នុងសម័យជាទីក្រាលនូវកឋិន ភិក្ខុទាំងឡាយ បានដេរនូវចីវរ ដើម្បីប្រគេនព្រះធម្មសេនាបតី ។ ក្នុងកាលនោះ ភិក្ខុទាំង ៣ សែនរូបនោះ សុទ្ធតែប្រាសចាកមន្ទិល មានអភិញ្ញា ៦ មានឫទ្ធិច្រើន ជាអ្នកមិនចាលចាញ់បានមកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។ មួយវិញទៀត ព្រះពុទ្ធព្រះនាមបទុមៈអង្គនោះ ទ្រង់ប្រសើរជាងពួកនរជន ស្តេចចូលទៅកាន់លំនៅក្នុងព្រៃធំ ក្នុងកាលនោះ មានភិក្ខុ ២ សែនរូបជួបជុំគ្នា នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគតកើតជាសត្វសីហៈគ្របសង្កត់លើពួកម្រឹគ បានឃើញព្រះជិនស្រី ព្រះអង្គកំពុងចម្រើននូវវិវេកក្នុងព្រៃធំ ។ តថាគតបានថ្វាយបង្គំនូវព្រះបាទទាំងគូ ដោយសិរ្សៈ

ហើយធ្វើប្រទក្សិណព្រះអង្គ រួចបន្លឺឡើងនូវសីហនាទអស់ ៣ ដង បានបម្រើព្រះជិនស្រីអស់ ៧ ថ្ងៃ ។ ព្រះតថាគតទ្រង់ចេញចាកសមាបត្តិដ៏ប្រសើរអស់ ៧ ថ្ងៃ ហើយទ្រង់ព្រះចិន្តាដោយព្រះហឫទ័យ រួចទ្រង់ប្រមូលមកនូវភិក្ខុចំនួនមួយកោដិ ។ កាលនោះ ព្រះលោកនាថនោះទ្រង់ព្យាករក្នុងកណ្តាលភិក្ខុសង្ឃ ទាំងមួយកោដិនោះថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ សត្វសីហៈនេះនឹងបានជាព្រះពុទ្ធ ។ សត្វនេះនឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់នូវសេចក្តីព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្សបានទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរាហើយចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់អំពីនោះមក ព្រះទសពល មានយសធំនឹងធ្វើប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនោះព្រះនាម មាយា ព្រះបិតា ព្រះនាម សុទ្ធោទនៈ ព្រះសម្ពុទ្ធនេះនឹងមានព្រះនាម គោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១

ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ។ ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះសម្ពុទ្ធអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតាទាំងឡាយ លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះបទុមសម្ពុទ្ធ មិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា សត្វសីហៈនេះនឹងជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយបើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ

គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំដែរ យ៉ាងណា យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្រ្ត នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះតម្រាស់របស់ ព្រះពុទ្ធ ទ្រង់ព្រះនាមបទុមៈនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋាននូវវត្តដ៏លើសលប់ ដោយការបំពេញនូវបារមីទាំង ១០ ។ ព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះ ចម្បកៈ មានមហាក្សត្រព្រះនាមអសមៈ ជាព្រះបិតា មានព្រះមាតា ព្រះនាមអសមា ។ ព្រះសម្ពុទ្ធ ព្រះនាមបទុមៈនោះ ព្រះអង្គគ្រប់គ្រង ព្រះរាជដំណាក់អស់មួយម៉ឺនឆ្នាំ មានប្រាសាទដ៏ប្រសើរ ដែលកើត ដោយបុញ្ញកម្ម ៣ ខ្នង គឺនន្ទប្រាសាទ ១ វសុប្រាសាទ ១ យសត្តរ-ប្រាសាទ ១ ។ មានពួកនារី ៣ ម៉ឺន ៣ ពាន់នាក់ សឹងតែតាក់តែងល្អ ឯនារីជាអគ្គមហេសីនោះ ឈ្មោះនាងឧត្តរា មានព្រះរាជបុត្រព្រះនាម រម្មៈ ។ ព្រះជិនស្រីទ្រង់បានឃើញនូវនិមិត្ត ៤ យ៉ាងហើយ ទ្រង់ចេញ បព្វជ្ជាដោយរថជាយាន ទ្រង់តម្កល់នូវព្យាយាមអស់ ៨ ខែគត់ ។ ព្រះបទុមសម្ពុទ្ធ ជាលោកនាយក ត្រូវមហាព្រហ្មអារាធនាហើយ

ទើបទ្រង់ញ៉ាំងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះធនញ្ជ: ។ ព្រះថេរៈឈ្មោះសាល: ១ ឧបសាល: ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះ វរុណ: ជាឧបដ្ឋាករបស់ព្រះបទុមសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះរាធា ១ សុរាធា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា មហាសោណ: ( ដើមម្រុំ ) ។ ឧបាសកឈ្មោះសភិយ: ១ អសម: ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះរុចិ ១ នន្ទិមារា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះសម្ពុទ្ធ ព្រះនាមបទុម: ជាមហាមុនី ទ្រង់មានកម្ពស់ ៥៨ ហត្ថ កម្រងរស្មីនៃព្រះលោកនាយកអង្គនោះ តែងផ្សាយចេញសព្វទិស ទាំងឥតមានអ្វីស្មើ ។ រស្មីព្រះច័ន្ទ រស្មីព្រះអាទិត្យ រស្មីកែវមណី រស្មីទាំងអស់នោះ ក៏សាបសូន្យទៅ ព្រោះប៉ះនឹងពន្លឺរបស់ព្រះជិនស្រី ដ៏ឧត្តម ។ ព្រះជន្មាយុ ( របស់ព្រះមហាមុនីនោះ ) មួយសែនឆ្នាំ ជាកំណត់ ព្រះសម្ពុទ្ធអង្គនោះ កាលទ្រង់ព្រះជន្មនៅជាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើន ឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះភគវាអង្គនោះ ទ្រង់ញ៉ាំងសត្វដែលមានឥន្ទ្រិយចាស់ក្លាឲ្យត្រាស់ដឹង មិនមានសេសសល់ ទ្រង់ប្រៀនប្រដៅសត្វទាំងឡាយ ដែលសេសសល់ ទ្រង់បរិនិព្វានទៅ

ជាមួយនឹងសាវក ។ ព្រះមហាមុនីអង្គនោះ ទ្រង់លះបង់នូវសង្ខារទាំងពួង ដូចជាពស់ដែលលះបង់នូវសំណកចាស់ ឬដូចជាដើមឈើជម្រុះនូវស្លឹកចាស់ ហើយទ្រង់បរិនិព្វានទៅ ដូចជាអណ្តាតប្រទីបដូច្នោះ ។ ព្រះភគវាព្រះនាមបទុមៈ ជាព្រះមុនីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងធម្មារាម មានព្រះធាតុផ្សាយទៅក្នុងប្រទេសនោះៗ ។

ចប់ បទុមពុទ្ធវង្សទី ៨

# នារទពុទ្ធវង្សទី ៩

ក្នុងកាលខាងក្រោយ អំពីព្រះលោកនាយកព្រះនាមបទុមៈមក មានព្រះសាស្តា ព្រះនាមនារទៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ ព្រះអង្គនោះជាព្រះរាជបុត្រច្បងជាព្រះរាជឱរស ជាទីស្រឡាញ់របស់ស្តេចចក្រពត្តិ ទ្រង់បានពាក់នូវកែវមណី និងគ្រឿងអាភរណៈ ហើយស្តេចចូលទៅកាន់ឧទ្យាន ។ ក្នុងឧទ្យាននោះ មានឈើមួយដើម ឈ្មោះមហាសោណព្រឹក្ស ជាឈើសមរម្យ ធំល្អស្អាត ព្រះសម្ពុទ្ធស្តេចទៅដល់ដើមឈើនោះហើយទ្រង់គង់ខាងក្រោមនៃឈើនោះ ។ ព្រះញាណប្រសើររកទីបំផុតគ្មាន

មានឧបមាដូចជាកែវវជិរៈ បានកើតឡើង ( ដល់ព្រះអង្គ ) ក្នុងទីនោះ ព្រះអង្គពិចារណានូវសង្ខារទាំងឡាយ ដោយព្រះញាណនោះ ដូចជាបុគ្គលដែលផ្កាប់ ឬផ្ងារឡើងនូវភាជនៈ ។ ក្នុងទីនោះ ព្រះសាស្តាទ្រង់បន្សាត់បង់នូវកិលេសទាំងពួង មិនឲ្យសេសសល់ ហើយបានសម្រេចនូវពោធិញ្ញាណទាំងអស់ផង នូវពុទ្ធញ្ញាណទាំង ១៤ ផង ។ លុះព្រះអង្គសម្រេចនូវសម្ពោធិហើយ ទើបទ្រង់សម្តែងនូវធម្មចក្រ សត្វមួយសែនកោដិ បានត្រាស់ដឹងជាដំបូង ។ ព្រះមហាមុនីទូន្មានស្តេចនាគ ឈ្មោះមហាទោណៈ ក្នុងកាលនោះ ទ្រង់ពន្យល់នូវពួកមនុស្ស ព្រមទាំងទេវតា ហើយទ្រង់ធ្វើនូវបាដិហារ្យ ។ ក្នុងកាលនោះ ទេវតា និងមនុស្សទាំងឡាយ ៩០ ពាន់កោដិ បានឆ្លងផុតនូវសេចក្តីសង្ស័យទាំងអស់ ក្នុងការប្រកាសនូវព្រះធម៌នោះ នេះជាការត្រាស់ដឹងទី ២ ។ ព្រះមហាវីរៈ ទ្រង់ទូន្មាននូវបុត្របង្កើតរបស់ព្រះអង្គ ក្នុងកាលណា ( កាលនោះ ) ពួកសត្វចំនួន ៨០ កោដិ បានត្រាស់ដឹងលើកទី ៣ ។ ព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកដំបូង មានពួកព្រះអរហន្តប្រមាណមួយសែនកោដិ ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសពុទ្ធគុណ ព្រមទាំងនិទាន ក្នុងកាលណា កាលនោះ

ព្រះអរហន្តប្រមាណ ៩០ ពាន់កោដិ ប្រាសចាកមន្ទិលមកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។ នាគរាជឈ្មោះវេរោចនៈ បានថ្វាយទាន ដល់ព្រះបរមសាស្តា ក្នុងកាលណា កាលនោះ ពួកសាវកជាបុត្រ នៃព្រះជិនស្រីប្រមាណ ៨០ សែនបានមកប្រជុំគ្នា ( នេះជាសន្និបាត លើកទី ៣ ) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមខ្លាំងក្លា បានដល់ត្រើយនៃអភិញ្ញាទាំង ៥ ត្រាច់ទៅតាម អាកាសបាន ។ គ្រានោះ តថាគតបានញ៉ាំងព្រះសម្ពុទ្ធ ដែលស្មើដោយ ព្រះពុទ្ធ មិនមានបុគ្គលស្មើ ព្រមទាំងព្រះសង្ឃ និងជនជាបរិស័ទ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ហើយបូជាដោយខ្លឹមចន្ទន៍ ។ គ្រានោះ ព្រះនារទៈជាលោកនាយកអង្គនោះ ទ្រង់បានព្យាករតថាគតថា ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះទៅ តាបសនេះនឹងបានជាព្រះពុទ្ធ ក្នុងលោក ។ សត្វនេះនឹងចេញអំពីក្រុងកបិលពស្តុ ដែលជាទីរីករាយ ទៅតម្កល់នូវសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយ ទៀបគល់នៃអជបាលព្រឹក្ស បានទទួលបាយាសក្នុងទីនោះ រួចហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះភគវាអង្គនោះ ទ្រង់សោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅជិតគល់ នៃពោធិព្រឹក្ស

តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់អំពីនោះមក ព្រះលោកនាយក មានយសធំ នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌល ដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតា បង្កើតរបស់ព្រះសាស្ដាអង្គនោះ ព្រះនាមមាយា ព្រះបិតា ព្រះនាម សុទ្ធោទនៈ ព្រះសម្ពុទ្ធអង្គនោះ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះ កោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវក ព្រះថេរៈ ឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរី ឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ។ ដើមឈើសម្រាប់ត្រាស់ដឹង របស់ព្រះលោកនាយកអង្គនោះ ហៅថា អស្សត្ថព្រឹក្ស (ដើមពោធិ៍) ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបាន ជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតាទាំងឡាយ បានស្ដាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំ

ហើយ ក៏មានចិត្តរីករាយថា ជដិលនេះនឹងជាពូជពន្ធកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបាន យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះលោកនាយកអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះតម្រាស់របស់ព្រះពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋាននូវវត្តដ៏លើសលប់ ដោយការបំពេញនូវបារមីទាំង ១០ ។ ព្រះនារទសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះធញ្ញវតី មានមហាក្សត្រព្រះនាមសុទេវៈ ជាព្រះបិតា ព្រះមាតា ព្រះនាមអនោមា ។ ព្រះនារទសម្ពុទ្ធអង្គនោះ ព្រះអង្គគ្រប់គ្រងព្រះរាជដំណាក់ អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្ម មាន ៣ ខ្នង គឺជិតប្រាសាទ ១ វិជិតប្រាសាទ ១

អភិរាមប្រាសាទ ១ ដែលគេស្អិតស្អាងហើយ ។ មានពួកនារី ៣-៤ ពាន់នាក់ សុទ្ធសឹងតែស្អិតស្អាងល្អ ឯនារីជាអគ្គមហេសីនោះ ព្រះនាម វិជិតសេនា មានព្រះរាជបុត្រព្រះនាមឧទ្ធុត្តរៈ ។ ព្រះពុទ្ធជាបុរសរ័ត្ន ដ៏ប្រសើរ ទ្រង់ទតឃើញនូវនិមិត្តទាំង ៤ ហើយ ស្តេចចេញបព្វជ្ជា ដោយការយាងទៅដោយព្រះបាទផ្ទាល់ ហើយទ្រង់ប្រព្រឹត្តព្យាយាម អស់ ៧ ថ្ងៃ ។ ព្រះនារទសម្ពុទ្ធ ជាលោកនាយក ត្រូវមហាព្រហ្ម អារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅក្នុងឧទ្យាន ដ៏ប្រសើរ ឈ្មោះធនញ្ជៈ ។ ព្រះថេរៈឈ្មោះភទ្ទសាលៈ ១ ជិតមិត្តៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះវាសេដ្ឋៈ ជាឧបដ្ឋាករបស់ព្រះនារទសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះឧត្តរា ១ ផគ្គុនី ១ ជាអគ្គ-សាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា មហាសោណព្រឹក្ស ។ ឧបាសកឈ្មោះឧគ្គរិន្ទៈ ១ វសភៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះឥន្ទវរី ១ គណ្ឌី ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៨៨ ហត្ថ មានព្រះរូបស្មើដោយ គ្រឿងបូជា ជាវិការនៃមាស បានញ៉ាំងលោកធាតុទាំងមួយម៉ឺន ឲ្យ ភ្លឺរុងរឿង ។ ព្រះរូបកាយរបស់ព្រះអង្គ មានរស្មីប្រមាណមួយព្យាម

តែងផ្សាយទៅកាន់ទិសតូចទិសធំ តែងផ្សាយទៅកាន់ទីប្រមាណមួយយោជន៍ ទាំងថ្ងៃ ទាំងយប់ ជានិរន្តរ៍ សព្វៗ កាល ។ សម័យនោះ ជនទាំងឡាយពួកខ្លះ នៅក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញ ត្រូវរស្មីទាំងឡាយនៃព្រះពុទ្ធគ្របសង្កត់ហើយ មិនចាំបាច់អុជភ្លើងគប់ ឬអុជភ្លើងប្រទីបទាំងឡាយឡើយ ។ ព្រះសម្ពុទ្ធអង្គនោះ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំគត់ កាលទ្រង់ព្រះជន្មាយុនៅជរាបនោះ តែងញុំាងប្រជុំជនដ៏ច្រើនឲ្យឆ្លងចាកវដ្តសង្សារ ។ អាកាសដ៏វិចិត្រ រុងរឿងដោយផ្កាយទាំងឡាយ យ៉ាងណា សាសនារបស់ព្រះនារទៈអង្គនោះ ក៏រុងរឿងដោយព្រះអរហន្តទាំងឡាយ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធព្រះនាមនារទៈប្រសើរជាងពួកនរៈអង្គនោះ ទ្រង់ធ្វើស្ពាន គឺព្រះធម៌ឲ្យមាំ ដើម្បីចម្លងនូវជនទាំងឡាយដ៏សេស ដែលកំពុងដើរទៅ ដើម្បីឆ្លងនូវខ្សែទឹក គឺសង្សារ ហើយបរិនិព្វាន ។ ព្រះពុទ្ធស្មើដោយព្រះពុទ្ធដែលគ្មានបុគ្គលស្មើអង្គនោះក្តី ព្រះខីណាស្រពទាំងឡាយ មានតេជះថ្លឹងពុំបាន ទាំងអម្បាលនោះក្តី ក៏និព្វានបាត់បង់អស់ របស់ទាំងពួងក៏អន្តរធានអស់ ឱហ្ន៎ ! សង្ខារទាំងពួងជារបស់សោះសូន្យពិត ។ ព្រះនារទៈជាព្រះមុនីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងសុទស្សនបុរី ព្រះស្តូបដ៏ប្រសើរ មានកម្ពស់

ប្រមាណ ៤ យោជន៍ ។

ចប់ នារទពុទ្ធវង្សទី ៩

# បទុមុត្តរពុទ្ធវង្សទី ១០

កាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងពួកសត្វជើងពីរ ទ្រង់ឈ្នះមារ ទ្រង់មិនរំភើប ឧបមាដូចសាគរ ។ ព្រះពុទ្ធនេះទ្រង់កើតឡើងក្នុងកប្បណាកប្បនោះឈ្មោះថា **មណ្ឌកប្ប** ប្រជុំជន មានកុសលដុះឡើងហើយតែងកើតក្នុងកប្បនោះ ។ កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈទ្រង់សម្ដែងនូវព្រះធម៌ជាដំបូង សត្វទាំងឡាយប្រមាណមួយសែនកោដិក៏បានត្រាស់ដឹងនូវមគ្គផល ។ លំដាប់តអំពីនោះមក កាលព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់បង្អុរចុះនូវធម៌ ទ្រង់ញុំាងពួកសត្វឲ្យឆ្អែតស្កប់ស្កល់ពួកសត្វប្រមាណ ៣ ម៉ឺន ៧ ពាន់ បានត្រាស់ដឹង ក្នុងលើកទី ២ ។ ក្នុងកាលណា ព្រះសម្ពុទ្ធស្ដេចចូលទៅរកព្រះបាទអានន្ទ ជាព្រះបិតាលុះស្ដេចចូលទៅកាន់សម្នាក់ព្រះបិតាហើយ ទ្រង់ទូងស្គរ គឺអមតធម៌ ។ កាលស្គរគឺអមតធម៌ដែលព្រះអង្គទ្រង់ទូងហើយ ភ្លៀងគឺធម៌ក៏ធ្លាក់ចុះ

(ក្នុងកាលនោះ) ពួកសត្វប្រមាណ ៥ លាន បានត្រាស់ដឹងក្នុងលើក ទី ៣ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងធម៌ទេសនា ទ្រង់ទូន្មានពន្យល់ចម្លង នូវសត្វទាំងពួង បានចម្លងហើយ នូវប្រជុំជនជាច្រើន ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានព្រះខីណាស្រពប្រមាណមួយសែនកោដិ ។ កាលណាព្រះសម្ពុទ្ធ ស្មើដោយព្រះអតីតពុទ្ធ រកបុគ្គលស្មើគ្មាន ទ្រង់គង់នៅលើភ្នំវេភារបព៌ត (ក្នុងកាលនោះ) ជាសន្និបាតលើកទី ២ មានព្រះខីណាស្រពប្រមាណ ៩០ ពាន់កោដិ ។ កាលព្រះសម្ពុទ្ធចៀសចេញចាកស្រុក ចាកនិគម និងដែន ទៅកាន់ចារិកបន្តទៀត នេះជាសន្និបាតលើកទី ៣ មានព្រះ ខីណាស្រពប្រមាណ ៨០ ពាន់កោដិ ។ សម័យនោះ តថាគតជាជដិល អ្នកនៅក្នុងដែន តថាគតបានថ្វាយសំពត់ ព្រមទាំងភត្តដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងកណ្តាល នៃភិក្ខុសង្ឃ ហើយទ្រង់ព្យាករតថាគតថា ក្នុងកប្បទីមួយសែនអំពី កប្បនេះ ជដិលនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីត្រេកអរ តម្កល់នូវសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្ស

ទទួលបាយាសក្ដុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរនៃស្ទឹងនេរញ្ជរា ហើយស្ដេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែង ។ លំដាប់នោះ ព្រះសម្ពុទ្ធទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធអង្គនោះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯព្រះសម្ពុទ្ធអង្គនេះ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតាំងមាំ ។ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ នឹងបានជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងបានជាឧបដ្ឋាយិកា ព្រះជន្មាយុរបស់ព្រះគោតម ដ៏មានយសអង្គនោះកំណត់ ១០០ ឆ្នាំ ។ ទេវតា និងមនុស្សទាំងឡាយ លុះបានស្ដាប់

ព្រះបន្ទូលនេះនៃព្រះសមុទ្ទ រកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយក៏ត្រេកអរថា ជដិលនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ។ មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ក៏យ៉ាងនោះដែរ ។ តថាគតបានឮព្រះបន្ទូលនៃព្រះសមុទ្ទអង្គនោះហើយ បានអធិដ្ឋានវត្តដ៏លើសលប់ឡើងទៅ បានធ្វើនូវសេចក្តីព្យាយាម ដ៏ខ្ជាប់ខ្ជួនមាំមួនដោយការបំពេញនូវបារមីទាំង ១០ ។ ក្នុងកាលនោះ តិរ្ថិយទាំងពួងអាក់អន់ តូចចិត្ត វិនាសខ្វាត់ខ្វាយ បរិស័ទពួកខ្លះនៃតិរ្ថិយទាំងនោះមិនបម្រើតិរ្ថិយទាំងនោះ ក៏នាំគ្នាចៀសចេញចាកដែនទៅ ។ តិរ្ថិយទាំងពួងមកប្រជុំគ្នាក្នុងទីនោះ ហើយបានចូលទៅក្នុងសម្នាក់នៃព្រះពុទ្ធ

( ហើយពោលថា ) បពិត្រព្រះមហាវីរៈ សូមព្រះអង្គជាទីពឹងពំនាក់ ( នៃយើងខ្ញុំទាំងឡាយ ) បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គជាទីរឭក ។ ព្រះពុទ្ធទ្រង់អនុគ្រោះ ទ្រង់ប្រកបដោយករុណា ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញុំាងតិរ្ថិយទាំងអស់ ដែលមកប្រជុំហើយ ឲ្យស្ថិតនៅក្នុងសីល ៥ ។ សាសនា ( របស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈនោះ ) មិនវឹកវរ ជាសាសនាសូន្យចាកពួកតិរ្ថិយយ៉ាងនេះ សាសនានោះ វិចិត្រហើយ ដោយព្រះអរហន្តទាំងឡាយជាអ្នកស្ទាត់ជំនាញ ជាតាទិគុណ ។ ព្រះសាស្ដា ព្រះនាមបទុមុត្តរៈមានព្រះនគរឈ្មោះហង្សវតី មានមហាក្សត្រព្រះនាមអានន្ទ ជាព្រះបិតា ព្រះមាតា ព្រះនាមសុជាតា ។ ព្រះអង្គទ្រង់នៅគ្រប់គ្រងផ្ទះអស់ ៩ ពាន់ឆ្នាំ ប្រាសាទទាំងឡាយដ៏ប្រសើរ មាន ៣ ខ្នង គឺនារីប្រាសាទ ១ ពាហនប្រាសាទ ១ យសវតីប្រាសាទ ១ ។ មាននារី ៣-៤ ពាន់ តាក់តែងល្អ ឯនារីដែលជាអគ្គមហេសីឈ្មោះវសុលទត្តា ព្រះរាជបុត្រព្រះនាមឧត្តរៈ ។ ព្រះជិនស្រីប្រសើរជាងបុរស ទ្រង់ឃើញនូវនិមិត្តទាំង ៤ យ៉ាងហើយ ស្ដេចចេញទៅបព្វជ្ជា ដោយប្រាសាទជាយានទ្រង់ប្រព្រឹត្តនូវសេចក្ដីព្យាយាមអស់ ៧ ថ្ងៃ ។ ព្រះសម្ពុទ្ធបទុមុត្តរៈ

ជានាយក ជាមហាវីរបុរស ត្រូវមហាព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះមិថិលា ។ ភិក្ខុឈ្មោះទេវិល ១ ឈ្មោះសុជាតៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះសុមនៈជាឧបដ្ឋាក របស់ព្រះសាស្តាព្រះនាមបទុមុត្តរៈ ។ ភិក្ខុនីឈ្មោះអមិត្តា ១ ឈ្មោះអសមា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា សលឡព្រឹក្ស ( ដើមស្រល់ ) ។ ឧបាសកឈ្មោះអមិតៈ ១ ឈ្មោះតិស្សៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះហត្ថា ១ សុចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះសម្ពុទ្ធទ្រង់មានកម្ពស់ ៥៨ ហត្ថ មានព្រះអង្គដ៏ល្អល្អះ ប្រាកដស្មើដោយគ្រឿងបូជាជាវិការនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ទ្វារក្តី គន្ទឹះទ្វារក្តី ជញ្ជាំងក្តី ឈើក្តី ភ្នំធំក្តី ជាគ្រឿងរាំងនៃព្រះសម្ពុទ្ធនោះ ក្នុងទីប្រមាណ ១២ យោជន៍ដោយជុំវិញ មិនមានឡើយ ។ ព្រះជន្មាយុមានកំណត់មួយសែនឆ្នាំ កាលព្រះលោកនាថនោះ ទ្រង់ព្រះជន្មាយុនៅដរាបនោះ ទ្រង់ញុំាងប្រជុំច្រើន ឲ្យឆ្លង ( ចាកសង្សារ ) លុះទ្រង់ចម្លងជនជាច្រើនហើយ កាត់នូវសេចក្តីសង្ស័យទាំងពួង ហើយបរិនិព្វានជាមួយនឹងសាវក ដូចជាគំនរភ្លើងដែលឆេះរុងរឿង ហើយរលត់ទៅ

ដូច្នោះ ។ ព្រះពុទ្ធជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបដ៏ប្រសើរ របស់ព្រះអង្គ មានកម្ពស់ ១២ យោជន៍ ( ដែលគេសាងឡើងហើយ ) ក្នុងនន្ទារាមនោះ ។

ចប់ បទុមុត្តរពុទ្ធវង្សទី ១០

# សុមេធពុទ្ធវង្សទី ១១

កាលជាខាងក្រោយ អំពីព្រះលោកនាថព្រះនាមបទុមុត្តរៈមក មានព្រះសម្ពុទ្ធព្រះនាមសុមេធ ព្រះអង្គជានាយក គេគ្របសង្កត់បានដោយក្រ ទ្រង់មានព្រះតេជះដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រីដ៏ប្រសើរ ឧត្តមជាងលោកទាំងមូល ។ ព្រះអង្គមានព្រះនេត្រថ្លាស្អាត មានព្រះភក្ត្រល្អល្អះ មានព្រះសរីរៈធំ មានព្រះសរីរៈត្រង់ល្អ មានព្រះតេជះ ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញ៉ាំងសត្វទាំងឡាយច្រើនឲ្យរួចចាកចំណង ។ កាលណា ព្រះពុទ្ធទ្រង់បានដល់នូវពោធិញ្ញាណដ៏ឧត្តមសព្វគ្រប់ហើយ ទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងនគរឈ្មោះសុទស្សនៈ ។ ក្នុងការសម្តែងធម៌ទេសនានៃព្រះពុទ្ធ ព្រះនាមសុមេធអង្គនោះ មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១

មានពួកសត្វមួយសែនកោដិ ។ តមកទៀត ការត្រាស់ដឹងទី ២ មានពួកសត្វប្រមាណ ៩០ ពាន់កោដិ ក្នុងគ្រាដែលព្រះជិនស្រី ទ្រង់ទូន្មានយក្សឈ្មោះគុម្ភកណ្ណៈ ។ តមកទៀត ការត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ ពាន់កោដិ ក្នុងគ្រាដែលព្រះសម្ពុទ្ធ មានយសរាប់មិនបាន ទ្រង់ប្រកាសនូវសច្ចៈ ៤ ប្រការ ។ ព្រះសុមេធមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រំងាប់ មានចិត្តនឹងធឹង គឺក្នុងកាលដែលព្រះជិនស្រី ស្តេចចូលទៅក្នុងនគរសុទស្សនៈ មានភិក្ខុជាព្រះខីណាស្រពមួយរយកោដិ បានមកប្រជុំ ( នេះសន្និបាតលើកទី ១ ) ។ តមកទៀត សន្និបាតលើកទី ២ មានភិក្ខុប្រមាណ ៩០ កោដិ ( មកប្រជុំ ) ក្នុងពេលក្រាលកឋិនលើភ្នំទេវកូដ ។ តមកទៀត សន្និបាតលើកទី ៣ មានភិក្ខុប្រមាណ ៨០ កោដិ មកប្រជុំក្នុងកាលព្រះលោកនាថ ស្តេចទៅកាន់ចារិក ។ សម័យនោះឯង តថាគតកើតជាមាណពឈ្មោះឧត្តរៈ តថាគតបានសន្សំទ្រព្យទុកក្នុងផ្ទះប្រមាណ ៨០ កោដិ ។ តថាគតថ្វាយទានទាំងអស់ឥតមានសេសសល់ដល់ព្រះពុទ្ធ ព្រមទាំងព្រះសង្ឃ ហើយបានយកព្រះលោកនាយកនោះជាទីពឹង បានពេញចិត្តចំពោះបព្វជ្ជា ។ គ្រានោះ

ព្រះអង្គទ្រង់ធ្វើនូវការអនុមោទនា ហើយព្យាករតថាគតថា ក្នុងកប្បទី ៣០ ពាន់ មាណពនេះនឹងបានជាព្រះពុទ្ធ ( មួយអង្គ ) សត្វនេះនឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយនៅទៀបគល់នៃអជបាលព្រឹក្សទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះមុនីអង្គនោះ នឹងសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះមានយសធំនឹងធ្វើប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់ នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសម្ពុទ្ធអង្គនោះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះសម្ពុទ្ធអង្គនោះ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនោះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ដើមឈើសម្រាប់ត្រាស់ដឹង របស់ព្រះមុនី

អង្គនោះ ហៅថា អសុត្តព្រឹក្ស ឧបាសកឈ្មោះ ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុព្រះគោតម មានយសនោះ មានកំណត់ ១០០ ឆ្នាំ ។ ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះនៃព្រះភគវា មិនមានបុគ្គលស្មើ ក៏មានចិត្តត្រេកអរថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ មនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃ សើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមនោះ ។ មនុស្សទាំងឡាយកាលឆ្លងស្ទឹង បើឃ្លាងកំពង់នៅចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនោះ ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះបន្ទូលនៃព្រះមុនីអង្គនេះហើយ បានញុំាងចិត្តឲ្យជ្រះថ្លាឡើង បានអធិដ្ឋានវត្តដ៏លើសលប់ ដោយការបំពេញនូវបារមី ១០ ។ តថាគតបានរៀននូវ

ព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនៈ ដែលមានអង្គ ៩ ទាំងអស់ ហើយញ៉ាំងសាសនានៃព្រះសាស្ដា ឲ្យល្អរុងរឿង ។ តថាគតជាអ្នកមិនប្រមាទ ក្នុងសាសនានោះ កាលតថាគតនៅក្នុងទីអង្គុយ ទីឈរ និងទីដើរ ក៏បានដល់អភិញ្ញាបារមី ហើយទៅកើតនៅក្នុងព្រហ្មលោក ។ ព្រះសម្ពុទ្ធព្រះនាមសុមេធ ជាមហេសី មានព្រះនគរឈ្មោះសុទស្សនៈ ព្រះមហាក្សត្រព្រះនាមសុទត្តៈ ជាព្រះបិតា ព្រះមាតាបង្កើតព្រះនាមសុទត្តា ។ ព្រះសុមេធសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះអស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺសុចន្ទប្រាសាទ ១ កញ្ចនប្រាសាទ ១ សិរីវឌ្ឍប្រាសាទ ១ ។ មាននារីប្រមាណ ១៦ ពាន់រូប សុទ្ធសឹងតែតាក់តែងល្អហើយ ឯនារីជាអគ្គមហេសីនោះ ព្រះនាមសុមនា ព្រះរាជបុត្រព្រះនាមបុនព្វៈ ។ ព្រះជិនស្រីទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាងហើយ ស្ដេចចេញទៅបព្វជ្ជាដោយហត្ថីជាយាន ទ្រង់តម្កល់ព្យាយាមអស់ ៨ ខែគត់ ។ ព្រះលោកនាយកព្រះនាមសុមេធ ជាមហាវីរៈ ត្រូវព្រហ្មអារាធនាហើយ ទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរឈ្មោះសុទស្សនៈ ភិក្ខុឈ្មោះសរណៈ ១ ឈ្មោះសព្វកាមៈ ១ ជាអគ្គសាវករបស់ព្រះសុមេធ ដែលទ្រង់ស្វែងរកនូវគុណដ៏ធំអង្គនោះ

ភិក្ខុជាឧបដ្ឋាកឈ្មោះសាគរៈ ។ ភិក្ខុនីឈ្មោះរាមា ១ ឈ្មោះសុរាមា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា និម្ពព្រឹក្ស (ដើមស្ដៅ) ។ ឧបាសកឈ្មោះឧរុវេលៈ ១ ឈ្មោះយសវៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះយសា ១ ឈ្មោះសិរិវ៉ា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនី ទ្រង់មានកម្ពស់ ៨៨ ហត្ថ ទ្រង់ញ៉ាំងទិសទាំងពួងឲ្យភ្លឺដូចព្រះច័ន្ទ ដ៏រុងរឿងកន្លងពួកផ្កាយ ។ កែវមណីរបស់ស្ដេចចក្រពត្តិ ភ្លឺរុងរឿងអស់ទីប្រមាណមួយយោជន៍យ៉ាងណា រតនៈគឺពន្លឺនៃព្រះមានព្រះភាគនោះ តែងផ្សាយទៅកាន់ទីប្រមាណមួយយោជន៍ដោយជុំវិញ ក៏យ៉ាងនោះដែរ ។ ព្រះជន្មាយុមានកំណត់ ៩ ម៉ឺនឆ្នាំគត់ ព្រះសុមេធអង្គនោះ កាលទ្រង់ព្រះជន្មាយុនៅដរាបនោះ តែងញ៉ាំងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារ ។ ព្រះសាសនានេះកុះករដោយពួកព្រះអរហន្តដែលមានវិជ្ជា ៣ និងអភិញ្ញា ៦ ដល់នូវកម្លាំងជាតាទិគុណ ព្រះអរហន្តទាំងពួងនោះ សឹងតែមានយសរាប់មិនបាន សុទ្ធតែរួបផុតហើយ មិនមានឧបធិទាំងអស់ ព្រះអរហន្តទាំងនោះមានយសធំ បានសម្ដែងនូវពន្លឺ គឺព្រះញាណ ហើយបរិនិព្វានទៅ ។ ព្រះពុទ្ធព្រះនាមសុមេធ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់និព្វានក្នុងមេធារាម

ព្រះធាតុផ្សាយទៅ ក្នុងប្រទេសទាំងឡាយនោះៗ ។

ចប់សុមេធពុទ្ធវង្សទី ១១

# សុជាតពុទ្ធវង្សទី ១២

ក្នុងមណ្ឌកប្បនោះឯង មានព្រះសម្ពុទ្ធ ជានាយក ព្រះនាមសុជាត ទ្រង់មានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ទ្រង់មានព្រះសុរងដូចជា-កនៃគោឧសភៈ ទ្រង់មានគុណប្រមាណមិនបាន គេគ្របសង្កត់មិនបាន ។ព្រះសម្ពុទ្ធដ៏បរិសុទ្ធប្រាសចាកមន្ទិល ដូចជាព្រះច័ន្ទមានតេជះដូចជាព្រះអាទិត្យ ភ្លឺរុងរឿងដោយព្រះសិរីសព្វៗ កាល យ៉ាងនេះ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ដល់នូវពោធិញ្ញាណដ៏ប្រសើរសព្វគ្រប់ហើយ ទ្រង់ញ៉ាំងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងព្រះនគរ ឈ្មោះសុមង្គល ។ កាលព្រះលោកនាយក ព្រះនាមសុជាត ទ្រង់សម្តែងនូវធម៌ដ៏ប្រសើរសត្វទាំងឡាយចំនួន ៨០ កោដិ បានសម្រេចមគ្គផលក្នុងធម្មទេសនាជាដំបូង ។ កាលណា ព្រះសាស្តា ព្រះនាមសុជាត ទ្រង់មានយសរាប់មិនបាន ស្តេចចូលទៅកាន់ព្រះវស្សាក្នុងទេវលោក កាលនោះការត្រាស់ដឹងនូវធម៌លើកទី ២ មានពួកសត្វ ៣៧ សែន ។ កាលណា

ព្រះពុទ្ធព្រះនាមសុជាត រកបុគ្គលស្មើគ្មាន ស្តេចចូលទៅកាន់សម្នាក់ព្រះរាជបិតា កាលនោះ ការត្រាស់ដឹងនូវធម៌ទី ៣ មានពួកសត្វ ៦០ សែន ។ ព្រះសុជាតមហេសីមានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រំងាប់ ជាតាទិគុណ ជាអ្នកដល់នូវអភិញ្ញា និងពលៈ ជាអ្នកមិនដល់ ( នូវការកើត ) ក្នុងភពតូច និងភពធំ គឺព្រះអរហន្តទាំងនោះ ប្រមាណ ៦០ សែន បានមកប្រជុំជាសន្និបាតលើកដំបូង ។ តមកទៀត ការប្រជុំក្នុងកាលដែលព្រះជិនស្រី ទ្រង់ចុះចាកទេវលោក នេះជាសន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ៥០ សែន ។ អគ្គសាវកណា របស់ព្រះពុទ្ធព្រះនាមសុជាតនោះ បានចូលទៅគាល់ព្រះសម្ពុទ្ធ ដ៏ប្រសើរជាងនរៈ អគ្គសាវកនោះ បានចូលទៅគាល់ព្រះទសពល មួយអន្លើដោយភិក្ខុប្រមាណ ៤ សែនរូប ( នេះជាសន្និបាតលើកទី ៣ ) ។ សម័យនោះ តថាគតជាស្តេចចក្រពត្តិ មានកម្លាំងច្រើន ជាធំក្នុងទ្វីបទាំង ៤ អាចហោះទៅក្នុងអាកាសបាន ។ តថាគតបានថ្វាយនូវរាជសម្បត្តិជាច្រើនក្នុងទ្វីបទាំង ៤ នូវកែវដ៏ឧត្តមទាំង ៧ ប្រការ ចំពោះព្រះពុទ្ធ ហើយបួសក្នុងសម្នាក់នៃព្រះសម្ពុទ្ធអង្គនោះ ។ អារាមិកជនទាំងឡាយ ក្នុងជនបទ

បានប្រមូលមកនូវស្មួយសារអាករ ជាបច្ច័យ ទីដេក ទីអង្គុយ ហើយនាំចូលទៅថ្វាយដល់ភិក្ខុសង្ឃ ។ កាលនោះ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់ព្យាករតថាគតថា ក្នុងទីបំផុតនៃកប្ប ៣០ ពាន់ ស្តេចចក្រពត្តិអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ជាធំក្នុងមួយម៉ឺនលោកធាតុ ។ សត្វនេះនឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយនៅទៀបគល់នៃអជបាលព្រឹក្ស បានទទួលនូវបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយនូវបាយាស ទៀបច្រាំងស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែង ។ លំដាប់នោះ ព្រះមានយសធំ ធ្វើប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់ នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសម្ពុទ្ធអង្គនោះ ព្រះនាម មាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ ព្រះពុទ្ធអង្គនោះ ព្រះនាម គោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះមុនីអង្គនោះ ។ នាងខេមា ១ នាងឧប្បលវណ្ណា

១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ដើមឈើសម្រាប់ត្រាស់ដឹង របស់ព្រះភគវានោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតម ដ៏ទ្រង់យសអង្គនោះមានកំណត់ ១០០ ឆ្នាំ ។ មនុស្ស និងទេវតាទាំងឡាយលុះបានស្តាប់ព្រះបន្ទូលនេះ នៃព្រះពុទ្ធរកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ត្រេកអរថា ស្តេចចក្រពត្តិអង្គនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា ពួកយើងបើឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាយកអង្គនេះ ក្នុងកាលជាអនាគត ពួកយើងទាំងអស់គ្នា គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនោះពុំខាន ។ ពួកមនុស្សកាលឆ្លងស្ទឹងបើឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគត គង់នឹងបានសម្រេចក្នុងទី

ចំពោះព្រះភក្ត្រនៃព្រះគោតមនោះ ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់នូវព្រះបន្ទូលនៃព្រះពុទ្ធនោះហើយ បានញ៉ាំងសេចក្តីរីករាយ ឲ្យកើតដ៏ក្រៃលែង ហើយបានអធិដ្ឋាននូវវត្តដ៏លើសលប់ ដោយការបំពេញនូវបារមីទាំង ១០ ។ តថាគតបានរៀននូវព្រះសូត្រផង ព្រះវិន័យផង សត្ថុសាសនៈដែលមានអង្គ ៩ ទាំងអស់ផង ហើយបានញ៉ាំងសាសនានៃព្រះជិនស្រី ឲ្យល្អរុងរឿង ។ កាលតថាគតនៅក្នុងសាសនានោះជាអ្នកមិនប្រមាទ បានចម្រើននូវភាវនាដ៏ប្រសើរ ហើយបានដល់នូវបារមីក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក ។ ព្រះសម្ពុទ្ធព្រះនាមសុជាត ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះនគរឈ្មោះសុមង្គល ព្រះមហាក្សត្រព្រះនាមឧគ្គតៈ ជាព្រះបិតា ព្រះមាតាព្រះនាមបភាវតី ។ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះអស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ ( របស់ព្រះពុទ្ធនោះ ) មាន ៣ ខ្នង គឺសិរីប្រាសាទ ១ ឧបសិរីប្រាសាទ ១ ចន្ទប្រាសាទ ១ ។ មាននារីប្រមាណ ២ ម៉ឺន ៣ ពាន់នាក់ សុទ្ធសឹងតែតាក់តែងល្អហើយ ឯនារីដែលជាអគ្គមហេសីព្រះនាមសិរិនន្ទា ព្រះរាជបុត្រព្រះនាមឧបសេន ។ ព្រះលោកនាយកទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាងហើយ ស្តេចចេញទៅបព្វជ្ជាដោយយាន

គឺសេះ តម្កល់នូវព្យាយាមអស់ ៩ ខែគត់ ។ ព្រះសម្ពុទ្ធព្រះនាមសុជាត ជាលោកនាយក ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះសុមង្គល ។ ភិក្ខុឈ្មោះសុទស្សនៈ ១ ឈ្មោះសុទេវៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះនារទៈ ជាឧបដ្ឋាកនៃព្រះពុទ្ធ ព្រះនាមសុជាត ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ភិក្ខុនីឈ្មោះនាគា ១ ឈ្មោះនាគសមានា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា មហាវេឡុព្រឹក្ស ( ដើមឫស្សីធំ )។ ដើមឫស្សីនោះ មានដើមតាន់មិនប្រហោង មានស្លឹកច្រើន ជាឫស្សី មានដើមត្រង់ មានដើមធំ គួររមិលមើល ជាទីរីករាយនៃចិត្ត ។ ជាឫស្សី តែមួយដើម លូតលាស់ឡើងហើយ ឯមែកក៏បែកចេញអំពីដើមនោះ ជា ៥ មែក ឫស្សីនោះជាឈើល្អ ដូចជាបាច់នៃកន្ទុយក្ងោក ដែលគេចងល្អហើយ ដូច្នោះ ។ ឫស្សីនោះ ជាឫស្សីឥតបន្លា ឥតប្រហោង មានមែកត្រសុំត្រសាយ ដេរដាសដោយមែក មានម្លប់ត្រឈៃ ជាទីរីករាយនៃចិត្ត ។ ឧបាសកឈ្មោះសុទត្តៈ ១ ឈ្មោះចិត្តៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនាងសុភទ្រា ១ នាងបទុមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះជិនស្រីអង្គនោះ មានកម្ពស់ ៥០ ហត្ថ ទ្រង់ប្រកបដោយអាការ

ប្រសើរគ្រប់យ៉ាង ទ្រង់ប្រកបដោយគុណទាំងពួង ។ រស្មីនៃព្រះសម្ពុទ្ធ អង្គនោះ ស្មើដោយរស្មីនៃព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ តែងផ្សាយ ចេញទៅក្នុងទីជុំវិញ ព្រះសម្ពុទ្ធនោះ មានព្រះគុណប្រមាណមិនបាន មានព្រះគុណថ្លឹងមិនបាន មិនមានឧបមា ដូចសេចក្តីឧបមាទាំងឡាយ ឡើយ ។ ព្រះជន្មាយុមានកំណត់ ៩០ ពាន់ឆ្នាំគត់ ព្រះពុទ្ធអង្គនោះ កាលគង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ក្នុងកាលនោះ សាសនារបស់ព្រះពុទ្ធអង្គនោះ ដ៏វិចិត្រដោយព្រះអរហន្តទាំងឡាយ ដូចជារលកនៅក្នុងសាគរ ឬដូច ជាផ្កាយក្នុងអាកាស ។ សាសនានេះកុះករដោយព្រះអរហន្តទាំងឡាយ ដែលមានវិជ្ជា ៣ និងអភិញ្ញា ៦ លោកដល់នូវកម្លាំង ជាតាទិគុណ ។ ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធរកបុគ្គលស្មើគ្មាន គុណទាំងឡាយនោះ ជាគុណថ្លឹងពុំបាន ធម្មជាតិទាំងពួង ក៏អន្តរធានអស់ ឱហ្ន៎! សង្ខារ ទាំងពួង ជារបស់សោះសូន្យទទេ ។ ព្រះភគវាព្រះនាមសុជាត ជាព្រះ ជិនស្រីដ៏ប្រសើរ បរិនិព្វានក្នុងសេលារាម ព្រះចេតិយរបស់ព្រះសាស្តា មានកម្ពស់ ៣ គាវុត ( ដែលគេសាង ) ក្នុងសេលារាមនោះ ។

**ចប់ សុជាតពុទ្ធវង្សទី ១២**

# បិយទស្សីពុទ្ធវង្សទី ១៣

កាលខាងក្រោយ នៃព្រះសម្ពុទ្ធព្រះនាមសុជាតមក មានព្រះពុទ្ធ ទ្រង់ព្រះនាមបិយទស្សី ជានាយក ទ្រង់មានយសច្រើន គេគ្របសង្កត់បាន ដោយក្រ ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានយសប្រមាណមិនបាន ទ្រង់រុងរឿង ដូចជាព្រះអាទិត្យ ទ្រង់កម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់ញ៉ាំងធម្មចក្រ ទាំងពួងឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះមានតេជៈប្រៀបមិនបាន មានការ ត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១ មានពួកសត្វមួយសែនកោដិ ។ ទេវរាជព្រះនាមសុទស្សនៈ គាប់ព្រះទ័យនឹងមិច្ឆាទិដ្ឋិ ព្រះបរមសាស្ដា កាលទ្រង់បន្ទោបង់នូវទិដ្ឋិនៃសុទស្សនទេវរាជនោះ ទ្រង់បានសម្ដែងធម៌ ។ ក្នុងកាលនោះ ការប្រជុំជនច្រើនប្រៀបមិនបាន ជាការប្រជុំធំ ឈ្មោះថា ត្រាស់ដឹងទី ២ មានពួកសត្វ ៩ ពាន់កោដិ ។ ក្នុងកាលណាព្រះពុទ្ធ ជាសារថីទូន្មាននូវនរៈ ទ្រង់ទូន្មានដំរីឈ្មោះរោណមុខៈ ក្នុងកាលនោះ ឈ្មោះថា ត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ កោដិ ។ ព្រះបិយទស្សី អង្គនោះ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានពួក

ព្រះអរហន្តមួយសែនកោដិ ។ តអំពីនោះមក ព្រះខីណាស្រពទាំងឡាយ ជាអ្នកប្រាជ្ញចំនួន ៩០ កោដិ បានមកប្រជុំព្រមក្នុងទីជាមួយគ្នា នេះជាសន្និបាតលើកទី ២ ក្នុងសន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ កោដិ ។ សម័យនោះ តថាគតកើតជាមាណព ឈ្មោះកស្សបៈ ជាអ្នកស្វាធ្យាយមន្ត ចងចាំមន្ត ដល់នូវត្រើយនៃត្រៃវេទទាំងពួង ។ តថាគតបានស្តាប់ធម៌របស់ព្រះពុទ្ធ ព្រះនាមបិយទស្សីនោះហើយ បានញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតឡើង តថាគតបានកសាងនូវសង្ឃារាម ដោយទ្រព្យប្រមាណមួយសែនកោដិ ។ តថាគតបានថ្វាយអារាមដល់ព្រះពុទ្ធអង្គនោះហើយ មានចិត្តរីករាយ មានចិត្តសង្វេគ បានសមាទានសីល ៥ និងដល់សរណគមន៍ ធ្វើឲ្យមាំមួន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ក្នុងកណ្តាលសង្ឃហើយ ទ្រង់ព្យាករតថាគតថា មាណពនេះនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ១៨០០ ។ សត្វនេះនឹងចេញចាកពីក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់ការព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយទ្រង់ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា រួចស្តេចចូលទៅទៀបគល់

នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះសាស្តាមានយសធំ នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះពុទ្ធអង្គនោះ ព្រះនាមមាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ ព្រះពុទ្ធអង្គនោះ ព្រះនាមគោតម ។ ភិក្ខុឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអគ្គសាវក ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតាំងមាំ ។ ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្ត-គហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតមមានយសអង្គនោះ មានកំណត់ ១០០ ឆ្នាំ ។ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះ នៃព្រះលោកនាថរកបុគ្គលស្មើគ្មាន ក៏ត្រេកអរថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ មនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃ

សើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្វាងមគ្គផល ក្នុងសាសនា នៃព្រះសាស្ដាអង្គនេះ ក្នុងកាលជាអនាគត ពួកយើង គង់នឹងបានសម្រេចមគ្គផល ចំពោះព្រះភក្ត្រនៃព្រះគោតមនោះមិនខាន ។ មនុស្សទាំងឡាយ កាលនឹងឆ្លងស្ទឹង បើឃ្វាងនូវកំពង់ក្នុងទីចំពោះមុខ ហើយ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្វាងព្រះជិនស្រីអង្គនេះហើយ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចមគ្គផល ក្នុងទីចំពោះ ព្រះភក្ត្រនៃព្រះគោតមនោះ ក៏យ៉ាងនោះដែរ ។ លុះតថាគតបានស្ដាប់ ព្រះបន្ទូលនៃព្រះពុទ្ធអង្គនេះហើយ បានញុំាងចិត្តឲ្យជ្រះថ្លាដ៏ក្រៃលែង ហើយអធិដ្ឋានវត្តដ៏លើសលប់ ដោយការបំពេញនូវបារមីទាំង ១០ ។

ព្រះបរមសាស្ដា ព្រះនាមបិយទស្សី មានព្រះនគរឈ្មោះសុធញ្ញៈ មានព្រះមហាក្សត្រព្រះនាមថា សុទត្តៈ ជាព្រះបិតា ព្រះមាតាព្រះនាម សុចន្ទា ។ ព្រះពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងផ្ទះអស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺសុនិម្មលប្រាសាទ ១ វិមលប្រាសាទ ១ គិរិគូហាប្រាសាទ ១ ។ មាននារីប្រមាណ ៣៣ ពាន់នាក់ សុទ្ធសឹងតែ តាក់តែងល្អ ឯនារីដែលជាអគ្គមហេសីនោះ ព្រះនាមនាងវិមលា

ព្រះរាជបុត្របង្កើតព្រះនាមកញ្ចនាវេឡុះ ។ ព្រះជិនស្រីជាបុរសប្រសើរ ទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាងហើយ ស្តេចចេញទៅបព្វជ្ជាដោយរថជាយាន ហើយទ្រង់ប្រព្រឹត្តនូវសេចក្តីព្យាយាមអស់ ៦ ខែគត់ ។ ព្រះភគវាព្រះនាមបិយទស្សីជាព្រះមហាវីរៈត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧសភឧទ្យាន ជាទីរីករាយនៃចិត្ត ។ ភិក្ខុបាលិតៈ ១ ឈ្មោះសព្វទស្សី ១ ជាអគ្គសាវក ភិក្ខុឈ្មោះសោភិតៈជាឧបដ្ឋាកនៃព្រះសាស្តា ព្រះនាមបិយទស្សី ។ ភិក្ខុនីឈ្មោះសុជាតា ១ ឈ្មោះធម្មទិន្នា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា កកុធព្រឹក្ស ( ដើមថ្វាន់ ) ។ ឧបាសកសន្នកៈ ១ ធម្មិកៈ ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនាងវិសាខា ១ ឈ្មោះនាងធម្មទិន្នា ១ ជាអគ្គឧបដ្ឋាយិកា ព្រះពុទ្ធអង្គនោះ ទ្រង់មានយសរាប់មិនបាន មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានកម្ពស់ ៨០ ហត្ថ ទ្រង់ប្រាកដដូចជាស្តេចនៃឈើ ឈ្មោះសាលព្រឹក្ស ។ រស្មីនៃភ្លើង រស្មីនៃព្រះច័ន្ទ និងរស្មីនៃព្រះអាទិត្យប្រាកដដូចជារស្មីនៃព្រះពុទ្ធ ជានាយក ដែលរកបុគ្គលស្មើគ្មាននោះមិនមានឡើយ ។ ព្រះសម្ពុទ្ធជាទេវតាដ៏ប្រសើរអង្គនោះ មានព្រះជន្មាយុ

នៅជរាបនោះ ទ្រង់ស្ថិតនៅក្នុងលោកអស់ ៩០ ពាន់ឆ្នាំ ។ ព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើអង្គនោះក្តី គូនៃសាវ័កទាំងអម្បាលនោះក្តី មានគុណប្រឹងពុំបាន របស់ទាំងអស់នោះអន្តរធានទៅ ឱហ្ន៎! សង្ខារ ទាំងពួង ជារបស់សោះសូន្យទទេ ។ ព្រះសាស្តា ព្រះនាមបិយទស្សី ជាព្រះលោកនាថដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអស្សត្ថារាម ព្រះស្តូប នៃព្រះជិនស្រីអង្គនោះ មានកម្ពស់ ៣ យោជន៍ (គេបានកសាងហើយ) នៅក្នុងអស្សត្ថារាមនោះ ។

ចប់ បិយទស្សីពុទ្ធវង្សទី ១៣

# អត្ថទស្សីពុទ្ធវង្សទី ១៤

ក្នុងមណ្ឌកប្បនោះឯង មានព្រះលោកនាថ ព្រះនាមអត្ថទស្សី មានយសធំ ទ្រង់កម្ចាត់បង់ងងឹតធំ សម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះសម្ពុទ្ធត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ហើយ មនុស្ស និងទេវតាទាំងម៉ឺនលោកធាតុឲ្យឆ្អែតដោយទឹកអម្រឹត ។ ព្រះសាស្តាអង្គនោះ ទ្រង់មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹង

លើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះសម្ពុទ្ធ ទ្រង់ព្រះនាមអត្ថទស្សី ទ្រង់ត្រាច់ទៅកាន់ទេវចារិក ។ តមកការត្រាស់ដឹងលើកទី ៣ មានពួកសត្វចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សម្តែងព្រះធម៌ក្នុងសម្នាក់ព្រះបិតា ។ ព្រះភគវាអង្គនោះមានសាវកសន្និបាត ( ការជួបជុំសាវក ) ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះទ័យស្ងប់ ប្រកបដោយតាទិគុណ គឺសន្និបាតលើកទី ១ មានពួកព្រះខីណាស្រពចំនួន ៩៨ ពាន់អង្គ សន្និបាតលើកទី ២ មានពួកព្រះខីណាស្រពចំនួន ៨៨ ពាន់អង្គ ។ សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រពចំនួន ៧៨ ពាន់អង្គ សុទ្ធតែមានព្រះទ័យផុតស្រឡះ ឥតប្រកាន់ ប្រាសចាកមន្ទិល ជាអ្នកស្វែងរកនូវគុណដ៏ធំ ។ ក្នុងសម័យនោះ តថាគតកើតជាជដិល ឈ្មោះសុសិមៈ មានតបៈដ៏ខ្ពង់ខ្ពស់ ដែលគេសន្មតថា ជាបុគ្គលដ៏ប្រសើរលើផែនដី ។ តថាគតបាននាំយកផ្កាមន្ទារវបុស្ស ផ្កាឈូក និងផ្កាបារិច្ឆត្តព្រឹក្សជាទិព្វអំពីទេវលោក មកបូជាចំពោះព្រះសម្មាសម្ពុទ្ធ ។ ឯព្រះសម្ពុទ្ធជាមហាមុនី ព្រះនាមអត្ថទស្សីអង្គនោះ ទ្រង់បានព្យាករ

តថាគតថា តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បទី ១៨០០ ។ សត្វនេះនឹងចេញអំពីបុរីជាទីរីករាយ ឈ្មោះកបិលពស្តុ តម្កល់ព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស បានទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះទសពលអង្គនោះ នឹងសោយមធុបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះមានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌល ហើយត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពោធិសត្វនេះព្រះនាម មាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ បុរសនេះនឹងជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ ។ នាងខេមាថេរី ១ នាងឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស គហបតី

ឈ្មោះចិត្តៈ ១ គហបតីឈ្មោះហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះនៃព្រះមហេសី ទ្រង់ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើហើយ ក៏រីករាយថា បុរសនេះជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាយកអង្គនេះ ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងទៅកាន់កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានយ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនោះ ក្នុងកាលជាអនាគតក៏យ៉ាងនោះដែរ ។ លុះតថាគតបានស្តាប់ភាសិតនៃព្រះមុនីអង្គនោះហើយ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមី ១០ ប្រការ ។ ព្រះមហេសី ព្រះនាម

អត្ថទស្សី មានទីក្រុងឈ្មោះសោភណៈ មានព្រះមហាក្សត្រព្រះនាម សាគរ ជាព្រះបិតា មានព្រះជននី ព្រះនាមសុទស្សនា ។ ព្រះអត្ថទស្សី អង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់ ៩ ពាន់ឆ្នាំ មានប្រាសាទ ដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះ អមរគិ ១ ប្រាសាទឈ្មោះ សុរគិ ១ ប្រាសាទឈ្មោះគិរិពាហនៈ ១ ។ នារី ៣ ម៉ឺន ៣ ពាន់រូប សឹងប្រដាប់យ៉ាងសមសួន នារី ( ជាអគ្គមហេសី ) នោះ ព្រះនាម វិសាខា ព្រះរាជបុត្រព្រះនាមសេលៈ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាងហើយ ស្ដេចចេញទៅបព្វជ្ជាដោយសេះជាយាន តម្កល់ព្យាយាម អស់ ៨ ខែគត់ ។ ព្រះអត្ថទស្សីមានយសធំ មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅក្នុង ឧទ្យានដ៏ថ្លៃថ្លា ។ ព្រះមហេសីព្រះនាមអត្ថទស្សី មានអគ្គសាវកពីរអង្គ គឺព្រះសន្តៈ ១ ព្រះឧបសន្តៈ ១ មានភិក្ខុជាឧបដ្ឋាកឈ្មោះអភយៈ ។ មានព្រះថេរីឈ្មោះធម្មា ១ សុធម្មា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ ត្រាស់ដឹងនៃព្រះសម្ពុទ្ធនោះ ហៅថា ចម្បកព្រឹក្ស ។ ឧបាសកឈ្មោះ នកុឡៈ ១ ឈ្មោះនិសភៈ ១ ជាអគ្គឧបដ្ឋាក នាងមកិលា ១ នាង សុនន្ទា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយ

ព្រះពុទ្ធដែលមិនមានបុគ្គលស្មើ មានកម្ពស់ ៨០ ហត្ថ ទ្រង់រុងរឿង ហាក់ដូចជាសាលរាជព្រឹក្ស ឬដូចព្រះច័ន្ទពេញវង់ ។ រស្មីជាប្រក្រតី នៃព្រះពុទ្ធអង្គនោះច្រើនរយកោដិ តែងផ្សាយទៅកាន់ទិសទាំង ១០ ទាំងខាងលើ ទាំងខាងក្រោម ចម្ងាយមួយយោជន៍សព្វៗ កាល ។ ម្យ៉ាងទៀត ព្រះពុទ្ធអង្គនោះប្រសើរជាងជន ខ្ពង់ខ្ពស់ជាងសត្វទាំងពួង ជាអ្នកប្រាជ្ញ មានបញ្ញាចក្ខុ ស្ថិតនៅក្នុងមនុស្សអស់មួយសែនឆ្នាំ ។ ព្រះពុទ្ធនោះ ទ្រង់សម្ដែងពន្លឺបឺងពុំបាន ញុំាងមនុស្សលោក ព្រមទាំងទេវលោកឲ្យរុងរឿង ហើយទ្រង់ដល់នូវអនិច្ចតាធម៌ ដូចជាភ្លើងអស់កំញម ។ព្រះអត្ថទស្សីជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអនោមារាម មានការសាយកាយទៅនៃព្រះធាតុ ក្នុងប្រទេសទាំងឡាយនោះៗ ។

ចប់ អត្ថទស្សីពុទ្ធវង្សទី ១៤

# ធម្មទស្សីពុទ្ធវង្សទី ១៥

ក្នុងមណ្ឌកប្បនោះឯង មានព្រះលោកនាថ ព្រះនាមធម្មទស្សី មានយសធំ ទ្រង់កម្ចាត់បង់ងងឹតអន្ធការ ហើយញុំាងមនុស្សលោក ព្រមទាំងទេវលោកឲ្យរុងរឿង ។ការត្រាស់ដឹងលើកទី ១ មានពួកសត្វ

មួយសែនកោដិ ក្នុងការញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅនៃព្រះធម្មទស្សីនោះ ទ្រង់មានតេជះប្រឹងពុំបាន ។ ការត្រាស់ដឹងលើកទី ២ មានសត្វចំនួន ៩០ កោដិ ក្នុងកាលដែលព្រះសាស្តា ព្រះនាមធម្មទស្សីទ្រង់ទូន្មានឥសី ឈ្មោះសញ្ជយៈ ។ ការត្រាស់ដឹងលើកទី ៣ មានសត្វចំនួន ៨០ កោដិ ក្នុងកាលដែលសក្កទេវរាជ ព្រមទាំងបរិស័ទចូលទៅគាល់ព្រះធម្មទស្សី ទ្រង់ជានាយក ។ ព្រះធម្មទស្សីនោះ ជាទេវតាក្រៃលែងជាងទេវតា មានសាវ័កសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព មានមន្ទិល ទៅប្រាសហើយ មានព្រះទ័យស្ងប់ ប្រកបដោយតាទិគុណ ។សន្និបាត លើកទី ១ មានព្រះខីណាស្រពមួយពាន់កោដិ ក្នុងវេលាដែលព្រះពុទ្ធ ព្រះនាមធម្មទស្សី ទ្រង់ចូលទៅកាន់វស្សាក្នុងអារាម ឈ្មោះសរណៈ ។ សន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ១០០ កោដិ ក្នុងវេលា ដែលព្រះពុទ្ធជាម្ចាស់ ស្តេចចុះចាកទេវលោកមកកាន់មនុស្សលោក ។ មួយទៀត សន្និបាតលើកទី ៣ មានព្រះខីណាស្រពចំនួន ៨០ កោដិ ក្នុងវេលាដែលព្រះសាស្តា ទ្រង់ប្រកាសនូវធុតង្គគុណទាំងឡាយ ។ ក្នុងសម័យនោះ តថាគតកើតជាព្រះឥន្ទ្រ ឈ្មោះបុរិន្ទទៈ បានបូជា ព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងក្រអូប ផ្កាកម្រង និងតូរ្យតន្ត្រីទិព្វ ។

ព្រះពុទ្ធអង្គនោះ ទ្រង់គង់ចំកណ្តាលពួកទេវតា ហើយព្យាករតថាគតថា ក្នុងកប្បទី ១៨០០ទេវរាជនេះនឹងបានត្រាស់ដឹងជាព្រះពុទ្ធ ។ សត្វនេះនឹងចេញពីបុរីជាទីគួរត្រេកអរ ឈ្មោះកបិលពស្តុ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅឯស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះបានឆាន់បាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយនឹងត្រឡប់ទៅឯគល់ពោធិព្រឹក្សតាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះព្រះទសពល មានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះតថាគតនោះព្រះនាមមាយាទេវី ព្រះបិតាព្រះនាម សុទ្ធោទនៈ ទេវរាជនេះនឹងបានជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ នឹងជាអគ្គសាវក ជាអ្នកមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទនឹងបម្រើព្រះជិនស្រីអង្គនោះ ។ ព្រះខេមាថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹង

នៃព្រះមានព្រះភាគអង្គនោះ ហៅថា អសុរត្តព្រឹក្ស ឧបាសកឈ្មោះ ចិត្តៈ ១ ឈ្មោះហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំគត់ ។ ពួកមនុស្ស និងទេវតាលុះបានស្តាប់ ព្រះពុទ្ធដីកានេះនៃព្រះលោកនាយក ឥតមានបុគ្គលស្មើ ក៏រីករាយថា ព្រះឥន្ទ្រនេះ ជាពូជពន្ធកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា ពួកយើងបើឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាល នឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាង ព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតម ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះឯង ។ តថាគតលុះបានស្តាប់ ភាសិតនៃព្រះទសពលអង្គនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះសាស្តា

ព្រះនាមធម្មទស្សី មានទីក្រុងឈ្មោះសរណៈ មានមហាក្សត្រព្រះនាម សរណៈ ជាព្រះបិតា មានព្រះជននីព្រះនាមសុនន្ទា ។ ព្រះធម្មទស្សី អង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់ ៨ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ខ្នង គឺប្រាសាទឈ្មោះអរជៈ ១ ប្រាសាទឈ្មោះវិរជៈ ១ ប្រាសាទឈ្មោះសុទស្សនៈ ១ ។ ពួកនារីចំនួន ៤០ ពាន់ សឹងប្រដាប់ខ្លួនយ៉ាងសមសួន នារី (ជាអគ្គមហេសី) ឈ្មោះវិចិកោលី ព្រះរាជបុត្រឈ្មោះបុញ្ញវឌ្ឍនៈ ។ ព្រះធម្មទស្សី ជាបុរសដ៏ប្រសើរ ទ្រង់ឃើញនូវនិមិត្ត ៤ ហើយ ទ្រង់ចេញទៅបព្វជ្ជាដោយប្រាសាទជាយាន ទៅប្រព្រឹត្តព្យាយាមអស់ ៧ ថ្ងៃ ។ ព្រះពុទ្ធព្រះនាមធម្មទស្សីប្រសើរជាងពួកជន មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន ។ ព្រះសាស្តាព្រះនាមធម្មទស្សី មានព្រះបទុមត្ថេរ ១ ព្រះបុស្សទេវត្ថេរ ១ ជាអគ្គសាវ័ក ព្រះសុទត្តត្ថេរ ជាឧបដ្ឋាក ។ មានព្រះខេមាថេរី ១ ព្រះសច្ចនាមាថេរី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា តម្ពជាលព្រឹក្ស ។ សុភទ្ទគហបតី ១ កដិស្សគហបតី ១ ជាអគ្គឧបដ្ឋាក នាងសាឡិសា ១ នាងកឡិស្សា ១

ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ទ្រង់មានកម្ពស់ ៨០ ហត្ថ ទ្រង់រុងរឿងក្រៃលែងដោយតេជះក្នុងមួយម៉ឺនលោកធាតុ ។ដើមសាលរាជព្រឹក្ស មានផ្ការីកស្គុសស្កាយល្អផ្ទេកបន្ទោរលើអាកាស ព្រះអាទិត្យនាថ្ងៃត្រង់ រុងរឿងល្អ យ៉ាងណាព្រះពុទ្ធអង្គនោះ ទ្រង់រុងរឿងល្អយ៉ាងនោះ ។ ព្រះលោកនាថអង្គនោះទ្រង់មានតេជះប្រឹងពុំបាន មានជីវិតដ៏ស្មើល្អ ព្រះសម្ពុទ្ធមានបញ្ញាចក្ខុទ្រង់ស្ថិតនៅក្នុងលោក អស់មួយសែនឆ្នាំ ។ ព្រះលោកនាថអង្គនោះព្រមទាំងសាវ័ក ទ្រង់សម្តែងរស្មី ធ្វើសាសនាមិនឲ្យមានមន្ទិល ដូចជាព្រះច័ន្ទកាលរុងរឿងឰដ៏អាកាស ហើយបរិនិព្វាន ។ ព្រះធម្មទស្សីទ្រង់មានព្យាយាមធំ ទ្រង់បរិនិព្វាន ក្នុងអារាមឈ្មោះកេសៈ ព្រះស្តូបដ៏ប្រសើរនោះ របស់ព្រះពុទ្ធអង្គនោះឯង មានកម្ពស់ ៣ យោជន៍ ។

**ចប់ ធម្មទស្សីពុទ្ធវង្សទី ១៥**

# សិទ្ធត្ថពុទ្ធវង្សទី ១៦

ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក ព្រះនាមសិទ្ធត្ថ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ បីដូចជាព្រះអាទិត្យរះឡើង ។

ព្រះសិទ្ធត្ថអង្គនោះ ទ្រង់ដល់នូវសម្ពោធិញ្ញាណ ហើយចម្លងមនុស្ស ព្រមទាំងទេវតា បង្អុរភ្លៀង គឺធម៌ ហើយញ៉ាំងមនុស្ស ព្រមទាំងទេវតា ឲ្យរលត់ទុក្ខ ។ ព្រះអង្គមានតេជះប្លឹងពុំបាន ទ្រង់មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងលើកទី ១ មានពួកសត្វមួយសែនកោដិ ។ តមក ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ក្នុងកាលព្រះសម្ពុទ្ធទ្រង់ទូងស្គរ គឺធម៌ ក្នុងដែនឈ្មោះភិមៈ ។ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធដ៏ប្រសើរជាងជនអង្គនោះ ទ្រង់សម្ដែងធម៌ ទៀបភ្នំឈ្មោះវេភាតៈ ។ ព្រះភគវាព្រះនាមសិទ្ធត្ថ មានសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រពឥតមានមន្ទិល មានចិត្តស្ងប់រំងាប់ ប្រកបដោយតាទិគុណ ។ ឋានៈ គឺសន្និបាតទាំង ៣ ក្នុងសមាគមនៃព្រះខីណាស្រព ដែលមិនមានមន្ទិលនុ៎ះមានចំនួន ១០០ កោដិម្ដង ៩០ កោដិម្ដង ៨០ កោដិម្ដង ។សម័យនោះតថាគតជាតាបស ឈ្មោះមង្គលៈ មានតេជះខ្ពង់ខ្ពស់ គេគ្របសង្កត់មិនបាន ជាអ្នកប្រកបដោយកម្លាំងនៃអភិញ្ញា ។តថាគតបាននាំផ្លែព្រីងមកថ្វាយព្រះសាស្ដា ព្រះនាមសិទ្ធត្ថ ព្រះសម្ពុទ្ធទ្រង់ទទួលយកហើយទ្រង់បានត្រាស់ព្រះតម្រាស់នេះថា អ្នកទាំងឡាយ ចូរមើលតាបស

ដែលមានតបៈខ្ពង់ខ្ពស់នេះចុះ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បទី ៩៤ អំពីកប្បនេះទៅ ។ សត្វនេះនឹងចេញពីបុរី ជាទីគួរត្រេកអរឈ្មោះកបិលពស្តុ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចត្រឡប់ចូលទៅឯគល់ពោធិព្រឹក្សតាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះជិនស្រីទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់ នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះតថាគតនោះព្រះនាមមាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ ។ ខេមាថេរី ១ ឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកាសុទ្ធតែមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រំងាប់មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះលោកនាយក

អង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះ ចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ក៏រីករាយថា តាបសនេះ ជាពូជពន្លកនៃព្រះសាស្តា ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃ ព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាល នឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់ទៅកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាង ព្រះសាស្តានេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមនោះ ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះដែរ ។ តថាគត លុះបានស្តាប់ ភាសិតនៃព្រះពុទ្ធអង្គ ព្រះនាមសិទ្ធត្ថនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លា ក្រៃលែង បានអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង ១០ ។

ព្រះមហេសី ព្រះនាមសិទ្ធត្ថ មានទីក្រុងឈ្មោះវេភារៈ មានមហាក្សត្រ ព្រះនាមឧទេន ជាព្រះបិតា ព្រះជននីព្រះនាមសុផស្សា ។ ព្រះសិទ្ធត្ថនោះ ទ្រង់គ្រប់គ្រងគេហដ្ឋាន អស់មួយម៉ឺនឆ្នាំ ទ្រង់មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺកោកាសប្រាសាទ ១ ឧប្បលប្រាសាទ ១ កោនុទប្រាសាទ ១ ។ ពួកនារីចំនួន ៤៨០០០ រូប សឹងមានខ្លួនតាក់តែងល្អ នារីជាអគ្គមហេសី ព្រះនាម សុមនា មានព្រះរាជបុត្រព្រះនាម អនុបមៈ ។ ព្រះជិនស្រី ទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាង ក៏ចេញទៅបព្វជ្ជា ដោយ.រ ( អស្រ្ទីង ) តម្កល់ព្យាយាមអស់ ១០ ខែគត់ ។ ព្រះលោកនាថ ព្រះនាមសិទ្ធត្ថ មានព្យាយាមធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទ្រង់ញ៉ាំង ធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន ។ ព្រះសាស្ដា ព្រះនាមសិទ្ធត្ថ មានព្រះសម្ពលត្ថេរ ១ ព្រះសុមិត្តត្ថេរ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះ រេវតៈ ជាឧបដ្ឋាក ។ ព្រះសីវលាថេរី ១ ព្រះសុរាមាថេរី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា កណ្ណិការព្រឹក្ស ។ សុប្បិយគហបតី ១ សមុទ្ទគហបតី ១ ជាអ្នកបម្រើដ៏ប្រសើរ រម្មាឧបាសិកា ១ សុរម្មាឧបាសិកា ១ ជាអ្នក បម្រើដ៏ប្រសើរ ។ ព្រះលោកនាថអង្គនោះ ទ្រង់មានកម្ពស់ ៦០ ហត្ថ

ទ្រង់ខ្ពស់ដល់អាកាស ប្រាកដស្មើដោយគ្រឿងបូជាមាស ទ្រង់រុងរឿងអស់មួយម៉ឺនលោកធាតុ ។ព្រះសាស្ដាអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ឥតមានបុគ្គលប្ដូរបាន ឥតមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់មានចក្ខុ ស្ថិតនៅក្នុងលោកអស់មួយសែនឆ្នាំ ។ ព្រះលោកនាយកអង្គនោះ ព្រមទាំងសាវក ទ្រង់សម្ដែងពន្លឺភ្លឺត្រចះ ហើយញុំាងសាវក ឲ្យសាយកាយទៅ ទ្រង់ក្រសាលដោយសមាបត្តិដ៏ប្រសើរ ហើយបរិនិព្វាន ។ ព្រះសាស្ដាព្រះនាមសិទ្ធត្ថ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងអនោមារាម ព្រះស្តូបដ៏ប្រសើរនោះនៃព្រះលោកនាយកនោះ មានកម្ពស់ ៤ យោជន៍ ប្រតិស្ឋានទៅក្នុងអនោមារាមនោះឯង ។

ចប់ សិទ្ធត្ថពុទ្ធវង្សទី ១៦

## តិស្សពុទ្ធវង្សទី ១៧

ក្រោយពីព្រះពុទ្ធ ព្រះនាមសិទ្ធត្ថមក មានព្រះពុទ្ធ ព្រះនាមតិស្សៈ ជានាយកដ៏ប្រសើរក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មានយសរាប់ពុំបាន ទ្រង់មានសេចក្ដីអាណិតអាសូរ មានព្យាយាមធំ មានបញ្ញាចក្ខុ ទ្រង់

កើតឡើងក្នុងលោក កម្ចាត់បង់ងងឹតអន្ធការ ញ៉ាំងលោកនេះ ព្រមទាំងទេវលោកឲ្យភ្លឺស្វាងហើយ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានឫទ្ធិឬងពុំបានមានសីល សមាធិឬងពុំបាន ព្រះអង្គសម្រេចនូវបារមីក្នុងធម៌ទាំងពួងហើយទ្រង់ញ៉ាំងចក្រ គឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះ ទ្រង់បញ្ចេញព្រះសូរសៀងដ៏ជ្រះស្អាតល្អ ក្នុងលោកធាតុមួយម៉ឺន ពួកសត្វទាំងមួយរយកោដិ សឹងបានត្រាស់ដឹង ក្នុងការសម្តែងធម៌លើកទី ១ ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៦០ កោដិ ពេលនោះ ព្រះសម្មាសម្ពុទ្ធនោះទ្រង់ដោះមនុស្ស និងទេវតា ដែលមកដល់ឲ្យរួចចាកចំណង គឺមារ ។ ព្រះតិស្សមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធសឹងតែជាពួកព្រះខីណាស្រព មិនមានមន្ទិល គឺកិលេស មានចិត្តស្ងប់រំងាប់ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រពមួយសែនអង្គ សន្និបាតលើកទី ២ មានព្រះខីណាស្រព ៩០ សែនអង្គ ។ សន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ សែនអង្គ សុទ្ធតែជាអ្នកអស់អាសវៈ ឥតមានមន្ទិល គឺកិលេស រីកហើយដោយវិមុត្តិ ។ គ្រានោះ តថាគត ជាក្សត្រនាម សុជាតៈ លះបោលភោគៈដ៏ច្រើន

ហើយទៅបួសជាឥសី ។ កាលដែលតថាគតបួសស្រេចហើយ ព្រះលោកនាយកទ្រង់កើតឡើង តថាគតកើតមានបីតិ ព្រោះបានស្តាប់សំឡេងថាព្រះពុទ្ធ ។ តថាគតបានកាន់ផ្កាមន្ទារវព្រឹក្ស ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ដោយដៃទាំងពីរ ជជុះរលាស់ហើយចូលទៅគាល់ ។ តថាគតកាន់ផ្កានោះ បាំងលើព្រះសិរ្សនៃព្រះជិនស្រី ព្រះនាមតិស្សៈ ជាលោកនាយក ដែលមានបរិស័ទ ៤ ចោមរោម ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់កណ្តាលប្រជុំជន ហើយព្យាករតថាគតកាលនោះថា ក្នុងកប្បទី ៩២ អំពីមណ្ឌកប្បនេះទៅ តាបសនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ។ សត្វនេះនឹងចេញពីបុរីឈ្មោះកបិលពស្តុ ជាទីត្រេកអរ ទៅតម្កល់សេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសនៅត្រង់ទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះលោកនាយកអង្គនោះ បានសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពុទ្ធនេះ ព្រះនាម មាយា ព្រះបិតា

ព្រះនាម សុទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមាន អាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ភិក្ខុ ជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ ។ នាងខេមាថេរី ១ នាងឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើ សម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ នន្ទមាតា ឧបាសិកា ១ ឧត្តរាឧបាសិកា ១ ជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតាបានស្ដាប់នូវព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ឥតមាន បុគ្គលស្មើហើយ ក៏រីករាយថា តាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតាទាំងមួយម៉ឺន លោកធាតុ នាំគ្នាទះដៃអបអរសាទរ ធ្វើអញ្ជលីនមស្ការថា បើយើង ឃ្លាងមគ្គផល ក្នុងសាសនាព្រះសម្ពុទ្ធអង្គនេះ យើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ក្នុងកាលជាអនាគតមិនខាន ។

ពួកមនុស្សក្រាលច្ងួងស៊ឹង បើឃ្វាងកំពង់ចំពោះមុខ គង់នឹងកាន់យក កំពង់ខាងក្រោម ហើយចូងស៊ឹងជំពុន យ៉ាងណា ពួកយើងទាំងអស់គ្នា បើឃ្វាងព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះគោតមនោះ ក្នុងកាលជាអនាគត យ៉ាងនោះដែរ ។ តថាគត លុះបានស្តាប់នូវព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះហើយ ធ្វើចិត្ត ឲ្យរីងរឹតតែជ្រះថ្លាថែមទៀត ខំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមី ទាំង ១០ ។ ព្រះមហេសី ព្រះនាមតិស្សៈ មានទីក្រុងឈ្មោះខេមកៈ មានព្រះមហាក្សត្រ ព្រះនាមជនសន្ធៈ ជាព្រះបិតា មានព្រះជននី ព្រះនាម បទុមា ។ ព្រះតិស្សៈនោះ ទ្រង់គ្រប់គ្រងព្រះរាជគេហដ្ឋាន អស់ ៧ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះ គុណសេលៈ ១ ប្រាសាទឈ្មោះអនាទិយៈ ១ ប្រាសាទឈ្មោះនិសភៈ ១ ។ ពួកនារីចំនួន ៣ ម៉ឺននាក់ សុទ្ធសឹងតែតាក់តែងខ្លួនល្អ ឯនាងនារី ជាអគ្គមហេសីនោះ ព្រះនាមសុភទ្រា ព្រះរាជបុត្រព្រះនាម អានន្ទ ។ ព្រះជិនស្រី ទ្រង់ឃើញនិមិត្ត ៤ ហើយ ស្តេចយាងចេញទៅបព្វជ្ជា ដោយសេះជាយាន ទៅតម្កល់ព្យាយាមអស់កាលកន្លះខែគត់ ។ ព្រះលោកនាយក ព្រះនាមតិស្សៈប្រសើរក្នុងលោក មានព្យាយាមធំ

ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រ គឺធម៌ឲ្យប្រព្រឹត្តទៅ ក្នុងយសវតីទាយវនដ៏ឧត្តម ។ ព្រះព្រហ្មទេវត្ថេរ ១ ព្រះឧទយត្ថេរ ១ ជាអគ្គសាវក ភិក្ខុឈ្មោះសមគៈ ជាឧបដ្ឋាក នៃព្រះមហេសីព្រះនាម តិស្សៈ ។ នាងផុស្សាថេរី ១ នាងសុទត្តាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានជោគអង្គនោះ ហៅថា អសនព្រឹក្ស ( ដើមធ្នង់ ) ។ សម្ពលគហបតី ១ សិរិគហបតី ១ ជាអគ្គឧបដ្ឋាក កីសាគោតមីឧបាសិកា ១ ឧបសេនាឧបាសិកា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះភគវាសម្ពុទ្ធនោះឯង ទ្រង់មានកម្ពស់ ៦០ ហត្ថ ឥតមានបុគ្គល ប្រៀបផ្ទឹមបាន ឥតមានបុគ្គលស្មើបាន ប្រាកដដូចភ្នំហិមពាន្ត ។ ព្រះជិនស្រីអង្គនោះ ទ្រង់មានតេជះប្រឹងពុំបាន ទ្រង់មានព្រះជន្មាយុ មួយសែនឆ្នាំ ព្រះអង្គមិនមានបុគ្គលក្រៃលែងជាង ទ្រង់មានចក្ខុស្ថិត នៅក្នុងលោក ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវក ទ្រង់សោយនូវ យសធំ ដ៏ឧត្តមដ៏ប្រសើរ រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវក ទ្រង់បរិនិព្វានហើយ ដូចជាភ្លៀង ( ដែលបាត់ទៅ ) ព្រោះខ្យល់ ឬដូចទឹកសន្សើម ( អស់ទៅ ) ព្រោះ ព្រះអាទិត្យ ឬដូចងងឹត ( បាត់ទៅ ) ព្រោះប្រទីប ។ ព្រះពុទ្ធព្រះនាម

តិស្សៈ ជាព្រះភគវាដ៏ប្រសើរ បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបព្រះមុនី អង្គនោះ ពួកមហាជនសាងទុកកម្ពស់ ៣ យោជន៍ ក្នុងនន្ទារាម ។

ចប់ តិស្សពុទ្ធវង្សទី ១៧

# ផុស្សពុទ្ធវង្សទី ១៨

ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តា ព្រះនាមផុស្សៈ ទ្រង់មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ជាលោកនាយកដ៏ប្រសើរ នៅក្នុងលោក ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ ហើយដោះគ្រឿងចាក់ស្រេះធំ ( កិលេស ) ទ្រង់ញ៉ាំងមនុស្ស ព្រមទាំងទេវតា ឲ្យឆ្អែតស្កប់ស្កល់ ទ្រង់បង្អុរភ្លៀងទឹកអម្រឹតចុះមក ។ កាលព្រះពុទ្ធព្រះនាមផុស្សៈ ញ៉ាំងចក្រ គឺធម៌ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វ ៨០ សែន នៅក្នុងមណ្ឌលនៃថ្ងៃនក្ខត្តឫក្ស ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ សែន ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ សែន ។ ព្រះមហេសីព្រះនាមផុស្សៈ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព

ឥតមានមន្ទិល គឺកិលេស មានចិត្តស្ងប់រំងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រព ៦០ សែន សន្និបាតលើកទី ២ មានព្រះខីណាស្រព ៥០ សែន សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រព ៤០ សែន លោកផុតស្រឡះហើយ ព្រោះមិនប្រកាន់មានតំណ គឺជាតិកាត់ផ្តាច់ហើយ ។ សម័យនោះ តថាគត ជាក្សត្រព្រះនាមវិជិតៈ លះបោលរាជសម្បត្តិដ៏ធំ ទៅបួសនៅក្នុងសម្នាក់ព្រះពុទ្ធនោះ ។ ព្រះពុទ្ធជាម្ចាស់ ព្រះនាមបុស្សៈ ជានាយកនោះបានទ្រង់ព្យាករតថាគតថា ក្នុងកប្បទី ៩២ អំពីកប្បនេះទៅ ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញអំពីក្រុងកបិលពស្តុបុរីជាទីរីករាយ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះលោកនាយកអង្គនោះ បានសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចទៅឯគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់ នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះលោកនាថអង្គនោះ ព្រះនាមមាយា

ព្រះបិតាព្រះនាម សុទ្ធោទនៈ ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធព្រះនាម គោតម ។ ព្រះកោលិតៈ ១ ឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះ អានន្ទ នឹងបម្រើព្រះលោកនាយកអង្គនោះ ។ ខេមាភិក្ខុនី ១ ឧប្បលវណ្ណាភិក្ខុនី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតាលុះបានស្តាប់ព្រះពុទ្ធដីកានេះនៃព្រះមហេសី ឥតមានបុគ្គលស្មើហើយក៏រីករាយថា ភិក្ខុនេះជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះសាស្តាជានាយកអង្គនេះ គង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនោះ ក្នុងកាលជាអនាគតមិនខាន ។ ចំណែកខាងតថាគត

បានស្តាប់ព្រះពុទ្ធដីកា នៃព្រះបុស្សសម្ពុទ្ធនោះហើយ ក៏បានញ៉ាំងចិត្ត ឲ្យរីងរឹតតែជ្រះថ្លា ហើយខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមី ទាំង ១០ ប្រការ ។ តថាគតរៀនយកនូវព្រះសូត្រផង នូវព្រះវិន័យផង ពាក្យប្រៀនប្រដៅព្រះសាស្តា ប្រកបដោយអង្គ ៩ ទាំងអស់ផង ហើយញ៉ាំងសាសនាព្រះទសពល ឲ្យរុងរឿង ។ តថាគតមិនប្រមាទ សម្រេចសម្រាន្តនៅក្នុងសាសនានោះ ខំចម្រើនភាវនា ដែលប្រកប ដោយព្រហ្មវិហារហើយ ដល់នូវបារមីក្នុងអភិញ្ញាទាំងឡាយ ហើយ ទៅកើតក្នុងព្រហ្មលោក ។ ព្រះមុនីព្រះនាមបុស្សៈ មានទីក្រុងឈ្មោះ កាសិកៈ មានមហាក្សត្រ ព្រះនាមជ័យសេន ជាព្រះបិតា ព្រះជននី ព្រះនាមសិរិមា ។ ព្រះបុស្សៈនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះគរុឡ្ហៈ ១ ប្រាសាទឈ្មោះហំសៈ ១ ប្រាសាទឈ្មោះសុវណ្ណតារៈ ១ ។ ពួកនារី ២៣ ពាន់ សឹងមានខ្លួនតាក់តែងល្អហើយ ឯនារីជាអគ្គមហេសីឈ្មោះ កីសាគោតមី ព្រះរាជបុត្រព្រះនាម អានន្ទ ។ ព្រះជិនស្រី ជាបុរស ដ៏ប្រសើរ ទ្រង់ទតឃើញនិមិត្តទាំង ៤ យ៉ាងហើយ ចេញទៅបព្វជ្ជា ដោយដំរីជាយាន បានប្រព្រឹត្តធ្វើព្យាយាមអស់ ៧ ថ្ងៃ ។ ព្រះសម្ពុទ្ធ

ព្រះនាមបុស្សៈ មានព្យាយាមធំ ទ្រង់ប្រសើជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រ គឺធម៌ឲ្យប្រព្រឹត្តទៅនាព្រៃមិគទាយវ័ន ។ ព្រះសុរក្ខិតភិក្ខុ ១ ព្រះធម្មសេនភិក្ខុ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសភិយ្យៈ ជាឧបដ្ឋាកនៃព្រះមហេសី ព្រះនាមបុស្សៈ ។ នាងចាលាភិក្ខុនី ១ នាងឧបចាលាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងនៃព្រះសាស្ដាអង្គនោះ ហៅថា អាមលកព្រឹក្ស (ដើមកន្ទួតព្រៃ) ។ អនញ្ជគហបតី ១ វិសាខគហបតី ១ ជាអគ្គឧបដ្ឋាក នាងបទុមា ១ នាងសិរិនាគា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមុនីអង្គនោះ មានកម្ពស់ ៥៨ ហត្ថ ទ្រង់រុងរឿងដូចព្រះអាទិត្យ ឬដូចព្រះច័ន្ទពេញវង់ ។ ទ្រង់មានព្រះជន្មាយុ ៩០ ពាន់ឆ្នាំ ព្រះសាស្ដាកាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនជាច្រើន ។ ព្រះលោកនាថអង្គនោះ ព្រមទាំងសាវ័កទ្រង់មានយសប្រឹងពុំបាន ទ្រង់ទូន្មានពួកសត្វជាច្រើន ហើយចម្លងពួកសត្វជាច្រើន រួចបរិនិព្វាន ។ ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមបុស្សៈ ទ្រង់ជាសាស្ដា បរិនិព្វានហើយ ក្នុងសេនារាម ការផ្សាយចេញទៅនៃព្រះធាតុ មាននៅក្នុងប្រទេសទាំងឡាយនោះៗ ។

ចប់ បុស្សពុទ្ធវង្សទី ១៨

# ទិវសិព្វពុទ្ធវង្សទី ១៩

ក្រោយអំពីព្រះពុទ្ធ ព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធព្រះនាម វិបស្សី ដ៏ឧត្តមជាងសត្វជើងពីរ ទ្រង់មានចក្ខុកើតឡើងនៅក្នុងលោក ។ ព្រះសម្ពុទ្ធទ្រង់រំលាយស៊ុត គឺអវិជ្ជាចេញ ហើយដល់សម្ពោធិញ្ញាណ ដ៏ឧត្តម ព្រះអង្គចៀសចេញទៅកាន់ពន្ធុមតីបុរី ដើម្បីញ៉ាំងចក្រ គឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះនាយក ទ្រង់ញ៉ាំងចក្រ គឺធម៌ឲ្យប្រព្រឹត្តតទៅ រួចហើយញ៉ាំងខណ្ឌរាជកុមារ និងតិស្សកុមារទាំងពីរ ឲ្យត្រាស់ដឹង ការត្រាស់ដឹងលើកទី ១ មានចំនួនសត្វ គេមិនគប្បីពោល ដោយការ រាប់ឡើយ ។ តមកទៀត ព្រះពុទ្ធជាម្ចាស់មានយសរាប់មិនបានប្រកាស សច្ចៈទាំង ៤ ក្នុងបុរីនោះ ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួន ៨ ម៉ឺន ៤ ពាន់ ។ មានមនុស្ស ៨ ម៉ឺន ៤ ពាន់ បួសតាមព្រះពុទ្ធ ព្រះពុទ្ធមានចក្ខុ ទ្រង់សម្តែងព្រះធម៌ដល់បព្វជិតទាំងនោះ ដែលមក ដល់អារាម ។ ភិក្ខុទាំងនោះ អាស្រ័យព្រះជិនស្រី កាលទ្រង់សម្តែង ដោយអាការទាំងពួង ក៏បានសម្រេចនូវធម៌ដ៏ប្រសើរ នេះជាការ ត្រាស់ដឹងលើកទី ៣ ។ ព្រះមហេសី ព្រះនាមវិបស្សី មានសាវក

សន្និបាត ៣ លើក ដែលសុទ្ធតែពួកព្រះខីណាស្រព ឥតមានមន្ទិល គឺកិលេស មានចិត្តស្ងប់រំងាប់ ប្រកបដោយតាទិគុណ ។ គឺសន្និបាតលើកទី ១ មានពួកព្រះខីណាស្រពចំនួន ៦៨ សែន សន្និបាតលើកទី ២ មានពួកព្រះខីណាស្រពចំនួនមួយសែន ។ សន្និបាតលើកទី ៣ មានភិក្ខុចំនួន ៨ ម៉ឺន ព្រះសម្ពុទ្ធរុងរឿង ក្នុងកណ្ដាលពួកភិក្ខុនោះ ។ សម័យនោះ តថាគតកើតជាស្ដេចនាគឈ្មោះ អតុលៈ មានឫទ្ធិច្រើន មានបុណ្យ ទ្រទ្រង់ពន្លឺ ។ ក្នុងកាលនោះ តថាគត មានពួកនាគច្រើនកោដិចោមរោម ប្រគំតូរ្យតន្ត្រីដ៏ជាទិព្វ ហើយចូលទៅជិតព្រះលោកជេដ្ឋៈ ។ លុះចូលទៅដល់ហើយ ក៏និមន្តព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ហើយថ្វាយតាំងមាស ដែលដាំដោយកែវមណី និងកែវមុក្តា ដ៏ស្អិតស្អាងហើយ ដោយអាភរណៈគ្រប់យ៉ាងដល់ព្រះអគ្គជាធម្មរាជ ។ ព្រះសម្ពុទ្ធជាម្ចាស់នោះ ទ្រង់គង់នៅក្នុងកណ្ដាលសង្ឃ ហើយព្យាករតថាគតថា ក្នុងកប្បទី ៩១ អំពីមណ្ឌកប្បនេះ ស្ដេចនាគនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញពីកបិលពស្តុបុរីជាទីត្រេកអរ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅ

កាន់ស៊ីងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាសទៀប ឆ្នេរស៊ីងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះលោកនាថមានយសដ៏ធំ ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយត្រាស់ដឹងនូវសម្ពោធិញ្ញាណ ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពុទ្ធនោះព្រះនាម មាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្ត តាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ ។ នាងខេមាភិក្ខុនី ១ នាងឧប្បលវណ្ណាភិក្ខុនី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្ត តាំងមាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានជោគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះមហេសី ព្រះនាមគោតមនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និង ទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះនៃព្រះមហេសី ឥតមានបុគ្គលស្មើ

ហើយ រីករាយថា នាគរាជនេះជាពូជពន្ធុកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នា ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាយកអង្គនេះ គង់នឹងសម្រេចក្នុងទីចំពោះ ព្រះភក្ត្រនៃព្រះគោតមនោះ ក្នុងកាលជាអនាគតមិនខាន ។ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងដ៏ធំបាន យ៉ាងណា ។ ពួកយើងទាំងអស់គ្នា បើឃ្លាង ព្រះមុនីអង្គនេះ គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនោះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ចំណែកខាងតថាគតបានស្តាប់ ព្រះពុទ្ធដីកានៃព្រះទសពលនោះហើយ ក៏ញុំាងចិត្តឲ្យរីងរឹតតែជ្រះថ្លា ហើយខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។ ព្រះមហេសីព្រះនាមវិបស្សី មានទីក្រុងឈ្មោះពន្ធុមតី មានមហាក្សត្រ ព្រះនាម ពន្ធុម: ជាព្រះបិតា មានព្រះជននីព្រះនាម ពន្ធុមតី ។ ព្រះវិបស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់ ៨ ពាន់ឆ្នាំ មានប្រាសាទ ដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះនន្ទ: ១ ប្រាសាទឈ្មោះសុនន្ទ: ១ ប្រាសាទឈ្មោះសិរិម: ១ ។ ពួកនារីចំនួន ៤ ម៉ឺន ៣ ពាន់ សឹងមានខ្លួន

តាក់តែងល្អហើយ ឯនារីជាអគ្គមហេសីព្រះនាមសុទស្សនា ព្រះរាជបុត្រ ព្រះនាមសមវត្តក្ខន្ធ ។ ព្រះជិនស្រីជាបុរសដ៏ប្រសើរ ទ្រង់ទតឃើញ និមិត្តទាំង ៤ យ៉ាងហើយចេញទៅបព្វជ្ជាដោយរថជាយាន បានប្រព្រឹត្ត ធ្វើព្យាយាមអស់ ៨ ខែគត់ ។ ព្រះលោកនាយក ព្រះនាមវិបស្សី មានព្យាយាមធំ ទ្រង់ប្រសើរជាងជន ត្រូវមហាព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រ គឺធម៌ ឲ្យប្រព្រឹត្តទៅ នៅក្នុងព្រៃមិគទាយវ័ន ។ ព្រះរាជកុមារនាមខន្ធៈ ១ បុត្រនៃបុរោហិតនាមតិស្សៈ ១ បានជាអគ្គ-សាវក ភិក្ខុឈ្មោះអសោកៈ ជាឧបដ្ឋាក នៃព្រះមហេសី ព្រះនាម វិបស្សី ។ នាងចន្ទាភិក្ខុនី ១ នាងចន្ទមិត្តាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា បាដលិព្រឹក្ស ។ បុនព្វសុមិត្តគហបតី ១ នាគគហបតី ១ ជាអគ្គឧបដ្ឋាក នាងសិរិមា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះវិបស្សីជានាយក មានកម្ពស់ ៨០ ហត្ថ ពន្លឺព្រះអង្គផ្សាយចេញទៅជុំវិញ ៧ យោជន៍ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ព្រះលោកនាយក កាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនច្រើន ចាកសង្សារវដ្ត ។ ព្រះពុទ្ធអង្គទ្រង់ដោះស្រាយ នូវចំណងនៃទេវតា និងមនុស្សជាច្រើន

ទាំងប្រាប់ផ្លូវត្រូវ ផ្លូវខុស ចំពោះពួកបុថុជ្ជនដ៏សេសទៀតផង ។ព្រះអង្គ ព្រមទាំងសាវ័ក ទ្រង់សម្តែងពន្លឺ ហើយបង្ហាញឧបាយជាទីទៅកាន់ ព្រះនិព្វានឈ្មោះអមតៈ ទ្រង់រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះសរីរៈដែលមានឫទ្ធិដ៏ខ្ពង់ខ្ពស់ មានបុណ្យដ៏ប្រសើរ ប្រជាប់ហើយ ដោយលក្ខណៈ គឺចក្រ គង់បាត់បង់អស់ទៅបាន ឱហ្ន៎ ! សង្ខារទាំងពួង សោះសូន្យទេតើ ! ព្រះវិបស្សីជានរៈដ៏ប្រសើរ ទ្រង់មានព្យាយាម បរិនិព្វានហើយ នៅក្នុងសុមិត្តារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះអង្គ នោះ គេបានសាងទុក កម្ពស់ ៧ យោជន៍ ក្នុងអារាមនោះ ។

ចប់វិបស្សីពុទ្ធវង្សទី ១៩

# សិខីពុទ្ធវង្សទី ២០

ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាមសិខីជិនស្រី ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀប-ផ្ទឹមបាន ។ ព្រះអង្គកម្ចាត់បង់សេនានៃមារ ហើយដល់សម្ពោធិញ្ញាណ ដ៏ប្រសើរ ញ៉ាំងចក្រ គឺធម៌ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីអនុគ្រោះ ដល់ពួកសត្វ ។ កាលព្រះជិនស្រីសិខីដ៏ប្រសើរ ទ្រង់ញ៉ាំងធម្មចក្រ

ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ។ កាលព្រះសិខីប្រសើរជាងគណៈ ឧត្តមជាងជន ទ្រង់សម្ដែងធម៌ដទៃទៀត ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួន ៩០ ពាន់កោដិ ។ កាលព្រះសិខីទ្រង់សម្ដែងយមកប្បាដិហារ្យ ក្នុងមនុស្សលោកព្រមទាំងទេវលោក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ ពាន់កោដិ ។ ព្រះមហេសីព្រះនាមសិខី មានសាវកសន្និបាត ៣ លើកដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រំងាប់ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានភិក្ខុចំនួនមួយសែនរូប សន្និបាតលើកទី ២ មានពួកភិក្ខុចំនួន ៨ ម៉ឺនរូប ។ សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៧ ម៉ឺនរូប ជាសមាគមមិនប្រឡាក់ ( ដោយពួកបុថុជ្ជន ) ដូចបទុមជាតិដែលលូតលាស់នៅក្នុងទឹក ។ សម័យនោះតថាគតជាក្សត្រនាមអរិន្ទមៈ បានញុំាងព្រះសង្ឃ មានព្រះលោកនាថជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ។ តថាគតបានប្រគេនសំពត់ជាច្រើន គឺកោដិនៃសំពត់មិនតិច ហើយថ្វាយយានដំរីដ៏ប្រដាប់ហើយដល់ព្រះសម្ពុទ្ធ ។ តថាគតសាងយានដំរី ហើយបង្អោនចូលទៅជិតឲ្យជារបស់គួរ បំពេញចិត្តរបស់តថាគត ឲ្យតម្កល់នៅមាំ

អស់កាលជានិច្ច ។ ព្រះពុទ្ធព្រះនាមសិខីជានាយកនោះ ទ្រង់ព្យាករ តថាគតថា ក្នុងកប្បទី ៣១ អំពីមណ្ឌកប្បនេះ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញអំពីក្រុងកបិលពស្តុបុរី ជាទីរីករាយ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលយកបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះពុទ្ធនោះ នឹងមានជនេះជននី ព្រះនាម មាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ ព្រះរាជាអង្គនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ។ នាងខេមាភិក្ខុនី ១ នាងឧប្បលវណ្ណាភិក្ខុនី ១ ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្ត

តម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះសម្ពុទ្ធអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះលោកនាថ ឥតមានបុគ្គលស្មើ ហើយរីករាយថា ព្រះរាជាអង្គនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ នាំគ្នា ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាយកអង្គនេះ គង់នឹងបានសម្រេចក្នុងទី ចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនោះ ក្នុងអនាគតកាលមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ខាងលើ គង់ទៅកាន់យក កំពង់ខាងក្រោម ហើយឆ្លងស្ទឹងបាន យ៉ាងណាមិញ ។ ពួកយើងទាំង អស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចក្នុងទីចំពោះ ព្រះភក្ត្រនៃព្រះគោតមអង្គនោះ យ៉ាងនោះដែរ ។ ឯតថាគតលុះបានស្តាប់ ព្រះពុទ្ធដីកានៃព្រះអង្គនោះហើយ រីងរឹតតែធ្វើចិត្តឲ្យជ្រះថ្លា ហើយបានទំ អធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។ ព្រះមហេសី

ព្រះនាមសិខី មានទីក្រុងឈ្មោះអរុណវតី មានព្រះមហាក្សត្រព្រះនាម អរុណៈ ជាព្រះបិតា មានព្រះជននី ព្រះនាមបភាវតី ។ ព្រះអង្គ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់ ៧ ពាន់ឆ្នាំ ទ្រង់មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះសុវឌ្ឍកៈ ១ ប្រាសាទឈ្មោះគិរី ១ ប្រាសាទ ឈ្មោះនារីវាហនៈ ១ ។ ពួកនារី ២ ម៉ឺន ៤ ពាន់ សុទ្ធឹងមានខ្លួន តាក់តែងល្អហើយ ឯនាងនារីជាអគ្គមហេសីនោះ ព្រះនាមសព្វកាមា ព្រះរាជបុត្រ ព្រះនាមអតុលៈ ។ ( ព្រះតថាគត ) ជាបុរសដ៏ឧត្តម ទ្រង់ឃើញនិមិត្តទាំង ៤ ហើយ ចេញទៅបព្វជ្ជាដោយដំរីជាយាន បាន ប្រព្រឹត្តធ្វើព្យាយាមអស់ ៨ ខែគត់ ។ ព្រះសិខីលោកនាថ មានព្យាយាម ដ៏ធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន ។ ព្រះសម្ពុទ្ធព្រះនាមសិខី មានអភិភូភិក្ខុ ១ សម្ភវភិក្ខុ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះខេមង្ករៈ ជាឧបដ្ឋាក ។ នាង មខិលាភិក្ខុនី ១ នាងបទុមាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើជាទី ត្រាស់ដឹង នៃព្រះសម្ពុទ្ធអង្គនោះ ហៅថា បុណ្ឌរីកព្រឹក្ស ( ដើម ស្វាយ-ស ) ។ សិរិវឌ្ឍគហបតី ១ នន្ទគហបតី ១ ជាអគ្គឧបដ្ឋាក នាងចិត្តា ១ នាងសុចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធអង្គនោះ

ទ្រង់មានកម្ពស់ ៧០ ហត្ថ ប្រាកដស្មើដោយគ្រឿងមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ព្រះពុទ្ធជាម្ចាស់អង្គនោះ មានពន្លឺប្រមាណមួយព្យាម ផ្សាយចេញអំពីព្រះកាយជានិច្ច ផ្សាយចេញទៅកាន់ទិសតូចនិងទិសធំ ក៏ចេញទៅចម្ងាយ ៣ យោជន៍ ។ ព្រះមហេសីអង្គនោះមានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ព្រះសម្ពុទ្ធកាលទ្រង់គង់ធរមាននៅឡើយបានញ៉ាំងប្រជុំជនជាច្រើនឲ្យឆ្លង ( ត្រើយសង្សារវដ្ត ) ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក បន្ទរនូវភ្លៀង គឺធម៌ ស្រោចស្រពផ្សើមពួកមនុស្ស ព្រមទាំងទេវតា ធ្វើឲ្យដល់នូវសភាពក្សេមក្សាន្ត ហើយបរិនិព្វាន ។ ព្រះសរីរៈបរិបូណ៌ដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ គង់បាត់បង់សូន្យទាំងអស់ ឱ ! សង្ខារទាំងពួងជារបស់ទទេ ។ ព្រះសិខីសម្ពុទ្ធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអស្សារាម ព្រះស្តូបដ៏ប្រសើរ នៃព្រះអង្គនោះ គេបានសាងទុកកម្ពស់ ៣ យោជន៍ ក្នុងទីនោះឯង ។

**ចប់ សិខីពុទ្ធវង្សទី ២០**

# វេស្សភូពុទ្ធវង្សទី ២១

ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រីព្រះនាមវេស្សភូ ព្រះអង្គ មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើង ក្នុងលោក ។ ព្រះជិនស្រីនោះ កាលជ្រាបច្បាស់នូវលោកទាំង ៣ នេះ ដែលឆេះសព្វដោយភ្លើង គឺរាគៈផង នូវដែននៃតណ្ហាទាំងឡាយផង ទ្រង់កាត់នូវចំណងដូចដំរីដ៏ប្រសើរ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះវេស្សភូ ជាលោកនាយក ទ្រង់សម្តែងធម្មចក្រ មានពួកបរិស័ទ ចំនួន ៨០ ពាន់កោដិ បានត្រាស់ដឹង ក្នុងគ្រាជាដំបូង ។ កាលដែល ព្រះលោកជេដ្ឋៈប្រសើរជាងពួកនរជន ចៀសចេញទៅកាន់ចារិក ក្នុងដែន មានពួកបរិស័ទចំនួន ៧០ ពាន់កោដិ បានត្រាស់ដឹងក្នុងគ្រា ទី ២ ។ ព្រះជិនស្រីអង្គនោះ ទ្រង់បន្ទោបង់នូវមហាទិដ្ឋិ ហើយធ្វើនូវ បាដិហារ្យ ពួកមនុស្ស និងទេវតា ក្នុងមួយម៉ឺនលោកធាតុ ព្រមទាំង ទេវលោក ក៏បានមកប្រជុំគ្នា ។ ពួកទេវតា និងមនុស្ស ចំនួន ៦០ កោដិ ឃើញហេតុអស្ចារ្យធំចម្លែក ជាទីព្រឺរោមហើយ ក៏បានត្រាស់ដឹង ( ក្នុងគ្រាទី ៣) ។ ព្រះលោកនាថព្រះនាមវេស្សភូ ស្វែងរកគុណដ៏ធំ

មានសាវកសន្និបាត ៣ លើក សុទ្ធតែព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រំងាប់ មានចិត្តនឹងធឹង ។ គឺសន្និបាតលើកទី ១ មានភិក្ខុចំនួន ៨០ ពាន់កោដិ សន្និបាតលើកទី ២ មានភិក្ខុចំនួន ៧០ ពាន់កោដិ ។ សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៦០ ពាន់កោដិ ដែលភ័យតក់ស្លុតអំពីទុក្ខ មានជរាជាដើម ជាឱរសរបស់ព្រះពុទ្ធ ស្វែងរកនូវគុណដ៏ធំ ។ កាលព្រះសម្ពុទ្ធ មិនមានបុគ្គលស្មើអង្គនោះ ទ្រង់សម្តែងធម្មចក្រដ៏ឧត្តម សម័យនោះ តថាគត ជាក្សត្រឈ្មោះ សុទស្សនៈ បានស្តាប់នូវធម៌ដ៏ប្រសើរហើយ ក៏ពេញចិត្តនឹងផ្នួសយ៉ាងក្រៃលែង បានបូជានូវព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ដោយបាយទឹក និងសំពត់ ។ តថាគតញុំាងមហាទានឲ្យប្រព្រឹត្តទៅ ជាអ្នកមិនខ្ជិលទាំងយប់ទាំងថ្ងៃ ហើយចូលទៅកាន់ផ្នួស ដែលបរិបូណ៌ទៅដោយគុណ ក្នុងសម្នាក់ព្រះជិនស្រី ។ តថាគតបរិបូណ៌ដោយអាចារគុណ មានចិត្តតម្កល់ខ្ជាប់ក្នុងវត្ត និងសីល ស្វែងរកនូវសព្វញ្ញុតញ្ញាណ ត្រេកអរនៅក្នុងសាសនានៃព្រះជិនស្រី ។ តថាគតញុំាងសទ្ធា និងបីតិឲ្យកើតឡើង ហើយថ្វាយបង្គំព្រះសម្ពុទ្ធជាសាស្តា បីតិរបស់តថាគតក៏កើតឡើង ព្រោះហេតុនៃការត្រាស់ដឹង ។ ព្រះមុនីទ្រង់ជ្រាបចិត្តមិនវិលត្រឡប់ ហើយទ្រង់ត្រាស់ថា

ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្សត្រនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញពីក្រុងកបិលពស្តុ ដែលជាទីរីករាយ ហើយតាំងនូវសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយ ទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានឆាន់បាយាសក្បែរឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែង ។ លំដាប់នោះ ព្រះលោកនាថមានយសធំ ធ្វើប្រទក្សិណនូវពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាព្រះពុទ្ធអង្គនោះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ស្តេចនេះនឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈពីរអង្គ គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនោះ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ដើមឈើជាទីត្រាស់ដឹង របស់ព្រះមុនីអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះ ចិត្តគហបតី ១

ហត្ថាឡវកគហបតី ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះ នន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះសម្ពុទ្ធព្រះនាម គោតម មានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកទេវតា និងមនុស្ស បានស្ដាប់នូវព្រះពុទ្ធដីកានេះ របស់ព្រះលោកនាយក ទ្រង់ស្វែងរកបុគ្គលស្មើគ្មាន ស្វែងរកគុណដ៏ធំហើយ ក៏រីករាយថា ក្សត្រនេះជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតា ទាំង មួយម៉ឺនលោកធាតុ មានសំឡេងហ៊ោឡើង នាំគ្នាទះដៃអបអរសាទរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះសម្ពុទ្ធអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះភគវា អង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយ ឆ្លងស្ទឹងធំបាន យ៉ាងណា ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រី អង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្ដាអង្គនោះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ តថាគត បានស្ដាប់នូវព្រះ ពុទ្ធដីកា នៃព្រះលោកនាថនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានទំអធិដ្ឋានវត្តតទៅ ដោយការបំពេញបារមីទាំង ១០ ។ ព្រះវេស្សភូសម្ពុទ្ធ

ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះអនោមៈ មានព្រះមហាក្សត្រ ព្រះនាម សុប្បតិតៈ ជាព្រះបិតា មានព្រះមាតា ព្រះនាម យសវតី ព្រះអង្គគង់នៅគ្រប់គ្រងព្រះរាជដំណាក់អស់ ៦ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ ខ្នង គឺរុចិប្រាសាទ ១ សុរតិប្រាសាទ ១ វឌ្ឍកប្រាសាទ ១ ។ ពួកនារីមិនខ្វះពី ៣០ ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសី ព្រះនាមសុចិត្តា ព្រះរាជបុត្រព្រះនាម សុប្បពុទ្ធ ។ ព្រះសម្ពុទ្ធជាបុរសដ៏ឧត្តម បានឃើញនូវនិមិត្ត ៤ យ៉ាង ស្តេចចេញទៅបព្វជ្ជាដោយ.រ ( អង្រឹង ) បានប្រព្រឹត្តព្យាយាម អស់ ៦ ខែ ។ ព្រះវេស្សភូជាលោកនាថ មានព្រះទ័យស្ងប់រំងាប់ មានចក្រ គឺធម៌ឲ្យប្រព្រឹត្តទៅ មានព្យាយាមធំ ឧត្តមជាងពពួកជន ត្រូវមហាព្រហ្មអារាធនាហើយ ក្នុងអរុណារាម ។ ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះសោណៈ ១ ឧត្តរៈ ១ ជាអគ្គសាវកព្រះថេរៈឈ្មោះឧបសន្តៈ ជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះរាមា ១ សមានា ១ ជាអគ្គសាវិកា ឯឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ គេតែងហៅថា មហាសាលព្រឹក្ស ។ ឧបាសកឈ្មោះ សោត្ថិកៈ ១ រម្មៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ គោតមី ១ សិរិមា ១

ជាអគ្គឧបដ្ឋាយិកា ។ រស្មីមានកម្ពស់ ៦០ ហត្ថ មានឧបមាស្មើដោយប្រាសាទមាស ផ្សាយចេញពីព្រះកាយ ដូចអណ្ដាតភ្លើងលើកំពូលភ្នំក្នុងវេលាយប់ ។ ព្រះលោកនាយក ទ្រង់ស្វែងរកនូវគុណដ៏ធំអង្គនោះ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ព្រះសាស្ដាស្ថិតនៅអស់កាលត្រឹមនោះ ញ៉ាំងប្រជុំជនជាច្រើនឲ្យឆ្លង (ចាកសង្សារ) ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ញែកធម៌ធ្វើឲ្យពិស្ដារ តម្កល់មហាជនក្នុងសំពៅគឺធម៌ ហើយបរិនិព្វាន ។ ជនទាំងអស់នោះ វិហារ និងឥរិយាបថជារបស់ដែលគេគប្បីរមិលមើល របស់ទាំងអស់នោះ វិនាសសាបសូន្យទៅអស់ ឱហ្ន៎! សង្ខារទាំងពួងជារបស់ទទេ ។ ព្រះជិនស្រីដ៏ប្រសើរព្រះនាមវេស្សភូ ជាសាស្ដាបរិនិព្វាន ក្នុងខេមារាម ព្រះធាតុផ្សាយទៅក្នុងប្រទេសនោះៗ ។

ចប់ វេស្សភូពុទ្ធវង្សទី ២១

# កកុសន្ធពុទ្ធវង្សទី ២២

ក្នុងកាលជាខាងក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មានព្រះមុនីព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មានគុណរាប់មិនបាន

គេគ្របសង្កត់បានដោយកម្រ ព្រះអង្គរំលើងនូវកពទាំងពួង ដល់នូវបារមីដោយចរិយា ហើយសម្រេចនូវពោធិញ្ញាណដ៏ឧត្តម ដូចសីហៈទម្លាយនូវទ្រុង ។ កាលព្រះកកុសន្ធៈ ជានាយក ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ មានពួកបរិស័ទចំនួន ៤ ម៉ឺនកោដិ បានត្រាស់ដឹង ក្នុងគ្រាដំបូង ។ ព្រះកកុសន្ធសម្ពុទ្ធ ទ្រង់ធ្វើនូវវិកុព្វនប្បាដិហារ្យ ជាគូៗ ពួដ៏អាកាស ញុំាងទេវតា និងមនុស្ស ៣ ម៉ឺនកោដិឲ្យត្រាស់ដឹង ( នេះជាការត្រាស់ដឹងលើកទី ២ ) ។ ក្នុងការប្រកាសចតុស្សច្ចធម៌ នៃព្រះពុទ្ធនោះ មានមនុស្សទេវតា និងយក្សត្រាស់ដឹងនូវធម៌ គេមិនអាចរាប់បាន ( នេះជាការត្រាស់ដឹងទី ៣ ) ។ ព្រះមានជោគព្រះនាមកកុសន្ធៈ មានសាវកសន្និបាតតែមួយដង សុទ្ធតែជាព្រះខីណាស្រព មិនមានមន្ទិល មានចិត្តស្ងប់រំងាប់មានចិត្តនឹងធឹង ។ សាវកសមាគមក្នុងកាលនោះ មានពួកព្រះខីណាស្រព ៤ ម៉ឺន ដែលដល់នូវទន្តភូមិ ( ភូមិនៃបុគ្គលអ្នកមានខ្លួនទូន្មានហើយ ) ព្រោះការអស់ទៅនៃកិលេស មានអាសវៈជាដើម ។ សម័យនោះ តថាគតជាក្សត្រឈ្មោះខេមៈ បានថ្វាយទានដ៏ច្រើន ចំពោះព្រះតថាគតនិងព្រះសង្ឃ ជាជិនបុត្រ ។ តថាគតបានចាត់ចែងថ្វាយ បាត្រ ចីវរ ថ្នាំបន្តក់ និងដើមឈើអែម ទាំងអស់នេះ ជារបស់ប្រសើរក្រៃពេក

ដែលតថាគតប្រាថ្នាហើយ ។ ព្រះភគវាកកុសន្ធៈ ជានាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងភទ្ទកប្បនេះ ក្សត្រនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញចាកក្រុងកបិលពស្តុ ដែលជាទីរីករាយ ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ នឹងសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចយាងសំដៅទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែង ។ លំដាប់នោះ ព្រះសាស្តា មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតានៃព្រះពុទ្ធនោះ ព្រះនាមមាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ ក្សត្រនេះជាព្រះពុទ្ធព្រះនាម គោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវក ព្រះថេរៈឈ្មោះ អានន្ទជាឧបដ្ឋាកបម្រើព្រះជិនស្រីនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវៈ ជាអ្នកប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវិកា ។ ដើមឈើជាទីត្រាស់ដឹងរបស់

ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះរបស់ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនមានបុគ្គលស្មើ ស្វែងរកនូវគុណដ៏ធំហើយ ក៏រីករាយថា ក្សត្រអង្គនេះជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោផង ទះដៃអបអរផង ធ្វើអញ្ជលីនមស្ការថា បើយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះសាស្តាអង្គនេះ យើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសម្ពុទ្ធអង្គនោះ ក្នុងកាលជាអនាគតមិនខាន ។ មនុស្សទាំងឡាយកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះលោកនាយកអង្គនេះហើយ គង់តែនឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតពុំខាន ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធនោះហើយ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាដ៏ក្រៃលែង បានអធិដ្ឋានវត្តតទៅ ដោយការបំពេញបារមី

ទាំង ១០ ។ កាលនោះ នគរឈ្មោះខេមវតី ឯតថាគតជាបុរសឈ្មោះខេមៈ ស្វែងរកនូវសព្វញ្ញុតញ្ញាណ បានបួសក្នុងសម្នាក់នៃព្រះពុទ្ធអង្គនោះ ។ ព្រះពុទ្ធព្រះនាមកកុសន្ធៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានអគ្គិទត្តព្រាហ្មណ៍ជាព្រះបិតា ព្រះមាតាព្រះនាមវិសាខា ។ មហាត្រកូលរបស់ព្រះសម្ពុទ្ធនៅក្នុងខេមបុរីនោះ ជាត្រកូលប្រសើរបំផុត មានជាតិខ្ពង់ខ្ពស់ មានយសធំ ជាងមនុស្សទាំងឡាយ ។ ព្រះកកុសន្ធៈអង្គនោះ ទ្រង់គង់នៅគ្រប់គ្រងឃរាវាសអស់ ៤ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺ កាមវឌ្ឍប្រាសាទ ១ កាមសុទ្ធិប្រាសាទ ១ រតិវឌ្ឍនប្រាសាទ ១ ។ មាននារី ៣ ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីនោះ ព្រះនាមរោបិនី ព្រះរាជបុត្រព្រះនាមឧត្តរៈ ។ ព្រជិនស្រីឃើញនូវនិមិត្តទាំង ៤ ទ្រង់ចេញទៅបព្វជ្ជាដោយរថជាយាន តម្កល់ទុកនូវព្យាយាមមិនលើសពី ៨ ខែ ។ ព្រះកកុសន្ធៈជានាយក មានព្រះទ័យស្ងប់រំងាប់ មានព្យាយាមធំ ទ្រង់ឧត្តមជាងពួកជន ត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងចក្រឲ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន ។ ព្រះកកុសន្ធៈស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះវិធុរៈ ១ សញ្ជីវៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះពុទ្ធិជៈ ជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះសាមា ១ ឈ្មោះ

ចម្បា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះភគវានោះ ហៅថា សិរិសព្រឹក្ស ( ដើមប្រេស ) ។ ឧបាសកឈ្មោះ អច្ចុគ្គតៈ ១ សុមនៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ នន្ទា ១ សុនន្ទា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះសម្ពុទ្ធ មានកម្ពស់ ៨០ ហត្ថ រស្មីដូចជាមាស ផ្សាយចេញទៅកាន់ទីចម្ងាយ ១០ យោជន៍ដោយជុំវិញ ។ ព្រះភគវានោះ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ព្រះអង្គគង់នៅកំណត់ប៉ុណ្ណោះ ទ្រង់ញុំាង ប្រជុំជនដ៏ច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះសម្ពុទ្ធនោះ ព្រមទាំងសាវ័ក តាំងពានផ្សារ គឺព្រះសទ្ធម្ម បន្លឺឡើងដូចជាសីហនាទ ចំពោះនរៈ និង នារីទាំងឡាយ ក្នុងមនុស្សលោក ព្រមទាំងទេវលោក ហើយនិព្វាន ។ ព្រះសម្ពុទ្ធបរិបូណ៌ដោយពាក្យ ប្រកបដោយអង្គ ៨ សីលទាំងឡាយ មិនដុះធ្លាយ ជាប់មិនដាច់ របស់ទាំងអស់វិនាសសូន្យទៅ ឱ ! សង្ខារ ទាំងពួង ជារបស់មិនទៀងទេតើ ។ ព្រះកកុសន្ធៈ ជាព្រះលោកនាថ ដ៏ប្រសើរ និព្វាននៅក្នុងខេមារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះពុទ្ធនោះ មានកម្ពស់ទៅក្នុងអាកាស ១ គាវុត ក្នុងទីនោះឯង ។

ចប់ កកុសន្ធពុទ្ធវង្សទី ២២

# កោនាគមនពុទ្ធវង្សទី ២៣

កាលជាខាងក្រោយ អំពីព្រះកកុសន្ធៈមក មានព្រះជិនស្រី ព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ព្រះសម្ពុទ្ធអង្គនោះ បានបំពេញបារមីទាំង ១០ កន្លងផ្លូវឆ្ងាយ គឺជាតិ លះបង់មន្ទិលទាំងអស់ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះកោនាគមនសម្ពុទ្ធ ជានាយក ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ពួកសត្វចំនួន ៣ ម៉ឺនកោដិបានត្រាស់ដឹងគ្រាដំបូង ។ កាលទ្រង់ធ្វើបាដិហារិយ៍ ញុំាញីពាក្យត្មះតិះដៀលនៃជនដទៃ ពួកសត្វចំនួន ២ ម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី ២ ។ លំដាប់អំពីនោះ ព្រះជិនស្រីធ្វើនូវវិកុព្វនប្បាដិហារិយ៍ ហើយទ្រង់យាងទៅកាន់ទេវបុរី ព្រះសម្ពុទ្ធគង់នៅលើបណ្ឌុកម្ពលសិលា នៅក្នុងទេវលោកនោះ ។ ព្រះសម្ពុទ្ធនោះកាលសម្តែងសត្តប្បករណាភិធម្ម គង់ចាំវស្សា ( ក្នុងទេវលោក ) ពួកសត្វចំនួនមួយម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី ៣ ។ ព្រះពុទ្ធជាទេវតា ទ្រង់ប្រសើរជាងទេវតាអង្គនោះ ទ្រង់មានសាវកសន្និបាតតែមួយដង ដែលសុទ្ធតែជាពួកព្រះខីណាស្រព ប្រាសចាកមន្ទិល

មានចិត្តស្ងប់រំងាប់ មានចិត្តនឹងធឹង ។ សាវកសមាគមក្នុងកាលនោះ មានភិក្ខុ ៣ ម៉ឺន ដែលកន្ទង់ឱឃៈ ផ្តាច់បង់មច្ចុ ។ សម័យនោះ តថាគត ជាក្សត្រ ឈ្មោះបពូតៈ បរិបូណ៌ដោយមិត្ត និងអាមាត្យ មានពល និងពាហនៈច្រើន ។ តថាគតទៅគាល់ព្រះសម្ពុទ្ធ ស្តាប់ធម៌ដ៏ប្រសើរ ហើយនិមន្តព្រះសង្ឃ ព្រមទាំងព្រះជិនស្រី បានថ្វាយទានតាមសេចក្តី ប្រាថ្នា ។ តថាគត បានថ្វាយវត្ថុ ៤ មុខ គឺសំពត់ចិនប្រទេស ១ សំពត់សូត្រ ១ សំពត់កម្ពល ១ ស្បែកជើងមាស ១ ចំពោះព្រះមុនី ព្រមទាំងសាវក ។ ព្រះលោកនាថនោះ ទ្រង់គង់នៅក្នុងកណ្តាលសង្ឃ ទ្រង់ព្យាករតថាគតថា មហាបុរសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បនេះ ។ សត្វនេះនឹងចេញពីនគរកបិលពស្តុ ជាទីត្រេកអរ តាំងនូវព្យាយាម ធ្វើនូវទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹង នេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានឆាន់បាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចយាងសំដៅទៅឯពោធិមណ្ឌល តាមផ្លូវដ៏ប្រសើរដែលគេ ចាត់ចែងហើយ ។ លំដាប់នោះ មហាបុរសមានយសធំ នឹងធ្វើប្រទក្សិណ ពោធិមណ្ឌលដ៏ប្រសើរ ហើយបានត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។

ព្រះមាតាបង្កើត របស់ព្រះពុទ្ធអង្គនោះ ព្រះនាមថា មាយា ព្រះបិតា ព្រះនាមថា សុទ្ធោទនៈ ក្សត្រអង្គនេះនឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ដើមឈើជាទីត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតាបានស្ដាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ ទ្រង់មិនមានបុគ្គលស្មើស្មើងរកនូវគុណដ៏ធំហើយ ក៏រីករាយថា មហាបុរសនេះជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុមានសំឡេងហ៊ោឡើង ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះសម្ពុទ្ធអង្គនេះ យើងគង់នឹងបាន

សម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគត មិនខាន ។ មនុស្សទាំងឡាយកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ ហើយ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណាមិញ ។ យើងទាំងអស់គ្នា បើឃ្លាងព្រះសាស្តាអង្គនេះហើយ គង់តែនឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនោះ ក្នុងកាល ជាអនាគតពុំខាន ក៏យ៉ាងនោះដែរ ។ តថាគតស្តាប់ព្រះពុទ្ធដីការបស់ ព្រះពុទ្ធនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាដ៏ក្រៃលែង បានអធិដ្ឋានវត្តតទៅ ដោយការបំពេញនូវបារមីទាំង ១០ ។ តថាគតប្រសើរជាងជន កាល ស្វែងរកសព្វញ្ញុតញ្ញាណ បានឲ្យទាន លះបង់រាជសម្បត្តិដ៏ធំ ហើយ បួសក្នុងសម្នាក់ព្រះជិនស្រី ។ កាលនោះ នគរឈ្មោះសោភវតី ក្សត្រ ព្រះនាមសោភៈ ត្រកូលធំរបស់ព្រះពុទ្ធ នៅក្នុងនគរនោះ ។ ព្រាហ្មណ៍ ឈ្មោះយញ្ញទត្ត ជាព្រះបិតា នាងឧត្តរា ជាព្រះមាតា របស់ព្រះសម្ពុទ្ធ ព្រះនាមកោនាគមនៈ ជាសាស្តានោះ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់គង់ នៅគ្រប់គ្រងព្រះដំណាក់អស់ ៣ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺតុសិតប្រាសាទ ១ សន្តុសិតប្រាសាទ ១ សន្តុដ្ឋប្រាសាទ ១ ។ មាននារីមិនខ្វះពី ១ ម៉ឺន ៦ ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារី

ជាអគ្គមហេសីនោះ ព្រះនាមរុចិគត្តា ព្រះរាជបុត្រព្រះនាមសត្ថវាហៈ ។ ព្រះជិនស្រីឃើញនូវនិមិត្តទាំង ៤ ទ្រង់ចេញទៅបព្វជ្ជាដោយដំរីជាយាន បានប្រព្រឹត្តព្យាយាម អស់ ៦ ខែ ។ ព្រះកោនាគមនៈ ជានាយក មានព្រះទ័យស្ងប់រំងាប់ មានព្យាយាមធំ ទ្រង់ឧត្តមជាងពពួកជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រឲ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន ។ ព្រះពុទ្ធព្រះនាមកោនាគមនៈដ៏មានយស មានព្រះថេរៈឈ្មោះភិយ្យោសៈ ១ ឧត្តរៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះសោត្ថិជៈ ជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះសមុទ្ទា ១ ឈ្មោះឧត្តរា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនោះ ហៅថា ឧទុម្ពរព្រឹក្ស ( ដើមល្វា ) ។ ឧបាសកឈ្មោះឧគ្គៈ ១ សោមទេវៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះសីវលា ១ សាមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីនោះ មានកម្ពស់ ៣០ ហត្ថ ប្រដាប់ដោយរស្មីយ៉ាងនេះ ដូចជាមាសក្នុងមាត់នៃបាវ ។ ព្រះមហេសីនោះ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គស្ថិតនៅកំណត់ត្រឹមនោះ ទ្រង់ញ៉ាំងប្រជុំជនដ៏ច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះសម្ពុទ្ធនោះ ព្រមទាំងសាវ័កលើកឡើងនូវធម្មចេតិយ ស្អិតស្អាងដោយសំពត់ គឺធម៌ ធ្វើនូវកម្រងផ្កា

គឺធម៌ បរិនិព្វានហើយ ។ ជនជាសាវ័ករបស់ព្រះពុទ្ធនោះ សម្តែងនូវធម៌ ដ៏មានសិរី ដល់នូវឫទ្ធិដ៏ធំទូលាយ របស់ទាំងអស់នោះ វិនាសសូន្យទៅ ឱ! សង្ខារទាំងពួង ជារបស់ទទេ ។ ព្រះសម្ពុទ្ធ ព្រះនាមកោនាគមនៈ និព្វានក្នុងបព្វតារាម ព្រះធាតុផ្សាយទៅក្នុងទីនោះៗ តាមចំណែក ។

ចប់ កោនាគមនពុទ្ធវង្សទី ២៣

# កស្សបពុទ្ធវង្សទី ២៤

កាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមកោនាគមនៈមក មានព្រះសាស្តា ព្រះនាមកស្សបៈ ដ៏ឧត្តមជាងសត្វទ្វេបាទ ជាធម្មរាជ ទ្រង់ធ្វើពន្លឺ ។ ផុះជាឫសគល់នៃត្រកូលព្រះពុទ្ធ ទ្រង់លះបង់ហើយ ព្រះពុទ្ធនោះ ទ្រង់ឲ្យទាន គឺបាយ និងទឹកច្រើន ដល់យាចកទាំងឡាយ ហើយញុំាងព្រះទ័យឲ្យពេញ ដល់សម្ពោធិញ្ញាណដ៏ឧត្តម ដូចជាគោឧសភៈទម្លាយនូវក្រោល ។ កាលព្រះកស្សបសម្ពុទ្ធ ជាលោកនាយក ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ពួកបរិស័ទចំនួន ២ ម៉ឺនកោដិ បានត្រាស់ដឹង ជាគ្រាដំបូង ។ កាលព្រះសម្ពុទ្ធយាងទៅកាន់ចារិក ក្នុងទេវលោកអស់

៤ ខែ ពួកបរិស័ទមួយម៉ឺនកោដិបានត្រាស់ដឹងជាគ្រាទី ២ ។ ព្រះសាស្តា ធ្វើយមកប្បាដិហារិយ៍ និងវិកុព្វនប្ញទ្ធិ សម្តែងនូវញាណធាតុ ពួកបរិស័ទ ៥ ពាន់កោដិបានត្រាស់ដឹងជាគ្រាទី ៣ ។ ព្រះជិនស្រីសម្តែងព្រះធម៌ ក្នុងសុធម្មទេវបុរី ជាទីរីករាយ ក្នុងទេវលោកនោះ ញុំាងទេវតា ៣ ពាន់កោដិឲ្យត្រាស់ដឹង ។ ក្នុងការសម្តែងព្រះធម៌ដទៃទៀតដល់ទេវតា មនុស្ស និងយក្ស ជនទាំងនោះបានត្រាស់ដឹងរាប់មិនអស់ ។ ព្រះពុទ្ធ ជាទេវតាដ៏ប្រសើរនោះ មានសាវកសន្និបាតតែមួយដង ដែលសុទ្ធតែ ជាពួកព្រះខីណាស្រព មិនមានមន្ទិល មានចិត្តស្ងប់រំងាប់ មានចិត្ត នឹងធឹង ។ ការប្រជុំក្នុងកាលនោះ មានភិក្ខុ ២ ម៉ឺនរូប ដែលមានកត កន្លងហើយ មានចិត្តនឹងធឹង ដោយហិរិ និងសីល ។ កាលនោះតថាគត ជាមាណព ឈ្មោះជោតិបាល ជាអ្នករៀនមន្ត ចេះចាំមន្ត ដល់នូវត្រើយ នៃវេទទាំង ៣ ។ តថាគតដល់នូវបារមីក្នុងគម្ពីរលក្ខណៈផង ក្នុងគម្ពីរ ឥតិហាសៈផង ក្នុងព្រះសទ្ទម្មផង ឈ្លាសវៃក្នុងផែនដី និងអាកាស មានវិជ្ជាធ្វើរួចហើយ ជាអ្នកមិនមានរោគ ។ ឧបាសកឈ្មោះឃដិការ ជាឧបដ្ឋាករបស់ព្រះទសពល ព្រះនាមកស្សបៈ ប្រកបដោយសេចក្តី គោរព ប្រកបដោយសេចក្តីកោតក្រែង និព្វានក្នុងផលទី ៣ ឃដិការ

នាំតថាគត ចូលទៅគាល់ព្រះលោកនាថ ព្រះនាមកស្សបៈ តថាគត ស្តាប់ធម៌របស់ព្រះពុទ្ធនោះ ក៏បួសក្នុងសម្នាក់នៃព្រះអង្គ ។ តថាគត មានព្យាយាមក្លៀវក្លា ឈ្លាសវៃក្នុងវត្តតូច និងវត្តធំ មិនមានសេចក្តី សាបសូន្យក្នុងសីល និងសមាធិណាមួយឡើយ បានញុំាងសាសនា នៃព្រះលោកនាយកឲ្យពេញបរិបូណ៌ ។ សាសនាព្រះសាស្តាមានអង្គ ៩ ដែលព្រះសាស្តាសម្តែងហើយទាំងប៉ុន្មាន តថាគតបានរៀននូវធម៌ ទាំងអស់នោះ ហើយញុំាងសាសនាព្រះជិនស្រីឲ្យរុងរឿង ។ ព្រះពុទ្ធនោះ ឃើញហេតុអស្ចារ្យរបស់តថាគត ក៏ទ្រង់ព្យាករថា ជោតិបាលមាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងភទ្ទកប្បនេះឯង ។ សត្វនេះនឹងចេញចាក ក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ នឹងសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយសំដៅទៅឯគល់ពោធិព្រឹក្ស តាមផ្លូវ ដ៏ប្រសើរដែលគេចាត់ចែង ។ លំដាប់ពីនោះ ព្រះសម្ពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌលដ៏ប្រសើរ ហើយនឹងបានត្រាស់ដឹងនូវ សម្មោធិញ្ញាណទៀបគល់ នៃអស្សត្ថព្រឹក្ស ។ ព្រះមាតានៃព្រះពុទ្ធ

ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាម គោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ ជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនោះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រំងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវិកា ។ ដើមឈើជាទីត្រាស់ដឹង របស់ព្រះសម្ពុទ្ធនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ ទ្រង់មិនមានបុគ្គលស្មើ ស្វែងរកនូវគុណដ៏ធំ ក៏រីករាយថា មាណពនេះជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏មានសំឡេងហ៊ោឡើង ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ យើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះលោកនាយកអង្គនោះ ក្នុងកាល

ជាអនាគតមិនខាន ។ មនុស្សទាំងឡាយ កាលចូងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយចូងនូវស្ទឹងធំបានដែរ យ៉ាងណាមិញ ។ យើងទាំងអស់គ្នា បើឃ្លាងព្រះភគវាអង្គនេះហើយ គង់តែនឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនោះ ក្នុងកាលជាអនាគតពុំខាន ក៏យ៉ាងនោះដែរ ។ តថាគតស្តាប់ព្រះពុទ្ធដីកា របស់ព្រះសាស្តានោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាបានអធិដ្ឋានវត្តតទៅ ដោយការបំពេញបារមីទាំង ១០ ។ តថាគតកាលបំពេញបារមីយ៉ាងនេះ តថាគតតែងអន្ទោលទៅ វៀរនូវមារយាទអាក្រក់ អំពើដែលបុគ្គលធ្វើដោយកម្រ តថាគតបានធ្វើហើយ ព្រោះហេតុពោធិញ្ញាណ ។ កាលនោះ នគរឈ្មោះពារាណសី ក្សត្រព្រះនាម **កិកិ** ត្រកូលធំរបស់ព្រះសម្ពុទ្ធនៅក្នុងនគរនោះ ។ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រហ្មទត្តព្រាហ្មណ៍ ជាព្រះបិតាព្រះមាតាព្រះនាម ធនវតី ។ ព្រះអង្គគង់គ្រប់គ្រងព្រះដំណាក់អស់ ២ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺហំសប្រាសាទ ១ យសប្រាសាទ ១ សិរិចន្ទប្រាសាទ ១ ។ មាននារី ១៦ ពាន់ ៣ ជង មានខ្លួនប្រដាប់សមរម្យឯនារីជាអគ្គមហេសីនោះ ព្រះនាម សុនន្ទា ព្រះរាជបុត្រ ព្រះនាម

វិជិតសេនៈ ។ ព្រះលោកនាយកឃើញនូវនិមិត្តទាំង ៤ ក៏បានចេញទៅបព្វជ្ជាដោយប្រាសាទ ទ្រង់ប្រព្រឹត្តសេចក្តីព្យាយាម អស់ ៧ ថ្ងៃ ( បានត្រាស់ជាព្រះពុទ្ធ ) ។ ព្រះសម្ពុទ្ធ ព្រះនាមកស្សបៈ ជានាយកមានព្រះទ័យស្ងប់រំងាប់ មានព្យាយាមធំ ទ្រង់ឧត្តមជាងពពួកជនត្រូវព្រហ្មអារាធនាហើយ ទើបញុំាងចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះថេរៈឈ្មោះតិស្សៈ ១ ភារទ្វាជៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះសព្វមិត្តៈ ជាឧបដ្ឋាក របស់ព្រះមុនីព្រះនាមកស្សបៈ ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះអនុលា ១ ឈ្មោះឧរុវេលា ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹងរបស់ព្រះភគវានោះ ហៅថា និគ្រោធព្រឹក្ស (ដើមជ្រៃ) ។ ឧបាសកឈ្មោះសុមង្គលៈ ១ ឃដិការ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះវិជិតសេនា ១ ភទ្រា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមុនីមានកម្ពស់ ២០ ហត្ថ ដូចជាធ្នូតនៃផ្ទៃកបន្ទោរព្វដ៏អាកាស ឬដូចជាព្រះច័ន្ទ ដែលផ្កាយចោមរោមហើយ ។ ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ព្រះអង្គស្ថិតនៅត្រឹមណោះ ទ្រង់ញុំាងប្រជុំជនដ៏ច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះអង្គនិម្មិតស្រះ គឺព្រះសទ្ធម្មទ្រង់ប្រទានគ្រឿងលាប គឺសីល ទ្រង់ញុំាងសត្វឲ្យស្លៀកសំពត់ គឺ

ព្រះធម៌ ទ្រង់បែកកម្រងផ្កា គឺព្រះធម៌ ទ្រង់តម្កល់ទុកកញ្ចក់មិនមានមន្ទិល គឺព្រះសទ្ធម្ម ចំពោះពួកមហាជនថា ពួកជនណាមួយ កាលប្រាថ្នានិព្វាន ចូរមើលមើលគ្រឿងប្រដាប់របស់តថាគតចុះ ។ ព្រះសម្ពុទ្ធនោះឲ្យដាវ គឺសីល ឲ្យស្បែកក្រោះ គឺឈាន ឲ្យដណ្តប់ស្បែក គឺព្រះធម៌ឲ្យកាំបិតស្នៀតដ៏ឧត្តម គឺព្យាយាម ។ ឲ្យខែល គឺសតិ ឲ្យកាំបិតគឺញាណដ៏មុត ឲ្យព្រះខ័នដ៏ប្រសើរ គឺធម៌ ឲ្យប្រដាប់សម្រាប់ញាំញីសត្រូវ គឺសីល ។ ឲ្យគ្រឿងស្អិតស្អាង គឺវិជ្ជា ៣ ឲ្យគ្រឿងពាក់ត្រចៀកគឺផល ៤ ឲ្យគ្រឿងអាភរណៈ គឺអភិញ្ញា ៦ ឲ្យគ្រឿងប្រដាប់ជាវិការនៃផ្កា គឺព្រះសទ្ធម្ម ។ ព្រះមុនីអង្គនោះ ព្រមទាំងសាវ័ក ឲ្យឆត្រ.សគឺព្រះសទ្ធម្ម ជាគ្រឿងឃាត់នូវបាប និម្មិតផ្កាមិនមានភ័យហើយ ទើបនិព្វាន ។ ព្រះសម្ពុទ្ធអង្គនោះ ប្រមាទមិនបាន បុគ្គលគ្របសង្កត់បានដោយកម្រ ព្រះធម្មរតនៈនោះ ដែលព្រះអង្គសម្តែងហើយដោយប្រពៃជាធម៌គួរហៅអ្នកផង ឲ្យចូលមកមើលបាន ។ ព្រះសង្ឃរតនៈនោះលោកបដិបត្តិហើយដោយប្រពៃ ជាព្រះសង្ឃដ៏ប្រសើរ របស់ទាំងអស់នោះ វិនាសសោះសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេ ។ ព្រះជិនស្រី ព្រះនាមមហាកស្សបៈ ទ្រង់និព្វាននៅក្នុងសេតព្យារាម

ព្រះស្តូបរបស់ព្រះកគវាអង្គនោះ មានកម្ពស់ ១ យោជន៍ ក្នុងទីនោះ ។

ចប់ កស្សបពុទ្ធវង្សទី ២៤

ក្នុងកប្បដែលព្រះសម្ពុទ្ធទីបង្ករ ស្តេចទ្រង់ឧប្បត្តិឡើង សូម្បីព្រះពុទ្ធនឹងមានដល់ទៅ ៣ ព្រះអង្គ ព្រះពោធិសត្វមិនបានទទួលការព្យាករណ៍ពីសម្នាក់ព្រះពុទ្ធទាំងនោះ ព្រោះដូច្នោះ ព្រះពុទ្ធទាំងនោះទើបលោកមិនបានសម្ដែងទុកនៅក្នុងទីនេះ តែក្នុងអដ្ឋកថា សូម្បីនឹងសម្ដែងព្រះពុទ្ធទាំងអស់ ចាប់ផ្ដើមតាំងពីកប្បនេះ ទើបលោកពោលពាក្យនេះថា

ព្រះលោកនាថទាំងនេះ គឺព្រះតណ្ហង្ករ ព្រះមេធង្ករ និងព្រះសរណង្ករ ព្រះទីបង្ករសម្ពុទ្ធ ព្រះកោណ្ឌញ្ញៈ ទ្រង់ខ្ពង់ខ្ពស់ជាងនរៈ ព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈ ព្រះអនោមទស្សី ព្រះបទុមៈ ព្រះនារទៈ ព្រះបទុមុត្តរៈ ព្រះសុមេធៈ ព្រះសុជាតៈ ព្រះបិយទស្សី ទ្រង់មានយសធំ ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថៈ ទ្រង់ជាលោកនាយក ព្រះតិស្សៈ ព្រះបុស្សៈ ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និងព្រះកស្សបៈ

មានរាគៈកម្ចាត់ចេញហើយ មានព្រះទ័យតាំងមាំ ទ្រង់កម្ចាត់ភាពងងឹតហាក់បីដូចដួងព្រះអាទិត្យរះឡើងហើយ ភ្លឺរុងរឿង ជាងគំនរភ្លើងស្តេចបរិនិព្វានហើយ ព្រមទាំងសាវក ដូចនេះ ។

ក្នុងរឿងនោះ ព្រះពោធិសត្វ កសាងសេចក្តីល្អ ក្នុងសម្នាក់នៃព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះទីបង្ករជាដើម អស់ ៤ អសង្ខេយ្យនិងមួយសែនកប្ប តពីព្រះលោកនាថទ្រង់ព្រះនាមកស្សបៈ មិនមានព្រះពុទ្ធអង្គដទៃ វៀរព្រះសម្ពុទ្ធអង្គនេះ ក៏ព្រះពោធិសត្វ បានទទួលការព្យាករណ៍ ក្នុងសម្នាក់នៃព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះទីបង្ករជាដើម ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា

ពុទ្ធធម៌ គឺធម៌ដែលធ្វើបុគ្គលឲ្យបានត្រាស់ដឹងជាព្រះពុទ្ធ មាន ១៨ គឺបារមីទាំង ១០ មានទានបារមីជាដើម មានឧបេក្ខាបារមីជាទីបំផុត ព្រមទាំងសម្បត្តិ ៨ ប្រការ គឺ ១- មានជាតិជាមនុស្ស ២- មានភេទជាបុរស ៣- មានឧបនិស្ស័យ ដែលអាចបានសម្រេចនូវអរហត្ត ៤- បានជួប បានឃើញព្រះសាស្តា ៥- បានទ្រទ្រង់ភេទជាបព្វជិត ៦- បាននូវគុណមានលោកិយជ្ឈានជាដើម ៧- បានបំពេញបរិច្ចាគទាំង ៥ មានបុត្តបរិច្ចាគជាដើម ៨- មានសេចក្តីស្រឡាញ់ព្រះសព្វញ្ញុតញ្ញាណ

រួមជា ១៨ ប្រការ ។

ព្រះមហាសត្វ លោកបានធ្វើសេចក្តីប្រាថ្នា ទៀបបាទមូលរបស់ព្រះពុទ្ធ ទ្រង់ព្រះនាមថា **ទីបង្ករ** ប្រមូលធម៌ ១៨ ប្រការទាំងនេះមកហើយ ធ្វើឧស្សាហៈថា ណ្ហើយចុះ យើងនឹងជ្រើសរើសធម៌ ដែលធ្វើឲ្យបានជាព្រះពុទ្ធ ចាកទីនោះខ្លះ ទីនេះខ្លះ បានឃើញពុទ្ធការកធម៌មានទានបារមីជាដើម ដោយពោលថា ក្នុងកាលយើងជ្រើសរើសបានឃើញទានបារមីជាប្រការដំបូង លោកបំពេញធម៌ទាំងនោះរហូតដល់អត្តភាពជាព្រះវេស្សន្តរ និងកាលមកដល់ ក៏បានសម្រេចអានិសង្សសម្រាប់ព្រះបរមពោធិសត្វ អ្នកបានធ្វើសេចក្តីប្រាថ្នាដែលតាំងចិត្តប្រាកដ ដូចដែលលោកពណ៌នានេះ ជាច្រើនៗ ថា

នរជនអ្នកបរិបូណ៌ដោយអង្គ នៃគុណគ្រប់ប្រការ អ្នកទៀងចំពោះពោធិញ្ញាណ រហូតសង្សារ ដែលមានរយៈកាលដ៏យូរ សូម្បីរាប់ដោយរយកោដិកប្ប នឹងមិនទៅកើតក្នុងអវិចិនរក សូម្បីនៅក្នុងលោកន្តរនរក ក៏ដូចគ្នា សូម្បីកើតក្នុងទុគ្គតិ នឹងមិនកើតជានិជ្ឈាមតណ្ហិក-ប្រេត ខុប្បិបាសិកប្រេត កាឡកញ្ជិកាសូរ មិនជាសត្វខ្ទតូចៗ កាលបើនឹងកើតជាមនុស្ស ក៏មិនជាមនុស្សខ្វាក់អំពីកំណើត មិនជាមនុស្ស

ថ្លង់-គ មិនជាមនុស្សឆ្កួត មិនកើតជាស្រ្តី មិនជាឧភតោព្យញ្ជនកៈ ( អ្នកមានភេទ ២ ) និងខ្ទើយ នរជនអ្នកទៀង ចំពោះពោធិញ្ញាណ នឹងមិនមានចិត្តជាប់ជំពាក់ ក្នុងវត្ថុណាមួយឡើយ ជាអ្នកផុតចាក អនន្តរិយកម្ម ជាអ្នកមានគោចរស្អាតក្នុងទីទាំងពួង មិនសេពមិច្ឆាទិដ្ឋិ ព្រោះឃើញផលក្នុងការធ្វើកម្ម សូម្បីនឹងទៅកើតក្នុងពួកសត្វទាំងឡាយ ក៏មិនកើតជាអសញ្ញីសត្វ ក្នុងពួកដែលរស់នៅសុទ្ធាវាស ក៏មិនមាន ហេតុទៅកើត ជាសប្បុរសបង្អោនចិត្តទៅ ក្នុងនេក្ខម្មៈ ដោះចេញនូវ ភពតូច-ធំ ប្រព្រឹត្តតែប្រយោជន៍ដល់លោក បំណងបំពេញនូវបារមី គ្រប់ប្រការ ត្រាច់ទៅ ។

កាលដែលព្រះមហាសត្វ បំពេញទានបារមីនោះ គឺនៅក្នុង អត្តភាព ដែលកើតជាព្រាហ្មណ៍ ឈ្មោះ អកិត្តិ សង្ខព្រាហ្មណ៍ កុរុធម្ម មហាសុទស្សនៈ មហាគោវិន្ទ នេមិរាជ ចន្ទកុមារ សិវិរាជ វេស្សន្តរ សសបណ្ឌិត ។ ទានបារមីរបស់ព្រះពោធិសត្វ ទ្រង់ធ្វើការ បរិច្ចាគជីវិត ក្នុងអត្តភាពជាសសបណ្ឌិត យ៉ាងនេះថា

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន ជារបស់ខ្លួន បុគ្គលអ្នកឲ្យទាន ស្មើដោយទាន របស់តថាគត

មិនមានឡើយ នេះជាទានបារមី របស់តថាគត ដូចនេះ ។

ក៏ដូចគ្នានឹងអត្តភាព ដែលបំពេញសីលបារមី គឺនៅក្នុងកាលដែលជា សីលវនាគ ភូរទត្ត ចម្បេយ្យ ចូឡពោធិ មហិសរាជ រុរុមិគ មាតង្គ ទេវធម្មបុត្ត ជយទិស សង្ខបាល ។ សីលបារមីព្រះពោធិសត្វទ្រង់ធ្វើការបរិច្ចាគជីវិត ក្នុងអត្តភាពជាសង្ខបាល យ៉ាងនេះថា

ប៉ុន្តែ តថាគត មិនរឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួច និងចាក់ដោយលំពែងទាំងឡាយ នេះជាសីលបារមីរបស់តថាគត ។

ក៏ដូចគ្នាអត្តភាព ដែលព្រះពោធិសត្វ បានលះបង់រាជសម្បត្តិដើម្បីបំពេញនូវនេក្ខម្មបារមី គឺក្នុងកាលដែលជា សោមនស្សកុមារ ហត្ថិបាលកុមារ អយោឃរបណ្ឌិត ។ នេក្ខម្មបារមីរបស់ព្រះពោធិសត្វទ្រង់លះបង់រាជសម្បត្តិចេញបួស ព្រោះជាអ្នកប្រាសចាកគ្រឿងជាប់ជំពាក់ ក្នុងចូឡសុតសោមជាតក យ៉ាងនេះថា

បុគ្គលលះបង់រាជសម្បត្តិយ៉ាងធំក្រៃលែង ដែលនៅក្នុងកណ្តាប់ដៃហើយទៅ ដូចដុំទឹកមាត់ កាលតថាគតលះបង់ហើយ មិនមានសេចក្តីជាប់ជំពាក់ឡើយ នេះជានេក្ខម្មបារមីរបស់តថាគត ដូចនេះឯង ។

ក៏ដូចគ្នាចំពោះអត្តភាព ដែលបំពេញបញ្ញាបារមី គឺក្នុងកាលដែលកើតជា វិធុរបណ្ឌិត ខុទ្ទាលបណ្ឌិត អរកបណ្ឌិត ពោធិបរិញ្វជក មហោសថបណ្ឌិត តែបញ្ញាបារមីរបស់ព្រះពោធិសត្វ ក្នុងមហោសថជាតក មានន័យដូច្នេះថា

បពិត្រមហារាជ ពិតមែនហើយ បណ្ឌិតទាំងឡាយ នាំមកនូវសេចក្ដីសុខយ៉ាងនោះឯង មហោសថបានដោះពួកយើង ដែលនៅក្នុងកណ្ដាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រី ដែលជាប់នៅក្នុងសំណាញ់ដូច្នោះ នេះជាបញ្ញាបារមីរបស់តថាគត ដូច្នេះឯង ។

ក៏ដូចគ្នាចំពោះអត្តភាព ដែលបំពេញវិរិយបារមី វិរិយបារមីរបស់ព្រះពោធិសត្វ ដែលហែលឆ្លងមហាសមុទ្រ នៅក្នុងមហាជនកជាតក យ៉ាងនេះថា

( នាងមណីមេខលា ) អ្នកមិនឃើញត្រើយនៃសមុទ្រដ៏ជ្រៅប្រមាណមិនបាន ការព្យាយាមតាមកម្លាំងបុរសរបស់អ្នក ជាអ្នកព្យាយាមសោះសូន្យទទេ អ្នកមិនដល់នូវត្រើយទេ មុខជានឹងស្លាប់ នេះជាវិរិយបារមីរបស់តថាគត យ៉ាងនេះឯង ។

ក៏ដូចគ្នាចំពោះអត្តភាព ដែលបំពេញខន្តិបារមី ខន្តិបារមីរបស់ព្រះពោធិសត្វ ទ្រង់អត់សង្កត់នូវទុក្ខ ឬការបៀតបៀនអំពីអ្នកដទៃ ព្រោះធ្វើដូចជាមិនមានចិត្ត ក្នុងខន្តិវាទីជាតក យ៉ាងនេះថា

**(តាបសពោធិសត្វពោលថា) ព្រះរាជាណា កាត់ដៃទាំងពីរក្តី កាត់ជើងទាំងពីរក្តី កាត់ត្រចៀក និងច្រមុះក្តី របស់អាត្មា សូមឲ្យព្រះរាជានោះ ទ្រង់មានព្រះជន្មយឺនយូរ ពួកអ្នកប្រាជ្ញដូចយ៉ាងអាត្មាមិនខឹងឡើយ នេះជាខន្តិបារមីរបស់តថាគត យ៉ាងនេះឯង ។**

ដូចគ្នាចំពោះអត្តភាព ដែលបំពេញនូវសច្ចបារមី របស់ព្រះពោធិសត្វ លះបង់ជីវិត តាមរក្សានូវសច្ចធម៌ ក្នុងមហាសុតសោមជាតក យ៉ាងនេះថា

**( ព្រះបាទសុតសោម ) រសឯណាទីមួយ មាននៅលើផែនដី សច្ចៈជារសល្អក្រៃលែងជាងរសទាំងឡាយនោះ ពួកសមណៈ និងព្រាហ្មណ៍ ដែលតាំងនៅក្នុងសច្ចៈ រមែងឆ្លងទៅកាន់ត្រើយនៃជាតិ និងមរណៈបាន នេះជាសច្ចបារមីរបស់តថាគត យ៉ាងនេះឯង ។**

ដូចគ្នាចំពោះអត្តភាព ដែលបំពេញនូវអធិដ្ឋានបារមី របស់ព្រះពោធិសត្វ លះបង់ជីវិតដើម្បីអធិដ្ឋានវត្ត ក្នុងមូគផក្ខចរិយា យ៉ាងនេះថា

មាតា បិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនក៏មិនមែនជាទីស្អប់ របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាននោះ នេះជាអធិដ្ឋានបារមីរបស់តថាគត យ៉ាងនេះឯង ។

ដូចគ្នាចំពោះអត្តភាព ដែលបំពេញនូវមេត្តាបារមី របស់ព្រះពោធិសត្វ ទ្រង់មិនយកចិត្តទុកដាក់សូម្បីតែជីវិត ក៏គង់មានមេត្តាក្នុងឯករាជចរិយា យ៉ាងនេះថា

មានចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចឈ្មោះឯករាជ បានអធិដ្ឋានសីលដ៏ក្រៃលែង ហើយគ្រប់គ្រងមហាប្រឹថពីក្នុងកាសិករដ្ឋ ។ តថាគតបានប្រព្រឹត្តកុសលកម្មបថ ១០ ឥតមានសេសសល់ សង្គ្រោះមហាជនដោយសង្គហវត្ថុទាំង ៤ ។ តថាគតមិនប្រមាទក្នុងលោកនេះ និងបរលោកយ៉ាងនេះ វេលានោះ ស្តេចក្នុងដែនកោសល ឈ្មោះទព្វសេន ចូលមកដណ្តើមរាជបុរីរបស់តថាគត ។ ស្តេចទព្វសេន ធ្វើនូវអ្នកនិគម ព្រមទាំងពល និងអ្នកជនបទ ដែលរស់នៅព្រោះអាស្រ័យស្តេចទាំងអស់ ឲ្យតាំងនៅក្នុងដៃ ហើយជីកកប់តថាគតក្នុងរណ្តៅ ។ តថាគតបានឃើញនូវមណ្ឌល

នៃអាមាត្យរាជ្យ និងវាំងដ៏ស្តុកស្តម្ភរបស់តថាគត ដូចកូនជាទីស្រឡាញ់ ដែលត្រូវស្តេចទព្វសេនដណ្តើមយកទៅហើយ ( ការផ្សាយមេត្តាចំពោះស្តេចទព្វសេននោះ ) គុណធម៌ដទៃស្មើនឹងមេត្តានៃតថាគតពុំមានឡើយ នេះជាមេត្តាបារមីរបស់តថាគត ។

ដូចគ្នាចំពោះអត្តភាព ដែលបំពេញនូវឧបេក្ខាបារមី របស់ព្រះពោធិសត្វ មិនប្រព្រឹត្តកន្លងឧបេក្ខា កាលពួកក្មេងអ្នកស្រុក សូម្បីនឹងបង្កឲ្យកើតទុក្ខ និងសេចក្តីសុខ ដោយការស្តោះទឹកមាត់ដាក់ជាដើមខ្លះ ដោយនាំយកផ្កា ឬគ្រឿងក្រអូបមកឲ្យខ្លះ ក្នុងមហាលោមហំសចរិយា យ៉ាងនេះថា

តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសព ក្នុងព្រៃស្មសាន ពួកក្មេងអ្នកស្រុកចូលមកជិត ( តថាគត ) ហើយសម្តែងនូវប្រការដ៏ប្លែកច្រើនយ៉ាង ។ ពួកក្មេងដទៃជាអ្នកដឹងការណ៍ ( ឃើញទារកទាំងឡាយ ) ក៏សប្បាយរីករាយ មានចិត្តសង្វេគ ទៅនាំយកគ្រឿងក្រអូប ផ្កាកម្រង ភោជនផ្សេងៗ ដ៏ច្រើន និងគ្រឿងបណ្ណាការមកឲ្យតថាគត ។ ពួកក្មេងអ្នកស្រុកណា នាំយកសេចក្តីទុក្ខមកឲ្យតថាគត ពួកក្មេងអ្នកស្រុកណា ឲ្យសេចក្តីសុខដល់តថាគត តថាគត

មានចិត្តស្មើ ចំពោះទាយកទាំងអស់នោះ មិនអាណិត មិនក្រោធ ។ តថាគតមានចិត្តជាកណ្តាល ក្នុងសុខ និងទុក្ខ ក្នុងយស និងអយស តថាគតមានចិត្តស្មើក្នុងលោកធម៌ទាំងពួង នេះជាឧបេក្ខាបារមីរបស់តថាគត ។

សេចក្តីសង្ខេបក្នុងទីនេះ មានត្រឹមតែប៉ុណ្ណោះឯង ។ ចំណែកឯសេចក្តីពិស្តារ គប្បីកាន់យកសេចក្តីនោះ ក្នុងគម្ពីរចរិយាបិដក និងសមោធានកថា ព្រះពោធិសត្វបំពេញបារមីយ៉ាងនេះហើយ តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរធ្វើបុណ្យធំ ដែលជាហេតុឲ្យផែនដីដ៏ធំកម្រើកយ៉ាងនេះថា

ផែនដីនេះពុំមានចិត្ត មិនទទួលដឹងសុខទុក្ខ សូម្បីផែនដីនោះក៏បានកម្រើកហើយដល់ ៧ លើក ព្រោះអំណាចនៃទានរបស់តថាគតដូច្នេះឯង ។

ក្នុងវេលាអស់នៃអាយុ ចុតិចាកអំពីជាតិនោះ បានទៅកើតនៅក្នុងតុសិតពិភព ។ ចាប់ផ្តើមអំពីបាទមូលរបស់ព្រះសាស្តា ទ្រង់ព្រះនាមទីបង្ករ រហូតមកដល់ព្រះពោធិសត្វនេះ កើតនៅក្នុងតុសិតបុរី សេចក្តីនោះគប្បីជ្រាបថាជា ទូរេនិទាន ។

ចប់ ទូរេនិទាន

# អចិន្ត្យនិទាន

កាលដែលព្រះបរមពោធិសត្វ កំពុងគង់នៅក្នុងស្ថានតុសិតបុរីនាទេវលោកនោះ ការផ្ដើលជ្រួលជ្រើមរឿងព្រះបរមសាស្ដាកើតឡើង ។ ពិតណាស់ ក្នុងលោករមែងមានកោលាហល ៣ យ៉ាង កើតឡើងគឺ

១- កប្បកោលាហល កោលាហលពីរឿងកប្ប ។

២- ពុទ្ធកោលាហល កោលាហលពីរឿងព្រះពុទ្ធ ។

៣- ចក្កវត្តិកោលាហល កោលាហលពីរឿងស្ដេចចក្រពត្តិ ។

ពពួកទេវតាជាន់កាមាវចរៈ ឈ្មោះលោកព្យុហៈ បានជ្រាបថា ហេតុដែលនឹងកើតឡើង អំណឹះកាលកន្លងពីត្រឹមនេះទៅ នៅសល់ចំនួនមួយសែនឆ្នាំទៀតនោះ ដូចនេះ ម្នាក់ៗ មានសរីរៈទទឹកជោករំសាយសក់ យំយកដៃទាំងពីរជូតទឹកភ្នែក ស្លៀកដណ្ដប់សំពត់ពណ៌ក្រហម មានរូបរាងកាយប្លែក ត្រាច់មកប្រកាសប្រាប់ដល់មនុស្សទាំងឡាយក្នុងលោកថា នែអ្នកនិទ៌ុក្ខទាំងឡាយ ដោយកាលកន្លងទៅមួយសែនឆ្នាំទៀត ហេតុដែលនឹងកើតមានឡើង ដោយសារនឹងមានការវិនាសកប្ប សូម្បីលោកនេះក្ដី ក៏នឹងវិនាសទៅ មហាសមុទ្រក្ដី

ក៏នឹងវិនាសទៅ មហាប្រឹថពីនេះក្តី និងស្តេចភ្នំឈ្មោះសិនេរុក្តី ក៏នឹងត្រូវភ្លើងឆេះវិនាសទៅដូចគ្នាដែរ ការវិនាសនឹងមានរហូតទៅដល់ព្រហ្មលោក នែអ្នកនិទ្ទុក្ខទាំងឡាយ សូមអ្នកទាំងឡាយចម្រើននូវព្រហ្មវិហារធម៌ គឺមេត្តា ករុណា មុទិតា ឧបេក្ខា ចូរបម្រើមាតាបិតា ចូរជាអ្នកបង្អោនចិត្តគោរពរាប់អាន ចំពោះត្រកូលរៀមច្បង ដូចនេះឈ្មោះថា **កប្បកោលាហល** កោលាហលពីរឿងកប្ប ។

ពួកទេវតាឈ្មោះលោកបាលបានជ្រាបថា អំណើះកាលកន្លងពីត្រឹមនេះទៅ នៅសល់ចំនួនមួយពាន់ឆ្នាំទៀត **ព្រះសព្វញ្ញុពុទ្ធ** ស្តេចនឹងកើតឡើងនៅក្នុងលោក ដូច្នេះហើយ ត្រាច់មកប្រកាសប្រាប់ដល់មនុស្សទាំងឡាយ ដូចនេះឈ្មោះថា **ពុទ្ធកោលាហល** កោលាហលពីរឿងព្រះពុទ្ធ ។

ទេវតាពួកនោះឯងបានជ្រាបថា អំណើះកាលកន្លងអំពីត្រឹមនេះទៅប្រមាណ ១០០ ឆ្នាំទៀត ស្តេចចក្រពត្តិនឹងកើតឡើងនៅក្នុងលោក ត្រាច់មកប្រកាសប្រាប់ថា នែអ្នកនិទ្ទុក្ខទាំងឡាយ អំណើះកាលកន្លងពីត្រឹមនេះទៅប្រមាណ ១០០ ឆ្នាំទៀត នឹងមានស្តេចចក្រពត្តិកើតឡើងនៅក្នុងលោក ដូច្នេះ នេះហៅថា **ចក្កវត្តិកោលាហល** កោលាហល

កើតឡើង ព្រោះស្ដេចចក្រពត្តិ ។

កោលាហលទាំង ៣ ប្រការនេះ រាប់ថាជា របស់ធំ បណ្ដាកោលាហលទាំង ៣ នោះ ពួកទេវតាដែលស្ថិតនៅក្នុងចក្រវាឡទាំងមួយម៉ឺនលោកធាតុ បានឮសំឡេងពុទ្ធកោលាហលហើយ ទើបមករួមប្រជុំគ្នាដោយបានជ្រាបថា សត្វឈ្មោះនេះនឹងបានជាព្រះពុទ្ធ ក៏នាំគ្នាចូលទៅអារាធនាព្រះពោធិសត្វ លុះកាលអារាធនារួចហើយ ក្នុងកាលបុព្វនិមិត្តកើតឡើងហើយនោះ ក៏ក្នុងកាលនោះ ទេវតាទាំងឡាយព្រមទាំងស្ដេចចតុលោកបាលទាំង ៤ សក្កទេវរាជ ទេវតាជាន់យាមាទេវតាជាន់តុសិត ទេវតាជាន់និម្មានរតី ទេវតាជាន់បរនិម្មិតវសវត្តីនិងមហាព្រហ្មនៅក្នុងចក្រវាឡនីមួយៗ មកប្រជុំគ្នា ហើយនាំគ្នាទៅកាន់សម្នាក់របស់ព្រះបរមពោធិសត្វ ក្នុងស្ថានតុសិត ចូលទៅអារាធនាព្រះបរមពោធិសត្វដោយពាក្យថា បពិត្រព្រះអង្គ អ្នកជានិទ្ទុក្ខ ព្រះអង្គកាលកសាងបំពេញនូវបារមីទាំង ១០ នោះ ក៏មិនបានប្រាថ្នានូវសក្កសម្បត្តិមារសម្បត្តិ ចក្កវត្តិសម្បត្តិ ឬព្រហ្មសម្បត្តិទេ ដែលព្រះអង្គកសាងបំពេញបុណ្យបារមីមកនោះ បានប្រាថ្នាចំពោះតែព្រះសព្វញ្ញុតញ្ញាណតែម៉្យាងប៉ុណ្ណោះ ដើម្បីនឹងត្រូវការចម្លងសត្វលោក ឲ្យរួចផុតអំពី

សេចក្តីទុក្ខ ឬសង្សារវដ្ត បពិត្រទ្រង់និទុក្ខ ឥឡូវនេះ កាលនេះ ជាកាលគួរដល់ព្រះអង្គហើយ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ ។

លំដាប់នោះ ព្រះបរមពោធិសត្វ ក៏មិនទាន់ទទួលពាក្យប្តេជ្ញា របស់ទេវតាទាំងឡាយទេ ទ្រង់បានប្រមើលមើលនូវមហាវិលោកនះ ទាំង ៥ ប្រការ គឺកាល ១ ទ្វីប ១ ប្រទេស ១ ត្រកូល ១ និងអាយុ របស់ព្រះមាតា ១ ។ ក្នុងមហាវិលោកនះទាំង ៥ ប្រការនោះ ព្រះពោធិសត្វ ឲ្យដឹងច្បាស់ជាមុនសិនថា ជាកាលមិនសមគួរ ឬជាកាលសមគួរ ។ ក្នុងសេចក្តីនោះ កាលនៃអាយុដែលចម្រើនឡើង ដល់ទៅមួយសែនឆ្នាំ ចាត់ថា ជាកាលមិនសមគួរ ។ ព្រោះហេតុអ្វី ? ព្រោះក្នុងកាលនោះ ជាតិ ជរា និងមរណៈ មិនប្រាកដលស់សត្វទាំងឡាយ ដ្បិតព្រះធម៌ទេសនា របស់ព្រះសម្ពុទ្ធទាំងឡាយ ដែលនឹងផុតចាកត្រៃលក្ខណ៍មិនមាន ។ កាលព្រះពុទ្ធត្រាស់ថា **អនិច្ចំ ទុក្ខំ អនត្តា** សត្វទាំងឡាយក៏នឹងគិតថា ព្រះសម្ពុទ្ធត្រាស់សេចក្តីនោះធ្វើអ្វី មុខជាមិនសម្គាល់នូវធម៌ដែលគួរ ស្តាប់ និងគួរជឿ តពីនោះ ក៏នឹងមិនមានការត្រាស់ដឹង កាលមិនមាន ការត្រាស់ដឹង សាសនាក៏នឹងមិនជាវត្ថុនាំចេញចាកទុក្ខបាន ព្រោះដូច្នោះ ទើបជាកាលមិនសមគួរ ។ សូម្បីកាលនៃអាយុតិចចុះពី ១០០ ឆ្នាំមក

ក៏ចាត់ជាកាលដែលមិនសមគួរដែរ ។ ព្រោះហេតុអ្វី ? ព្រោះក្នុងកាលនោះ សត្វទាំងឡាយមានកិលេសក្រាស់នៅក្នុងខន្ធសន្តាន កាលឲ្យឱវាទដល់អ្នកមានកិលេសក្រាស់នៅក្នុងខន្ធសន្តាននោះ មិនអាចធ្វើឲ្យអ្នកនោះ តាំងនៅក្នុងឱវាទនោះបានឡើយ ឱវាទនោះនឹងវិនាសបាត់បង់ទៅយ៉ាងឆាប់រហ័ស ដូចជាស្នាមគំនូសនៅក្នុងទឹកដូច្នោះដែរ ។ ព្រោះដូច្នោះ សូម្បីកាលនោះ ក៏ចាត់បានថាជាកាលមិនសមគួរ ។ កាលនៃអាយុថយតិចចុះមក ពីមួយសែនឆ្នាំដល់ត្រឹម ១០០ ឆ្នាំ ចាត់ជាកាលសមគួរ ។ និងក្នុងកាលនោះក៏ជាកាលនៃអាយុ ១០០ ឆ្នាំ ។ ព្រះពោធិសត្វក៏ប្រមើលមើលថា នេះជាកាលគួរដល់ព្រះពុទ្ធ ទ្រង់កើតឡើងនៅក្នុងលោកហើយ ។

បន្ទាប់អំពីនោះទៀត ក៏បានប្រមើលមើលនូវទ្វីបទាំង ៤ គឺប្រមើលមើលទ្វីបដែលព្រះពុទ្ធតែងកើត ព្រោះថា អតីតពុទ្ធទាំងឡាយមិនដែលកើតក្នុងទ្វីប ៣ គឺបុព្វវិទេហទ្វីប ១ អមរគោយានទ្វីប ១ និងឧត្តរកុរុទ្វីប ១ ទ្រង់កើតតែក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។

បន្ទាប់អំពីនោះទៀត ក៏ទ្រង់ប្រមើលមើលចំពោះប្រទេសថា ជម្ពូទ្វីបធំទូលំទូលាយ មានបរិមាណដល់មួយម៉ឺនយោជន៍ អតីតពុទ្ធ

ទាំងឡាយតែងកើតនៅក្នុងប្រទេសណាហ្ន៎ ទើបប្រមើលមើលឃើញមជ្ឈិមប្រទេស ។ ដែលឈ្មោះថា **មជ្ឈិមប្រទេស** គឺប្រទេសដែលលោកពោលទុកនៅក្នុងព្រះវិន័យយ៉ាងនោះថា ក្នុងទិសខាងកើតមាននិគមឈ្មោះថា **កជង្គលៈ** ទីដទៃចាកនិគមនោះ ជាទីធំទូលំទូលាយ ដទៃចាកទីនោះ ជាជនបទតាំងនៅក្នុងជាយដែន **រួមជាមជ្ឈិមប្រទេស** ។ ក្នុងទិសខាងត្បូងមានស្ទឹងមួយឈ្មោះថា **សល្លវតី** តពីនោះ ជាជនបទតាំងនៅក្នុងជាយដែន **រួមជាមជ្ឈិមប្រទេស** ។ ក្នុងទិសទក្សិណមាននិគមមួយឈ្មោះថា **សេតកណ្ណិក** តពីនោះ ជាជនបទតាំងនៅក្នុងជាយដែន **រួមជាមជ្ឈិមប្រទេស** ។ ក្នុងទិសខាងលិច មាននិគមមួយឈ្មោះថា **ថូណគ្រាម** តពីនោះ ជាជនបទតាំងនៅក្នុងជាយដែន **រួមជាមជ្ឈិមប្រទេស** ។ ក្នុងទិសខាងជើងមានភ្នំមួយ ដែលមានឈ្មោះថា **ឧសីរទ្ធជៈ** តពីនោះ ជាជនបទតាំងនៅក្នុងជាយដែន **រួមជាមជ្ឈិមប្រទេស** ។ មជ្ឈិមប្រទេសនោះ មានបណ្តោយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ ទំហំជុំវិញ ៩០០ យោជន៍ ។ ក្នុងប្រទេសនោះ ព្រះពុទ្ធទាំងឡាយក្តី ព្រះបច្ចេកពុទ្ធទាំងឡាយក្តី អគ្គសាវកពុទ្ធទាំងឡាយក្តី ស្តេចចក្រពត្តិទាំងឡាយក្តី ក្សត្រក្តី ព្រាហ្មណ៍ក្តី គហបតីមហាសាលទាំងឡាយក្តី

ជាអ្នកមានយសសក្តិធំៗ ក្តី តែងកើតនៅក្នុងមជ្ឈិមប្រទេស ។ នគរឈ្មោះថា **កបិលពស្តុ** ក៏តាំងនៅក្នុងមជ្ឈិមប្រទេសនោះដែរ ។ ព្រះពោធិសត្វ ទើបបានដល់នូវការសម្រេចចិត្តថា យើងគួរនឹងទៅកើតនៅក្នុងនគរនោះ ។

តអំពីនោះ ព្រះបរមពោធិសត្វ កាលនឹងជ្រើសរើសត្រកូល ទើបឃើញថា ត្រកូលនៃព្រះមាតារបស់ព្រះពុទ្ធទាំងឡាយ មិនដែលកើតនៅក្នុង **វេស្សត្រកូល** និង **សូទ្រត្រកូលទេ** ទ្រង់កើតតែនៅក្នុងត្រកូលពីរ គឺ **ខត្តិយត្រកូល** និង **ព្រាហ្មណត្រកូល** ត្រកូលណានីមួយក្នុងត្រកូលទាំងពីរនោះ ក៏ឥឡូវនេះ មានត្រកូលក្សត្រ ដែលមហាជនលើកតម្កើង យើងនឹងទៅកើតនៅក្នុងត្រកូលនោះ ព្រះបាទសុទ្ធោទនមហារាជ នឹងបានជាព្រះបិតារបស់យើង ដូចនេះ ។

បន្ទាប់អំពីនោះ កាលនឹងជ្រើសរើសព្រះមាតា ក៏បានឃើញថា ធម្មតាស្ត្រីជាពុទ្ធមាតា ជាអ្នកមិនល្មោះល្មោភក្នុងបុរស ជាអ្នកមិនផឹកសុរា ប៉ុន្តែនឹងជាអ្នកបានបំពេញបារមីរួចមកហើយ អស់មួយសែនកប្ប ជាអ្នករក្សាសីល ៥ មិនដាច់ជានិច្ច តាំងតែអំពីកំណើតមកផង ជាអ្នកប្រកបដោយសេចក្តីសុខជាប្រក្រតី មិនមានរោគយ៉ាងណានីមួយចូល

មកបៀតបៀនបានទៀតផង ។ វេលាព្រះបរមពោធិសត្វប្រសូតមក ពុទ្ធមាតាមានព្រះជន្មាយុតាំងនៅបាន ៧ ថ្ងៃ ព្រះរាជទេវីទ្រង់ព្រះនាមថា **មហាមាយា** ព្រះនាងជាព្រះមាតារបស់យើង ដូចនេះ ។

លុះព្រះពោធិសត្វបានប្រមើលមើលវិលោកនៈទាំង ៥ ប្រការ ដូច្នេះរួចហើយ បានគិតថា នែអ្នកនិទ្ទុក្ខទាំងឡាយ កាលនេះជាកាលដែលគួរ យើងនឹងបានជាព្រះពុទ្ធហើយ ទើបបានទទួលពាក្យបណ្ដូលរបស់ទេវតាទាំងឡាយ ហើយពោលថា សូមពួកលោកទៅចុះ បានជូនដំណើរទេវតាទាំងនោះត្រឡប់ទៅវិញហើយ ព្រះបរមពោធិសត្វចូលទៅកាន់ **នន្ទវនឧទ្យាន** ដែលស្ថិតនៅក្នុងស្ថានតុសិតបុរី ជាមួយនឹងពួកទេវតាជាបរិវារ ។ ការពិត នន្ទវនឧទ្យានមាននៅក្នុងទេវតាគ្រប់ជាន់ទេវតាក្នុងនន្ទវនឧទ្យាននោះពោលថា បពិត្រព្រះអង្គអ្នកជានិទ្ទុក្ខ សូមព្រះអង្គច្យុតចាកនន្ទវនឧទ្យាននេះទៅចុះ ដោយពួកទេវតាទាំងនោះ រង់ចាំក្រើនរំលឹកឲ្យព្រះពោធិសត្វរឭកដល់ឱកាសនៃកុសលកម្ម ដែលធ្លាប់ធ្វើកាលពីមុនមក ។ ព្រះពោធិសត្វដែលពួកទេវតារង់ចាំរំលឹក ឲ្យរឭកដល់កុសលកម្មយ៉ាងនេះហើយ ក៏បានបង្អោនចិត្តមកចុះចាប់បដិសន្ធិនៅក្នុងផ្ទៃនៃព្រះនាងមហាមាយាទេវី ក្នុងសក្យត្រកូល ត្រូវនឹងថ្ងៃព្រហស្បតិ៍

១៥ កើត ខែអាសាឍ ក្នុងឆ្នាំរកា ។ មានពាក្យដែលនឹងអធិប្បាយ តាមលំដាប់ ដូចនេះ ។

បានឮថា ក្នុងកាលនោះ នៅក្នុងនគរកបិលពស្តុ មានបុណ្យនក្ខត្តឫក្សយ៉ាងឱឡារិក មហាជនបាននាំគ្នាទៅលេងមហោស្រព រីឯព្រះនាងមហាមាយាទេវីនៅសល់ ៧ ថ្ងៃទៀត នឹងដល់ថ្ងៃពេញបូរមីនៃខែអាសាឍ ទ្រង់បានទៅលេងបុណ្យនក្ខត្តឫក្សនឹងគេដែរ តែទ្រង់មិនបានសោយសុរាទេ មានតែការស្អិតស្អាងព្រះកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូបផ្សេងៗ ហើយក៏ស្តេចយាងចេញទៅកម្សាន្តបុណ្យនក្ខត្តឫក្សនោះនឹងគេដែរ លុះដល់ថ្ងៃទី ៧ ព្រះនាងបានតើនឡើងអំពីព្រលឹម ទ្រង់ស្រង់សុគន្ធវារីរួចហើយ ក៏បានបរិច្ចាគទ្រព្យ ចំនួន ៤ សែនកហាបណៈ ឲ្យជាទាន ទ្រង់ស្អិងស្អាងនូវព្រះកាយ ដោយគ្រឿងប្រដាប់គ្រប់យ៉ាង ទ្រង់សោយព្រះក្រយាហារយ៉ាងប្រណីតរួចព្រះនាងបានអធិដ្ឋាននូវអដ្ឋឧបោសថសីល ហើយស្តេចក៏បានយាងចូលទៅកាន់បន្ទប់ដ៏មានសិរី ផ្ទំលើព្រះសិរីសេយ្យនា ឈានចុះកាន់និទ្រារម្មណ៍ ទ្រង់បានព្រះសុបិនឃើញថា មានស្តេចចតុលោកទាំង ៤ មកលើកព្រះនាងទាំងសេយ្យា នាំចូលទៅកាន់ព្រៃហិមពាន្ត ហើយដាក់

ព្រះនាងលើមនោសិលា មានទំហំប្រមាណ ៦០ យោជន៍ ខាងក្រោមដើមមហាសាលព្រឹក្សមួយដើមកម្ពស់ ៧ យោជន៍ ។ គ្រានោះ នាងទេពធីតាទាំងឡាយរបស់ស្តេចចតុលោកទាំង ៤ នោះ មកយាងព្រះនាងទៅស្រង់ទឹកនៅឯអនោតត្តស្រះ ដុសជម្រះព្រះកាយ ដែលជាមន្ទិលរបស់មនុស្សចេញ ហើយឲ្យព្រះនាងស្លៀកដណ្តប់សំពត់ជាទិព្វថែមទាំងលាបដោយគ្រឿងក្រអូបជាទិព្វទៀតផង ។ នៅក្នុងទីជិតស្រះនោះមានភ្នំប្រាក់មួយ នៅខាងលើភ្នំប្រាក់នោះ មានសុវណ្ណវិមាន ។ នាងទេពធីតាទាំងឡាយ បានតាក់តែងទិព្វសេយ្យាសនរួចហើយ ក៏យាងព្រះនាងឲ្យទៅផ្ទំ នៅក្នុងសុវណ្ណវិមាននោះ បែរសិរសាទៅកាន់ទិសខាងកើតទូលឲ្យព្រះនាងផ្ទំនៅក្នុងសុវណ្ណគិរីនោះ មានសេតហត្ថី ១ ត្រាច់ចរលើសុវណ្ណបព៌តនោះ ឡើងទៅកាន់ភ្នំប្រាក់ តាមផ្លូវទិសឧត្តរ ( ទិសខាងលើ ឬទិសខាងជើង ) មានប្រមោយសម្បុរ.ស ហាក់បីដូចជាកម្រងផ្កាប្រាក់ កាន់ផ្កាឈូក.ស បានបន្លឺនូវកោញ្ចនាទ ចូលមកក្នុងសុវណ្ណវិមាន ដើរប្រទក្សិណព្រះនាង ៣ ជុំ ហើយហាក់បីដូចជាទម្លាយព្រះឧទរ ចូលមកតាមសរីរៈប្រទេសខាងស្តាំ ។ សុបិននិមិត្តនេះ គឺជាតួអង្គព្រះពោធិសត្វមកចុះចាប់បដិសន្ធិក្នុងវេលានោះ ដោយប្រការ

ដូច្នេះឯង ។

លុះដល់វេលាព្រឹកឡើង ព្រះនាងតើនឡើងហើយ ក៏ស្ដេចយាង ទៅក្រាបទូលនូវព្រះសុបិននោះចំពោះព្រះរាជា ( ព្រះបាទសុទ្ធោទនៈ ជាព្រះស្វាមី ) ព្រះរាជាទ្រង់ត្រាស់បង្គាប់រាជបុរស ឲ្យអញ្ជើញពួក ព្រាហ្មណ៍ចំនួន ៦៤ នាក់ ចូលមកគាល់ ឲ្យចាត់ចែងក្រាលអាសនៈ ដ៏មានតម្លៃ ថែមទាំងឲ្យរៀបចំគ្រឿងសក្ការៈដែលជាមង្គល ធ្វើដោយ លាជជាដើម ឲ្យរៀបចំដាក់បាយាសដ៏ប្រសើរ លាយដោយទឹកដោះថ្លា ទឹកឃ្មុំ និងស្ករគ្រាត ដរាបដល់ពេញភាជនៈមាស និងភាជនៈប្រាក់ គ្របដោយសាជី ហើយឲ្យជូនដល់ពួកព្រាហ្មណ៍ពិសាដរាបដល់ឆ្អែត ស្កប់ស្កល់ ព្រមទាំងឲ្យសំពត់ថ្មីជាដើម ។ គ្រានោះ កាលពួកព្រាហ្មណ៍ ទាំងនោះ បរិភោគឆ្អែតស្កប់ស្កល់ដោយបាយ និងទឹកគ្រប់យ៉ាងហើយ ទើបព្រះរាជាត្រាស់ប្រាប់ព្រះសុបិន ហើយត្រាស់សួរថា នឹងមានអ្វី ដែលត្រូវកើតឡើងឬ ? ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ ព្រះអង្គទ្រង់កុំមានវិតក្កអ្វីឡើយ ព្រះរាជទេវី ទ្រង់តាំងព្រះគភ៌ហើយ ព្រះគភ៌ដែលតាំងឡើងនោះ ជាព្រះរាជបុត្រា មិនមែនជាព្រះរាជបុត្រីទេ ព្រះអង្គនឹងមានព្រះរាជបុត្រា ។ ប្រសិនបើព្រះរាជបុត្រានោះ ទ្រង់

នឹងនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ បើស្តេចយាងទៅសាងព្រះផ្នួស នឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ទ្រង់មានកិលេសដូចដំបូលផ្ទះដែលរបើកហើយ ព្រះអង្គជាអ្នកស្រោចស្រង់សត្វលោកឲ្យរួចអំពីសេចក្តីទុក្ខទៀតផង ។

ក្នុងខណៈដែលព្រះពោធិសត្វ មកចុះចាប់បដិសន្ធិនៅក្នុងផ្ទៃនៃព្រះមាតានោះ លោកធាតុទាំងមួយម៉ឺន ក៏បានកម្រើកញាប់ញ័រឡើងទាំងបុព្វនិមិត្ត ៣២ ប្រការ ក៏ប្រាកដឡើងដែរ ។ ក្នុងម៉ឺនចក្រវាឡមានពន្លឺភ្លឺច្បុះផ្សាយទូទៅសព្វចក្រវាឡប្រមាណមិនបាន ។ពួកមនុស្សខ្វាក់ក៏ទៅជាមានភ្នែកភ្លឺ ហាក់បីដូចថា មានបំណងនឹងមើលព្រះសរីរៈរបស់ព្រះពោធិសត្វនោះ ។ ពួកមនុស្សថ្លង់ ក៏បានស្តាប់ឮសូរស័ព្ទសំឡេងបាន ។ ពួកមនុស្ស.គ ក៏អាចនិយាយឆ្លើយឆ្លងគ្នាបាន ។ ពួកមនុស្សគម បែរជាមានខ្លួនត្រង់បានវិញ មនុស្សខ្វិន មានអវយវៈដើរបាន សត្វទាំងពួងដែលជាប់ចំណង ឬខ្នោះឃ្នាងជាដើម បានរួចចាកចំណង ភ្លើងដែលឆេះនៅក្នុងនរកទាំងអស់ ក៏បានរលត់ទាំងអស់ដែរ សេចក្តីស្រេកឃ្លានរបស់ពួកប្រេត ក៏បានស្ងប់រំងាប់ទៀត ពួកសត្វតិរច្ឆានក៏មិនមានភ័យដែរ ពាក្យពោលជាទីស្រឡាញ់ពេញចិត្តដល់គ្នា

និងគ្នាក៏មានឡើង រោគ និងភ្លើងកិលេស មានរាគៈជាដើមរបស់សត្វទាំងពួងក៏ស្ងប់រំងាប់ សេះក៏កញ្ច្រៀវដោយសំឡេងដ៏ពីរោះ ដំរីក៏បានស្រែកដោយសំឡេងដ៏ពីរោះ តូរ្យតន្ត្រីទាំងពួង ក៏បានបញ្ចេញសំឡេងទ្រហឹងអឺងកងដោយខ្លួនឯង មិនបាច់មានអ្នកណាវាយ ឬផ្លុំឡើយ គ្រឿងអាភរណៈ ដែលពាក់នឹងដៃមនុស្សទាំងឡាយ ក៏បានបញ្ចេញសូរស័ព្ទលាន់ឮឡើង ទិសទាំងពួង ក៏ភ្លឺស្រឡះថ្លាស្អាត ខ្យល់ត្រជាក់បក់ផាត់មកត្រសៀកៗ ឲ្យកើតសេចក្តីសុខដល់សត្វទាំងឡាយ មេឃក៏បង្អុរភ្លៀងមកខុសកាល ទឹកផុសផុលឡើងលើផែនដី ពួកបក្សីក៏បានលះបង់ដំណើរទៅតាមអាកាស នទីធំតូចដែលមានទឹកហូរទៅក៏ឈប់ហូរ ទឹកសមុទ្រក៏ត្រឡប់ជាមានរសផ្អែម ផ្ទៃផែនដីដេរដាសទៅដោយផ្កាឈូក ៥ ពណ៌ ផ្កានៃរុក្ខជាតិ តិណជាតិដែលស្ថិតនៅលើគោកនិងនៅក្នុងទីទឹក ក៏រីកស្គុសស្គាយឡើងទាំងអស់ ដើមឈើទាំងឡាយមានផ្ការីកចេញអំពីដើមខ្លះ រីកចេញអំពីមែកខ្លះ ដើមឈូកដុះទម្លាយចេញអំពីផ្ទៃថ្ម ៧ ដើម គ្រប់ដុំថ្ម មានផ្កាឈូកសំយុងចុះអំពីទ្ធដ៏អាកាស មានភ្លៀងផ្កាបង្អុរចុះមក មានតន្ត្រីទិព្វប្រគំនាទ្ធដ៏អាកាស លោកធាតុទាំងមួយម៉ឺន ក៏វិលទៅដូចជាសំណុំកម្រងផ្កា ដែលគេបោះគ្រវែងទៅ

ពួដ៏អាកាស បានប្រោះព្រំដោយគ្រឿងក្រអូប មានលម្អដ៏ឆើតឆាយ ។

តាំងអំពីថ្ងៃ ដែលព្រះពោធិសត្វចាប់បដិសន្ធិមក ដើម្បីនឹងជួយរក្សាការពារនូវសេចក្តីអន្តរាយ ក្រែងកើតមានដល់ព្រះពោធិសត្វ និងព្រះរាជមាតា មានទេវបុត្រ ៤ អង្គ ដែលមានដៃកាន់ព្រះខ័នចាំរក្សាការពារ ។ ការគិតទាក់ទងនឹងរាគៈ ក្នុងបុរសទាំងឡាយ មិនបានកើតឡើង ចំពោះព្រះរាជមាតានៃព្រះពោធិសត្វឡើយ ព្រះនាងមានតែសម្បូរទៅដោយលាភដ៏ច្រើន និងភាពប្រសើរដោយឥស្សរិយយស ថែមទាំងមានសេចក្តីសុខ មានព្រះវរកាយមិនលំបាកទៀតផង បានទតឃើញព្រះពោធិសត្វ ដែលនៅក្នុងគភ៌ ហាក់បីដូចជាអំបោះពណ៌ស ដែលដោតទុកក្នុងកែវមណីដ៏ថ្លា ធម្មតាគភ៌ដែលព្រះពោធិសត្វអាស្រ័យនៅ ដូចគ្នានឹងបន្ទប់នៅក្នុងព្រះគន្ធកុដិ សត្វដទៃមិនអាចនឹងអាស្រ័យនៅ ឬបរិភោគរួមបាន ព្រោះដូច្នោះ ព្រះរាជមាតានៃព្រះពោធិសត្វ ទើបទ្រង់សោយព្រះវិលាល័យ ហើយទៅកើតនៅក្នុងស្ថានតុសិតបុរី ក្នុងកាលដែលព្រះពោធិសត្វប្រសូតបាន ៧ ថ្ងៃ ។ ចំពោះស្ត្រីដទៃមិនដល់ ១០ ខែខ្លះ ១០ ខែគត់ខ្លះ អង្គុយប្រសូតខ្លះ ដេកប្រសូតខ្លះ យ៉ាងណានីមួយ ចំណែកព្រះរាជមាតារបស់ព្រះពោធិសត្វ ពុំមែនដូច្នោះទេ ។ ព្រះនាង

នឹងរក្សាព្រះពោធិសត្វនៅក្នុងព្រះគភ៌គ្រប់ ១០ ខែគត់ហើយ ប្រថាប់ឈរប្រសូត ប្រការនេះឯង ជាធម្មតារបស់ព្រះរាជមាតានៃព្រះពោធិសត្វ ។ សូម្បីព្រះនាងមហាមាយាទេវី ទ្រង់រក្សាព្រះពោធិសត្វនៅក្នុងព្រះគភ៌អស់ ១០ ខែគត់នោះ ហាក់បីដូចរក្សាប្រេងទុកនៅក្នុងភាជនៈដូច្នោះ ។

ចំណែកខាងព្រះបរមពោធិសត្វ ដែលស្ថិតនៅក្នុងព្រះឧទរនៃព្រះរាជមាតា ព្រះអង្គគង់ពែនភ្នែន បែរព្រះភក្ត្រទៅខាងឧទរនៃព្រះមាតា ។ ព្រះបិដ្ឋិ ( ខ្នង ) ក៏បែរទៅខាងព្រះបិដ្ឋិ នៃព្រះរាជមាតាដែរ មិនមែនដូចជាមនុស្សសាមញ្ញដទៃឡើយ ។ ព្រះនាងទេវី លុះទ្រទ្រង់គភ៌គ្រប់បរិបូណ៌ហើយ ទ្រង់មានព្រះរាជបំណង នឹងស្តេចយាងទៅកាន់នគរទេវទហៈ ដែលជាជាតិភូមិនៃព្រះនាង ទើបក្រាបបង្គំទូលព្រះបាទសុទ្ធោទនមហារាជថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ប្រាថ្នានឹងទៅកាន់នគរទេវទហៈ ។ គ្រានោះ ព្រះបាទសុទ្ធោទនៈ ទ្រង់អនុញ្ញាតហើយ ទ្រង់ត្រាស់បង្គាប់ឲ្យពួករាជសេវកាមាត្យ ឲ្យតាក់តែងរាជវិថីតាំងអំពីនគរកបិលពស្តុ ទៅដល់នគរទេវទហៈ ។ តាក់តែងដោយចងដើមចេក តម្កល់ក្អមទឹកដោយទឹកពេញ ឲ្យចងទង់ជ័យ និងទង់សំពត់ឲ្យព្រះនាងទេវីគង់ប្រថាប់នៅលើសុវណ្ណសិវិកា ( គ្រែស្នែងមាស )

ឲ្យពួករាជសេវកាមាត្យមួយពាន់នាក់សែងទៅ មានសេនាយោធាមាត្យជាច្រើនហែហមទៅផងដែរ ។ ក៏ក្នុងចន្លោះព្រះនគរទាំងពីរ សូម្បីនគរទាំងពីរ ក៏មានសាលវ័នជាមង្គល ឈ្មោះថា **លុម្ពិនីវ័ន** ក៏ក្នុងសម័យនោះសាលវ័នទាំងអស់ មានផ្ការីកដូចគ្នា តាំងអំពីគល់ រហូតដល់ចុងចន្លោះពីមែក និងផ្កា មានហ្វូងបក្សី ៥ ពណ៌ មានពណ៌ដូចសត្វកន្លង់ចំនួនច្រើន ហើរយំបន្តគ្នាពេញលុម្ពិនីវ័នទាំងអស់ ព្រះរាជទេវី លុះបានឃើញដូច្នោះហើយ ក៏មានព្រះរាជហឫទ័យចង់ទស្សនា ឬកម្សាន្តក្នុងព្រៃនោះ ព្រោះបានទតឃើញលុម្ពិនីវ័ននោះ រាជសេវកាមាត្យ ក៏យាងព្រះនាងឲ្យចូលទៅក្នុងព្រៃសាលវ័ននោះ ។ ព្រះនាងស្តេចបានយាងចូលទៅ ខាងក្រោមដើមសាលព្រឹក្សមួយដើម ព្រះនាងទេវី ទ្រង់មានព្រះរាជបំណង ចង់ឈោងតោងមែកសាលព្រឹក្សនោះ ប៉ុន្តែមិនអាចនឹងឈោងព្រះហស្តទៅចាប់បាន ឯមែកសាលព្រឹក្សនោះ ហាក់បីដូចជាមានវិញ្ញាណ ក៏ទោរទន់ចុះមកថ្វាយឲ្យព្រះនាងចាប់ កាលបើព្រះនាងឈោងចាប់នូវមែកសាលព្រឹក្សនោះបានហើយ ក្នុងខណៈនោះឯង ខ្យល់កម្មជវាតក៏បណ្តាលកម្រើកឡើង នៅក្នុងព្រះឧទរនៃព្រះនាងទេវី ។ ពេលនោះមហាជនបានជ្រាបនូវហេតុនោះ ក៏បាននាំគ្នាយកសន្និយា ទៅបិទបាំង

ថ្វាយខាងក្រោមដើមសាលព្រឹក្ស ហើយថយចេញមក កាលព្រះនាងទេវី ទ្រង់ឈោងចាប់មែកសាលព្រឹក្សប្រថាប់ឈរនោះឯង ព្រះពោធិសត្វ ក៏ប្រសូត ( ទ្រង់ប្រសូតនៅថ្ងៃសុក្រ ១៥ កើត ខែពិសាខ ឆ្នាំច ) ។ គិតពីថ្ងៃព្រហស្បតិ៍ ១៥ កើត ខែអាសាឍ មកដល់ថ្ងៃ ១៥ ខែពិសាខនេះ គ្រប់ ១០ ខែគត់ ) ចាកព្រះឧទរ នៃព្រះរាជមាតាក្នុងវេលានោះ ។ ក្នុងខណៈនោះឯង ស្តេចមហាព្រហ្មមានចិត្តបរិសុទ្ធ ៤ អង្គ ក៏មកដល់ព្រមគ្នា យកបណ្តាញមាសទៅទទួលព្រះពោធិសត្វ ដាក់ទុកនៅត្រង់ព្រះភក្ត្រនៃព្រះរាជមាតា ទូលបណ្តើរថា បពិត្រព្រះរាជទេវី សូមព្រះនាងសប្បាយព្រះទ័យចុះ ព្រះរាជបុត្ររបស់ព្រះនាង មានសក្តាខ្ពង់ខ្ពស់ឡើងហើយ ដូចយ៉ាងថា មិនមែនដូចជាសត្វយ៉ាងដទៃ ការប្រសូតិចេញចាកគភ៌នៃមាតា រមែងប្រឡាក់វត្ថុដែលជារបស់បដិកូល ដែលមិនស្អាតប្រសូតចេញមក យ៉ាងណា ឯព្រះពោធិសត្វពុំមែនដូច្នោះទេ គឺព្រះពោធិសត្វនោះ ប្រសូតមកដោយសណ្តូកដៃ និងជើងទាំងពីរចុះក្រោម ប្រសូតមកឈរត្រង់ ដូចជាធម្មកថិក ចុះពីលើធម្មាសនៈ ពុំនោះសោត ដូចជាបុរសដែលចុះអំពីជណ្តើរ ពុំបានប្រឡាក់ដោយរបស់មិនស្អាតយ៉ាងណាទីមួយឡើយ ដែលមាននៅក្នុងគភ៌នៃព្រះមាតា

ជាអ្នកស្អាតបរិសុទ្ធរុងរឿង ដូចជាកែវមណី ដែលគេដាក់ទុកលើសំពត់កម្ពល ឬសំពត់កាសិកពស្ត្រ ការប្រសូតិបាកគភ៌ ព្រះរាជមាតារបស់ព្រះពោធិសត្វ សូម្បីដូចនេះហើយ ក៏មានធារទឹកពីរខ្សែ គឺទឹកក្ដៅនិងទឹកត្រជាក់ ហូរធ្លាក់ចុះមកអំពីអាកាសមកស្រោចស្រពព្រះសរីរៈរបស់ព្រះពោធិសត្វ និងព្រះរាជមាតា ធ្វើអប់ឧណ្ហជាទីសប្បាយ ដើម្បីជាគ្រឿងសក្ការៈដល់ព្រះពោធិសត្វ និងព្រះរាជមាតា ។ លំដាប់នោះស្ដេចមហារាជទាំង ៤ អង្គ បានទទួលព្រះពោធិសត្វនោះ ពីដៃរបស់មហាព្រហ្ម ដោយគ្រឿងកម្រាល ដែលគេធ្វើដោយស្បែកខ្លាមានសម្ផស្សទន់ល្មៃ ដែលសន្មតថា ជាមង្គល ឯពួកមនុស្ស ទើបយកសំពត់ទុកូលពស្ត្រ ទៅទទួលព្រះពោធិសត្វអំពីដៃរបស់ស្ដេចមហារាជទាំង ៤ លុះផុតពីដៃនៃពួកមនុស្សហើយ ព្រះពោធិសត្វ ក៏ទ្រង់ប្រថាប់ឈរនៅលើប្រឹថពី បែរព្រះភក្ត្រទៅទិសខាងកើត ពួកទេវតា និងមនុស្សក្នុងទីនោះ បាននាំគ្នាបូជាដោយរបស់ក្រអូប និងផ្កាកម្រងជាដើម បានក្រាបទូលថា បពិត្រព្រះអង្គ បុរសដទៃក្នុងទីនេះ ដូចគ្នានឹងព្រះអង្គមិនមានឡើយ មនុស្សដែលក្រៃលែងជាងព្រះអង្គ នឹងមានមកអំពីទីណា ។ លំដាប់នោះ ព្រះពោធិសត្វ ទ្រង់ប្រមើលមើលទៅ

គ្រប់ទិសទាំង ១០ គឺទិសតូច ៤ ទិសធំ ៤ ទិសខាងក្រោម និងទិសខាងលើ ក៏ទ្រង់មិនបានមើលឃើញនរណាមួយស្មើនឹងព្រះអង្គឡើយ ទ្រង់បានត្រិះរិះថា នេះជាទិសខាងជើង ហើយទ្រង់បែរព្រះភក្ត្រផ្ទោះទៅកាន់ទិសខាងជើង ទ្រង់យាងទៅបាន ៧ ជំហាន មានស្តេចមហាព្រហ្មបាំងស្វេតច្ឆត្រថ្វាយ ស្តេចសុយាមទេវបុត្រកាន់វាលវិជនីបក់ថ្វាយ និងពួកទេវតាអង្គដទៃ មានដៃកាន់គ្រឿងរាជកកុធភណ្ឌដ៏សេសតាមហែហមព្រះអង្គ ។ តពីនោះ ទ្រង់ប្រថាប់ឈរនៅត្រង់ជំហានទី ៧ ទ្រង់បានបន្លឺនូវអសភិវាចា ( វាចាជារបស់ឧសភបុរស ) ជាដើមថា **ខ្លួនអញជាកំពូលនៃលោក ខ្លួនអញជាបុគ្គលប្រសើរជាងគេក្នុងលោក ខ្លួនអញជាចម្បងជាងគេទាំងអស់ក្នុងលោក ជាតិនេះជាកំណើតចុងក្រោយបំផុតរបស់អញ អំណឹះតទៅមុខ អញគ្មានកើតទៀតឡើយ ។**

ពិតណាស់ ព្រះពោធិសត្វ ដែលប្រសូតចាកគភ៌មាតាមក ដែលអាចបញ្ចេញវាចាបានមាន ៣ អត្តភាពប៉ុណ្ណោះ គឺអត្តភាពជាព្រះមហោសថ ១ ក្នុងអត្តភាពជាព្រះវេស្សន្តរ ១ និងនៅក្នុងអត្តភាពជាតិចុងក្រោយនេះ ១ ។ មានន័យថា ក្នុងអត្តភាពជាព្រះមហោសថ កាលព្រះពោធិសត្វប្រសូតចាកគភ៌មាតាមក សក្កទេវរាជ ទ្រង់យក

ខ្ទឹមចន្ទន៍មកដាក់នៅត្រង់បាតដៃ នៃព្រះពោធិសត្វ ហើយស្តេចយាង ត្រឡប់ទៅវិញ ព្រះពោធិសត្វក្តាប់ខ្ទឹមចន្ទន៍នោះទុកនៅត្រង់បាតដៃ ។ គ្រានោះ មាតាទើបសួរព្រះពោធិសត្វថា នែបា កូនកាន់អ្វី ព្រះពោធិសត្វ ឆ្លើយថា បាទម៉ែ ថ្នាំ ដូច្នេះហើយ ញាតិទាំងឡាយ ទើបដាក់ឈ្មោះថា **ឱសថទារក** ( ក្មេងកាន់ថ្នាំ ) ជនទាំងឡាយ ទើបយកថ្នាំនោះទៅដាក់ទុក ក្នុងពាងឱសថនោះឯង បានជាថ្នាំរក្សារោគសព្វគ្រប់ សូម្បីមនុស្ស ដែលមានភ្នែកខ្វាក់ ត្រចៀកថ្លង់ជាដើមក៏ជាដែរ ដែលនាំគ្នាមកសូម ។ តមក ព្រោះប្រកាន់យកពាក្យដែលនិយាយថា ឱសថនេះមានគុណច្រើន ឱសថនេះមានគុណច្រើន ព្រះពោធិសត្វ ទើបមានឈ្មោះឡើងមួយ ទៀតថា **មហោសថ** ។ ចំណែកក្នុងអត្តភាពជាព្រះវេស្សន្តរ ព្រះពោធិសត្វ ប្រសូតចាកគភ៌មាតាមកភ្លាមហើយ ក៏លាតដៃចេញមកពោលថា បពិត្រព្រះមាតា ក្នុងផ្ទះមានទ្រព្យខ្លះទេ កូននឹងឲ្យទាន គ្រានោះ ព្រះមាតានៃព្រះពោធិសត្វនោះពោលថា នែបុត្រ បុត្រកើតនៅក្នុង ត្រកូលដែលមានទ្រព្យ ពោលដូច្នេះហើយ ក៏ដាក់ថង់ប្រាក់មួយពាន់ កហាបណៈ នៅលើបាតដៃរបស់ព្រះអង្គ នៅក្នុងអត្តភាពជាព្រះវេស្សន្តរ បានបន្លឺសីហនាទដូច្នេះឯង ។ ព្រះពោធិសត្វ ដែលប្រសូតចាកគភ៌មាតា

មកក្លាម បានបន្ទឹវាចាបាន ដូចដែលបានពោលមកយ៉ាងនេះឯង ។ បុព្វនិមិត្ត ៣២ ប្រការ ក៏បានប្រាកដឡើង ក្នុងសម័យដែលព្រះពោធិសត្វនៃយើងកើតឡើងហើយ ក្នុងលុម្ពិនីវ័ននោះ ព្រះរាជទេវីទ្រង់ជាព្រះមាតានៃព្រះរាហុល ១ ឆន្នអាមាត្យ ១ កាឡុទាយីអាមាត្យ ១ ព្រះអានន្ទ ១ សេះកណ្ឋកៈ ១ មហាពោធិព្រឹក្ស ១ កំណប់ទ្រព្យទាំង ៤ រណ្តៅ ១ បានកើតឡើងក្នុងថ្ងៃជាមួយគ្នា ។ បណ្តារណ្តៅកំណប់ទ្រព្យទាំងនោះ កំណប់ទ្រព្យមួយមានទំហំ ១ គាវុត កំណប់ទ្រព្យមួយទៀតមានទំហំប្រមាណកន្លះយោជន៍ កំណប់ទ្រព្យមួយមានទំហំ ៣គាវុត កំណប់ទ្រព្យមួយមានទំហំ ១ យោជន៍ ព្រោះដូច្នោះ ទើបរួមជាសហជាតវត្ថុ ៧ យ៉ាងទាំងនេះ ។ ពួកអ្នកនគរទាំងពីរបាននាំព្រះពោធិសត្វត្រឡប់ទៅកាន់នគរកបិលពស្តុវិញ ។ ក្នុងថ្ងៃនោះឯង បណ្តាទេវតាក្នុងស្ថានតាវត្តិង្សរីករាយត្រេកអរថា ព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនមហារាជប្រសូតហើយនៅក្នុងនគរកបិលពស្តុ ព្រះរាជកុមារនេះ នឹងប្រថាប់គង់នៅក្រោមដើមពោធិព្រឹក្ស ហើយនឹងបានត្រាស់ជាព្រះពុទ្ធដូចនេះ ទើបទេវតាទាំងឡាយទូទាំងទេវលោក បាននាំគ្នាថ្វាយពរសាធុការ ទាំងបូជាដោយគ្រឿងសក្ការៈដ៏ច្រើនក្រៃលែងទៀតផង ។

ក្នុងសម័យនោះ មានតាបសម្នាក់ ដែលធ្លាប់ស្និទ្ធស្នាលជាមួយនឹងត្រកូលរបស់ព្រះបាទសុទ្ធោទនៈ ទាំងជាអ្នកបានសម្រេចសមាបត្តិ ៨ ឈ្មោះថា **កាឡទេវិលតាបស** ឬ **អសិតតាបស** ក្រោយអំពីទទួលភត្តាហាររួចស្រេចហើយ ទើបហោះទៅកាន់ស្ថានតាវត្តិង្ស ដើម្បីសម្រាកក្នុងពេលថ្ងៃ ។ គ្រាដែលអង្គុយសម្រាកពេលថ្ងៃនៅទីនោះ បានឃើញទេវតាទាំងអស់នោះ មានសភាពសប្បាយរីករាយក្នុងចិត្ត ទើបសួរថា ព្រោះហេតុអ្វី បានជាពួកលោកមានចិត្តត្រេកអររីករាយយ៉ាងនេះ សូមប្រាប់ហេតុនោះដល់អាត្មាបានជ្រាបផង ពួកទេវតាទាំងអស់នោះ បានប្រាប់ហេតុនោះយ៉ាងនេះថា បពិត្រលោកម្ចាស់ អ្នកជានិទ៌ុក្ខ ព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនមហារាជបានប្រសូតហើយ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធនៅក្រោមដើមពោធិព្រឹក្ស ហើយទ្រង់ប្រកាសនូវធម្មចក្រ ពួកខ្ញុំម្នាក់ៗ ដែលត្រេកអររីករាយព្រោះហេតុនេះឯង ពួកយើងនឹងបានឃើញព្រះពុទ្ធ និងបានស្តាប់ព្រះធម៌របស់ព្រះអង្គ តាបសនោះ បានស្តាប់ពាក្យរបស់ពួកទេវតាទាំងនោះហើយ ចុះចាកស្ថានទេវលោកមួយរំពេចមក ចូលទៅកាន់ព្រះរាជនិវេសន៍ អង្គុយលើអាសនៈដែលគេរៀបចំទុកដោយល្អ ហើយបានក្រាបទូលព្រះរាជាថា

បពិត្រមហារាជ អាត្មាបានឮថា ព្រះរាជឱរសរបស់ព្រះអង្គប្រសូតហើយមែនឬ ព្រះអង្គ ? អាត្មាកាពចង់ឃើញព្រះរាជឱរសនោះ ព្រះរាជាត្រាស់ឲ្យនាំព្រះរាជឱរស ដែលប្រដាប់ស្អិតស្អាងព្រះកាយហើយឲ្យយកមក ដើម្បីឲ្យតាបសបានឃើញ ឬបានទមស្ការតាបស ។ លំដាប់នោះ ព្រះបាទទាំងគូរបស់ព្រះពោធិសត្វត្រឡប់ទៅជាប្រតិស្ឋាននៅលើជដារបស់តាបសនោះវិញ ពិតណាស់ បុគ្គលដទៃដែលឈ្មោះថាព្រះពោធិសត្វគួរនឹងសំពះ ឬថ្វាយបង្គំដោយអត្តភាពនោះមិនមានប្រសិនបើមនុស្សអ្នកមិនដឹង ដាក់សិរសោរបស់ព្រះពោធិសត្វត្រង់បាទទាំងមូលរបស់តាបស សិរសោរបស់តាបសនោះនឹងបែកជា ៧ ភាគ ។ តាបសគិតថា ការធ្វើខ្លួនរបស់យើងឲ្យវិនាសមិនសមគួរ ទើបក្រោកចាកអាសនៈហើយ ផ្គងអញ្ជលីសំពះចំពោះព្រះពោធិសត្វ ព្រះរាជបិតាទតឃើញហេតុអស្ចារ្យដូច្នោះហើយ ទើបទ្រង់សំពះព្រះរាជបុត្ររបស់ព្រះអង្គដែរ ។ តាបសនោះរឭកជាតិបាន ៨០ កប្ប គឺក្នុងអតីត ៤០ កប្បអនាគត ៤០ កប្ប ឃើញលក្ខណសម្បត្តិរបស់ព្រះពោធិសត្វដូច្នោះហើយទើបពិចារណាថា ព្រះរាជកុមារនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធទេហ្ន៎ បានជ្រាបថា នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ដោយមិនមានការសង្ស័យ

បានគិតទៀតថា ព្រះរាជបុត្រនេះជាអច្ឆរិយបុរស ទើបបានធ្វើការញញឹមឲ្យប្រាកដ តពីនោះ ទើបពិចារណាថា អាត្មាអញនឹងបានទាន់ ឬឃើញចំពោះការត្រាស់ដឹងជាព្រះពុទ្ធនេះទេហ្ន៎ ក៏បានជ្រាបថា យើងមិនបានទាន់ ឬឃើញចំពោះការត្រាស់ដឹងជាព្រះពុទ្ធនេះទេ ដោយយើងបានអស់ជីវិតទៅ ក្នុងរវាងនោះឯង ហើយបានទៅកើតក្នុងអរូបព្រហ្ម ដែលព្រះពុទ្ធចំនួនរយអង្គក្តី ពាន់អង្គក្តី មិនអាចនឹងស្តេចយាងទៅដើម្បីសម្តែងធម៌ឲ្យត្រាស់ដឹងបាន ហើយគិតថា អាត្មាអញនឹងមិនឃើញអច្ឆរិយបុរសដែលទ្រង់បានជាព្រះពុទ្ធដូចនេះបានឡើយ អាត្មាអញជាអ្នកមានសេចក្តីវិនាសយ៉ាងធំ គិតឃើញដូច្នេះហើយ ក៏ស្រែកយំឡើងភ្លាម ។ ពួកមនុស្សឃើញហើយ ទើបសួរថា លោកម្ចាស់ កាលអម្បាញ់មិញនេះឯងលោកម្ចាស់សើច ហើយឥឡូវនេះ ត្រឡប់បែរទៅជាយំវិញ បពិត្រលោកម្ចាស់ដ៏ចម្រើន អន្តរាយអ្វីនឹងកើតមានចំពោះព្រះរាជបុត្ររបស់យើងឬ ? តាបសតបថា ព្រះអង្គមិនមានអន្តរាយអ្វីទេ នឹងបានត្រាស់ជាព្រះពុទ្ធ ដោយមិនត្រូវសង្ស័យ ។ ពួកមនុស្សសួរថា បើដូច្នោះព្រោះហេតុអ្វី បានជាលោកម្ចាស់យំ ? តាបសនោះតបថា ដែលអាត្មាយំព្រោះសោកស្តាយខ្លួនអាត្មាថា មិនបានទាន់ ឬមិនបានឃើញព្រះមហា

បុរស ទ្រង់ជាព្រះពុទ្ធ ដូច្នេះ សេចក្តីវិនាសយ៉ាងធំ នឹងមានចំពោះអាត្មា អាត្មាជ្រាបដូច្នេះហើយ ទើបបានជាអាត្មាយំ ។

តពីនោះ តាបសពិចារណាទៅទៀតថា ក្នុងពពួកញាតិរបស់អាត្មាអញ នឹងមានញាតិណាមួយ បានឃើញ ឬទាន់ព្រះអង្គបានត្រាស់ជាព្រះពុទ្ធ លុះពិចារណាទៅៗ ក៏បានដឹងថា នាលកកុមារ ជាក្មួយរបស់យើង ជាអ្នកបានទាន់ ឬបានឃើញព្រះពុទ្ធ ។ កាលគិតឃើញដូច្នេះហើយ ក៏លាព្រះរាជា ដោយដើរសំដៅទៅកាន់ផ្ទះប្អូនស្រីរបស់លោក លុះទៅដល់ហើយ ក៏បង្គាប់ទៅប្អូនស្រី ឲ្យហៅនាលកមាណពមក កាលនាលកមាណពមកដល់ហើយ បាននិយាយប្រាប់ថា នែនាលកៈ ព្រះរាជឱរសកើតឡើងហើយ នៅក្នុងត្រកូលរបស់ព្រះបាទសុទ្ធោទនៈ ជាពូជពន្លកនៃព្រះពុទ្ធ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ កាលកន្លងទៅ ៣៥ ឆ្នាំ តពីឆ្នាំនេះទៅ អ្នកនឹងបានឃើញព្រះអង្គ ចូរអ្នកបួសក្នុងថ្ងៃនេះឲ្យហើយទៅ នាលកៈ លោកក៏ជាអ្នកមានបុណ្យបារមីម្នាក់ដែរ ទើបធ្វើឲ្យលោកកើតនៅក្នុងត្រកូល ដែលជាអ្នកមានទ្រព្យសម្បត្តិ ៨៧ កោដិ លោកបានគិតថា ឪពុកធំរបស់អញមិនមែនដឹកនាំអញឲ្យប្រកបក្នុងអំពើឥតប្រយោជន៍ទេ ខណៈនោះឯង

ឲ្យមនុស្សទៅទិញសំពត់កាសាវៈ និងបាត្រដីមកអំពីផ្សារ ឲ្យគេកោរសក់ និងពុកមាត់ពុកចង្ការរួចហើយ បានស្លៀកដណ្តប់សំពត់កាសាវៈ ផ្គងអញ្ជលីបែរមុខទៅរកព្រះបរមពោធិសត្វ ដោយពោលថា បុគ្គលជាឧត្តមបុរសក្នុងលោក ផ្នួសរបស់អាត្មាអញនេះ សូមឧទ្ទិសចំពោះបុគ្គលនោះ ហើយបានក្រាបថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន ហើយក៏ប្រកបបាត្រចូលទៅក្នុងស្ពាក ស្ពាយលើចង្កេះស្មា ហើយដើរទៅធ្វើនូវសមណធម៌ នៅក្នុងព្រៃហិមពាន្ត ។ លោកចូលទៅគាល់ព្រះតថាគត ដែលព្រះអង្គបានសម្រេចអភិសម្ពោធិគ្រាដំបូង ទូលសូមឲ្យព្រះអង្គ ទ្រង់សម្តែងនាលកបដិបទា ហើយចូលទៅកាន់ព្រៃហិមពាន្តទៀត បានសម្រេចព្រះអរហត្ត ប្រព្រឹត្តខ.បដិបទាយ៉ាងតឹងរ៉ឹងបំផុត រក្សាអាយុបានត្រឹមតែ ៧ ខែ លោកក៏បានបរិនិព្វានទៅ ។

ក្នុងថ្ងៃទី ៥ ញាតិវង្សទាំងឡាយគិតថា ពួកយើងនឹងស្រោចស្រង់ព្រះកេសរបស់ព្រះពោធិសត្វ ហើយតាំងវិធីជ្រើសរើសព្រះនាមថ្វាយចំពោះព្រះអង្គ ដូចនេះហើយ ឲ្យតាក់តែងព្រះរាជវាំង ប្រោះព្រំដោយគន្ធជាតិ ៤ យ៉ាង ព្រមទាំងរាយផ្កាជាទី ៥ ឲ្យចម្អិនបាយាសសុទ្ធ ឲ្យអញ្ជើញពួកព្រាហ្មណ៍ អ្នករៀនចប់វិជ្ជាត្រៃវេទចំនួន ១០៨ នាក់មក

ដើម្បីទទួលបិណ្ឌបាត កាលពួកព្រាហ្មណ៍ទាំងនោះមកដល់ ក៏អញ្ជើញឲ្យអង្គុយលើអាសនៈដែលគេរៀបចំទុកហើយដោយល្អ រួចបានអង្គាសភត្តាហារដ៏ប្រណីតដល់ពួកព្រាហ្មណ៍ទាំងអស់នោះ ថែមទាំងបូជាដោយគ្រឿងសក្ការៈជាច្រើនទៀត ពេលដែលពួកព្រាហ្មណ៍ទាំងនោះ ទទួលទានអាហារបិណ្ឌបាតរួចហើយ ឲ្យទុកតែពួកព្រាហ្មណ៍ ៨ នាក់ប៉ុណ្ណោះ ព្រះរាជាបានសួរពួកព្រាហ្មណ៍ទាំងនោះថា អ្វីហ្ន៎នឹងមាន ហើយឲ្យពិនិត្យមើលលក្ខណៈព្រះបរមពោធិសត្វ បណ្តាពួកព្រាហ្មណ៍ ៨ នាក់នោះគឺ

១- រាមព្រាហ្មណ៍ ២- ធជព្រាហ្មណ៍ ៣- សុជាតព្រាហ្មណ៍ ៤- លក្ខណព្រាហ្មណ៍ ៥- ភោជព្រាហ្មណ៍ ៦- សុយាមព្រាហ្មណ៍ ៧- កោណ្ឌញ្ញព្រាហ្មណ៍ ៨- សុទត្តព្រាហ្មណ៍ ។

សុទ្ធតែជាព្រាហ្មណ៍ចេះចាំស្ទាត់ក្នុងវិជ្ជាត្រៃវេទ ។ ព្រាហ្មណ៍អ្នកពិនិត្យមើលព្រះលក្ខណៈ សូម្បីសុបិនក្នុងថ្ងៃដែលព្រះពោធិសត្វមកចុះចាប់បដិសន្ធិ ព្រាហ្មណ៍ទាំងនោះ ក៏បានពិនិត្យមើលហើយ ។ បណ្តាព្រាហ្មណ៍ទាំង ៨ នាក់នោះ ព្រាហ្មណ៍ ៧ នាក់ បានលើកម្រាមដៃពីរឡើង ព្យាករ ២ យ៉ាងថា ព្រះរាជកុមារនេះ ដែលប្រកបដោយលក្ខណៈបែបនេះ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបាន

ជាស្ដេចចក្រពត្តិ បើព្រះអង្គចេញទៅបួស នឹងបានត្រាស់ជាព្រះពុទ្ធ ដូចនេះ ព្រាហ្មណ៍ម្នាក់ៗ នាំគ្នាទូលប្រាប់ដល់សម្បត្តិដ៏មានសិរី របស់ស្ដេចចក្រពត្តិ ។ ចំណែកកោណ្ឌញ្ញព្រាហ្មណ៍ ដែលនៅក្មេងជាងព្រាហ្មណ៍ទាំងនោះ ពិចារណាមើលភាពបរិបូណ៌នៃលក្ខណសម្បត្តិ របស់ព្រះពោធិសត្វហើយ ក៏លើកតែម្រាមដៃមួយ ហើយព្យាករតែម្យ៉ាងថា ព្រះពោធិសត្វនេះ មិនមានហេតុដែលត្រូវជាអ្នកនៅគ្រប់គ្រងផ្ទះនោះទេ ពិតជានឹងបានចេញបួសត្រាស់ដឹង ជាព្រះពុទ្ធយ៉ាងពិតប្រាកដមែន ។ ទ្រង់ជាអ្នកប្រាសចាកកិលេស ដែលដូចជាដំបូលផ្ទះដូច្នោះដែរ ។ ពិតណាស់ កោណ្ឌញ្ញព្រាហ្មណ៍នេះ ជាអ្នកបានកសាងសេចក្ដីល្អរួមកហើយ ជាសត្វដែលមានជាតិ ជាចុងក្រោយ មានបញ្ញាខ្ពង់ខ្ពស់ជាងព្រាហ្មណ៍ ៧ នាក់ទៀត បានឃើញគតិតែម្យ៉ាងប៉ុណ្ណោះថា ចំពោះអ្នកដែលប្រកបដោយលក្ខណសម្បត្តិយ៉ាងនេះ មិនមែនជាបុគ្គលដែលត្រូវនៅគ្រប់គ្រងផ្ទះនោះទេ ប្រាកដជានឹងចេញបួសបានត្រាស់ជាព្រះពុទ្ធដោយពិតប្រាកដមែន ព្រោះដូច្នោះ ទើបគេលើកតែម្រាមដៃមួយ ហើយព្យាករតែម្យ៉ាង ។ លំដាប់ពីនោះមក ព្រាហ្មណ៍ទាំងនោះ ក៏នាំគ្នាថ្វាយព្រះនាម ដល់ព្រះរាជកុមារថា **ព្រះសិទ្ធត្ថ** ។ បន្ទាប់មក ពួក

ព្រាហ្មណ៍ទាំងនោះ នាំគ្នាលាព្រះរាជា ត្រឡប់ទៅកាន់ផ្ទះវិញរៀងៗ ខ្លួន ហើយព្រាហ្មណ៍ម្នាក់ៗ បានហៅកូនមកប្រាប់ថា នែបាទាំងឡាយ ឪពុកចាស់ណាស់ទៅហើយ មិនអាចនៅទាន់ ឬបានឃើញព្រះរាជបុត្រ របស់ព្រះបាទសុទ្ធោទនៈ ទ្រង់បានសម្រេចព្រះសព្វញ្ញុតញ្ញាណនោះទេ ពួកអ្នកកាលបើព្រះរាជកុមារនោះ បានសម្រេចព្រះសព្វញ្ញុតញ្ញាណ ហើយ គប្បីចេញទៅបួសក្នុងសាសនារបស់ព្រះអង្គចុះ ព្រាហ្មណ៍ទាំង ៧ នាក់នោះ ក៏ស្ថិតនៅដរាបដល់អាយុក្ខ័យ ហើយក៏បានធ្វើមរណកាលទៅ ទៅតាមយថាកម្ម កោណ្ឌញ្ញមាណពប៉ុណ្ណោះ មិនមានរោគភ័យឈឺថ្កាត់ ផ្សេងៗ (មានជីវិតរស់នៅ) ។ កាលបើព្រះបរមពោធិសត្វចម្រើនវ័យ ធំដឹងក្តីហើយ ស្តេចបានចេញសាងមហាភិនេស្ក្រមណ៍ ស្តេចយាងទៅ កាន់ឧរុវេលាប្រទេសតាមលំដាប់ ទ្រង់កើតព្រះតម្រិះថា ភូមិភាគនេះ គួរជាទីរីករាយពិតណាស់ហ្ន៎ ស្ថានទីនេះសមរម្យដែលអាត្មាអញត្រូវ បំពេញនូវសេចក្តីព្យាយាម ចំពោះកុលបុត្រអ្នកមានសេចក្តីត្រូវការ ដោយការព្យាយាមនោះ សមគួរណាស់ គិតដូច្នេះហើយ ស្តេចក៏យាង ចូលទៅចាំវស្សាក្នុងទីនោះ ។ គ្រានោះ កោណ្ឌញ្ញព្រាហ្មណ៍ បានស្តាប់ ឮដំណឹងថា ព្រះមហាបុរសទ្រង់ព្រះផ្នួសហើយ ទើបចូលទៅរកបុត្រ

របស់ព្រាហ្មណ៍ទាំងនោះ និយាយយ៉ាងនេះថា ខ្ញុំបានឮដំណឹងមកថា ព្រះសិទ្ធត្ថកុមារទ្រង់ព្រះផ្នួសហើយ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ ដោយមិនសង្ស័យ បើបិតារបស់ពួកអ្នកមានជីវិតរស់នៅ ពួកគាត់ ប្រាកដជានឹងចេញបួសនៅក្នុងថ្ងៃនេះមិនខានឡើយ បើពួកអ្នកត្រូវការ នឹងបួសនោះ ចូរមកពួកយើង នឹងនាំគ្នាទៅបួសតាមព្រះមហាបុរស ពួកគេមិនបានព្រមគ្នា ជាឯកច្ឆ័ន្ទទាំងអស់គ្នាឡើយ ដោយបីនាក់ មិនព្រមចេញទៅបួស ៤ នាក់ក្រៅអំពីនោះ នាំគ្នាចេញទៅបួសតាម កោណ្ឌញ្ញព្រាហ្មណ៍ កោណ្ឌញ្ញព្រាហ្មណ៍បានជាប្រធាន លើអ្នកទាំង ៤ នាក់នោះ ទើបមានឈ្មោះថា **បញ្ចវគ្គិយ** ។

ក្នុងកាលនោះ ព្រះរាជាត្រាស់សួរថា ព្រះរាជបុត្រយើងឃើញអ្វី ទើបចេញបួស ? ព្រាហ្មណ៍បានក្រាបបង្គំទូលថា ឃើញនូវបុព្វនិមិត្ត ៤ ប្រការ ត្រាស់សួរទៀតថា អ្វីខ្លះ ? ព្រាហ្មណ៍ក្រាបទូលថា ១- មនុស្សចាស់ ២- មនុស្សឈឺ ៣- មនុស្សស្លាប់ ៤- អ្នកបួស ។ ព្រះរាជាត្រាស់ថា ចាប់ពីថ្ងៃនេះតទៅ កុំឲ្យមនុស្សបែបនេះ ចូលមក កាន់សម្នាក់នៃព្រះរាជបុត្រយើងឲ្យសោះ ដើម្បីឲ្យព្រះរាជបុត្រយើង បានគ្រប់គ្រងរាជសម្បត្តិ ដែលជាអ្នកធំក្នុងទ្វីបទាំង ៤ ដែលមានទ្វីប

តូចៗ ២០០០ ជាបរិវារ ជុំវិញទៅដោយប្រជានុរាស្ត្រ មានបរិមណ្ឌល បាន ៣៦ យោជន៍ ត្រាច់ទៅក្នុងផ្ទៃនភាកាស ។ កាលត្រាស់ដូច្នេះហើយ ទ្រង់មានព្រះតម្រាស់ឲ្យដាក់អ្នកចាំរក្សា ក្នុងទីគ្រប់ៗ កន្លែង ចម្ងាយមួយគាវុតគ្រប់ទិសទាំង ៤ ដើម្បីការពារនូវមនុស្សដែលមានប្រការដូចនេះ ចូលមកកាន់គន្លងចក្ខុរបស់ព្រះបរមពោធិសត្វបានឡើយ ។ ក្នុងថ្ងៃនោះ កាលត្រកូលព្រះញាតិ ៨០០០០ មកប្រជុំគ្នាក្នុងទីមង្គលដ្ឋាន ព្រះញាតិមួយព្រះអង្គៗ យល់ព្រមលើកបុត្រឲ្យមួយអង្គៗ ថា ព្រះរាជ-កុមារសិទ្ធត្ថនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ឬជាព្រះរាជាក៏ដោយ ពួកយើងនឹងថ្វាយបុត្រ ១ ព្រះអង្គៗ ទោះបីនឹងបានត្រាស់ជាព្រះពុទ្ធ ក៏នឹងមានសមណក្សត្រឲ្យកិត្តិយស និងហែហមត្រាច់ទៅ ។ ចំណែកឯព្រះរាជាក៏ទ្រង់តាំងនាងស្នំ ដែលសុទ្ធតែជាអ្នកមានរូបសម្ផស្សស្អាតល្អប្រាសចាកទោសគ្រប់ប្រការ ធ្វើឲ្យជាមេនំមេនាងថែរក្សា ព្រះពោធិសត្វទ្រង់ចម្រើនរុងរឿងជាមួយនឹងបរិវារ និងសិរីសម្បត្តិបែបនេះឯង ។

តមកថ្ងៃមួយ ព្រះរាជាមានព្រះរាជពិធីច្រត់ព្រះនង្គ័ល គឺវិធីវប្បមង្គល ថ្ងៃនោះ ពួកអាមាត្យតាក់តែងព្រះនគរទាំងមូល ដូចជាវិមាននៃទេវតា ។ ទាំងពួកទាសៈ និងពួកកម្មករទាំងអស់ ម្នាក់ៗ ស្លៀក-

ដណ្តាប់សំពត់ថ្មីៗ ស្អិតស្អាងដោយផ្កាកម្រង និងគ្រឿងក្រអូប ទៅប្រជុំគ្នាក្នុងព្រះរាជត្រកូល ។ ព្រះរាជវិធីនេះ មានទឹមនង្គ័លដល់ទៅ ១០០០ នង្គ័ល ក្នុងថ្ងៃនោះ នង្គ័ល ១០៨ ដែលខ្វះ ១ នង្គ័ល ( ១០៧ នង្គ័ល ) ស្រោបដោយប្រាក់ ព្រមដោយគោ ជង់ជន្ទួញ និងខ្សែ ។ ចំណែកត្រង់ចន្ទោលនង្គ័លរបស់ព្រះរាជាស្រោបទៅដោយមាស ព្រមទាំងគោជង់ជន្ទួញ ខ្សែក៏ស្រោបដោយមាសទាំងនោះ ។ ព្រះរាជាព្រមដោយបរិវារជាច្រើន ស្តេចយាងចេញចាកព្រះនគរ នាំព្រះរាជឱរសទៅដែរ ។ ក្នុងទីប្រកបព្រះរាជវិធី មានដើមព្រីងមួយដើម ដែលមានស្លឹកក្រាស់ម្ញប់ជិតស្និទ្ធល្អ មានសណ្ឋានដូចជាមណ្ឌប ( បារាំ ) ។ ខាងក្រោមដើមព្រីងនោះ ព្រះរាជាទ្រង់ត្រាស់ឲ្យក្រាលព្រះទែនទីផ្ទំរបស់ព្រះរាជឱរសខាងលើឲ្យចងពិតាន វិចិត្រទៅដោយផ្កាយមាស ឲ្យបិទបាំងដោយរនាំងជុំវិញ ឲ្យពួកមេនំមេនាងនៅរក្សាព្រះឱរសក្នុងទីនោះ ។ ចំណែកព្រះអង្គ ក៏ទ្រង់ប្រដាប់ប្រដាព្រះកាយ ដោយគ្រឿងអលង្ការទាំងពួង ទាំងមានពួកអាមាត្យហែហម ស្តេចយាងទៅកាន់ទីប្រត់ព្រះនង្គ័ល ក្នុងទីនោះព្រះរាជាទ្រង់កាន់នង្គ័លមាស ពួកអាមាត្យកាន់នង្គ័លប្រាក់ ពួកប្រជាជនផ្សេងៗ បាននាំគ្នាកាន់នង្គ័លដ៏សេស ដោយនាំគ្នាភ្ជួរខាងនេះ

ខាងនោះ តែព្រះរាជាទ្រង់កាន់ព្រះនង្គ័លចេញពីផ្នែកក្នុង ទៅកាន់ផ្នែកខាងក្រៅ ចេញពីផ្នែកខាងក្រៅ ទៅកាន់ផ្នែកខាងក្នុង ។ ក្នុងទីនោះមានមហាសម្បត្តិ ។ នាងមេនំមេនាងដែលអង្គុយជុំវិញ ព្រះពោធិសត្វម្នាក់ៗ បាននាំគ្នាចេញមកខាងក្រៅ ចេញពីមណ្ឌបដោយគិតថា ពួកយើងនឹងទៅមើលមហាសម្បត្តិរបស់ព្រះរាជា ។ ព្រះពោធិសត្វទតមើលខាងនោះ ខាងនេះ មិនឃើញមាននរណាមួយ ទើបស្ដេចក្រោកចាកទីសេយ្យាដោយរហ័ស គង់ពត់ព្រះភ្នែនកំណាត់ចម្រើននូវអានាបានស្សតិកម្មដ្ឋាន ហើយញុំាងបឋមជ្ឈានឲ្យកើតឡើង ។ ពួកមេនំមេនាងនាំគ្នាដើរទៅ ក្នុងរវាងវេលាទទួលទានអាហារ យឺតយូរទៅបន្តិច ។ ស្រមោលរបស់ដើមឈើដ៏សេសក៏ជ្រេទៅ ចំណែកឯស្រមោលនៃដើមព្រីងដែលជាទីតាំងនៃមណ្ឌបនោះ នៅតែកន្លែងដដែល មិនជ្រេទៅតាមព្រះអាទិត្យឡើយ ។ ពួកមេនំមេនាងបានគិតថា ព្រះអយ្យបុត្រប្រថាប់នៅតែមួយព្រះអង្គឯង ទើបប្រញាប់បើកមណ្ឌបឡើងចូលទៅខាងក្នុងឃើញព្រះបរមពោធិសត្វ ប្រថាប់គង់ពែនព្រះភ្នែនលើព្រះទែនទី និងបាដិហារិយ៍នោះ ទើបនាំគ្នាទៅក្រាបទូល ចំពោះព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារប្រថាប់គង់យ៉ាងនេះ ម្លប់នៃដើមឈើ

ដទៃៗ ជ្រេទៅអស់ តែម្លប់នៃដើមព្រីង ដែលជាក់ន្លែងព្រះពោធិសត្វនោះ នៅតែដដែល មិនជ្រេទៅតាមព្រះអាទិត្យឡើយ ។ព្រះរាជាស្ដេចយាង ប្រញាប់មកដោយរួតរះ ឃើញបាដិហារិយ៍នោះហើយ ទើបត្រាស់ថា នៃបាដ៏ចម្រើន អស្ចារ្យណាស់ នេះជាការថ្វាយបង្គំសរសើរអំពីបារមី របស់ព្រះរាជបុត្រជាលើកទី ២ ហើយទ្រង់ថ្វាយបង្គំបុត្រ ។

តមក ព្រះពោធិសត្វ មានព្រះជន្មាយុបាន ១៦ ឆ្នាំ ព្រះរាជា ទ្រង់មានព្រះតម្រាស់ឲ្យសាងប្រាសាទ ៣ ខ្នង សមគួរដល់រដូវទាំង ៣ ថ្វាយដល់ព្រះរាជឱរស ។ ប្រាសាទ ១ ខ្នង មាន ៩ ជាន់ ប្រាសាទ ១ ខ្នងទៀត មាន ៧ ជាន់ ប្រាសាទ ១ ខ្នងទៀត មាន ៥ ជាន់ និង ឲ្យរៀបចំរកស្ត្រីរបាំ ៤ ម៉ឺននាក់ ទៅបម្រើព្រះពោធិសត្វ មានស្ត្រីរបាំ តាក់តែងខ្លួននៅចោមរោមជាប់ជានិច្ច ហាក់បីដូចជាទេវតា ដែលមាន នាងទេពអប្សរបវរកញ្ញាចោមរោមជាបរិវារ ដោយតូរ្យតន្ត្រីទាំងឡាយ មិនមានបុរសឡើយ ទ្រង់សោយសម្បត្តិយ៉ាងធំបែបនេះ នៅក្នុងប្រាសាទ នោះតាមរដូវកាល ។ ចំណែករាហុលមាតា បានជាអគ្គមហេសីរបស់ ព្រះអង្គ កាលព្រះអង្គសោយមហាសម្បត្តិបែបនេះ ក្នុងថ្ងៃមួយ ពពួក ញាតិបាននិយាយគ្នាឡើងយ៉ាងនេះថា ព្រះសិទ្ធត្ថរវល់តែខ្វល់ខ្វាយ

នឹងល្បែងលេង ឥតមានការសិក្សាសិល្បសាស្រ្តអ្វីសោះ ប្រសិនបើមានសឹកសង្រ្គាមកើតឡើងដល់ព្រះនគរ តើនឹងធ្វើដូចម្តេចទៅ ព្រះបាទសុទ្ធោទនៈ ទ្រង់ជ្រាបហេតុនោះហើយ ក៏ឲ្យយាងព្រះពោធិសត្វមកប្រាប់ថា នែកូន ពពួកព្រះញាតិរបស់អ្នកបាននិយាយថា សិទ្ធត្ថកុមារឥតបានរៀនវិជ្ជាអ្វីសោះ រវល់តែនឹងល្បែងលេងដូចនេះ កូននឹងយល់ថាដល់កាលដ៏សមគួរហើយឬ ព្រះពោធិសត្វទូលថា បពិត្រព្រះសម្មតិទេពខ្ញុំព្រះអង្គមិនមានកិច្ច ដែលនឹងត្រូវសិក្សាសិល្បសាស្រ្តអ្វីទៀតទេ ។ សូមព្រះវររាជបិតាឲ្យប៉ាវគង ទូងគេរី ឲ្យដំណឹងដល់ពួកសក្យៈដែលជាព្រះញាតិទាំងឡាយ ក្នុងព្រះនគរ ដើម្បីឲ្យមកមើលការសម្តែងសិល្បសាស្រ្តបង្ហាញដល់ពួកព្រះញាតិទាំងអស់ឲ្យឃើញចេស្តារាល់គ្នា ។ ព្រះរាជាទ្រង់បានធ្វើតាមដូច្នោះ ព្រះពោធិសត្វត្រាស់ឲ្យប្រជុំពួកអ្នកខ្មាន់ធ្នូដែលអាចបាញ់បានរហ័សដូចជាផ្លេកបន្ទោរ បាញ់រោមកន្ទុយសត្វបានបាញ់ប្រឆាំងកូនសរបាន បាញ់តាមសំឡេងបាន និងបាញ់កូនសរតាមកូនសរបាន ហើយទ្រង់បានសម្តែងសិល្បៈ ១២ យ៉ាង ដែលពួកនាយខ្មាន់ធ្នូដទៃ និងព្រះញាតិទាំងឡាយ មិនមានក្នុងកណ្តាលសន្និបាតនៃមហាជន ។ សេចក្តីនេះគប្បីជ្រាបតាមន័យ ដែលមានមកហើយ

ក្នុងសរភង្គជាតកនោះចុះ ។ ក្នុងគ្រានោះ ពួកព្រះញាតិទាំងអស់លែង មានសន្ទិះសង្ស័យ រិះគន់ចំពោះព្រះអង្គតទៅទៀត ។

លុះសម័យតមក ថ្ងៃមួយ ព្រះពោធិសត្វមានព្រះរាជបំណង នឹងស្តេចយាងទៅកាន់ភូមិភាគនៅក្នុងព្រះរាជឧទ្យាន ទើបត្រាស់ហៅ នាយសារថីមកប្រាប់ថា អ្នកចូរទៅរៀបចំរាជរថថ្វាយដល់យើង នាយ សារថីទទួលព្រះតម្រាស់ថា ករុណាថ្ងៃវិសេសព្រះអង្គ ហើយទើប ទៅចាត់ចែងរាជរថទឹមដោយសិន្ធពជាមង្គល ២ គូ ដែលមានសម្បុរ ដូចត្របកនៃផ្កាឈូកពណ៌ស រួចស្រេចហើយ ទៅក្រាបទូលចំពោះ ព្រះពោធិសត្វៗ ទ្រង់គង់លើរាជរថប្រាកដស្មើ ដោយវិមាននៃទេវតា ទ្រង់បែរព្រះភក្ត្រ សំដៅទៅកាន់ព្រះរាជឧទ្យាន ទេវតាទាំងឡាយគិតថា កាលជាទីត្រាស់ដឹងនៃព្រះសិទ្ធត្ថកុមារជិតចូលមកដល់ហើយ ពួកយើង នឹងសម្តែងនូវបុព្វនិមិត្ត ហើយឲ្យទេវបុត្រមួយអង្គនិម្មិតធ្វើជាមនុស្សជរា មានធ្មេញបាក់ សក់ស្កូវ ខ្នងកោង ដៃកាន់ឈើច្រត់ញ័រទទ្រើក ដើរពី ខាងមុខ ។ ឯព្រះបរមពោធិសត្វ និងនាយសារថី ក៏បានទតឃើញ មនុស្សជរានោះ ។ គ្រានោះ ព្រះបរមពោធិសត្វត្រាស់សួរតាមន័យ ដែលមាននៅក្នុងអបទាននោះថា នៃសម្លាញ់ដ៏ចម្រើន បុរសនេះជាអ្វី

សូម្បីតែសក់របស់គេ ក៏មិនដូចជាសក់របស់ពួកយើងសោះ នាយសារថីបានក្រាបទូលថា មនុស្សជរា ករុណាថ្លៃវិសេសព្រះអង្គ ដូចនេះ ទ្រង់ព្រះសណ្ដាប់ពាក្យរបស់នាយសារថីហើយ ទ្រង់ក៏មានព្រះរាជហឫទ័យសង្វេគថា នៃអ្នកដ៏ចម្រើន គួរឲ្យតិះដៀលពិតណាស់ហ្ន៎ នូវការកើតឡើងនេះ ភាពជរា នឹងត្រូវប្រាកដដល់សត្វលោក ដែលអាស្រ័យការកើតជាពិតប្រាកដ ដូច្នេះហើយ ស្ដេចក៏យាងត្រឡប់ចាកព្រះរាជឧទ្យានទៅកាន់ប្រាសាទវិញ ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ព្រះរាជបុត្ររបស់យើង ទើបប្រញាប់ឆាប់វិលត្រឡប់ចូលមកវិញម្ល៉េះ ពួកអាមាត្យក្រាបទូលថា ព្រោះទ្រង់ទតឃើញនូវមនុស្សជរា ព្រះករុណាថ្លៃវិសេសព្រះអង្គ ។ ព្រះរាជាត្រាស់ថា ពួកអ្នកនិយាយថា ព្រះរាជបុត្ររបស់យើងកាលបានឃើញមនុស្សជរាហើយ នឹងចេញបួស ព្រោះហេតុអ្វី ទើបមកបំបែកបំបាក់យើងពីព្រះរាជបុត្រ ចូរប្រញាប់ទៅរកល្ខោនមកសម្ដែងឲ្យដល់បុត្ររបស់យើងយ៉ាងរហ័ស ដើម្បីកុំឲ្យបុត្ររបស់យើង នឹកភ្នកទៅរកការបព្វជ្ជាឲ្យសោះ ហើយព្រះអង្គទ្រង់ដាក់បន្ថែម ឲ្យរាជបុរសមកយាមល្បាតប្រាសាទនៃព្រះរាជបុត្រ កំណត់ទីកន្លះយោជន៍ជុំវិញ ដើម្បីការពារកុំឲ្យមនុស្សមានភាពជរា ចូលមកជិតព្រះបរមពោធិសត្វ

បានឡើយ ។ ក្នុងថ្ងៃស្អែកឡើង ព្រះបរមពោធិសត្វក៏ស្ដេចយាងទៅកាន់ព្រះរាជឧទ្យានម្ដងទៀត ទ្រង់បានទតឃើញមនុស្សឈឺ ដែលទេវតានិម្មិតឡើង ទើបត្រាស់សួរដោយន័យមុននោះឯង ក៏មានព្រះរាជហឫទ័យសង្វេគទៀត ហើយក៏ប្រញាប់យាងត្រឡប់ទៅកាន់ប្រាសាទវិញ ។ ចំណែកព្រះរាជាក៏ត្រាស់សួរ ហើយទ្រង់ចាត់ចែងតាមន័យដែលពោលហើយ ទ្រង់ដាក់បន្ថែមឲ្យរាជបុរសមកយាមល្បាត ក្នុងទីមានចម្ងាយប្រមាណ ៣ គាវុតជុំវិញប្រាសាទ ។ ចំណោរកាលតពីនោះមក ថ្ងៃមួយព្រះបរមពោធិសត្វ ស្ដេចយាងទៅកាន់ព្រះរាជឧទ្យានម្ដងទៀត ទ្រង់បានទតឃើញមនុស្សស្លាប់ ដែលទេវតានិម្មិតឡើង ត្រាស់សួរដោយន័យមុននោះឯង ក៏មានព្រះរាជហឫទ័យសង្វេគ ហើយស្ដេចក៏ប្រញាប់យាងត្រឡប់មកកាន់ប្រាសាទវិញ ។ ចំណែកព្រះរាជាក៏ត្រាស់សួរ ហើយទ្រង់ចាត់ចែងតាមន័យដែលពោលមកហើយ ទ្រង់ដាក់បន្ថែមឲ្យរាជបុរសមកយាមល្បាត ក្នុងទីមានចម្ងាយប្រមាណមួយយោជន៍ជុំវិញប្រាសាទ ។ ចំណោរកាលតពីនោះមក ព្រះពោធិសត្វស្ដេចយាងទៅកាន់ព្រះរាជឧទ្យានម្ដងទៀត ទ្រង់បានទតឃើញបព្វជិត ( ភេទអ្នកបួស ) មានសម្លៀកបំពាក់សមរម្យល្អ ដែលទេវតានិម្មិតឡើង ទើបត្រាស់សួរនាយសារថីថា

នៃសម្លាញ់ មនុស្សនេះគេហៅថា ជាមនុស្សអ្វី នាយសារថីមិនជ្រាប នូវបព្វជិត ឬមនុស្សដែលធ្វើឲ្យបានជាបព្វជិតនោះឡើយ ព្រោះមិនមានការកើតឡើង នៃព្រះពុទ្ធក៏ពិតមែន តែដោយអានុភាពនៃទេវតា ទើបក្រាបទូលថា មនុស្សនេះគេហៅថា **បព្វជិត** ករុណាថ្លៃវិសេសព្រះអង្គ ហើយពណ៌នាអំពីគុណនៃការចេញបួស ព្រះពោធិសត្វទ្រង់ព្រះសណ្ដាប់ហើយ ក៏មានព្រះហឫទ័យសប្បាយ ពេញចិត្តចំពោះភេទបព្វជ្ជា ទើបព្រះអង្គស្ដេចយាងទៅក្រសាលព្រះឧទ្យាន ទ្រង់ទៅកម្សាន្តសប្បាយពេញមួយថ្ងៃ ។ តែលោកពោលទុកនៅក្នុង **គម្ពីរទីឃនិកាយថា** ព្រះបរមពោធិសត្វ ស្ដេចបានទតឃើញនិមិត្តទាំង ៤ ក្នុងវេលាតែមួយថ្ងៃប៉ុណ្ណោះ ។ ព្រះបរមពោធិសត្វស្ដេចយាងកម្សាន្តពេញមួយថ្ងៃ ស្ដេចយាងចុះស្រង់ទឹក ក្នុងស្រះបោក្ខរណីជាមង្គល លុះព្រះអាទិត្យអស្ដង្គត ទ្រង់នៅគង់លើផែនមង្គលសិលា ទ្រង់មានព្រះបំណងនឹងឲ្យគេតាក់តែងព្រះអង្គ ដោយគ្រឿងអលង្ការ ។ គ្រានោះ ពួកស្ត្រីដែលជាបរិចារិកា យកសំពត់មានពណ៌ផ្សេងៗ ព្រមទាំងគ្រឿងអាភរណៈ មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម មកតាក់តែងថ្វាយព្រះអង្គ ។ នៅក្នុងខណៈនោះ អាសនៈដែលជាទីគង់ប្រថាប់ របស់

សក្កទេវរាជ បានកើតការក្តៅខុសប្រក្រតីឡើង ទើបសក្កទេវរាជរំពឹងពិចារណាមើល ទើបដឹងថា កាលដែលគួរថ្វាយគ្រឿងអលង្ការដល់ព្រះបរមពោធិសត្វ ។ គ្រានោះ សក្កទេវរាជ ទើបទ្រង់ត្រាស់ហៅវិស្សកម្មទេវបុត្រមកបង្គាប់ថា នៃវិស្សកម្មជាសម្លាញ់ ថ្ងៃនេះ ព្រះសិទ្ធត្ថកុមារ នឹងទ្រង់ចេញសាងព្រះផ្នួស នៅក្នុងវេលាពាក់កណ្តាលអធ្រាត្រយប់នេះ នេះជាគ្រឿងប្រដាប់ចុងក្រោយបំផុត របស់ព្រះអង្គ អ្នកចូរទៅកាន់ឧទ្យាន ឃើញព្រះមហាបុរសហើយ ចូរតាក់តែងកាយព្រះអង្គដោយគ្រឿងប្រដាប់គ្រប់បែបយ៉ាង ។ វិស្សកម្មទេវបុត្រទទួលព្រះតម្រាស់ថា ល្អហើយ រួចយកគ្រឿងប្រដាប់ទាំងនោះ ចូលទៅរកព្រះបរមពោធិសត្វនៅក្នុងខណៈនោះឯង ដោយទេវានុភាព ក៏និម្មិតខ្លួនក្លែងភេទជាអ្នកខ្មាន់ព្រះកេសម្នាក់ យកសំពត់ឈ្នួតពីដៃខ្មាន់ព្រះកេសម្នាក់ទៀត ហើយចូលទៅជូតព្រះកាយថ្វាយព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វ ទ្រង់ជ្រាបដោយសម្ផស្សនៃដៃប៉ុណ្ណោះថា អ្នកនេះពុំមែនជាមនុស្ស គេជាទេវបុត្រ ។ លុះវិស្សកម្មទេវបុត្រជូតព្រះកាយថ្វាយ សំពត់ជូតព្រះកាយមួយពាន់ផ្ទាំង ក៏អណ្តែតខ្ពស់ឡើង ដោយអាការដូចកែវមណី ត្រង់ព្រះមោលីលើព្រះសិរសា កាលជូតទៀត

ក៏ជាសំពត់មួយពាន់ផ្ទាំង ព្រោះដូច្នោះ កាលជូត ១០ ជុំ ក៏ក្លាយទៅជាមួយម៉ឺនស្រទាប់ អណ្តែតខ្ពស់ឡើង មិនគួរគិតថា ព្រះសិរសាតូចសំពត់មានច្រើនណាស់ អណ្តែតខ្ពស់ឡើង បានយ៉ាងណា ក៏បណ្តាសំពត់ទាំងនោះ ផ្ទាំងដ៏ធំបំផុត មានប្រមាណប៉ុនផ្កាបីលតា ដ៏សេសក្រៅអំពីនេះប៉ុនផ្កាកុត្តុម្ពកៈ ព្រះសិរសារបស់ព្រះបរមពោធិសត្វក្រាស់-ណែនដោយសក់ ដូចជាផ្កាស៊ុរកី ដែលក្រាស់ណែនដោយកេសរ ។ តមក កាលពួកអ្នកតន្ត្រីសម្តែងបដិភាណរបស់ខ្លួន ពួកព្រាហ្មណ៍ក៏ពោលសរសើរ ដោយមានពាក្យជាដើមថា បពិត្រព្រះចមនរិន្ទ សូមព្រះអង្គទ្រង់ឈ្នះចុះ កាលពួកនាយសារថី និងពួកមាយតន្ទកៈជាដើម បានពោលសរសើរដោយពាក្យជាមង្គល ពាក្យសរសើរ និងពាក្យប្រកាសជាអនេកប្បការថ្វាយចំពោះព្រះពោធិសត្វ ដែលទ្រង់ស្អិតស្អាងហើយដោយគ្រឿងអលង្ការផ្សេងៗ នោះ ព្រះអង្គក៏ស្តេចឡើងជិះលើព្រះរាជរថដ៏ប្រសើរ ដែលមានព្រះកាយប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាងហើយនោះ ។

ក្នុងសម័យនោះ ព្រះបាទសុទ្ធោទនៈ ទ្រង់ព្រះសណ្តាប់ដំណឹងថា ព្រះរាជមាតារបស់ព្រះរាហុល ព្រះនាងទ្រង់ប្រសូតព្រះរាជឱរសហើយ

ទើបទ្រង់បញ្ជូនសារទៅដោយត្រាស់ថា ពួកអ្នកចូរទៅប្រាប់ពីរឿងការសប្បាយចិត្ត របស់យើងដល់ព្រះអយ្យបុត្រផង ព្រះពោធិសត្វទ្រង់ព្រះសណ្តាប់ដំណឹងនោះហើយ ត្រាស់ថា រាហុលកើតហើយ ( គ្រឿងចងកើតហើយ ) ។ ព្រះបាទសុទ្ធោទនៈត្រាស់សួរថា បុត្ររបស់យើងមានព្រះបន្ទូលយ៉ាងណាខ្លះ ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយទើបត្រាស់ថា ចាប់ផ្តើមអំពីថ្ងៃនេះទៅ ចៅរបស់យើងមានឈ្មោះថារាហុលកុមារចុះ ។ ចំណែកព្រះបរមពោធិសត្វស្តេចឡើងកាន់រាជរថដ៏ប្រសើរ ស្តេចយាងចូលទៅក្នុងព្រះនគរ ដោយឥស្សរិយយសដ៏ធំដោយព្រះសិរីសោភាគ្យដ៏រីករាយក្រៃលែងណាស់ ។ ក្នុងសម័យនោះព្រះនាងកិសាគោតមីខត្តិយកញ្ញា ព្រះនាងកំពុងស្ថិតនៅនាផ្ទៃប្រាសាទជាន់ខាងលើ បានឃើញរូបសិរីរបស់ព្រះពោធិសត្វ ដែលកំពុងគង់លើព្រះទីន័ងរាជរថ ទ្រង់ធ្វើការប្រទក្សិណព្រះនគរ ទ្រង់កើតមានបីតិសោមនស្សបានបន្លឺវាចាឡើងថា

ព្រះសិទ្ធត្ថអង្គនេះ បើបានជាបុត្រនៃមាតាណា មាតានោះរលត់ទុក្ខដោយពិត បើបានជាបុត្រនៃបិតាណា បិតានោះរលត់ទុក្ខដោយពិត បើបានជាស្វាមីនៃនារីណា នារីនោះរលត់ទុក្ខដោយពិត ។

ព្រះពោធិសត្វ ទ្រង់បានព្រះសណ្តាប់ ឧទានវាចានោះហើយ ទ្រង់ត្រិះរិះថា ព្រះនាងកិសាគោតមីនេះ ត្រាស់យ៉ាងនេះថា ហឫទ័យរបស់មាតា ហឫទ័យរបស់បិតា ហឫទ័យរបស់ភរិយា អ្នកឃើញអត្តភាពដូចនេះរមែងរលត់ទុក្ខបាន ពេលណារលត់ទុក្ខហ្នឹ ហឫទ័យទើបឈ្មោះថារលត់បាន ។ គ្រានោះ ព្រះពោធិសត្វ ដែលមានព្រះទ័យរំសាយតម្រេកហើយក្នុងកិលេសទាំងឡាយ ទ្រង់បានត្រិះរិះថា កាលបើភ្លើង គឺរាគៈរលត់ ឈ្មោះថា ការរលត់សេចក្តីទុក្ខ កាលបើភ្លើងគឺទោសៈរលត់ ឈ្មោះថា ការរលត់សេចក្តីទុក្ខ កាលបើភ្លើង គឺមោហៈរលត់ ឈ្មោះថា ការរលត់សេចក្តីទុក្ខ កាលភាពក្តៅទាំងឡាយក្នុងកិលេសទាំងពួង មានមានះ និងទិដ្ឋិជាដើមរលត់ហើយ ឈ្មោះថា ការរលត់សេចក្តីទុក្ខ ព្រះនាងឲ្យយើងបានស្តាប់ពាក្យដ៏ល្អ ការពិតយើងកំពុងតែត្រាច់ស្វែងរកនិព្វាន យើងគួរនឹងលះបង់ភាពជាឃរាវាសចេញទៅបួស នឹងស្វែងរកនិព្វានក្នុងថ្ងៃនេះកុំខាន ហើយទ្រង់ដោះកងកែវមុក្តាមានតម្លៃ ១០០០ កហាបណៈអំពីព្រះសូរង ឲ្យយកទៅប្រទានដល់ព្រះនាងកិសាគោតមី ក្នុងពេលនោះភ្លាម ដោយទ្រង់ត្រិះរិះថា នេះចូរជាអាចរិយភាគ ( ចំណែកដែលត្រូវបានអាចារ្យ, កំណល់គ្រូ ) ចំពោះ

ព្រះនាងចុះ ។ ព្រះនាងកើតបីតិនិងសោមនស្សថា សិទ្ធត្ថកុមារមានចិត្តឬពេញចិត្តចំពោះយើង ទើបប្រទានបណ្ណាការនេះមកឲ្យយើង ។

ចំណែកព្រះពោធិសត្វ ស្តេចឡើងកាន់ប្រាសាទរបស់ព្រះអង្គ ដោយព្រះសិរីសោភាគ្យដ៏ធំក្រៃលែង ស្តេចផ្ទំលើព្រះសិរីសយនាក្រឡាព្រះបន្ទំ ក្នុងកាលភ្លាមៗ នោះឯង ។ ចំណែកខាងពួកស្រីរបាំ សុទ្ធតែប្រដាប់តាក់តែងរាងកាយ ដោយគ្រឿងអលង្ការគ្រប់បែបគ្រប់យ៉ាង ទាំងរូបឆោមលោមពណ៌ក៏ល្អស្រស់ឆើតឆាយ ហាក់បីដូចជាទេពកញ្ញាក្នុងស្ថានទេវលោក ដែលជាអ្នកស្ទាត់ក្នុងល្បែង ច្រៀង រាំជាដើម នាំគ្នាប្រគំតូរ្យតន្ត្រីច្រៀងរាំថ្វាយព្រះបរមពោធិសត្វ ។ ព្រះពោធិសត្វ ព្រោះហេតុដែលព្រះអង្គ ទ្រង់មានព្រះទ័យរំសាយតម្រេកក្នុងកិលេសទាំងឡាយហើយ ទើបទ្រង់ពុំអភិរម្យក្នុងការរាំជាដើម មួយស្របក់មក ក៏ទ្រង់ចូលកាន់និទ្រា ពួកស្រីទាំងនោះគិតថា ពួកយើងសម្តែងការរាំច្រៀងជាដើម ដើម្បីប្រយោជន៍ដល់ព្រះរាជកុមារណា ព្រះរាជកុមារនោះទ្រង់ចូលកាន់និទ្រាហើយ ឥឡូវនេះ នឹងលំបាកទៅដើម្បីអ្វី ម្នាក់ៗ នាំគ្នាដាក់គ្រឿងតន្ត្រីដែលកាន់ចុះហើយ ក៏ដេកលក់ទៅ ដួងប្រទីបប្រេងក្រអូបនៅឆេះដដែល ។ លុះមជ្ឈិមយាម ព្រះពោធិសត្វទ្រង់តើនឡើង

ហើយ ទ្រង់គង់លើក្រឡាព្រះបន្ទំ បានទតឃើញវិការនៃស្ត្រីទាំងនោះ ដេកលក់សង្កត់គ្រឿងតន្ត្រី ពួកខ្លះ មានទឹកមាត់ហូរ មានខ្លួនប្រឡាក់ ដោយទឹកមាត់ ពួកខ្លះ ខាំធ្មេញ ពួកខ្លះ ស្រមុក ពួកខ្លះ មមើ ពួកខ្លះ ហាមាត់ ពួកខ្លះ សំពត់ស្បៀករបូត អាក្រាតកាយ ព្រះពោធិសត្វ ទតឃើញអាការខុសប្រក្រតីនៃស្ត្រីទាំងនោះ ក៏មានព្រះរាជហឫទ័យ សង្វេគនឿយណាយយ៉ាងខ្លាំងក្នុងកាមគុណទាំងឡាយ ផ្ទៃប្រាសាទធំ នោះប្រដាប់តាក់តែងហើយ សូម្បីដូចក្នុងស្ថានទេវលោក បានប្រាកដ ដល់ព្រះពោធិសត្វ ហាក់បីដូចជាព្រៃស្មសាន ដែលពាសពេញទៅដោយ សាកសពៗ ដែលគេបោលនោះ ភពបីប្រាកដដូចថាជាផ្ទះដែលត្រូវ ភ្លើងឆេះ ទើបឧទានឡើងថា ខ្វល់ខ្វាយពិតណាស់ហ្ន៎ ជាប់ជំពាក់ពិត ណាស់ហ្ន៎ ក៏មានព្រះហឫទ័យបង្អោនទៅ នៅក្នុងការបព្វជ្ជារឹងរឹតតែ ក្រៃលែងឡើង ។

ព្រះបរមពោធិសត្វ ទ្រង់ត្រិះរិះថា យើងគួរនឹងចេញបួសក្នុង ថ្ងៃនេះឲ្យទាល់តែបាន ទើបទ្រង់ក្រោកចាកទីសយនា ទៅកាន់ទីជិតទ្វារ ត្រាស់ថា នរណានៅក្នុងទីនេះ ឆន្នាមាត្យដេកយកក្បាលទល់នឹងទ្វារនោះ ទូលតបថា បពិត្រព្រះអយ្យបុត្រ ខ្ញុំព្រះអង្គឈ្មោះឆន្ន ព្រះពោធិសត្វ

បានត្រាស់ថា នៃឆន្ន ថ្ងៃនេះយើងមានបំណងនឹងចេញទៅបួសឲ្យទាល់តែបាន ហេតុដូច្នេះ ចូរអ្នកចាត់ចែងទៅរកសេះកណ្ឋកៈ ជាសេះអាជានេយ្យមក ។ ឆន្នទូលតបថា ព្រះករុណាថ្លៃវិសេស ហើយយកគ្រឿងតាក់តែងសេះទៅកាន់ក្រោលសេះ កាលបើដួងប្រទីបឆេះសន្ធោសន្ធៅ ឃើញសេះកណ្ឋកៈឈរនៅភូមិភាគ គួរជាទីរីករាយខាងក្រោមពិតានដែលទាញសន្ធឹងដោយជុំវិញគិតថា ថ្ងៃនេះយើងគួររៀបចំសេះកណ្ឋកៈនេះឯងថ្វាយព្រះអង្គ ទើបទៅប្រដាប់តាក់តែងសេះកណ្ឋកៈៗ នោះកាលគេរៀបចំត្រៀម បានដឹងច្បាស់ថា ការរៀបចំត្រៀមយើងក្នុងគ្រានេះ មាំមួនចម្លែកណាស់ មិនដូចជាកាលត្រៀម ក្នុងវេលាស្តេចយាងទៅក្រសាលព្រះរាជឧទ្យានក្នុងថ្ងៃដទៃជាដើមនោះទេ ថ្ងៃនេះព្រះអយ្យបុត្រជាម្ចាស់របស់អញ គង់នឹងទ្រង់មានព្រះរាជបំណង ស្តេចយាងចេញទៅបួស សេះកណ្ឋកៈគិតឃើញដូច្នេះហើយ ក៏មានចិត្តត្រេកអររីករាយឡើង ទើបស្រែកកញ្ជ្រៀវយ៉ាងខ្លាំង សំឡេងនោះលាន់ឮខ្ទរផ្សាយទៅទូទាំងនគរ តែទេវតាខ្ទប់បិទសំឡេងនោះ មិនឲ្យនរណាៗ បានឮ ។ ចំណែកព្រះពោធិសត្វ ទ្រង់ប្រើឆន្នាមាត្យទៅហើយទ្រង់ត្រិះរិះថា យើងនឹងទៅមើលបុត្ររបស់យើងសិន ទើបក្រោកចាកទី

ដែលទ្រង់ប្រថាប់ពែនក្អែន ទៅកាន់បន្ទប់នៃរាហុលមាតា បើកទ្វារបន្ទប់ហើយ ក្នុងខណៈនោះ ប្រទីបដែលពេញទៅដោយប្រេងក្រអូប ក៏នៅកំពុងតែឆេះ សូម្បីព្រះរាហុលមាតា ក៏ផ្ទំដាក់ព្រះហស្តគងលើព្រះរាជឱរស លើក្រឡាបន្ទំ ដែលដេរដាសទៅដោយផ្កាម្លិះរូត និងម្លិះលាជាដើមប្រមាណមានមួយអម្មណៈ ( មាត្រាវាល់អង្ករមានទម្ងន់ ១១ ទោណ ) ព្រះពោធិសត្វ ទ្រង់ប្រថាប់ឈរដាក់ព្រះបាទជាន់មាត់ទ្វារនោះឯងទ្រង់ទតហើយត្រិះរិះថា បើយើងចាប់ដៃព្រះទេវីចេញ ហើយចាប់បុត្ររបស់យើង លើកយកមកបី ព្រះទេវីនឹងតើនឡើងមិនខាន កាលបើដូចនេះ អន្តរាយនៃការចេញទៅបួសនឹងមានដល់យើង សូម្បីយើងបានជាព្រះពុទ្ធហើយ មកសួរសុខទុក្ខកូនក៏មិនជាអ្វី ដូច្នេះ ទើបស្តេចចុះចាកផ្ទៃប្រាសាទទៅ ក៏ពាក្យដែលលោកពោលទុកនៅក្នុងអដ្ឋកថាជាតកថា ក្នុងពេលនោះ ព្រះរាហុលកុមារប្រសូតបាន ៧ ថ្ងៃ មិនមានក្នុងអដ្ឋកថាដ៏សេស ព្រោះដូច្នោះគប្បីកាន់យកពាក្យនេះឯង ។

ព្រះពោធិសត្វ ចុះចាកផ្ទៃប្រាសាទទៅ ដោយប្រការដូចនេះហើយទៅឡើងជិះសេះ ហើយត្រាស់ថា នៃកណ្ឋកៈ ឯងចូរចម្លងយើងក្នុងវេលាយប់នេះ បើយើងបានត្រាស់ជាព្រះពុទ្ធហើយ នឹងចម្លងមនុស្សលោក

ព្រមទាំងទេវលោក ដោយអាស្រ័យនឹងឯង ។ គ្រានោះ ព្រះពោធិសត្វ ក៏ទ្រង់ឡើងលើខ្នងសេះកណ្ឋកៈៗ មានខ្លួនប្រវែង ១៨ ហត្ថ សម្បូណ៌ទៅដោយកម្លាំង និងមានភាពរហ័សរហួន មានសម្បុរពណ៌.សសុទ្ធ ដូចស័ង្ខដែលខាត់ល្អហើយ ។ ឯសេះកណ្ឋកៈនោះឯង បើនឹងស្រែក ឬនឹងធ្វើសូរនៃជើងកាលណា សម្រែក និងសូរនៃជើងនោះ ក៏លាន់ឮទូទាំងព្រះនគរ ព្រោះដូច្នោះ ក្នុងកាលនោះ ទើបទេវតាខ្ទប់បិទនូវសម្រែក និងសូរនៃជើងនោះ មិនឲ្យជនណាមួយបានឮឡើយ ដោយអានុភាពរបស់ខ្លួន ។ ព្រះពោធិសត្វ ឡើងជិះលើខ្នងសេះដ៏ប្រសើរ ទ្រង់ឲ្យឆន្នាមាត្យតោងកន្ទុយសេះ ស្តេចជិះចេញទៅ លុះទៅដល់ខ្លោងទ្វារធំ គឺក្នុងវេលាពាក់កណ្តាលអធ្រាត្រ ក៏ក្នុងកាលនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ត្រិះរិះថា ព្រះពោធិសត្វ មិនអាចបើកទ្វារចេញទៅក្រៅបានទេ ដោយទ្វារធំនោះ ទាន់តែបុរសមួយពាន់នាក់ទើបអាចបើកបាន ។ ប៉ុន្តែព្រះពោធិសត្វ ទ្រង់សម្បូណ៌ទៅដោយកម្លាំងៗរបស់ព្រះពោធិសត្វ កាលប្រៀបធៀបជាមួយនឹងដំរី ស្មើនឹងមួយពាន់កោដិ កាលបើប្រៀបធៀបនឹងបុរស ស្មើនឹងបុរសដល់ទៅដប់សែនកោដិ ។ ព្រោះដូច្នោះ ព្រះអង្គ ទើបទ្រង់ត្រិះរិះថា ប្រសិនបើមិនមាន

នរណា បើកទ្វារនេះទេ អាត្មាអញជិះលើខ្នងសេះកណ្ឋកៈនេះ ហើយតៀតសេះនឹងភ្លៅ មួយអន្លើដោយឆន្នាមាត្យ ផ្លោះរំលងកំពែងដែលមានកម្ពស់ ១៨ ហត្ថ ចេញទៅ ។ ឯឆន្នាមាត្យក៏គិតថា បើមិនមាននរណា បើកទ្វារនេះឲ្យយើងទេ អាត្មាអញនឹងយាងព្រះមហាបុរសឲ្យជិះលើ-ក ហើយទ្រពោះសេះ ដោយដៃ លោតផ្លោះរំលងកំពែងនេះចេញទៅឲ្យទាល់តែបាន ។ ឯសេះកណ្ឋកៈក៏គិតថា បើមិនមាននរណាបើកទ្វារនេះឲ្យទេ អញនឹងនាំព្រះពោធិសត្វ ដែលគង់នៅលើខ្នងអញនេះព្រមជាមួយគ្នា នឹងឆន្នាមាត្យ ដែលឈរចាប់កន្ទុយលោតផ្លោះរំលងកំពែងនេះចេញទៅវេលាយប់នេះ កុំបីអាក់ខានឡើយ ។ បណ្ដាអ្នកទាំងបីនាក់នោះ ម្នាក់ៗ មានគំនិតស្របគ្នា ប៉ុន្តែទេវតាដែលអាស្រ័យនឹងទ្វារនោះ ក៏បានបើកទ្វារថ្វាយដល់ព្រះពោធិសត្វមួយរំពេចនោះឯង ។

ក្នុងខណៈនោះ មារមានចិត្តបាបមកដោយគិតថា អាត្មាអញនឹងឲ្យព្រះពោធិសត្វត្រឡប់ទៅវិញ ហើយស្ថិតនៅឰដ៏អាកាសទូលថា បពិត្រលោកនិទ្ទុក្ខដ៏ចម្រើន លោកកុំចេញទៅបួសឡើយ ដ្បិតនៅក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃនេះទៅ ចក្ករតន៍នឹងប្រាកដដល់ព្រះអង្គៗ នឹងបានគ្រប់គ្រងរាជសម្បត្តិ លើទ្វីបទាំង ៤ មានទ្វីបតូចពីរពាន់ជាបរិវារ

បពិត្រលោកនិទ្ទុក្ខ សូមព្រះអង្គត្រឡប់ទៅវិញចុះ ។ ព្រះពោធិសត្វទ្រង់តបវិញថា លោកជានរណា មារតបថា យើងជាវសវត្តីមារ ។ ព្រះពោធិសត្វត្រាស់ថា នែមារ យើងដឹងថា សម្បត្តិចក្ករតន៍នឹងមានប្រាកដដល់យើង យើងមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិនោះឡើយ ។ យើងនឹងឲ្យម៉ឺនលោកធាតុបន្ទឺសំឡេងលាន់ឡើង ដោយភាពយើងជាព្រះពុទ្ធ ។ មារពោលតបថា ចាប់តាំងពីឥឡូវនេះជាដើមទៅ ក្នុងពេលដែលព្រះអង្គ ទ្រង់ត្រិះរិះដល់កាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហិង្សាវិតក្កក្តី យើងនឹងចាំស្វែងរកចន្លោះ ប្រកិតជាប់តាមព្រះអង្គ គន់រំពៃមើលដូចជាស្រមោល អន្ទោលតាមប្រាណ ដូច្នោះដែរ ។

ចំណែកព្រះពោធិសត្វ ពុំមានសេចក្តីអាល័យ លះបង់ចោលនូវចក្រពត្តិរាជសម្បត្តិ ដែលតាំងនៅក្នុងកណ្តាប់ព្រះហស្តហើយ ដូចជាដុំនៃទឹកមាត់ ស្តេចយាងចេញចាកនគរទៅ ក្នុងវេលាយប់នោះឯង ត្រូវនឹងថ្ងៃពេញបូណ៌មី **ខែអាសាឍ** ដោយមានគ្រឿងសក្ការៈដ៏ធំអស្ចារ្យ ដែលមានពួកទេវតាណែនតាន់តាប់ នាំគ្នាមកធ្វើការបូជាដង្ហែអបអរព្រះរាជដំណើរ របស់ព្រះអង្គចេញទៅបួស ។ លុះព្រះអង្គស្តេចយាងចេញចាកនគរហើយ ក៏មានព្រះទ័យនឹកក្នក ចង់ទតឃើញ

ព្រះនគរ កាលព្រះពោធិសត្វ មានព្រះទ័យនឹកក្នុកឡើងប៉ុណ្ណោះ មហាប្រឹថពីហាក់បីដូចទូលថា បពិត្រមហាបុរស ព្រះអង្គមិនត្រូវបែរព្រះភក្ត្រ ទតមកមើលព្រះនគរទៀតទេ ។ ព្រះពោធិសត្វ ក៏បានប្រថាប់ឈរបែរព្រះភក្ត្រមកមើលព្រះនគរ លុះទ្រង់ទតមកព្រះនគររួចហើយ ទ្រង់បង្ហាញសម្តែងចេតិយដ្ឋានហើយ ទ្រង់ធ្វើឲ្យសេះកណ្ឋកៈបែរមុខកាន់ផ្លូវ ដែលព្រះអង្គគប្បីស្តេចយាងទៅ ក្នុងរាជដំណើរនោះមានគ្រឿងសក្ការៈដ៏ធំអស្ចារ្យ ដោយភាពឱឡារិក ។ បានឮថា ក្នុងកាលនោះទេវតាទាំងឡាយ លើកគប់ភ្លើង ៦ ម៉ឺន នៅខាងមុខព្រះពោធិសត្វ ខាងក្រោយ ៦ ម៉ឺន ខាងស្តាំ ៦ ម៉ឺន ខាងឆ្វេង ៦ ម៉ឺន គប់ភ្លើង ទេវតាមួយពួកទៀតរកប្រមាណពុំបាន ទល់កណ្តាប់ចក្រវាឡ ទេវតា នាគ និងគ្រុឌជាដើមមួយពួកទៀត ដើរបូជា ដោយផ្កាកម្រង និងគ្រឿងក្រអូបដែលជាទិព្វ ។ ផ្ទៃអាកាស បានជាប់គ្នាមិនដាច់ទៅ ដោយផ្កាបារិជាត និងផ្កាមន្ទារវៈ ដូចជាភ្លៀងផ្កា ។ តន្ត្រី ៦៨០០០ យ៉ាងប្រគំឡើង ។ កាលរមែងប្រព្រឹត្តទៅ ដូចវេលាដែលមេឃគំរាមក្នុងផ្ទៃមហាសមុទ្រ និងដូចវេលាសាគរ មានសំឡេងគឹកកងក្នុងផ្ទៃភ្នំយុគន្ធរ ។

ព្រះពោធិសត្វ កាលស្ដេចយាងទៅដោយសិរីសោភាគ្យនេះ ធ្វើរាជាណាចក្រទាំង ៣ តែមួយរាត្រីប៉ុណ្ណោះ ស្ដេចយាងទៅដល់ឆ្នេរស្ទឹងអនោមា ក្នុងទីបំផុតផ្លូវចម្ងាយ ៣០ យោជន៍ ។ សួរថា សេះនោះអាចត្រាច់ទៅឲ្យក្រៃលែងជាងនោះបានឬទេ ? ឆ្លើយថា អាចទៅបាន ព្រោះសេះកណ្ឋកៈនោះ អាចត្រាច់ទៅជាបដល់កណ្ដាប់ចក្រវាឡ ដោយមិនមានព្រំដែនយ៉ាងនេះ ដូចជាជាន់វង់នៃដុំកង់ ដែលសិកក្នុងដុំ ហើយត្រឡប់មកវិញ មុនអាហារពេលព្រឹក បរិភោគអាហារដែលគេរៀបចំទុកចំពោះខ្លួន ។ ក្នុងកាលនោះ សេះកណ្ឋកៈត្រូវប៉ះពាល់កាយដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម ដែលទេវតា នាគ និងគ្រុឌជាដើមឈរនៅឰដ៏អាកាស ហើយរោយរាយចុះមក លិចរហូតដល់ឱរប្រទេស ( ពាក់កណ្ដាលភ្លៅ ) ហើយ ការរត់លុយដោយសភាពបែបនោះទៅ ទើបមានការយឺតយូរ ព្រោះដូច្នោះ សេះកណ្ឋកៈទើបរត់បាន ៣០ យោជន៍ប៉ុណ្ណោះ ។ ព្រះពោធិសត្វ ប្រថាប់នៅត្រង់ឆ្នេរស្ទឹង ហើយត្រាស់សួរឆន្នាមាត្យថា ស្ទឹងនេះឈ្មោះថាស្ទឹងអ្វី ? ឆន្នាមាត្យបានក្រាបទូលថា ស្ទឹងនេះឈ្មោះ **អនោមា** ព្រះករុណាថ្លៃវិសេសព្រះអង្គ ។ ព្រះពោធិសត្វទ្រង់ត្រិះរិះថា សូម្បីបព្វជ្ជារបស់យើងក៏នឹង

មិនអន់ថយ ទើបយកកែងព្រះបាទរុញ ឲ្យសញ្ញាសេះកណ្ឋកៈ ។ សេះកណ្ឋកៈ បានលោតឆ្លងស្ទឹង ដែលមានប្រមាណទទឹង ៨ ឧសភៈ ទៅត្រើយខាងនាយ ។ ព្រះពោធិសត្វ ស្ដេចចុះអំពីខ្នងសេះ ទៅគង់ប្រថាប់នៅត្រង់ផ្នូកខ្សាច់ ដូចផ្ទាំងប្រាក់ ត្រាស់ហៅឆន្នាមាត្យមកថា នែឆន្ន ជាសម្លាញ់ អ្នកចូរនាំយកគ្រឿងអាភរណៈ និងសេះកណ្ឋកៈ របស់យើងទៅ យើងនឹងបួសនៅក្នុងទីនេះ ។ ឆន្នាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព សូម្បីខ្ញុំព្រះអង្គក៏នឹងបួសជាមួយនឹងព្រះអង្គដែរ ករុណាថ្លៃវិសេស ។ ព្រះពោធិសត្វត្រាស់ហាមបីដងថា អ្នកបួសមិនទាន់បានទេ អ្នកត្រូវត្រឡប់ទៅកាន់ព្រះនគរវិញ ហើយទ្រង់ប្រគល់គ្រឿងអាភរណៈ និងសេះកណ្ឋកៈឲ្យដល់ឆន្នាមាត្យ ហើយទ្រង់ត្រិះរិះថា សក់ទាំងឡាយរបស់យើងនេះ មិនសមគួរដល់សមណៈ ។ ទ្រង់ត្រិះរិះតទៅទៀតថា អ្នកដទៃដែលសមគួរកាត់សក់របស់ព្រះពោធិសត្វ រមែងមិនមាន ព្រោះហេតុនោះ យើងនឹងកាត់សក់របស់យើង ដោយព្រះខ័ននេះដោយខ្លួនឯង ទើបយកព្រះហស្ដស្ដាំចាប់ព្រះខ័ន យកព្រះហស្ដឆ្វេងចាប់ព្រះចូឡា ព្រមទាំងព្រះមោលី ( ផ្នួងសក់ ) ហើយទើបកាត់ចេញ ។ សរសៃព្រះកេសាដែលនៅសល់ប្រមាណពីរអង្គុលី វិលទៅ

ខាងស្តាំណែនជាប់ព្រះសិរសា ។ ព្រះកេសាមានប្រមាណប៉ុណ្ណោះឯង ដរាបដល់ព្រះអង្គអស់ព្រះជន្មាយុ ។ ព្រះមស្សុ (ពុកមាត់) ក៏មានល្មមសមរម្យ សមគួរនឹងព្រះកេសានោះ ឈ្មោះថាកិច្ចដោយការកោរសក់និងពុកមាត់ពុកចង្កាពុំមានទៀតឡើយ ។ ព្រះពោធិសត្វចាប់ព្រះចូឡាព្រមដោយព្រះមោលី ទ្រង់អធិដ្ឋានថា ប្រសិនបើយើងនឹងត្រាស់ជាព្រះពុទ្ធមែននោះ សូមព្រះមោលីតាំងនៅក្នុងពួជអាកាស ព្រះចូឡាមណីនោះអណ្តែតទៅលើអាកាសកម្ពស់ដល់ទៅមួយយោជន៍ ហើយតាំងនៅក្នុងទីនោះ ។ គ្រានោះ សក្កទេវរាជទ្រង់ប្រមើលមើលដោយទិព្វចក្ខុទ្រង់បានជ្រាប ទើបយកប្រអប់កែវមកទទួល ទៅតម្កល់ទុកនៅក្នុងចូឡាមណីចេតិយ នាស្ថានត្រៃត្រិង្សទេវលោក ដូចដែលលោកពោលទុកថា

អគ្គបុគ្គលដ៏ប្រសើរបានកាត់ព្រះមោលី ដែលអប់ដោយក្លិនក្រអូបដ៏ប្រសើរ ហើយបានបោះឡើងទៅកាន់វេហាស៍ ស្តេចវាសវៈអ្នកមានព្រះនេត្រមួយពាន់ យកប្រអប់មាសដ៏ប្រសើរ ទូលលើព្រះសិរសាទទួលទុកហើយ ។

ព្រះបរមពោធិសត្វ ទ្រង់ត្រិះរិះទៀតថា កាសិកពស្ត្រទាំងនេះ

មិនសមគួរដល់សមណភេទឡើយ ។ លំដាប់នោះ ឃដិការមហាព្រហ្ម ដែលជាសម្លាញ់ចាស់របស់ព្រះបរមពោធិសត្វ តាំងអំពីសាសនា នៃព្រះពុទ្ធកស្សបៈ បានគិតថា ថ្ងៃនេះ សម្លាញ់របស់យើងចេញបួស ហើយទេតើ យើងនឹងកាន់យកសមណបរិក្ខារទៅថ្វាយដល់សម្លាញ់ របស់យើង ទើបបាននាំយកបរិក្ខារទាំង ៨ នេះទៅថ្វាយ គឺ

**បរិក្ខារទាំង ៨ នោះ គឺស្បង់ ១ ចីវរ ១ សង្ឃាដិ ១ បាត្រ ១ កាំបិតកោរ ១ បំពង់ម្ជុល ១ វត្ថពន្ធចង្កេះ ១ តម្រងទឹក ១ រមែងគួរ ដល់ភិក្ខុអ្នកប្រកបដោយសេចក្តីព្យាយាម យកទៅថ្វាយដល់ព្រះបរម ពោធិសត្វ ។**

គ្រានោះ ព្រះបរមពោធិសត្វទ្រង់ស្លៀកដណ្តប់ទង់ជ័យនៃព្រះ អរហន្តហើយ កាន់យកភេទបព្វជ្ជាដ៏ខ្ពង់ខ្ពស់ ទើបទ្រង់បញ្ជូនឆន្នាមាត្យ ទៅដោយទ្រង់ត្រាស់ថា នៃឆន្ន អ្នកចូរទូលដល់ការមិនមានរោគដល់ ព្រះជនក និងព្រះជននី តាមពាក្យរបស់យើងផងចុះ ។ ឆន្នាមាត្យ ថ្វាយបង្គំលាព្រះបរមពោធិសត្វ ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។ ចំណែកឯសេះកណ្ឋកៈ ដែលបានឈរស្តាប់ពាក្យឆ្លើយឆ្លងរបស់ព្រះ បរមពោធិសត្វ និងឆន្នាមាត្យ បានគិតថា ឥឡូវនេះ អញលែងបាន

ឃើញម្ចាស់អញតទៅទៀតហើយ កាលដើរកន្ទងផុតក្រសែភ្នែកនៃព្រះបរមពោធិសត្វទៅ មិនអាចអត់សង្កត់សេចក្តីសោកនោះបាន ក៏បែកទ្រូងស្លាប់ទៅ បានទៅកើតជាកណ្ឋកទេវបុត្រ នៅស្ថានតាវត្តិង្ស ។ គ្រាដំបូងនាយឆន្នមាននូវសេចក្តីសោកសៅត្រឹមតែម្យ៉ាង ប៉ុន្តែកាលសេះកណ្ឋកៈស្លាប់ទៅ នាយឆន្នាមាត្យត្រូវសេចក្តីសោកសៅលើកទី ២ ចូលមកគ្របសង្កត់ទៀត បានដើរយំខ្សឹកខ្សួលទៅកាន់ព្រះនគរវិញ ( កាលដែលព្រះបរមពោធិសត្វ ស្តេចចេញសាងព្រះផ្នួស ត្រូវនឹងថ្ងៃ ១៥ ខែអាសាឍ ឆ្នាំថោះ នៅក្នុងមជ្ឈិមយាមនៃរាត្រី ក្នុងព្រះជន្មគម្រប់ ២៩ ព្រះវស្សា ) ។

លុះព្រះបរមពោធិសត្វ ទ្រង់ទ្រទ្រង់ភេទបព្វជ្ជារួចហើយ បានទៅសម្រាកដោយសេចក្តីសុខដែលកើតអំពីបព្វជ្ជា រហូតមួយសប្តាហ៍ក្នុងអនុបិយអម្ពវនប្រទេស ។ លុះដល់ថ្ងៃទី ៨ ស្តេចត្រាច់ចរទៅដោយព្រះបាទ ក្នុងចម្ងាយផ្លូវ ៣០ យោជន៍ តែមួយថ្ងៃប៉ុណ្ណោះ ហើយស្តេចយាងចូលទៅកាន់ក្រុងរាជគ្រឹះ លុះស្តេចយាងចូលទៅដល់ហើយព្រះបរមពោធិសត្វត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក ។ ពេលនោះមនុស្សទាំងឡាយក្នុងក្រុងទាំងអស់ បានដល់នូវការញាប់ញ័រចិត្ត

ព្រោះបានឃើញរូបសម្បត្តិនៃព្រះបរមពោធិសត្វ ដូចពេលដែលដំរីធនបាលចូលទៅក្នុងក្រុងរាជគ្រឹះ ដូច្នោះ ។ លំដាប់នោះ រាជបុរសទាំងឡាយ បានក្រាបទូលព្រះបាទពិម្ពិសារថា បពិត្រព្រះសម្មតិទេព បុគ្គលយ៉ាងនេះ បានឃើញបុគ្គលម្នាក់ត្រាច់ចរបិណ្ឌបាតនៅក្នុងក្រុង ខ្ញុំព្រះអង្គទាំងឡាយ មិនជ្រាបសោះថា អ្នកនេះឈ្មោះអ្វី ជាទេវៈ ជាមនុស្ស ជានាគ ឬជាគ្រុឌទេ ព្រះអង្គ ។ គ្រានោះ ព្រះរាជាប្រថាប់ឈរទីផ្ទៃប្រាសាទទតឃើញព្រះមហាបុរស ក៏មានសេចក្តីស្ងើចភាពអស្ចារ្យក្នុងព្រះទ័យ ទ្រង់ត្រាស់បង្គាប់ពួករាជបុរសថា នែអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ទៅឃ្លាំមើលឲ្យបានដឹងថា បើជាអមនុស្សពេលចេញអំពីក្រុងទៅ គង់តែនឹងបាត់ បើជាទេវតា គង់តែនឹងហោះទៅតាមអាកាស បើជានាគវិញ គង់នឹងមុជជ្រែក ចូលទៅក្នុងផែនដី បើជាមនុស្សវិញ គង់នឹងបរិភោគនូវអាហារ ដែលខ្លួនបាននោះ ក្នុងកន្លែងណាមួយមិនខាន ។

ចំណែកព្រះមហាបុរស មានឥន្ទ្រិយស្រគត់ស្រគំដោយប្រពៃ ស្តេចត្រាច់ចរបិណ្ឌបាតតាមលំដាប់ លុះបានភត្តដែលលាយច្របូកច្របល់ដោយរបស់ច្រើនមុខ ល្មមមួយចម្អែតហើយ ទ្រង់ស្តេចយាង

ចេញចាកក្រុង ទៅគង់ឯញកភ្នំបណ្ឌវបព៌ត បែរព្រះភក្ត្រទៅទិសខាងកើត ប្រារព្ធនឹងសោយនូវអាហារ ។ លំដាប់នោះ ទ្រង់មានព្រះរាជហឫទ័យក្រាញចំពោះអាហារ ដែលច្របូកច្របល់ដាក់នៅក្នុងបាត្រនោះ ទៅជាបដិកូលគួរឲ្យខ្ពើមរអើម រកកលសោយពុំកើត ព្រោះព្រះអង្គពុំធ្លាប់បានទតឃើញអាហារបែបនេះសោះឡើយ ហើយទ្រង់ទូន្មានខ្លួនឯងថា នែសិទ្ធត្ថ អ្នកឯងកើតនៅក្នុងត្រកូលខ្ពង់ខ្ពស់ ដែលសម្បូណ៌ទៅដោយភោជន និងទឹកមានរសជាតិប្រសើរថ្លៃថ្លាណាស់ ឥឡូវនេះ អ្នកបានអាហារបែបនេះ ជាការគួរដល់អ្នកឯងហើយ អ្នកឯងបរិភោគទៅកុំខ្ពើមរអើមឡើយ ។ លុះព្រះអង្គទូន្មានខ្លួនឯងយ៉ាងនេះហើយ ក៏ខំប្រឹងសោយអាហារនោះទៅ ។

គ្រានោះ រាជបុរសទាំងឡាយ ដែលតាមមកមើលនោះ លុះបានឃើញព្រះពោធិសត្វកំពុងសោយកត្តាហារក្បែរញកភ្នំ ក៏ត្រឡប់ទៅក្រាបទូលព្រះបាទពិម្ពិសារ ឲ្យទ្រង់ជ្រាបតាមដំណើរសព្វគ្រប់ប្រការ ។ ព្រះបាទពិម្ពិសារ ទ្រង់បានព្រះសណ្ដាប់ពាក្យនោះហើយ ស្ដេចប្រញាប់យាងចេញចាកព្រះនគរ ទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ទ្រង់ជ្រះថ្លាចំពោះព្រះឥរិយាបថដ៏ស្រគត់ស្រគំ ទើបទ្រង់ប្រគល់ភាពជាធំ ឲ្យដល់

ព្រះពោធិសត្វ ។ ព្រះពោធិសត្វត្រាស់ថា មហាបពិត្រ អាត្មាមិនត្រូវការវត្ថុកាម ឬកិលេសកាមទាំងឡាយឡើយ អាត្មាប្រាថ្នានូវសម្ពោធិញ្ញាណតែម៉្យាងប៉ុណ្ណោះ ទើបចេញមកបួស ។ ព្រះរាជាសូម្បីនឹងទ្រង់អង្វរជាអនេកប្បការ ក៏ព្រះទ័យរបស់ព្រះពោធិសត្វមិនយល់ស្របតាម ទើបត្រាស់ថា បើព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយ សូមព្រះអង្គស្តេចយាងមកប្រោសខ្ញុំព្រះអង្គមុនគេ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ចំណែកឯសេចក្តីពិស្តារ សូមមើលស័ព្ទក្នុងបព្វជ្ជាសូត្រថា យើងនឹងសរសើរការបួសដូចអ្នកមានចក្ខុបួសហើយដូចនេះគប្បីជ្រាបនៅក្នុងអដ្ឋកថាចុះ ។

ចំណែកព្រះបរមពោធិសត្វ បានថ្វាយបដិញ្ញា ចំពោះព្រះបាទពិម្ពិសារហើយ ស្តេចក៏បានយាងចារិកទៅតាមលំដាប់ទៀត រហូតទៅដល់សម្នាក់របស់អាឡារតាបសកាឡាមគោត្រ និងឧទកតាបសរាមបុត្រ ទ្រង់បានចម្រើនសមាបត្តិឲ្យកើតឡើង ហើយទ្រង់ត្រិះរិះថា នេះមិនមែនជាផ្លូវ ដើម្បីត្រាស់ដឹងជាព្រះពុទ្ធទេ ទើបទ្រង់មិនសព្វព្រះទ័យ ក្នុងសមាបត្តិភាវនានោះ មានព្រះបំណង ដើម្បីតាំងសេចក្តីព្យាយាមយ៉ាងធំ ដើម្បីទ្រង់សម្តែងកម្លាំង និងសេចក្តីព្យាយាមរបស់ព្រះអង្គ ដល់មនុស្ស

លោក ព្រមទាំងទេវលោក ទើបស្ដេចយាងទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេស ទ្រង់ព្រះតម្រិះថា ភូមិភាគនេះគួរជាទីរីករាយ ទើបស្ដេចយាងចូលទៅនៅក្នុងសេនានិគម ក្នុងឧរុវេលាប្រទេសនោះ ព្រះអង្គក៏បានតាំងមហាបធានឡើង ។

គ្រានោះ តាបស ៥ រូប មានកោណ្ឌញ្ញៈជាប្រធាន បាននាំគ្នាត្រាច់ស្វែងរកកិក្ខាក្នុងគាមនិគម និងរាជធានីជាលំដាប់ រហូតបានទៅជួបព្រះបរមពោធិសត្វ នៅឯសេនានិគមនោះ ។ លំដាប់នោះ តាបសទាំង ៥ រូបនោះ បានជានាខ្លួនធ្វើជាឧបដ្ឋាក បម្រើព្រះបរមពោធិសត្វ ដែលទ្រង់បានតាំងមហាបធានអស់ ៦ ព្រះវស្សា ( ធ្វើទុក្ករកិរិយាអស់ ៦ វស្សា ) ដោយវត្តបដិបត្តិ មានការបោសសម្អាតជាដើម ដោយម្នាក់ៗសង្ឃឹមក្នុងចិត្តថា ព្រះបរមពោធិសត្វ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលឥឡូវនេះ ដោយតាបសទាំង ៥ រូបនោះ បាននាំគ្នារស់នៅក្នុងសម្នាក់របស់ព្រះពោធិសត្វនោះឯង ។

ចំណែកព្រះបរមពោធិសត្វទ្រង់ព្រះតម្រិះថា នឹងធ្វើទុក្ករកិរិយាឲ្យដល់នូវទីបំផុត ទើបព្រះអង្គបន្ថយអាហារជាលំដាប់ៗ ដរាបដល់ប៉ុនគ្រាប់ល្ងមួយគ្រាប់ជាដើម ទ្រង់បានបន្ថយអាហារ ដោយប្រការ

ទាំងពួងហើយ ។ ចំណែកទេវតា ក៏បាននាំគ្នាយកឱជាជាទិព្វបញ្ចូល ទៅក្នុងរណ្តៅនៃរោមទាំងឡាយ នាកាលព្រះបរមពោធិសត្វមានព្រះ វរកាយដល់នូវកាពទន់ អស់កម្លាំងល្ហិតល្ហៃយ៉ាងក្រៃលែង ព្រោះ ការរស់នៅមិនមានព្រះក្រយាហារនោះ ព្រះវរកាយដែលមានសម្បុរ ដូចជាមាស ក៏ត្រឡប់ទៅជាមានសម្បុរខ្មៅជាំទៅវិញ ថែមទាំងមហា បុរិសលក្ខណៈ ៣២ ប្រការ ក៏ទៅជាស្រអាប់កំបាំងបាត់មិនប្រាកដដែរ ។ ក្នុងគ្រាខ្លះ កាលទ្រង់សម្ងំឈានមិនមានខ្យល់ដកដង្ហើម ត្រូវទុក្ខវេទនា គ្របសង្កត់យ៉ាងខ្លាំង ធ្វើឲ្យបាត់ស្មារតីដួលដេក ក្នុងទីបំផុតនៃកន្លែង ចង្ក្រម ។ លំដាប់នោះ ទេវតាមួយពួកបានពោលដល់ព្រះបរមពោធិសត្វថា ព្រះសមណគោតម ធ្វើកាលកិរិយាទៅហើយ ទេវតាមួយពួកទៀត ពោលថា ព្រះសមណគោតមនៅរស់នៅឡើយទេ ។ ពួកទេវតាដែល និយាយថា ព្រះសមណគោតម បានធ្វើកាលកិរិយាទៅហើយនោះ បាននាំគ្នាទៅក្រាបទូលដល់ព្រះបាទសុទ្ធោទនៈថា ព្រះរាជឱរសរបស់ ព្រះអង្គទ្រង់សោយទិវង្គតទៅហើយ ។ ព្រះរាជាត្រាស់តបថា បុត្ររបស់ យើងនៅមិនទាន់បានត្រាស់ជាព្រះពុទ្ធទេនោះ នឹងមិនធ្វើកាលកិរិយាទេ ។ ទេវតានោះក្រាបទូលថា ព្រះរាជឱរសរបស់ព្រះអង្គ មិនអាចត្រាស់

ជាព្រះពុទ្ធទេ ទ្រង់ដួលដេកនៅលើផែនដីក្នុងទីបំផុត នៃទីចង្ក្រមសោយទិវង្គតហើយ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទើបទ្រង់ត្រាស់ថា ខ្ញុំពុំជឿទេ បុត្ររបស់ខ្ញុំ កាលនៅមិនទាន់បានសម្រេចសម្ពោធិញ្ញាណ នឹងធ្វើកាលកិរិយានោះ រមែងមិនមាន ។ សួរថា ក៏ព្រោះហេតុអ្វី ទើបព្រះរាជាទ្រង់មិនជឿ ? ឆ្លើយថា ព្រោះព្រះអង្គទ្រង់បានឃើញបាដិហារិយ៍ទាំងឡាយ ក្នុងថ្ងៃដែលឲ្យព្រះពោធិសត្វសំពះដល់កាឡទេវិលតាបសម្ដង និងខាងក្រោមដើមព្រីងម្ដងទៀត ។ ព្រះបរមពោធិសត្វ ទ្រង់មានស្មារតីក្រោកឡើងវិញបានម្ដងទៀត កាលបើព្រះបរមពោធិសត្វក្រោកឡើងហើយ ទេវតាទាំងនោះ មកក្រាបទូលដល់ព្រះរាជាថា បពិត្រមហារាជ រាជឱរសរបស់ព្រះអង្គមិនមានរោគទេ ។ ព្រះរាជាត្រាស់ថា ខ្ញុំតែងដឹងថា បុត្ររបស់ខ្ញុំ មិនធ្វើកាលកិរិយាឡើយ ។

កាលបើព្រះបរមពោធិសត្វ ទ្រង់បំពេញនូវទុក្ករកិរិយាអស់ ៦ វស្សានោះហើយ ទ្រង់ព្រះតម្រិះថា ការធ្វើទុក្ករកិរិយានេះ ពុំមែនជាផ្លូវឲ្យសម្រេចភាពជាព្រះពុទ្ធទេ ទើបស្ដេចត្រាច់ទៅបិណ្ឌបាត នៅក្នុងគាមនិគមទាំងឡាយ ដើម្បីត្រូវការអាហារសោយ ។ គ្រានោះ មហាបុរិសលក្ខណៈ ៣២ ប្រការរបស់ព្រះបរមពោធិសត្វ ក៏មានឡើងវិញ

ទាំងព្រះកាយ ក៏មានសម្បុរស្រស់បស់ល្អពេញលេញឡើងវិញ ។

ចំណែកតាបសទាំង ៥ រូប ( គឺពួកបញ្ចវគ្គិយ ) គិតគ្នាថា ព្រះបរមពោធិសត្វនេះ សូម្បីធ្វើទុក្ករកិរិយាដល់ទៅ ៦ ឆ្នាំក៏មិនអាចសម្រេចនូវសព្វញ្ញុតញ្ញាណបាន ឥឡូវនេះ បានត្រាច់ទៅបិណ្ឌបាតក្នុងស្រុកជាដើម នាំយកនូវអាហារដើម្បីសោយវិញ បើធ្វើយ៉ាងនេះ នឹងបានត្រាស់ដឹងដូចម្ដេចកើត សូម្បីតែប្រឹងប្រែងធ្វើយ៉ាងនោះ អស់ ៦ ឆ្នាំហើយក៏ដោយ ក៏នៅតែមិនបានសម្រេច ព្រះមហាបុរសនេះ ក្លាយជាមនុស្សប្រាថ្នាច្រើន លះបង់នូវសេចក្ដីព្យាយាម ឈ្មោះថា ការប៉ុន់ស្មានចំពោះគុណវិសេសនៃព្រះបរមពោធិសត្វនេះ ក៏ដូចជាមនុស្សមុជទឹកក្នុងស្រះ គិតស្មានដំណក់ទឹកជាប់នឹងក្បាលដូចនេះ ណ្ហើយចុះ តើមានប្រយោជន៍អ្វីទៀត ដែលពួកយើងនៅបម្រើព្រះមហាបុរសនោះ ទើបនាំគ្នាដើរចោលព្រះមហាបុរស ដោយនាំគ្នាកាន់យកបាត្រ និងចីវររៀងៗខ្លួន ធ្វើដំណើរទៅអស់ចម្ងាយផ្លូវ ១៨ យោជន៍ ក៏ទៅដល់ព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី តាមអធ្យាស្រ័យរបស់ខ្លួន ។

ក្នុងសម័យនោះឯង ទារិកាម្នាក់ឈ្មោះនាងសុជាតា ជាធីតានៃសេនកុដុម្ពិក នៅក្នុងសេនានិគម ក្នុងឧរុវេលាប្រទេស នាងមាន

វ័យចម្រើនឡើង បានទៅបន់ទេវតា តាំងសេចក្តីប្រាថ្នា នៅក្រោមដើមជ្រៃមួយដើមថា បើខ្ញុំបានប្តីមានជាតិស្មើគ្នា ហើយបានកូនប្រុសជាលើកដំបូង ដូចសេចក្តីប្រាថ្នារបស់ខ្ញុំនេះពិត ខ្ញុំនឹងធ្វើពលិកម្ម ដោយការបរិច្ចាគទ្រព្យមួយសែនកហាបណៈ ដល់លោកជារៀងរាល់ឆ្នាំ ។ លុះចំណេរកាលតមក សេចក្តីប្រាថ្នារបស់នាងសុជាតា ក៏បានសម្រេចដូចបំណងមែន កាលនោះ ព្រះមហាសត្វធ្វើទុក្ករកិរិយាអស់ ៦ វស្សាបរិបូណ៌ហើយ នាងសុជាតានេះប្រាថ្នានឹងធ្វើពលិកម្ម ក្នុងថ្ងៃពេញបូណ៌មីខែពិសាខ នាងបានបង្គាប់ឲ្យមនុស្សនាំយកមេគោមួយពាន់ទៅលែងក្នុងព្រៃឈើអែម ។ លុះដល់វេលាល្ងាច នាងឲ្យយកកាជនៈមកត្រងទឹកដោះគោ អំពីគោ ៥០០ យកទៅឲ្យមេគោ ៥០០ ដែលមិនទាន់បានរូតទឹកដោះនោះផឹក ។ នាងសុជាតាឲ្យបែងភាគចែកជាពាក់កណ្តាលៗយ៉ាងនេះ ដរាបសល់តែមេគោ ៨ ។ បានជានាងសុជាតាធ្វើដូច្នោះដើម្បីឲ្យទឹកដោះនោះ មានរសផ្អែមល្អ នៅវេលាព្រឹកថ្ងៃនោះ ជាថ្ងៃពេញបូណ៌មីខែពិសាខ នាងសុជាតា ក្រោកឡើងក្នុងវេលាជិតភ្លឺឲ្យរូតទឹកដោះគោ ៨ ក្បាលនោះ ។ កូនគោទាំងឡាយ ក៏មិនទៅបៅគេគ្រាន់តែនាំយកកាជនៈថ្មី ចូលទៅជិត កន្សោមដោះមេគោនោះ

ជាទឹកដោះក៏ហូរចេញមកតាមធម្មតារបស់ខ្លួន នាងសុជាតាបានឃើញហេតុអស្ចារ្យដូច្នោះហើយ ទើបកាន់យកភាជនៈទឹកដោះនោះដោយដៃរបស់ខ្លួនឯង ដាក់ចុះក្នុងភាជនៈថ្មី ហើយបង្កាត់ភ្លើងដោយដៃខ្លួនឯងទៀតប្រារព្ធនឹងចម្អិនមធុបាយាសៗ ដែលនាងកំពុងចម្អិននោះ មានពពុះធំៗវិលជាទក្ខិណាវដ្ដ សូម្បីតែមួយដំណក់ ក៏មិនបានហៀរស្រក់ធ្លាក់ចុះទៅខាងក្រៅមាត់ឆ្នាំងឡើយ ទាំងផ្សែងភ្លើងសោត សូម្បីបន្តិចបន្តួចក៏គ្មានហុយឡើង អំពីជើងក្រានឆ្នាំងដែរ ។ សម័យនោះ មហារាជទាំង ៤ ចុះមកជួយរក្សាជើងក្រាន មហាព្រហ្មយកស្វេតច្ឆត្រមកបាំងឯសក្កទេវរាជជាអ្នកដាក់ឧស និងជាអ្នកមកជួយថែរក្សាភ្លើង ។ ពិតហើយទេវតាទាំងឡាយ ក៏នាំយកឱជារស ជាទិព្វមកដាក់ក្នុងមធុបាយាសដោយអានុភាពនៃខ្លួន ។ ឯអមនុស្សទាំងឡាយក្នុងទ្វីបទាំង ៤ ដែលមានទ្វីបតូចពីរពាន់ជាបរិវារ ក៏នាំយកឱជារសជាទិព្វ មកដាក់ក្នុងមធុបាយាសនោះ ដោយអានុភាពរបស់ខ្លួនដែរ ដូចបុគ្គលប្របាច់សម្បុកឃ្មុំដែលជាប់នឹងបង្គង ហើយកាន់យកតែទឹកផ្អែមដូច្នោះ ។

ការពិត នៅក្នុងពេលដទៃ ទេវតាទាំងឡាយដាក់ឱជារសក្នុងពំនូតបាយ ប៉ុន្ដែក្នុងថ្ងៃត្រាស់ដឹង និងថ្ងៃបរិនិព្វានដាក់ឱជារសក្នុង

ឆ្នាំងតែម្តង ។ នាងសុជាតាបានឃើញហេតុអស្ចារ្យពុំមែនតិច ដែលប្រាកដដល់ខ្លួនក្នុងទីនោះ ដោយត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ទើបនាងហៅនាងបុណ្ណទាសីមកនិយាយប្រាប់ថា នែនាងបុណ្ណា ថ្ងៃនេះ ពួកទេវតាមានចិត្តជ្រះថ្លានឹងយើងពេកណាស់ ក្នុងកាលមានប្រមាណប៉ុណ្ណោះ ខ្ញុំមិនធ្លាប់បានឃើញហេតុដ៏អស្ចារ្យដូច្នេះឡើយ ចូរនាងប្រញាប់ប្រញាល់ទៅបោសសម្អាតក្រោមដើមជ្រៃ ដែលជាទីលំនៅនៃទេវតារបស់យើងឲ្យបានស្អាត ។ នាងបុណ្ណទាសី ក៏ទទួលតាមបង្គាប់របស់នាងសុជាតាសព្វគ្រប់ ។

ចំណែកព្រះបរមពោធិសត្វ បានឃើញមហាសុបិន ៥ ប្រការ ក្នុងពេលអាធ្រាត្រ ទើបទ្រង់ពិចារណា និងធ្វើសន្និដ្ឋានថា ថ្ងៃនេះ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យឡើយ ។ លុះរាត្រីនោះកន្លងទៅហើយ ទ្រង់ធ្វើការប្រតិបត្តិសរីរៈ រង់ចាំវេលាភិក្ខាចារ លុះព្រឹកព្រលឹមឡើង ទើបស្តេចយាងទៅគង់ប្រថាប់ក្រោមដើមជ្រៃនោះ ទ្រង់ញ៉ាំងគល់ទាំងអស់ ឲ្យភ្លឺរុងរឿងដោយរស្មីរបស់ព្រះអង្គ ។

លំដាប់នោះ នាងបុណ្ណទាសីបានទៅឃើញព្រះពោធិសត្វគង់ប្រថាប់នៅក្រោមដើមជ្រៃ កំពុងទតលោកធាតុ បែរព្រះភក្ត្រទៅទិស

ខាងកើត ។ នាងបុណ្ណាទាសីបានឃើញដើមជ្រៃទាំងអស់ មានពណ៌ដូចជាមាស ដោយមានរស្មីផ្សាយចេញអំពីសរីរៈរបស់ព្រះពោធិសត្វនោះ ទើបនាងគិតដូច្នេះថា ថ្ងៃនេះ ទេវតារបស់យើងចុះអំពីដើមឈើមកអង្គុយរង់ចាំ ដើម្បីនឹងទទួលពលិកម្ម ដោយដៃរបស់ខ្លួនឯងទេដឹង ? នាងក៏មានចិត្តត្រេកអរ ប្រញាប់ប្រញាល់ទៅជម្រាបហេតុនោះដល់នាងសុជាតាវិញ ។ នាងសុជាតាបានស្តាប់ពាក្យរបស់នាងបុណ្ណាទាសីដូច្នេះហើយ ក៏សប្បាយចិត្តឡើង ទើបពោលតបទៅវិញថា បើពិតដូច្នោះមែន ចាប់ពីថ្ងៃនេះតទៅ ឯងចូរនៅក្នុងនាទីជាធីតាច្បងរបស់យើង ។ លុះពោលដូច្នេះហើយ ក៏ឲ្យគ្រឿងអលង្ការគ្រប់បែបយ៉ាងដល់នាងបុណ្ណាទាសី ។ ព្រោះហេតុដែលក្នុងថ្ងៃនោះ នឹងបានសម្រេចភាពជាព្រះពុទ្ធ បានភាជនៈមាស ដែលមានតម្លៃមួយសែនទើបនឹងគួរ ព្រោះដូច្នោះ នាងសុជាតានោះ ទើបធ្វើការគិតឡើងថា នឹងដាក់មធុបាយាសក្នុងភាជនៈមាសនេះ ទើបរំពឹងដល់កោជនដែលឆ្អិនហើយ ។ បាយាសទាំងអស់ ក៏ស្រោប់តែត្រឡប់មកស្ថិតនៅក្នុងភាជនៈមាស ពេញដោយខ្លួនឯងមួយរំពេច ហាក់បីដូចជាទឹក ដែលហូរធ្លាក់ចុះអំពីស្លឹកឈូក ។ មធុបាយាសនោះ បានពេញភាជនៈមាសនោះល្មម ។ ទើបនាងយក

កាជនៈដទៃមកគ្របកាជនៈនោះ ហើយវេចដោយសំពត់ស នាងប្រដាប់តាក់តែងរាងកាយ ដោយគ្រឿងអលង្ការទាំងពួង រួចហើយក៏លើកកាជនៈនោះ ដាក់ទូលលើសិរសារបស់ខ្លួន ដើរសំដៅទៅកាន់ដើមជ្រៃនោះ ដោយភាពជាធំ លុះទៅដល់បានក្រឡេកឃើញព្រះពោធិសត្វ ក៏កើតសោមនស្សយ៉ាងខ្លាំង ដោយសម្គាល់ថាជាទេវតាមែន ទើបបង្អោនកាយដើរចូលទៅ តាំងអំពីវេលាក្រឡេកឃើញ បានដាក់កាជនៈចុះអំពីសិរសា ហើយបើកគម្របយកឃ្លោកទឹកមាស ដែលអប់ដោយផ្កាក្រអូប ហើយបានចូលទៅឈរនៅជិតព្រះពោធិសត្វ ។ បាត្រដែលឃដិការមហាព្រហ្មថ្វាយនោះ មិនឃ្លាតឆ្ងាយអំពីព្រះពោធិសត្វមករហូត អស់កាលដ៏យូរប្រមាណប៉ុណ្ណោះ ក៏បានបាត់ទៅក្នុងខណៈនោះ ។ ព្រះពោធិសត្វ ទ្រង់រាករកបាត្រនឹងយកទៅដាក់ទទួល ក៏មិនឃើញបាត្រ ទើបលាតព្រះហស្តខាងស្តាំចេញមកទទួល ។ នាងសុជាតាទើបដាក់កាជនៈមាសមធុបាយាសលើព្រះហស្ត នៃព្រះមហាបុរស ។ ព្រះពោធិសត្វទតមើលនាងសុជាតាៗ កំណត់អាការនៃព្រះពោធិសត្វហើយ ទើបទូលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កាន់យកវត្ថុដែលខ្ញុំម្ចាស់បានបរិច្ចាគដល់លោកម្ចាស់ទៅចុះ សំពះហើយទូលថា

មនោរថ គឺសេចក្ដីប្រាថ្នាសូមសម្រេចដល់លោកម្ចាស់ ដូចសេចក្ដីប្រាថ្នារបស់ខ្ញុំម្ចាស់សម្រេចហើយដែរ នាងមិនកន្សល់អាល័យកាជនះមាសដែលមានតម្លៃមួយសែនកហាបណៈ ដូចជាកាជនះដីចាស់ដូច្នោះដែររួចហើយ នាងក៏ថ្វាយបង្គំលាត្រឡប់ មកកាន់និវេសន៍វិញ ។

ចំណែកព្រះពោធិសត្វទ្រង់ក្រោកចាកអាសនៈ ទ្រង់ប្រទក្សិណដើមជ្រៃរួចហើយ ទ្រង់ក៏បានកាន់យកនូវកាជនៈមាសនោះ ស្ដេចយាងសំដៅទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ។ ក្នុងថ្ងៃដែលព្រះពោធិសត្វច្រើនសែនព្រះអង្គនឹងបានត្រាស់ មានកំពង់ទឹកឈ្មោះ សុប្រតិស្ឋ ជាទីកន្លែងស្ដេចចុះស្រង់ទឹក ហើយទ្រង់ស្លៀកទង់ជ័យនៃព្រះអរហន្ត ដែលជាគ្រឿងស្លៀកដណ្ដប់របស់ព្រះពុទ្ធច្រើនសែនព្រះអង្គមកនោះ ទ្រង់គង់បែរព្រះភក្ត្រទៅទិសខាងកើត ទ្រង់ពូតពំនូតបាយមធុបាយាសជាពំនូតៗបានប្រមាណ ៤៩ ពំនូត ក្នុងមួយពំនូតៗ ប្រមាណប៉ុនគ្រាប់ត្នោតហើយទ្រង់សោយមធុបាយាសមានទឹកតិចទាំងអស់ ឥតមានសេសសល់ឡើយ ។ មធុបាយាសនោះ ជាអាហាររបស់ព្រះពោធិសត្វ ដែលទ្រង់បានត្រាស់ដឹងជាព្រះពុទ្ធ ហើយនាំឲ្យមានព្រះកាយពល ទ្រង់គង់នៅត្រង់ពោធិមណ្ឌលដ្ឋាន អស់ ៧ សប្ដាហ៍ ( ៤៩ ថ្ងៃ ) ក្នុងកាលមាន

ប្រមាណប៉ុណ្ណោះ មិនមានអាហារដទៃទៀត មិនស្រង់ទឹក មិនលុបលាង ជម្រះព្រះឱស្ឋ មិនបន្ទោបង់វលញ្ជៈក្នុងសរីរៈ ទ្រង់អាស្រ័យនៅដោយឈានសុខ មគ្គសុខ និងផលសុខប៉ុណ្ណោះ ។ ព្រះពោធិសត្វទ្រង់សោយមធុបាយាសនោះរួចស្រេចហើយ ទ្រង់កាន់ភាជនៈមាស ទៅបណ្តែតក្នុងស្ទឹងនេរញ្ជរា ដោយទ្រង់អធិដ្ឋានថា បើយើងបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃនេះពិតមែន សូមឲ្យភាជនៈមាសនេះអណ្តែតច្រាស់ខ្សែទឹកឡើងទៅ បើយើងមិនបានត្រាស់ដឹងជាព្រះពុទ្ធនោះទេ សូមអណ្តែតទៅតាមខ្សែទឹកចុះ ។ លុះទ្រង់បានអធិដ្ឋាន ដូច្នេះរួចហើយ ក៏បានបណ្តែតភាជនៈមាសនោះទៅ ភាជនៈមាសនោះ ក៏បានអណ្តែតកាត់ទទឹងខ្សែទឹកទៅដល់ពាក់កណ្តាលស្ទឹង បានអណ្តែតច្រាស់ខ្សែទឹកទៅខាងលើអស់ប្រមាណ ៨០ ហត្ថ ប្រៀបដូចជាជំហានជើងសេះ ដ៏រហ័សរត់ទៅដូច្នោះ ហើយក៏លិចចុះទៅក្នុងអន្លង់មួយរំពេចនោះឯង ជិតទីលំនៅនៃ **កាឡនាគរាជ** ទៅប៉ះទង្គិចភាជនៈមាសរបស់ព្រះពុទ្ធ ៣ ព្រះអង្គពីបុរាណដែលបានត្រាស់ដឹងរួចមកហើយ ក៏មានសំឡេងលាន់សូរឡើង ក្រឹកៗ ហើយស្ថិតនៅពីខាងក្រោមភាជនៈទាំង ៣ នោះឯង ។ នៅក្នុងខណៈនោះ កាឡនាគរាជ បានឮសំឡេងនោះហើយ បានពោលថា កាលពីថ្ងៃ

ម្សិលមិញនេះ មានព្រះពុទ្ធត្រាស់ដឹងមួយព្រះអង្គហើយ ។ ឥឡូវថ្ងៃនេះ មានព្រះពុទ្ធត្រាស់ដឹងមួយព្រះអង្គទៀត ។ ទើបបានពោលសរសើរព្រះពុទ្ធគុណដោយបទច្រើនរយបទ ។ បានឮថា ពេលដែលមហាប្រឹថពីដុះឡើងប្រមាណមួយយោជន៍បីគាវុតបានដូចជាថ្ងៃនេះ ឬថ្ងៃស្អែកនេះ ដល់កាឡនាគរាជនោះភ្ញាក់ឡើងម្តង ។

ចំណែកខាងព្រះបរមពោធិសត្វ ទ្រង់សម្រាកព្រះកាយពេលថ្ងៃនៅជិតច្នេរស្ទឹងនេរញ្ជរា ដែលមានផ្កាឈើរីកស្គុសស្គាយហើយ លុះដល់សាយណ្ហសម័យ ក្នុងពេលដែលផ្កាទាំងឡាយ រុះរោយចាកទង ទ្រង់យាងចេញចាកសាលវ័ន ឆ្ពោះទៅកាន់ពោធិមណ្ឌល ដោយមានចម្ងាយផ្លូវប្រមាណ ៨ ឧសភៈ ដែលទេវតាទាំងឡាយតាក់តែងហើយ ទ្រង់យាងទៅដូចដំណើររាជសីហ៍ យក្ស នាគ និងគ្រុឌជាដើម បានបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាទិព្វ ម៉ឺនលោកធាតុមានក្លិនក្រអូបដូចគ្នា និងមានសំឡេងសាធុការដូចគ្នាដែរ ។ សម័យនោះ ព្រាហ្មណ៍ឈ្មោះ **សោត្ថិយ** កំពុងតែរែកស្មៅស្គាដើរតាមផ្លូវមក បានជួបនឹងព្រះពោធិសត្វ ថែមទាំងដឹងអាការនៃព្រះមហាបុរស ទើបយកស្មៅស្គា ៨ ក្តាប់ថ្វាយដល់ព្រះអង្គ ។ ព្រះពោធិសត្វ ទទួលស្មៅស្គានោះហើយ

ស្តេចឡើងកាន់ពោធិមណ្ឌល បានប្រថាប់ឈរនៅក្នុងទិសខាងត្បូង បែរព្រះភក្ត្រទៅទិសខាងជើង ។ ខណៈនោះ ចក្រវាឡទិសខាងត្បូងស្រុតចុះ ហាក់បីដូចទៅទល់អវីចិនរកខាងក្រោម ចក្រវាឡខាងជើងក៏បានអណ្តែតឡើង ហាក់បីដូចទៅទល់ភវគ្គព្រហ្មខាងលើ ព្រះពោធិសត្វទ្រង់ត្រិះរិះថា ត្រង់ទីនេះមិនមែនជាកន្លែង ដែលនឹងឲ្យសម្រេចសម្ពោធិញ្ញាណ ទើបធ្វើប្រទក្សិណ ស្តេចយាងទៅកាន់ទិសខាងលិចប្រថាប់ឈរបែរព្រះភក្ត្រទៅកាន់ទិសខាងកើត ។ លំដាប់នោះ ចក្រវាឡទិសខាងលិចបានស្រុតចុះ ហាក់បីដូចទៅទល់អវីចិនរក ចក្រវាឡខាងកើតអណ្តែតឡើង ហាក់បីដូចទៅទល់ភវគ្គព្រហ្ម មានន័យថាក្នុងទីកន្លែងនេះ ព្រះមហាបុរសនោះ ប្រថាប់ឈរហើយៗ មហាប្រឹថពីបានស្រុតចុះ និងប៉ោងឡើង ដូចកង់រទេះដែលត្រូវមនុស្សជាន់ប្រែក-ងលិចខ្នងកង់ដូច្នោះ ។ ព្រះពោធិសត្វទ្រង់ត្រិះរិះថា ទីនេះមិនមែនជាទីកន្លែង ដែលឲ្យសម្រេចសម្ពោធិញ្ញាណ ទើបទ្រង់ធ្វើប្រទក្សិណ ស្តេចយាងទៅកាន់ទិសខាងជើង ប្រថាប់ឈរបែរព្រះភក្ត្រទៅកាន់ទិសខាងត្បូង ។ លំដាប់នោះ ចក្រវាឡទិសខាងជើង បានស្រុតចុះ ហាក់បីដូចទៅទល់អវីចិនរក ចក្រវាឡទិសខាងត្បូងអណ្តែតឡើង ហាក់បី

ដូចទៅទល់កវគ្គព្រហ្ម ព្រះពោធិសត្វទ្រង់ត្រិះរិះថា សូម្បីទីនេះក៏មិនមែន ជាទីបានត្រាស់ដឹងសម្ពោធិញ្ញាណដែរ ទើបទ្រង់ធ្វើប្រទក្សិណ ស្តេច យាងទៅកាន់ទិសខាងកើត បានប្រថាប់ឈរបែរព្រះកក្ត្រទៅកាន់ទិស ខាងលិច ។ ក៏ទីកន្លែងទីតាំងបល្ល័ង្ករបស់ព្រះពុទ្ធទាំងឡាយ មាននៅ ទិសខាងកើត ទីនេះទើបមិនញាប់ញ័រ ព្រះមហាសត្វ ទ្រង់ជ្រាបថា ទីកន្លែងនេះជាទីកន្លែង ដែលព្រះសម្មាសម្ពុទ្ធទាំងពួង ទ្រង់មិនលះបង់ ជាទីកន្លែងដែលមិនញាប់ញ័រ ជាទីកន្លែងកម្ចាត់ទ្រុង គឺកិលេស ទើប ទ្រង់ចាប់ចុងស្មៅស្គាអង្រួនឲ្យញ័រ រំពេចនោះឯង មានបល្ល័ង្កកម្ពស់ ១៤ ហត្ថ ឯស្មៅស្គានោះ ក៏តាំងនៅជាកម្រាលតាមសភាពនៃខ្លួន ដដែល ដោយការក្រាលដូចនេះ ដែលជាងគំនូរ ឬជាងលាបពណ៌ សូម្បីអ្នកឆ្លាតក្រៃលែង ក៏មិនអាចនឹងគូរ ឬលាបពណ៌បានឡើយ ។

ព្រះពោធិសត្វ ទ្រង់បែរព្រះកក្ត្រទៅកាន់ទិសខាងកើត ដោយ ឲ្យដើមពោធិ៍នៅខាងក្រោយព្រះបិដ្ឋិ ព្រះពោធិសត្វទ្រង់ពែនព្រះភ្នែន ទ្រង់តាំងព្រះហឫទ័យប្រកបដោយសេចក្តីព្យាយាមដ៏មាំថា ស្បែកក្តី សរសៃក្តី ឆ្អឹងក្តីរបស់អាត្មាអញ ចូរឲ្យនៅសល់ចុះ ត្រង់សាច់ និង ឈាមទាំងអស់ក្នុងសរីរៈនេះ ចូរឲ្យរីងស្ងួតទៅចុះ ទ្រង់ពែនព្រះភ្នែនលើ

អបរាជិតបល្ល័ង្ក ទោះបីមានផ្លេកបន្ទោរ និងរន្ទះបាញ់ ១០០ ដង ក៏អាត្មាអញ មិនទម្លាយនូវភ្នែននេះឡើយ ដោយទ្រង់អធិដ្ឋានថា

សាច់ និងឈាមទាំងអស់ក្នុងសរីរៈ ចូរឲ្យរីងស្ងួតទៅចុះ ឲ្យសល់នៅតែស្បែក សរសៃ និងឆ្អឹងប៉ុណ្ណោះ ។

បើអាត្មាអញ មិនអាចសម្រេចសម្មាសម្ពោធិញ្ញាណ នៅលើបល្ល័ង្កនេះទេ នឹងមិនទម្លាយនូវភ្នែននេះឡើយ ។ សម័យនោះ ទេវបុត្តមារមានគំនិតអាក្រក់ គិតថា ព្រះសិទ្ធត្ថកុមារនេះ ប្រាថ្នានឹងកន្លងនូវវិស័យរបស់អញ ឥឡូវនេះ អញមិនឲ្យព្រះសិទ្ធត្ថកុមារនេះកន្លងអំណាចអញទៅបានឡើយ ។ លុះគិតឃើញដូច្នេះហើយ ទើបចេញទៅកាន់សម្នាក់នៃពលមារ ប្រាប់សេចក្តីនោះ ដល់ពពួកមារៗ ក៏ស្រែកហ៊ោទះដៃ ហើយបាននាំពលមារចេញមក ក៏សេនាមារនោះ មានពលដ៏រីកម្រាស់ ១២ យោជន៍ ដ៏គិរិមេខលៈកម្ពស់ ១៥០ យោជន៍មួយទៀត ។ ចំណែកទេវបុត្តមារខាងឆ្វេងព្រះពោធិសត្វមានកម្រាស់ដល់ទៅ ១២ យោជន៍ ខាងស្តាំ ក៏មានកម្រាស់ដល់ទៅ ១២ យោជន៍ដែរ ។ រីឯសេនាមារដែលស្ថិតនៅពីខាងក្រោយ ច្រើនតាន់តាប់ដេរដាស ពាសពេញទៅរហូតដល់កណ្តាប់មាត់ចក្រវាឡ ។ នៅពីខាងលើក៏មានពួកមារកម្រាស់

ទៅដល់ ៩ យោជន៍ ឯការបន្ទឺសំឡេងឡើង ក៏លាន់ឮកងរំពង ដូចសម្រេកផែនដីស្រុត តាំងអំពីប្រមាណមួយពាន់យោជន៍ ។ លំដាប់នោះទេវបុត្តមារឡើងជិះដំរីឈ្មោះ **គិរិមេខលៈ** ជាពាហនៈ ដែលមានកម្ពស់ ១៥០ យោជន៍ និម្មិតដៃ ១០០០ កាន់នូវអាវុធផ្សេងៗ ។ ចំណែកខាងសេនាមារឯទៀត មារពីរនាក់នឹងមិនកាន់អាវុធដូចគ្នា ជាអ្នកមានមុខមាត់ផ្សេងៗ គ្នា ម្យ៉ាងៗ ម្នាក់ ដូចនឹងគ្របសង្កត់ព្រះពោធិសត្វ ក៏ទេវតាម៉ឺនចក្រវាឡ ដែលមកឈរចោមរោម ព្រមទាំងពោលសរសើរព្រះមហាបុរស ឯសក្កទេវរាជបានឈរផ្លុំស័ង្ខវិជយយុទ្ធ ។ បានឮថា ស័ង្ខនោះមានទំហំប្រវែង ១២០ ហត្ថ ដើម្បីឲ្យរក្សាខ្យល់ នេះម្តងហើយផ្លុំនឹងមានសំឡេងនៅដដែលដល់ ៤ ខែ ទើបអស់សំឡេង **មហាកាឡនាគរាជ** បានឈរពោលសរសើរគុណច្រើនជាងរយបទ ស្តេចមហាព្រហ្មបានឈរកាន់ស្វេតច្ឆត្របាំង ប៉ុន្តែកាលពលមារលើកគ្នាចូលមកជិតដល់ពោធិមណ្ឌល បណ្តាទេវតាជាដើមទាំងនោះ សូម្បីតែទេវតាមួយអង្គក៏មិនអាចស្ថិតនៅបាន នាំគ្នារត់ខ្ចាត់ខ្ចាយទៅកាន់ទីផ្សេងៗ ទាំងអស់ទៅ កាឡនាគរាជ ក៏នាំនាគកញ្ញាទាំងអស់ មុជជ្រែកផែនដី ចូលទៅកាន់ពិភពនាគ មានរាជវាំងប្រមាណ ៥០០ យោជន៍ ហើយដេកយកដៃ

ទាំងពីរខ្នប់មុខ សក្កទេវរាជយកស័ង្ខវិជយយុទ្ធលាក់ក្រោយខ្នងហើយ បានទៅឈរនៅឯកណ្តាប់មាត់ចក្រវាឡ ។ ស្តេចមហាព្រហ្ម ក៏ចាប់ ស្វេតច្ឆត្រទៅកាន់ព្រហ្មលោកវិញ ក្នុងខណៈនោះ សូម្បីតែទេវតា មួយអង្គ ក៏មិនអាចស្ថិតនៅក្នុងទីនោះបានឡើយ ។

ចំណែកមារ ក៏ពោលប្រាប់នឹងបរិស័ទរបស់ខ្លួនថា នៃអ្នកទាំង ឡាយ ឈ្មោះថា បុរសដទៃ ដូចគ្នានឹងព្រះសិទ្ធត្ថ ជាព្រះឱរស នៃ ព្រះបាទសុទ្ធោទនៈ រមែងមិនមាន ពួកយើងមិនអាចនឹងធ្វើសង្គ្រាម ចូលតយុទ្ធក្នុងទីចំពីខាងមុខនៃសិទ្ធត្ថបានឡើយ ពួកយើងចូលទៅនៅ បានត្រឹមតែពីខាងឆ្វេង ពីខាងស្តាំ និងពីខាងក្រោយប៉ុណ្ណោះ។ចំណែក ឯព្រះមហាបុរសទ្រង់ទតទៅទិសទាំង ៣ ស្ងាត់សូន្យ ឥតមានទេវតា មួយអង្គឡើយ ព្រោះទេវតាទាំងនោះរត់បាត់ទៅអស់ ទ្រង់បានទតឃើញ សុទ្ធតែពពួកពលសេនាមារ លើកគ្នាមកយ៉ាងណែនតាន់តាប់អំពីទិស ខាងឧត្តរ ។ ទើបទ្រង់ព្រះតម្រិះថា ជនទាំងអម្បាលនេះ ប៉ុនប៉ងចំពោះ យើងតែម្នាក់ បានធ្វើនូវសកាពយ៉ាងគគ្រឹកគគ្រេង យ៉ាងនេះឡើង ។ ក្នុងទីនេះមិនមានមាតា បិតា បុត្រ ធីតា បងប្អូន ឬញាតិដទៃណាមួយទេ មានតែបារមីទាំង ១០ នេះប៉ុណ្ណោះ ដែលទុកដូចជាបុត្រ ឬជាញាតិ និង

ជាបរិវាររបស់អាត្មាអញអស់កាលដ៏យូរណាស់មកហើយ ។ គ្រានោះ ព្រះមហាបុរស ទ្រង់គន់រឭកដល់បារមីទាំង ១០ ស្រេចហើយ ក៏គង់ស្ងៀមព្រងើយ ។ លំដាប់នោះ ទេវបុត្តមារ បានបណ្តាលនូវមណ្ឌល នៃខ្យល់ឲ្យតាំងឡើង ដោយគិតថា អញនឹងធ្វើឲ្យព្រះសិទ្ធត្ថនេះរត់ចេញ ដោយខ្យល់នេះ ។ ឯខ្យល់នោះ ក៏បណ្តាលមកអំពីទិសទាំង ៤ មាន កម្លាំងយ៉ាងខ្លាំងក្លាអាចបក់បោកបំបាក់កំពូលភ្នំ សូម្បីមានទំហំប្រមាណ កន្លះយោជន៍ មួយយោជន៍ ពីរយោជន៍ ឬបីយោជន៍ក៏បាន (សណ្តក ដើមឈើទាំងឫស ទាំងគុម្ពជាដើមបាន) ។ធ្វើគាម និងនិគម ទិសជុំវិញ ឲ្យទៅជាធូលីក៏ដោយ ក៏មិនអាចធ្វើអ្វីព្រះមហាបុរសបាន ដោយអានុភាព នៃបុណ្យបារមីរបស់ព្រះពោធិសត្វ លុះខ្យល់បក់មកដល់ព្រះពោធិសត្វ ហើយ សូម្បីត្រឹមតែជាយចីវរ ក៏ពុំអាចបក់ឲ្យកម្រើកបានឡើយ ។ គ្រានោះ ទេវបុត្តមារ បានបណ្តាលភ្លៀងដ៏ធំធ្លាក់ចុះមកទៀត ដោយ បំណងនឹងឲ្យជោរជន់លិចស្លាប់ព្រះពោធិសត្វ ដោយអានុភាពរបស់ ខ្លួន ។ ភ្លៀងនោះឯង មានកម្រាស់ ១០០ ស្រទាប់ ១០០០ ស្រទាប់ ជាដើម ធ្លាក់ចុះមកពីពួដ៏អាកាស ហូរជ្រោះផែនដីដោយក្រសែទឹក ភ្លៀងលិចដើមឈើ និងព្រៃជាដើម ប៉ុន្តែដោយបុញ្ញានុភាពរបស់ព្រះ

ពោធិសត្វ ទឹកភ្លៀងនោះ សូម្បីត្រឹមតែមួយតំណក់ ក៏មិនអាចធ្វើឲ្យទទឹកចីវររបស់ព្រះអង្គបានឡើយ ។ បន្ទាប់អំពីនោះមកទៀត ទេវបុត្តមារក៏បណ្ដាលឲ្យកើតមានភ្លៀងដុំថ្ម កំពូលភ្នំធំៗ ឆេះជាផ្សែង ឆេះជាអណ្ដាតភ្លើង អណ្ដែតមកតាមផ្លូវអាកាស លុះមកដល់ព្រះពោធិសត្វ ក៏ត្រឡប់ក្លាយទៅជាកម្រងផ្កាទិព្វ បូជាទៀបបាទមូលនៃព្រះពោធិសត្វ ។

បន្ទាប់អំពីនោះទៀត បានបណ្ដាលភ្លៀងគ្រឿងប្រហារ មានដាវលំពែង និងសរជាដើម មានមុខតែម្ខាង មានមុខទាំងសងខាងឆេះជាផ្សែង ឆេះជាអណ្ដាតភ្លើង អណ្ដែតមកតាមផ្លូវអាកាស លុះមកដល់ព្រះពោធិសត្វភ្លាម ក៏ក្លាយទៅជាផ្កាទិព្វទាំងអស់ ។ រួចបានបណ្ដាលឲ្យមានភ្លៀងរងើកភ្លើងទាំងឡាយ មានពណ៌ក្រហមដូចផ្កាចារ អណ្ដែតមកតាមផ្លូវអាកាស លុះមកដល់ព្រះពោធិសត្វភ្លាម ក៏ក្លាយទៅជាផ្កាទិព្វរាត់រាយចុះទៀបបាទមូលនៃព្រះពោធិសត្វវិញ ។ បានបណ្ដាលឲ្យមានភ្លៀងផេះក្ដៅ មានពណ៌ដូចភ្លើង អណ្ដែតមកតាមផ្លូវអាកាស លុះមកដល់ព្រះពោធិសត្វភ្លាម ក៏ក្លាយទៅជាលម្អិតខ្លឹមចន្ទន៍ធ្លាក់ចុះមកទៀបបាទមូលនៃព្រះពោធិសត្វ ។ ក៏បណ្ដាលឲ្យមានភ្លៀងដីខ្សាច់មកទៀត ដីខ្សាច់ទាំងឡាយល្អិតម៉ដ្ឋ បំពក់ជាផ្សែង ឆេះជាភ្លើង អណ្ដែតមក

តាមផ្លូវអាកាស កាលមកដល់ព្រះពោធិសត្វភ្លាម ក៏ក្លាយទៅជាផ្កាទិព្វ ធ្លាក់ចុះទៀបបាទមូលនៃព្រះពោធិសត្វ ។ ក៏បណ្ដាលឲ្យមានភ្លៀងភក់មកទៀតដែរ ភ្លៀងភក់នោះក៏បំពក់ជាផ្សែង ឆេះជាភ្លើង អណ្ដែតមកតាមផ្លូវអាកាស កាលមកដល់ជិតព្រះពោធិសត្វភ្លាម ក៏ក្លាយទៅជាគ្រឿងលាបជាទិព្វ ធ្លាក់ចុះមកទៀបបាទមូលនៃព្រះពោធិសត្វ ។ បានបណ្ដាលឲ្យមានអ័ព្ទងងឹតតាំងឡើង ដោយគិតថា អញនឹងធ្វើឲ្យរន្ធត់ចិត្តខ្លាចដោយភាពងងឹតនេះ ហើយឲ្យព្រះសិទ្ធត្ថកុមាររត់ចេញទៅ ភាពងងឹតនោះ មានសភាពងងឹតគ្រប់ទិសទាំងពួង ហាក់បីដូចជាថ្ងៃ ១៤ រោច ព្រៃក្រាស់ អ័ព្ទ និងពេលអធ្រាត្រដូច្នោះដែរ លុះមកដល់ជិតព្រះពោធិសត្វ ក៏អន្តរធានបាត់ទៅអស់ ដូចភាពងងឹតដែលត្រូវកម្ចាត់ដោយពន្លឺនៃព្រះអាទិត្យ ។ មារមិនអាចឲ្យព្រះពោធិសត្វរត់ចេញទៅដោយខ្យល់ ភ្លៀង ភ្លៀងដុំថ្ម ភ្លៀងសស្ត្រា ភ្លៀងរងើកភ្លើង ភ្លៀងផេះក្ដៅ ភ្លៀងដីខ្សាច់ ភ្លៀងភក់ និងភាពអ័ព្ទ ងងឹតទាំង ៩ យ៉ាងនេះបាន ទើបបង្គាប់ទៅពួកពលសេនាមារថា នែវ៉ុយ អ្នករាល់គ្នា ចូរទៅចាប់ព្រះសិទ្ធត្ថនេះសម្លាប់ចោល ឬធ្វើឲ្យរត់ចេញអំពីទីនេះទៅ ។ ចំណែកខាងមារាធិរាជ ដែលជិះនៅលើដំរី **គិរីមេខលៈ** ដៃកាន់ចក្រាវុធ បរដំរី

សម្រុកចូលទៅជិតព្រះពោធិសត្វ ហើយពោលថា នែព្រះសិទ្ធត្ថ ចូរអ្នកក្រោកចេញអំពីរតនបល្ល័ង្កនេះៗ មិនមែនត្រូវបានអ្នកឯងទេ ត្រូវបានមកយើងទេតើ ព្រះមហាបុរសទ្រង់ព្រះសណ្ដាប់ពាក្យមារនោះហើយ ទើបបានត្រាស់តបទៅមារវិញថា នែមារ អ្នកមិនបានបំពេញបារមី ១០ ឧបបារមី ១០ និងបរមត្ថបារមី ១០ ទាំងមិនបានបរិច្ចាគ មហាបរិច្ចាគ ៥ មិនបានបំពេញញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយា បល្ល័ង្កនេះ ទើបមិនគួរដល់អ្នកទេ បល្ល័ង្កនេះសមគួរដល់យើង ។ លំដាប់នោះ មារាធិរាជក្រោធខឹងយ៉ាងខ្លាំង រឹងរឹតតែក្ដៀវក្ដាឡើង បានចាប់យកចក្រាវុធ បោលតម្រង់ទៅរកព្រះពោធិសត្វ កាលព្រះមហាបុរសនោះ ទ្រង់រំពឹងដល់បារមីទាំង ១០ ចក្រាវុធនោះ បានក្លាយទៅជាពិតាន បាំងនៅលើព្រះពោធិសត្វ បានឮថា ចក្រាវុធនោះមុតខ្លាំងណាស់ កាលបើមារនោះក្រោធហើយ គេវែងទៅទីដទៃៗ នឹងកាត់សរសៃថ្មដ៏ក្រាស់ ដូចគ្នានឹងកាត់ទំពាំងឫស្សី ប៉ុន្តែឥឡូវនេះ កាលបើចក្រាវុធនោះ ក្លាយជាពិតាន បាំងនៅពីលើព្រះមហាបុរសហើយ បរិស័ទក្រៅអំពីនេះ គិតថា ព្រះសិទ្ធត្ថនឹងក្រោកចេញអំពីរតនបល្ល័ង្កទៅក្នុងពេលនេះ ទើបនាំគ្នាលើកយកកំពូលភ្នំធំៗ បោលសំដៅទៅរក

ព្រះមហាបុរស កាលព្រះមហាបុរសរំពឹងដល់បារមីទាំង ១០ នោះ សូម្បីកំពូលភ្នំធំៗ នោះ ក៏ដល់នូវការៈជាកម្រងផ្កា ធ្លាក់ចុះមកលើផែនដីបូជាព្រះពោធិសត្វវិញ ។ ពួកទេវតា ដែលរត់ចោលព្រះពោធិសត្វទៅស្ថិតនៅឯកណ្តាប់មាត់ចក្រវាឡនោះ គ្រាន់តែអើត-ក អើតសីសៈមើលមកព្រះពោធិសត្វ ក៏នាំគ្នាគិតថា អត្តភាពរបស់ព្រះសិទ្ធត្ថ ដែលមានរូបឆោមលោមពណ៌ល្អនោះ ប្រហែលជាវិនាសទៅដោយដៃរបស់មារហើយ ទេដឹង ។

លំដាប់នោះ ព្រះមហាបុរសក៏បានត្រាស់ថា បល្ល័ង្កនេះកើតឡើងសម្រាប់យើង ក្នុងថ្ងៃដែលព្រះបរមពោធិសត្វទាំងឡាយ បានបំពេញបារមីរួចមកហើយ និងក្នុងថ្ងៃជាទីត្រាស់ដឹង ដូចនេះហើយ ទើបត្រាស់ទៅមារដែលឈរនោះថា នែមារ តើនរណាជាសាក្សីក្នុងរឿង ដែលអ្នកឲ្យទានហើយ ? មារក៏លើកដៃចង្អុលទៅពពួកពលរបស់ខ្លួន ដោយនិយាយថា ពួកមារមានប្រមាណប៉ុណ្ណេះជាសាក្សីរបស់យើងមែនឬ ? ខណៈនោះ សំឡេងនៃបរិស័ទមារ ក៏លាន់ឮគឹកកងរំពងព្រមគ្នាឡើងស្ទើរតែស្រុតផែនដី ដោយមានបរិស័ទស្រែកថា យើងជាសាក្សី យើងជាសាក្សី ដូចនេះ ។ លំដាប់នោះ ទើបមារត្រឡប់សួរទៅព្រះមហា

បុរសវិញថា នែសិទ្ធត្ថ នៅក្នុងការៈដែលអ្នកឲ្យទាន តើបាននរណាជាសាក្សី ? ព្រះមហាបុរសត្រាស់ថា មុនដំបូងបង្អស់ ក្នុងការៈដែលអ្នកឲ្យទាន ពួកពលមារទាំងឡាយជាសាក្សី តែសម្រាប់យើងនៅក្នុងទីនេះ មិនមានអ្នកណាជាសាក្សីរបស់យើងទេ ទានដែលយើងឲ្យហើយក្នុងអត្តភាពដទៃៗ លើកទុកសិនចុះ ក៏ក្នុងការៈដែលយើងស្ថិតនៅក្នុងអត្តភាពជាព្រះវេស្សន្តរ បានបរិច្ចាគមហាទាន ឲ្យវត្ថុនីមួយៗ ៧០០ មហាប្រឹថពីដ៏ក្រាស់នេះ សូម្បីមិនមានចេតនាក៏ជាសាក្សី ទើបព្រះអង្គបញ្ចេញព្រះហស្តខាងស្តាំអំពីក្នុងចីវរមក ចង្អុលទៅលើផែនដី ព្រមទាំងត្រាស់ថា នែមហាប្រឹថពី ក្នុងគ្រាដែលយើងជាព្រះវេស្សន្តរ យើងបានឲ្យទាន អ្នកឯងជាសាក្សីរបស់យើងមែនឬទេ ? មហាប្រឹថពីក្នុងគ្រានោះក៏បន្លឺសំឡេងខ្ទរខ្ទារឡើង ហាក់បីដូចគ្របសង្កត់សេនាមារ ដោយរយសំឡេង ពាន់សំឡេងថា យើងជាសាក្សី មហាប្រឹថពីបានពោលថា ព្រះសិទ្ធត្ថ ទានដែលលោកឲ្យហើយជាមហាទាន ជាឧត្តមទាន ព្រះ-មហាបុរសកំពុងពិចារណានូវមហាទាន ដែលព្រះអង្គបានឲ្យហើយ នៅក្នុងអត្តភាពជាព្រះវេស្សន្តរ **ដំរីគិរីមេខលៈ** មានកម្ពស់ប្រមាណជា ១៥០ យោជន៍ ពុំអាចទប់ទល់បាន ក៏ទន់ជង្គង់លុតចុះលើផែនដី បរិស័ទ

របស់មារ ម្នាក់ៗ នាំគ្នារត់ទៅកាន់ទិសានុទិសរៀងៗ ខ្លួន ក្នុងផ្លូវតែមួយ ដែលទៅម្នាក់ៗ នោះ មិនមានឡើយ ម្នាក់ៗ បានលះបោលប្រដាប់ប្រដា និងសំពត់ស្លៀកដណ្តប់ រត់ទៅដ៏យ៉ាងលឿនរហ័ស តម្រង់ទៅមុខ ។ លំដាប់នោះ ពួកទេវតាទាំងឡាយឃើញមារ និងសេនារបស់មាររត់ទៅអស់ហើយ បានពោលថា មារបរាជ័យ ចុះចាញ់ព្រះសិទ្ធត្ថហើយ ព្រះសិទ្ធត្ថបានទទួលជ័យជម្នះហើយ ពួកយើងមកទៅដើម្បីធ្វើការបូជាដល់ព្រះសិទ្ធត្ថ ពួកនាគក៏ប្រកាសដល់ពួកនាគ ពួកគ្រុឌក៏ប្រកាសដល់ពួកគ្រុឌ ពួកទេវតាក៏ប្រកាសដល់ពួកទេវតា ពួកព្រហ្មក៏ប្រកាសដល់ពួកព្រហ្ម ម្នាក់ៗ មានដៃកាន់ទៅដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម សំដៅទៅកាន់ពោធិបល្ល័ង្ក ដែលព្រះពោធិសត្វគង់ប្រថាប់ ។ ក៏កាលមារ និងសេនាមារទាំងនោះ រត់ទៅអស់ហើយ ក្នុងកាលនោះ ពួកនាគមានចិត្តរីករាយត្រេកអរ បានប្រកាសការឈ្នះរបស់ព្រះមហេសីនៅទីពោធិមណ្ឌលនោះថា

**ព្រះពុទ្ធទ្រង់មានសិរី ព្រះអង្គមានជ័យជម្នះហើយ ចំណែកមារមានចិត្តបាប បានចុះចាញ់ព្រះអង្គហើយ ។**

កាលនោះ ពួកគ្រុឌមានចិត្តរីករាយត្រេកអរ បានប្រកាសការ

ឈ្នះរបស់ព្រះមហេសីនៅទីពោធិមណ្ឌលនោះថា

ព្រះពុទ្ធទ្រង់មានសិរី ព្រះអង្គមានជ័យជម្នះហើយ ចំណែកមារមានចិត្តបាប បានចុះចាញ់ព្រះអង្គហើយ ។

កាលនោះ ពួកទេវតាមានចិត្តរីករាយត្រេកអរ បានប្រកាសការឈ្នះរបស់ព្រះមហេសីនៅទីពោធិមណ្ឌលនោះថា

ព្រះពុទ្ធទ្រង់មានសិរី ព្រះអង្គមានជ័យជម្នះហើយ ចំណែកមារមានចិត្តបាប បានចុះចាញ់ព្រះអង្គហើយ ។

កាលនោះ ពួកព្រហ្មមានចិត្តរីករាយត្រេកអរ បានប្រកាសការឈ្នះរបស់ព្រះមហេសីនៅទីពោធិមណ្ឌលនោះថា

ព្រះពុទ្ធទ្រង់មានសិរី ព្រះអង្គមានជ័យជម្នះហើយ ចំណែកមារមានចិត្តបាប បានចុះចាញ់ព្រះអង្គហើយ ។

ទេវតាទាំងឡាយ ក្នុងចក្រវាឡទាំងមួយម៉ឺន បាននាំគ្នាបូជាគ្រឿងសក្ការៈ មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម ចំពោះព្រះពោធិសត្វ ថែមទាំងបានឈរពោលសរសើរគុណ នៃព្រះពោធិសត្វ មានប្រការផ្សេងៗ ជាច្រើន ។ កាលព្រះអាទិត្យពុំទាន់អស្តង្គតនៅឡើយ ព្រះពោធិសត្វទ្រង់កម្ចាត់ពួកមារ និងរេហ៍ពលមារស្រេចហើយ ត្រួយសន្ទឹកពោធិព្រឹក្ស

មានពណ៌ប្រាកដដូចជាកែវប្រវាឡ ក៏ជ្រុះធ្លាក់មកលើចីវរព្រះអង្គ ។ លំដាប់នោះ ព្រះអង្គរឭកបាននូវ **បុព្វេនិវាសានុស្សតិញ្ញាណ** ក្នុង **បឋមយាម** ព្រះអង្គជម្រះ **ទិព្វចក្ខុ** ក្នុង **មជ្ឈិមយាម** ព្រះអង្គញ៉ាំងញាណឲ្យប្រឈមចុះក្នុងបដិច្ចសមុប្បាទក្នុង **បច្ឆិមយាម** ។ នាកាលព្រះមហាបុរសនោះ ទ្រង់ពិចារណានូវ **បច្ចយាការ** ដែលប្រកបដោយអង្គទាំង ១២ នោះ **ដោយអនុលោម បដិលោម** ដោយអំណាចនៃវដ្តៈ និងវិវដ្តៈ ម៉ឺនលោកធាតុក៏កម្រើកញ្រាប់ញ័រដល់ទៅ ១២ ដង ទល់នឹងទឹកទ្រផែនដីជាទីបំផុត ក៏ព្រះមហាបុរស ទ្រង់ញ៉ាំងម៉ឺនលោកធាតុឲ្យលាន់ឮខ្ទរខ្ទាឡើង ទ្រង់បានត្រាស់ដឹង ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណហើយ ក្នុងវេលាអរុណរះឡើង ។ កាលព្រះមហាបុរសនោះ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ម៉ឺនលោកធាតុទាំងអស់ បានមានការប្រដាប់តាក់តែងហើយ ស្មើនៃទង់ជ័យ និងទង់ផ្កាលា ដែលលើកឡើងនៅកណ្តាប់ចក្រវាឡទិសខាងកើត កកិតដល់កណ្តាប់មាត់ចក្រវាឡទិសខាងលិច ដែលលើកឡើង នៅកណ្តាប់មាត់ចក្រវាឡ ទិសខាងលិច ក៏ដូចគ្នា កកិតដល់កណ្តាប់ចក្រវាឡទិសខាងកើត ដែលលើកឡើងនៅកណ្តាប់ចក្រវាឡទិសខាងជើង កកិតដល់កណ្តាប់មាត់ចក្រវាឡទិសខាងត្បូង

ដែលលើកឡើងនៅកណ្តាប់មាត់ចក្រវាឡទិសខាងត្បូង កកិតដល់កណ្តាប់មាត់ចក្រវាឡទិសខាងជើង រីឯស្នើនៃទង់ជ័យ និងទង់ផ្កាលាដែលលើកឡើងនៅផ្ទៃប្រឹថពី បានតាំងទៅទល់នឹងព្រហ្មលោក ។ ស្នើដែលតាំងនៅក្នុងព្រហ្មលោក ក៏តាំងដល់ផ្ទៃប្រឹថពី ។ ដើមឈើមានផ្កាទាំងម៉ឺនចក្រវាឡក៏បញ្ចេញផ្កាឡើង ដើមឈើមានផ្លែ ក៏បានបញ្ចេញផ្លែឡើង ជាចង្កោមៗ ដើមឈើ មែកឈើ និងវល្លិ៍ ក៏មានផ្ការីកស្គុសស្គាយសំយុងចុះមក ផ្កាឈូកដែលរីកសំយុងចុះពីឰដ៏អាកាសក៏មាន ដែលទម្លាយផែនដី ផែនថ្មដុះឡើង ហើយរីកក៏មាន ឬរីកត្រួតបន្តគ្នា ៧ ជាន់ក៏មាន លោកធាតុទាំងមួយម៉ឺន សុទ្ធសឹងតែជេរជាសពាសពេញទៅដោយទង់ជ័យ និងផ្កាទាំងអស់ ។ លោកន្តរនរក ដែលមានទទឹង ៥០០ យោជន៍ ក្នុងចន្លោះចក្រវាឡទាំងឡាយ មិនធ្លាប់ភ្លឺដោយពន្លឺនៃព្រះអាទិត្យ ៧ ដួង ក៏មានពន្លឺឡើងដូចគ្នា ។ មហាសមុទ្រជម្រៅ ៨៤០០០ យោជន៍ បានក្លាយទៅជាទឹកមានរសផ្អែម ទឹកស្ទឹងទាំងឡាយមិនហូរ មនុស្សខ្វាក់អំពីកំណើត ទៅជាមានភ្នែកភ្លឺ មនុស្សថ្លង់អំពីកំណើត ទៅជាស្តាប់ឮសំឡេងបាន មនុស្សខ្វិនអំពីកំណើតទៅជាមានអវយវៈល្អវិញបាន ឬដើរបាន សត្វដែលជាប់ចំណង ឬ

ខ្ទោះឃ្មានជាដើម បានរួចចាកចំណងជាដើម ។ ព្រះពោធិសត្វដែល ទេវតា និងមនុស្សទាំងឡាយនាំគ្នាបូជាដោយសម្បត្តិ ដែលប្រកបដោយ សិរីពុំអាចប្រមាណបាន ដោយប្រការយ៉ាងនេះឯង កាលអច្ឆរិយធម៌ គឺធម៌ដ៏អស្ចារ្យទាំងឡាយ ដែលមានប្រការផ្សេងៗ ប្រាកដហើយ បានចាក់ធ្លុះសព្វញ្ញុតញ្ញាណ ទើបទ្រង់បន្លឺឧទាន ដែលព្រះពុទ្ធគ្រប់ ព្រះអង្គ ពុំដែលលះបង់ តែងបន្លឺនូវឧទានដូច្នេះថា

កាលតថាគតមិនទាន់បានជួបប្រទះ នូវពោធិញ្ញាណនៅឡើយ តថាគតរវល់តែស្វែងរកនូវជាងផ្ទះ គឺតណ្ហា អ្នកធ្វើនូវផ្ទះ គឺអត្តភាពនេះ ហើយអន្ទោលទៅក្នុងវដ្តសង្សារ មានជាតិមិនតែមួយ, ជាតិ គឺការកើត ជារឿយៗ រមែងនាំមកនូវសេចក្តីទុក្ខ, នែជាងផ្ទះ គឺតណ្ហា ឥឡូវនេះ តថាគតបានឃើញអ្នកច្បាស់ហើយ អ្នកឯងនឹងធ្វើនូវផ្ទះ គឺអត្តភាពនេះ ឲ្យតថាគតទៀតពុំបានឡើយ, ឆ្អឹងជំនីរ គឺកិលេសទាំងឡាយរបស់ អ្នកឯង តថាគតបានកាច់បំបាក់ចោលហើយ ទាំងកំពូលនៃផ្ទះ គឺអវិជ្ជា របស់អ្នកឯងទៀតសោត តថាគតក៏បានបំបាក់ចោលហើយដែរ ចិត្ត របស់តថាគតបានដល់នូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ, តថាគតបានដល់នូវព្រះអរហត្ត គឺការអស់ទៅនៃតណ្ហាទាំងឡាយហើយ ។

( ព្រះអង្គបានត្រាស់ដឹងក្នុងថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្មាយុគម្រប់ ៣៥ ព្រះវស្សា ) ។

ការតំណាលអំពីប្រវត្តិនៃព្រះសព្វញ្ញុពុទ្ធ ជាបរមគ្រូនៃយើង ចាប់តាំងអំពីព្រះអង្គនៅជាសន្តុសិតទេវបុត្រ ដែលស្ថិតនៅក្នុងស្ថានតុសិតបុរី នាស្ថានទេវលោក ដរាបមកដល់បានត្រាស់ដឹង គង់លើរតនបល្ល័ង្ក ក្រោមមណ្ឌលពោធិព្រឹក្សនេះ ហៅថា **អវិទូរេនិទាន** ដោយប្រការដូច្នេះឯង ។

ចប់ អវិទូរេនិទាន

# សន្តិកេនិទាន

**សន្តិកេនិទាន** លោកពោលថា កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីនោះៗ យ៉ាងនេះថា ព្រះលោកនាថទ្រង់គង់នៅក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ដោយរាប់ចាប់តាំងអំពីព្រះពុទ្ធអង្គ គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័នទៀបក្រុងវេសាលី ដូចនេះ ហៅថា **សន្តិកេនិទាន** រមែងមាននៅក្នុងទីនោះៗ ឯង។ លោកពោលទុកយ៉ាងនោះៗ ក៏ពិតមែន សូម្បីយ៉ាងនោះ

សន្តិកេនិទាននោះ គប្បីជ្រាបយ៉ាងនោះ ចាប់ផ្តើមអំពីនេះតទៅ ។

ព្រះពុទ្ធជាម្ចាស់ គង់នៅលើរតនបល្ល័ង្ក បានបន្លឺឧទាននេះហើយ ព្រះសម្ពុទ្ធមានព្រះតម្រិះដូច្នេះថា តថាគតត្រាច់ចរទៅ សូម្បីអស់ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប ក៏ព្រោះហេតុតែរតនបល្ល័ង្កនេះ តថាគតកាត់សិរសា ដែលប្រដាប់ហើយត្រង់-ក ហើយឲ្យទានអស់កាលដ៏យូរប៉ុណ្ណោះ ក៏ព្រោះហេតុតែរតនបល្ល័ង្កនេះ តថាគតខ្វេះភ្នែកឲ្យទាន និងពុះទ្រូងរួងយកបេះដូងឲ្យជាទាន ឲ្យបុត្រជាទាន ដូចជាជាលី និងនាងក្រស្នា ឲ្យកិរិយាដូចជាព្រះនាងមទ្រីទេវី ដើម្បីឲ្យជាទាសៈរបស់អ្នកដទៃ ព្រោះហេតុតែរតនបល្ល័ង្កនេះ ។ រតនបល្ល័ង្កនេះ ជារតនបល្ល័ង្កដ៏ប្រសើររបស់តថាគត ការត្រិះរិះរបស់តថាគត នៅលើរតនបល្ល័ង្កនេះនៅមិនទាន់បរិបូណ៌ត្រឹមណា តថាគតនឹងមិនក្រោកចេញពីរតនបល្ល័ង្កនោះ ក្នុងកាលនោះឡើយ ដូចនេះ ទើបទ្រង់គង់ចូលសមាធិច្រើនសែនកោដិ នៅលើរតនបល្ល័ង្កនោះឯងអស់មួយសប្តាហ៍ ទើបលោកកំណត់ពោលទុកថា

គ្រានោះឯង ព្រះមានជោគ ទ្រង់គង់សោយវិមុត្តិសុខនៅលើរតនបល្ល័ង្កអស់មួយសប្តាហ៍ ( ក្រោយពីព្រះអង្គត្រាស់ដឹង ) គ្រានោះ

ទេវតាពួកខ្លះកើតបរិវិតក្កថា សូម្បីក្នុងថ្ងៃនេះ ព្រះសិទ្ធត្ថក៏នៅមានកិច្ច ដែលនឹងត្រូវធ្វើតែប៉ុណ្ណឹងទេដឹង ព្រោះព្រះអង្គមិនលះអាល័យចំពោះ រតនបល្ល័ង្ក ។ ព្រះសាស្ដា ទ្រង់ជ្រាបបរិវិតក្ករបស់ទេវតាទាំងឡាយ ដើម្បីនឹងទ្រង់រំងាប់បរិវិតក្ករបស់ទេវតាទាំងនោះ ទើបទ្រង់ហោះឡើង ទៅឰដ៏អាកាស ទ្រង់បានសម្ដែងយមកប្បាដិហារិយ៍ ។ ពិតណាស់ យមកប្បាដិហារិយ៍ដែលទ្រង់សម្ដែងនៅពោធិមណ្ឌលក្ដី បាដិហារិយ៍ ដែលទ្រង់សម្ដែងក្នុងសមាគមព្រះញាតិក្ដី បាដិហារិយ៍ដែលទ្រង់សម្ដែង ក្នុងសមាគមអ្នកដែនបត្តលីបុត្រក្ដី ទាំងអស់នេះដូចជាយមកប្បាដិហារិយ៍ ត្រង់គល់នៃគណ្ឌាមពព្រឹក្ស ។

លុះព្រះបរមសាស្ដា ទ្រង់រំងាប់បរិវិតក្ករបស់ទេវតាទាំងឡាយ ដោយបាដិហារិយ៍នេះហើយ ទើបព្រះពុទ្ធអង្គស្ដេចយាងទៅកាន់ទិស ឦសាន ទ្រង់ត្រិះរិះថា តថាគតបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណលើ ពោធិបល្ល័ង្កនេះ ទើបព្រះអង្គសម្លឹងមើលទៅពោធិមណ្ឌល ដោយមិន ប៉ប្រិចព្រះនេត្រ ដែលជាស្ថានទីសម្រេចឡើងអំពីផលនៃបារមី ដែល ទ្រង់បានបំពេញមកអស់ ៤ អសង្ខេយ្យ និងមួយសែនកប្បនោះ អស់ មួយសប្ដាហ៍ ស្ថានទីនោះទើបឈ្មោះថា **អានិមិស្សកចេតិយ** ។

លំដាប់ពីនោះ ទ្រង់និម្មិតទីចង្ក្រមក្នុងចន្លោះនៃរតនបល្ល័ង្ក និង ទីដែលព្រះអង្គទ្រង់ប្រថាប់ឈរសម្លឹងទៅមើលពោធិមណ្ឌល ហើយ ទ្រង់ចង្ក្រមលើរតនចង្ក្រមដ៏វែង តាំងពីទិសបូព៌ដរាបដល់ទិសបស្ចិម អស់មួយសប្តាហ៍ ស្ថានទីនេះទើបឈ្មោះថា **រតនចង្ក្រមចេតិយ** ។

ប៉ុន្តែក្នុងសប្តាហ៍ទី ៤ ទេវតាទាំងឡាយនិម្មិតផ្ទះកែវ ក្នុងទិស ពាយព្យអំពីពោធិមណ្ឌល ព្រះអង្គស្តេចយាងទៅគង់លើរតនបល្ល័ង្ក ក្នុងផ្ទះកែវនោះ ព្រះអង្គពិចារណាព្រះអភិធម្មបិដក និងសមន្តប្បដ្ឋាន អនន្តន័យក្នុងផ្ទះកែវនោះ អស់មួយសប្តាហ៍ ស្ថានទីនោះទើបឈ្មោះថា **រតនឃរចេតិយ** ។

ព្រះលោកនាយក ទ្រង់គង់សម្រាកនៅទីក្បែរៗ ( ទីជិតៗ ) ដើមពោធិព្រឹក្សនោះឯង អស់ ៤ សប្តាហ៍ ដោយអាការយ៉ាងនេះ ។ ក្នុងសប្តាហ៍ទី ៥ ទើបព្រះអង្គប្រទក្សិណពោធិព្រឹក្ស យាងចេញទៅ កាន់ដើម **អជបាលនិគ្រោធ** ទ្រង់គង់ពិចារណាធម៌ និងសោយវិមុត្តិសុខ នៅក្រោមដើមអជបាលនិគ្រោធនោះអស់មួយសប្តាហ៍ ។

សម័យនោះ ទេវបុត្តមារទៅជាប់តាមព្រះអង្គអស់កាល មាន ប្រមាណប៉ុណ្ណោះ សូម្បីនឹងសម្លឹងរកមើលចន្លោះផ្លូវ ក៏មិនបានឃើញ

ការភ្ញាំងភ្ញាត់អ្វីៗ របស់ព្រះពោធិសត្វ ទើបដល់នូវសភាពទោមនស្សថា ឥឡូវនេះ ព្រះសិទ្ធត្ថនេះ កន្លងផុតវិស័យរបស់អញហើយ ទើបទៅអង្គុយក្នុងផ្លូវធំ គិតដល់ហេតុ ១៦ ប្រការ ទើបគូសគំនូស ១៦ លើផែនដី គឺគិតថា អញមិនបានបំពេញទានបារមី ដូចព្រះសិទ្ធត្ថនេះហើយ ទើបគូសគំនូសទី ១ ។ មួយទៀតគិតថា អញមិនបានបំពេញសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វិរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី ដូចព្រះសិទ្ធត្ថនេះ ដោយហេតុនោះអាត្មាអញ ទើបមិនដូចជាព្រះសិទ្ធត្ថនេះ ហើយទើបគូសគំនូសទី ២ ដល់ទី ១០ ។ មួយទៀត គិតថា អាត្មាអញមិនបានបំពេញបារមី ១០ ដែលជាឧបនិស្ស័យនៃការបាក់ធ្លុះអាសយានុសយញ្ញាណ ឥន្ទ្រិយប-រោបរិយញ្ញាណ មហាករុណាសមាបត្តិញ្ញាណ យមកប្បាដិហារិយញ្ញាណ អានាសវរណាញ្ញាណ និងសព្វញ្ញុតញ្ញាណ មិនទូទៅដល់អ្នកដទៃ ដូចព្រះសិទ្ធត្ថនេះ ដោយហេតុនោះ ទើបអាត្មាអញមិនដូចព្រះសិទ្ធត្ថនេះហើយទើបគូសគំនូសទី ១១ ដល់ទី ១៦ ។ កាលទេវបុត្តមារនោះអង្គុយគូសគំនូស ១៦ គំនូសក្នុងផ្លូវធំ ព្រោះហេតុទាំងនោះ ដោយប្រការយ៉ាងនេះហើយ ។ សម័យនោះ ធីតាមារទាំង ៣ គឺនាងតណ្ហា

១ នាងអរតី ១ និងនាងរាគា ១ បានពោលថា បិតារបស់ពួកយើង កំពុងប្រាកដនៅក្នុងទីណាឥឡូវនេះ ទើបសម្លឹងរកមើល ក៏បានឃើញទេវបុត្តមារនោះ កំពុងតែកើតទុក្ខ គូសគំនូសលើផែនដី ទើបនាំគ្នាចូលទៅរក លុះចូលទៅដល់ហើយ បានសួរថា ព្រះបិតា ព្រោះហេតុអ្វីបានជាព្រះបិតាកើតទុក្ខអាក់អន់ចិត្ត ? ទេវបុត្តមារពោលថា កូនអើយ មហាសមណៈនេះកន្លងផុតអំណាចរបស់បិតាហើយ បិតារង់ចាំមើលរហូតអស់កាលមានប្រមាណប៉ុណ្ណោះ នៅមិនទាន់អាចឃើញចន្លោះឱកាសរបស់មហាសមណៈនេះបានសោះ ដោយហេតុនេះ ទើបបិតាកើតទុក្ខ អាក់អន់ចិត្តទៅ ។ គ្រានោះ ធីតាមារពោលថា ប្រសិនបើយ៉ាងនោះ ព្រះបិតាកុំអាក់អន់តូចចិត្តអ្វីឡើយ ពួកខ្ញុំម្ចាស់នឹងធ្វើឲ្យសមណៈនោះ ស្ថិតនៅក្នុងអំណាចនៃពួកខ្ញុំ រួចហើយក៏នាំគ្នាទៅ ។ ទេវបុត្តមារពោលថា កូនអើយ នរណាៗ មិនអាចធ្វើមហាសមណៈនេះឲ្យនៅក្នុងអំណាចបានឡើយ ព្រោះមហាសមណៈនោះ តាំងនៅក្នុងសទ្ធាមិនញាប់ញ័រ ។ ធីតាមារពោលថា ព្រះបិតា ពួកខ្ញុំម្ចាស់ជាកូនស្រី ពួកខ្ញុំម្ចាស់នឹងយកអន្ទាក់ គឺរាគៈជាដើម ទៅចងមហាសមណៈនោះឲ្យជាប់ ហើយនាំយកមកថ្វាយព្រះបិតា ក្នុងកាលឥឡូវនេះ ព្រះបិតា

កុំគិតអ្វីឡើយ ។ពោលហើយ ធីតាមារទាំងនោះ ក៏នាំគ្នាទៅរកព្រះមានជោគ លុះទៅដល់ហើយ ក្រាបទូលថា បពិត្រមហាសមណៈ ពួកនាងខ្ញុំម្ចាស់នឹងបម្រើព្រះអង្គ ព្រះសម្ពុទ្ធពុំបានបើកព្រះនេត្រមើល មានព្រះទ័យបង្អោនទៅក្នុងធម៌ និងគង់សោយវិមុត្តិសុខ ដែលកើតអំពីវិវេកប៉ុណ្ណោះ ។ ធីតារបស់មារនាំគ្នាគិតទៀតថា សេចក្តីប្រាថ្នារបស់ពួកបុរសមិនដូចគ្នា បុរសខ្លះស្រឡាញ់ស្រីវ័យក្រមុំ ខ្លះស្រឡាញ់ស្រីដែលស្ថិតនៅក្នុងបឋមវ័យ ខ្លះស្រឡាញ់ស្រីដែលតាំងនៅក្នុងមជ្ឈិមវ័យ ខ្លះស្រឡាញ់ស្រី ដែលតាំងនៅក្នុងបច្ឆិមវ័យ ប្រសិនបើដូច្នោះ គួរតែពួកយើងលួងលោមព្រះមហាសមណៈនេះដោយរូប ទើបម្នាក់ៗ និម្មិតអត្តភាពជារយៗ អត្តភាព មានរូបស្ត្រីក្រមុំជាដើម ជាស្ត្រីនៅមិនទាន់ប្រសូតបុត្រ ជាស្ត្រីប្រសូតបុត្រម្តង ជាស្ត្រីប្រសូតបុត្រពីរដង ជាស្ត្រីវ័យកណ្តាល និងជាស្ត្រីចាស់ ចូលទៅរកព្រះមានជោគ ដល់ ៦ ដង បានពោលថា បពិត្រព្រះមហាសមណៈ ពួកខ្ញុំម្ចាស់នឹងបម្រើព្រះអង្គ ។ ព្រះលោកនាថ ទ្រង់ពុំយកព្រះទ័យទុកដាក់ដល់សេចក្តីនោះ ដោយប្រការដែលទ្រង់បង្អោនចិត្តទៅក្នុងធម៌ ដែលជាគ្រឿងអស់ទៅនៃឧបធិដ៏ប្រសើរ ។ ចំណែកអាចារ្យពួកខ្លះបានពោលទុកថា លុះព្រះជិនស្រី

ឃើញធីតាមារទាំងនោះ ចូលមករកដោយការៈជាស្ត្រីចាស់ ទើបទ្រង់អធិដ្ឋានថា ស្រីនេះចូរជាស្ត្រីមានធ្មេញបាក់ មានសក់ស្កូវយ៉ាងនេះ ។ ពាក្យរបស់កេចិអាចារ្យនោះពុំគួរជឿ ព្រោះព្រះសាស្តា ទ្រង់នឹងមិនធ្វើអធិដ្ឋានដូច្នោះឡើយ ។ ព្រះលោកនាយក ទ្រង់ត្រាស់ថា ពួកនាងចូរចៀសចេញទៅ ពួកនាងម្តេចបានជាមកព្យាយាមធ្វើយ៉ាងនេះ ឈ្មោះថាកម្មដូចនេះ គួរធ្វើចំពោះមុខអ្នកដែលមិនទាន់ប្រាសចាករាគៈជាដើមតថាគតលះរាគៈ ទោសៈ មោហៈបានហើយ ទើបទ្រង់ប្រារព្ធដល់ការលះកិលេសរបស់ព្រះអង្គ ព្រះអង្គត្រាស់ព្រះគាថា ដែលមាននៅក្នុងគម្ពីរធម្មបទ ពុទ្ធវគ្គ ដូច្នេះថា

ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជម្នះ របស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេស ដូចស្នាមជើង ដោយកិលេស ដូចស្នាមជើងម្តេចកើត ។ តណ្ហាដែលមានបណ្តាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធអង្គណា សូម្បីនឹងនាំទៅក្នុងភពណាមួយ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចររកទីបំផុត

គ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេស ដូចស្នាមជើងម្តេចកើត ។

ធីតាមារទាំងនោះ បានពោលពាក្យជាដើមថា បិតារបស់យើងនិយាយការពិត ការនាំព្រះអរហន្តទៅមិនមែនជាការបានងាយឡើយ ចំពោះលោកដោយរាគៈ ហើយនាំគ្នាទៅកាន់សម្នាក់បិតាវិញ ។

ចំណែកព្រះមានជោគ ទ្រង់សម្រាកនៅក្រោមដើម **អជបាលនិគ្រោធ** នោះអស់មួយសប្តាហ៍ហើយ ព្រះពុទ្ធអង្គស្តេចយាងទៅកាន់ **ស្រះមុច្ចលិន្ទ** ហើយទ្រង់គង់នៅទៀបស្រះនោះ ភ្លៀងក៏បង្អុរចុះមក ៧ យប់ ៧ ថ្ងៃ ។ ស្តេចនាគឈ្មោះថា **មុច្ចលិន្ទ** ចេញចាកស្រះឡើងនិម្មិតកាយដ៏ធំ ពេនពទ្ធព្រះកាយនៃព្រះមានព្រះភាគដោយខ្នង ៧ ជុំ ហើយបើកពពារដ៏ធំ បាំងអំពីលើព្រះសិរសារបស់ព្រះសម្ពុទ្ធ ដើម្បីការពារភាពត្រជាក់ជាដើម ។ ព្រះមានព្រះភាគ ទ្រង់គង់សោយវិមុត្តិសុខនៅក្នុងទីនោះ ហាក់បីដូចគង់នៅក្នុងព្រះគន្ធកុដិ អស់មួយសប្តាហ៍ទៀត ។

ក្នុងសប្តាហ៍ទី ៧ ព្រះមានបុណ្យ ស្តេចយាងទៅគង់នៅក្រោម **ដើមកែស** ដោយទ្រង់គង់សោយវិមុត្តិសុខ នៅក្រោមដើមកែសនោះអស់មួយសប្តាហ៍ ។ រាប់ចាប់តាំងពីថ្ងៃដែលព្រះលោកនាថគង់ក្រោម

មណ្ឌលពោធិព្រឹក្ស ដរាបដល់ព្រះអង្គគង់នៅក្រោមដើមកែស សរុបទាំងអស់ត្រូវជា ៤៩ ថ្ងៃគត់ ។

ក្នុងវេលានេះ មិនមានការលាងជម្រះព្រះកាយ និងលុបព្រះភក្ត្រឡើយ មិនមានកិច្ចដោយព្រះក្រយាហារ ទ្រង់សម្រាកអាស្រ័យនៅក្នុងឈានសុខ មគ្គសុខ និងផលសុខ ។ ក្នុងថ្ងៃទី ៤៩ ដែលជាថ្ងៃចុងក្រោយនៃសប្តាហ៍ទី ៧ នោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្រោមដើមកែសនោះ កើតសេចក្តីត្រិះរិះឡើងថា នឹងលុបលាងព្រះភក្ត្រ សក្កទេវរាជបានយកទឹក ឈើស្ទន់ និងផ្លែសម៉មកថ្វាយព្រះសម្ពុទ្ធ ។ កាលព្រះសាស្តាទ្រង់សោយនូវផ្លែសម៉នោះ ដោយហេតុនោះ ទើបព្រះទសពលមានការបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ។ ព្រះលោកនាថទ្រង់ទំពាឈើស្ទន់ ជម្រះព្រះទន្ត លុបលាងព្រះភក្ត្រ ដោយទឹកក្នុងអនោតត្តស្រះ ហើយទ្រង់គង់នៅក្រោមដើមកែសនោះឯង ។

សម័យនោះ ពាណិជពីរនាក់ ជាបងប្អូននឹងគ្នា បងឈ្មោះ **តបុស្សៈ** ប្អូនឈ្មោះ **ភល្លិកៈ** បាននាំពួកឈ្មួញរទេះ ៥០០ ផ្ទុកទៅដោយទំនិញ ទៅលក់ឯ **ឧត្តរាបថជនបទ** ក្នុង **មជ្ឈិមប្រទេស** ត្រូវទេវតាដែលជាញាតិសាលោហិតរបស់លោក ពីអតីតធ្វើរទេះមិនឲ្យទៅមុខ

ដើម្បីឲ្យឱកាសថ្វាយទានចំពោះព្រះទសពល កាលពាណិជទាំងពីរនាក់បងប្អូនបានជ្រាបរឿងទាំងអស់នោះហើយ ទើបកាន់យកសដូវជុំ សដូវផង់ចូលទៅថ្វាយដល់ព្រះមានជោគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាអនុគ្រោះទទួលយកសដូវជុំ និងសដូវផង់នេះ ដើម្បីជាប្រយោជន៍ដល់ខ្ញុំព្រះករុណាផង ហើយក៏ឈរនៅក្នុងទីសមគួរ ។ ព្រះមុនីដោយអាស្រ័យបាត្រ ដែលបាត់ទៅក្នុងថ្ងៃទទួលមធុបាយាសនោះ ព្រះលោកនាថ ទ្រង់ត្រិះរិះថា ព្រះតថាគតទាំងឡាយ រមែងមិនទទួលដោយដៃ តថាគតនឹងទទួលដូចម្តេចទៅហ្ន៎ !

លំដាប់នោះ ស្តេចចតុលោកបាលទាំង ៤ ដឹងបរិវិតក្ករបស់ព្រះមានជោគ ទើបនាំយកបាត្រ ដែលសម្រេចដោយកែវឥន្ទនិលមកថ្វាយ ព្រះលោកនាថទ្រង់មិនបដិសេធចំពោះការប្រគេនបាត្រនោះទេ ស្តេចចតុលោកបាលទាំង ៤ ក៏បានបង្អោនបាត្រទាំង ៤ ដែលសម្រេចដោយថ្ម មានពណ៌ដូចជាសណ្តែកបាយទៅថ្វាយ ។ ដើម្បីនឹងទទួលឬអនុគ្រោះដល់ស្តេចចតុលោកបាល ទាំង ៤ ព្រះអង្គ ទើបទ្រង់ទទួលបាត្រទាំង ៤ ហើយដាក់តម្រួតលើគ្នា ទ្រង់អធិដ្ឋានថា ចូរឲ្យជាបាត្រតែមួយ ។ បាត្រទាំង ៤ ទើបមិនមានស្នាមប្រាកដនៅត្រង់កណ្តាប់

មាត់បាត្រ រួមជាបាត្រតែមួយ ជាបាត្រខ្នាតកណ្ដាល ។ ព្រះជិនស្រី ទ្រង់ទទួលអាហារដោយបាត្រនោះឯង ហើយសោយ កាលព្រះអង្គទ្រង់សោយរួចជាស្រេច ក៏បានធ្វើការអនុមោទនាគាថាដល់ពាណិជទាំងពីរនាក់បងប្អូន ។ ពាណិជទាំងពីរនាក់បងប្អូន បានដល់ព្រះពុទ្ធនិងព្រះធម៌ជាសរណៈ **បានជាទ្វេវាចិកឧបាសកតទៅ** ។ លំដាប់នោះពាណិជទាំងពីរនាក់បងប្អូនបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រោសប្រទាននូវវត្ថុ ជាទីសក្ការគោរពបូជាដល់ខ្ញុំព្រះអង្គទាំងពីរនាក់ផង ទើបព្រះសម្ពុទ្ធទ្រង់យកព្រះហស្ដ ស្ទាបព្រះសិរសារបស់ព្រះអង្គ ហើយប្រទាន ព្រះកេសធាតុ ៨ សរសៃ ឲ្យទៅដល់ពាណិជទាំងពីរនាក់នោះ ដើម្បីយកទៅធ្វើសក្ការគោរពបូជា នៅឯស្រុករបស់ខ្លួន ។ពាណិជទាំងពីរនោះ ពេលដែលខ្លួនត្រឡប់ទៅដល់ស្រុកកំណើតវិញ បានកសាងព្រះចេតិយបញ្ចុះព្រះកេសធាតុ ដើម្បីទុកជាទីសក្ការគោរពបូជា ដល់មហាជនទាំងឡាយ ។

ចាប់តាំងអំពីពេលនោះមក ព្រះសម្ពុទ្ធ ស្ដេចយាងទៅកាន់ដើមអជបាលនិគ្រោធទៀត ទ្រង់គង់នៅទៀបដើមនិគ្រោធ លុះទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធនោះហើយ ទ្រង់ពិចារណាសេចក្ដីនៃធម៌

ដែលព្រះអង្គទ្រង់បានសម្រេចហើយ ជាធម៌ជ្រាលជ្រៅគម្ភីរភាព ទ្រង់ព្រះតម្រិះថា ធម៌នេះ ព្រះសាស្តាទាំងពួងប្រព្រឹត្តសន្សំទុកមកហើយ តថាគតបានសម្រេចហើយ ទើបកើតការត្រិះរិះនូវអាការ គឺការមិនប្រាថ្នាដើម្បីនឹងសម្តែងធម៌ដល់មហាជន ។ លំដាប់នោះ សហម្បតីព្រហ្មបានបញ្ចេញវាចាថា អ្នកដ៏ចម្រើនទាំងឡាយ សត្វលោកនឹងវិនាសសាបសូន្យទៅហើយ អ្នកដ៏ចម្រើនទាំងឡាយ សត្វលោកនឹងវិនាសសាបសូន្យទៅហើយ ហើយទ្រង់នាំសក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត ស្តេចវសវត្តី និងស្តេចមហាព្រហ្មទាំងម៉ឺនចក្រវាឡចូលទៅក្រាបទូលអារាធនា ឲ្យព្រះអង្គសម្តែងធម៌ ដោយន័យមានជាអាទិ៍ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះលោកនាថ ទ្រង់សម្តែងព្រះធម៌ ព្រះបរមសាស្តាទ្រង់ឲ្យប្តេជ្ញាដល់សហម្បតីព្រហ្មនោះហើយ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងធម៌ដល់នរណាមុនគេ ទ្រង់ញុំាងការត្រិះរិះឲ្យកើតឡើងថា **អាឡារតាបស** ជាបណ្ឌិត អាឡារតាបសនោះនឹងដឹងនូវទៅនូវធម៌នេះដោយឆាប់រហ័ស ហើយទ្រង់ប្រមើលមើលទៀតក៏បានជ្រាបថា អាឡារតាបសនោះធ្វើកាលកិរិយាទៅអស់ ៧ ថ្ងៃហើយ ។ ទើបទ្រង់រំពឹងដល់ **ឧទកតាបស** ទ្រង់បានជ្រាបថា សូម្បីឧទកតាបសនោះ

ក៏បានធ្វើកាលកិរិយាទៅហើយដែរ ក្នុងវេលាព្រលប់ល្ងាចមុញ្ញនេះ ទើបទ្រង់មនសិការប្រារព្ធដល់ពួកបញ្ចវគ្គិយថា **ពួកបញ្ចវគ្គិយ** ក៏ជាអ្នកមានឧបការៈដល់តថាគតដែរ ទើបព្រះសម្ពុទ្ធព្រះតម្រិះថា ឥឡូវនេះពួកបញ្ចវគ្គិយនៅទីណាហ្ន៎ ទ្រង់បានជ្រាបថា នៅឯព្រៃឥសិបតនមិគទាយវ័នទៀបក្រុងពារាណសី ទើបទ្រង់ត្រិះរិះថា តថាគតនឹងទៅកាន់ព្រៃឥសិបតនមិគទាយវ័ននោះ ហើយសម្ដែងធម្មចក្រ ទើបស្ដេចត្រាច់ទៅបិណ្ឌបាតជុំវិញពោធិមណ្ឌល ២-៣ ថ្ងៃ ទ្រង់ត្រិះរិះថា តថាគតនឹងទៅកាន់ក្រុងពារាណសី ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ។ នាថ្ងៃ ១៤ កើតក្នុងវេលាបច្ចូសសម័យជិតភ្លឺ កាលរាត្រីកន្លងទៅហើយ ព្រឹកព្រលឹមឡើងក៏ទ្រង់ប្រដាប់ដោយបាត្រ និងចីវរ ស្ដេចយាងទៅកាន់ចារិកអស់ចម្ងាយផ្លូវ ១៨ យោជន៍ ទ្រង់បានជួបឧបកាជីវកក្នុងរវាងផ្លូវ ទើបព្រះអង្គត្រាស់ប្រាប់ដល់ភាពដែលព្រះអង្គជាព្រះពុទ្ធដល់ **ឧបកាជីវក** នោះ ហើយស្ដេចយាងបន្តទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ព្រះសាស្ដាស្ដេចបានយាងទៅដល់ព្រៃឥសិបតនមិគទាយវ័ន ជាទីនៅនៃបញ្ចវគ្គិយក្នុងវេលាល្ងាចនៃថ្ងៃនោះឯង ។

ពួកបញ្ចវគ្គិយកាលឃើញព្រះភគវា ស្ដេចយាងមកអំពីចម្ងាយ

ទើបបានធ្វើនូវកតិកាគ្នាទុកថា នែអាវុសោទាំងឡាយ ព្រះសមណគោតម វិលមកដើម្បីភាពជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ មានឥន្ទ្រិយផូរផង់ សម្បុរដូចជាមាស កំពុងតែដើរមក យើងទាំងឡាយ កុំធ្វើសាមីចិកម្ម មានអភិវាទនកម្មជាដើម ដល់ព្រះសមណគោតមនោះ តែទ្រង់ប្រសូតក្នុងត្រកូលធំ យើងគួររៀបចំក្រាលអាសនៈទុក ដោយហេតុនេះ ពួកយើងនឹងក្រាលត្រឹមតែអាសនៈទុកដើម្បីទ្រង់ ព្រះសាស្តាទ្រង់រំពឹងថា ពួកបញ្ចវគ្គិយនេះគិតយ៉ាងណាហ្ន៎ ក៏ទ្រង់បានជ្រាបការគិតដោយព្រះញាណ ដែលអាចដឹងវារៈចិត្ត របស់សត្វលោកទាំងឡាយ ។ លំដាប់នោះ ទើបទ្រង់បង្រួញឲ្យខ្វី យកមេត្តាចិត្ត ដែលអាចផ្សាយទៅដោយមិនចំពោះក្នុងពួកទេវតា និងមនុស្សទាំងពួង ហើយទ្រង់ផ្សាយមេត្តាចិត្តទៅចំពោះពួកបញ្ចវគ្គិយទាំងនោះ ។ កាលពួកបញ្ចវគ្គិយទាំងនោះ ដែលព្រះមានជោគពាល់ត្រូវដោយមេត្តាចិត្តហើយ កាលបើព្រះមហាមុនីចូលទៅជិត មិនអាចធ្វើឲ្យពពួកបញ្ចវគ្គិយនោះ តាំងនៅក្នុងកតិការបស់ខ្លួនបានឡើយ ក៏ត្រឡប់ជាត្រេកអរ នាំគ្នាធ្វើនូវកិច្ចទាំងពួងមានអភិវាទនកម្មជាដើម ប៉ុន្តែនៅមិនទាន់ដឹងថា ជាព្រះសម្មាសម្ពុទ្ធនៅឡើយ ទើបប្រើសម្តីហៅដោយឈ្មោះ ដោយពាក្យថា **អាវុសោ**

តែម្យ៉ាង ។ ពេលនោះ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងបញ្ចវគ្គិយទាំងនោះ ឲ្យដឹងថា ព្រះអង្គជាព្រះពុទ្ធហើយ ដោយព្រះតម្រាស់ថា នែអ្នកទាំងឡាយ អ្នកទាំងឡាយ កុំហៅតថាគតដោយឈ្មោះ ដោយពាក្យថា អាវុសោឡើយ អ្នកទាំងឡាយ តថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធ ដូចនេះហើយ ក៏បានគន់លើបវរពុទ្ធាសនៈ ដែលតាក់តែងទុកនោះ ។ លុះរាត្រីកន្លងទៅ ថ្ងៃ ១៥ កើត គឺជាថ្ងៃអាសាឡ្ហបុណ្ណមី មានពួកទេវតា ១៨ កោដិ ចោមរោមព្រះអង្គ ព្រះសម្ពុទ្ធបានត្រាស់ហៅបញ្ចវគ្គិយមក ទ្រង់បានសម្តែងធម្មចក្កប្បវត្តនសូត្រដល់ពួកបញ្ចវគ្គិយទាំងនោះ បណ្តាពួកបញ្ចវគ្គិយទាំងនោះ **អញ្ញាកោណ្ឌញ្ញៈ** បានបញ្ជូនញាណទៅតាមក្រសែព្រះធម៌ទេសនា ក្នុងពេលចប់ព្រះធម៌នោះ បានតាំងនៅក្នុងសោតាបត្តិផល ព្រមទាំងទេវតា ១៨ កោដិ ។ ព្រះមុនីទ្រង់គង់ចាំវស្សានៅក្នុងព្រៃឥសិបតនមិគទាយវ័ន ។ លុះដល់ថ្ងៃ ១ រោចឡើង ទ្រង់សម្តែងព្រះធម៌ជាពាក្យប្រៀនប្រដៅដល់ព្រះវប្បៈ នៅសល់ ៤ រូប ត្រាច់ទៅបិណ្ឌបាត ។ ព្រះវប្បៈបានសម្រេចសោតាបត្តិផល ក្នុងវេលាព្រឹកនោះឯង ។ ដោយឧបាយនេះ ទ្រង់ញ៉ាំងព្រះភទ្ទិយៈឲ្យតាំងនៅក្នុងសោតាបត្តិផលក្នុងថ្ងៃ ២ រោច ។ ព្រះមហានាមក្នុងថ្ងៃ ៣ រោច និង

ព្រះអស្សជិនៅក្នុងថ្ងៃ ៤ រោច រួមសេចក្តីមកថា ទ្រង់ញ៉ាំងបញ្ចវគ្គិយទាំងនោះ ឲ្យតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃ ៥ រោច ព្រះថេរៈទាំង ៥ រូបមកប្រជុំគ្នាហើយ ព្រះសម្ពុទ្ធទ្រង់សម្តែង **អនត្តលក្ខណសូត្រ** ក្នុងពេលដែលចប់ព្រះធម៌ទេសនានោះ ព្រះថេរៈទាំង ៥ រូប ក៏បានតាំងនៅក្នុងអរហត្តផល ព្រះអរហន្តមាននៅក្នុងលោក ៦ ព្រះអង្គ រួមទាំងព្រះសម្មាសម្ពុទ្ធផង ។

ក្នុងសម័យនោះ ព្រះវិជិតមារ ទ្រង់ឃើញឧបនិស្ស័យរបស់យសកុលបុត្រដែលគេនឿយណាយ លះបង់ផ្ទះចេញទៅពាក់កណ្តាលយប់ ( អឌ្ឍរាត្រ ) ទើបទ្រង់ត្រាស់ហៅថា នែអ្នកដ៏ចម្រើន មកនេះ ទីនេះមិនវរវឹកទេ ហើយព្រះលោកនាថ ទ្រង់សម្តែងអនុបុព្វីកថាចប់ យសកុលបុត្របានសម្រេចសោតាបត្តិផល ។ ថ្ងៃស្អែកឡើង បានតាំងនៅក្នុងអរហត្តផល ទ្រង់ញ៉ាំងសម្លាញ់របស់យស ៥៤ នាក់ទៀត ឲ្យបព្វជ្ជាដោយឯហិភិក្ខុ ហើយបានសម្រេចជាព្រះអរហន្ត ។ ព្រះអរហន្ត ៦១ អង្គ កើតមានឡើងនៅក្នុងលោក ដោយប្រការយ៉ាងនេះឯង ។ ព្រះសាស្តាទ្រង់ចេញវស្សាបវារណាហើយ ទ្រង់បញ្ជូនភិក្ខុ ៦០ អង្គ ដើម្បីចេញទៅផ្សព្វផ្សាយព្រះសាសនា ដោយព្រះតម្រាស់ថា ម្នាល

ភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចារិកទៅកាន់ជនបទ និងរាជធានីផ្សេងៗ ដើម្បីប្រកាសព្រះពុទ្ធសាសនា ឬដើម្បីជាប្រយោជន៍ដល់មហាជនទាំងឡាយផង ។ ចំណែកព្រះអង្គបានស្តេចយាងទៅកាន់តំបន់ឧរុវេលា ក្នុងរវាងផ្លូវ ទ្រង់បានណែនាំភទ្ទវគ្គិយកុមារ ៣០ ក្នុងព្រៃកប្បាសិកវ័ន ។ បណ្តាភទ្ទវគ្គិយកុមារ ៣០ នោះ បានសម្រេចគុណធម៌ថ្នាក់ទាបបំផុតត្រឹមព្រះសោតាបន្ន ថ្នាក់លើបំផុតបានត្រឹមព្រះអនាគាមី ។ ព្រះសម្ពុទ្ធឲ្យភទ្ទវគ្គិយកុមារទាំង ៣០ នោះបព្វជ្ជាដោយវិធីឯហិភិក្ខុឧបសម្បទាដូចគ្នា ហើយទ្រង់បញ្ជូនឲ្យទៅកាន់ទិសផ្សេងៗ ដូចគ្នាដែរ រួចព្រះលោកនាថស្តេចបានយាងទៅកាន់តំបន់ឧរុវេលា ទ្រង់សម្តែងបាដិហារិយ៍ ៣៥០០ បាដិហារិយ៍ ទ្រង់ណែនាំជដិល ៣ នាក់បងប្អូន មានឧរុវេលកស្សបៈជាដើម ព្រមទាំងបរិវារ ១០០០ នាក់ទៀត ឲ្យបព្វជ្ជាឧបសម្បទាដោយវិធីឯហិភិក្ខុដូចគ្នាទៀត ហើយព្រះមានជោគ ទ្រង់គង់នៅក្នុងគយាសីសប្រទេស ឲ្យជដិល ៣ នាក់បងប្អូន ព្រមទាំងបរិវារ ១០០០ ឲ្យតាំងក្នុងអរហត្ត ដោយព្រះអង្គទ្រង់សម្តែងអាទិត្តបរិយាយសូត្រ រួចព្រះបរមគ្រូមានព្រះអរហន្ត ១០០០ រូបហែហម ទ្រង់ព្រះតម្រិះថា នឹងដោះបដិញ្ញាឲ្យដល់ព្រះបាទពិម្ពិសារ ទើបព្រះអង្គស្តេចយាងទៅកាន់

លដ្ឋិវនុទ្យាន នៅជាយក្រុងរាជគ្រឹះ ។ ព្រះរាជាទ្រង់បានជ្រាបអំពីនាយរក្សាឧទ្យានថា ព្រះសាស្តាស្តេចយាងមកហើយ ទើបទ្រង់ស្តេចយាងទៅដែលមានការហែហមដោយព្រាហ្មណ៍ និងគហបតី ១២ ម៉ឺននាក់ចូលទៅគាល់ព្រះសម្ពុទ្ធ កាលផ្ទៃព្រះបាទដែលវិចិត្រដោយចក្រកំពុងបញ្ចេញរស្មីដូចពិតានមាស ទើបព្រះរាជាក្រាបព្រះសិរសាចុះ ទៀបព្រះបាទរបស់ព្រះមានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ព្រមគ្នានឹងបរិស័ទទាំងអស់នោះ ។ លំដាប់នោះ ព្រាហ្មណ៍ និងគហបតីទាំងនោះមានគំនិតដូច្នេះថា ព្រះមហាសមណៈប្រព្រឹត្តព្រហ្មចរិយធម៌នៅក្នុងសម្នាក់របស់ឧរុវេលកស្សបៈ ឬឧរុវេលកស្សបៈប្រព្រឹត្តព្រហ្មចរិយៈ នៅក្នុងសម្នាក់របស់ព្រះមហាសមណៈ ។ គ្រានោះព្រះមានជោគទ្រង់ជ្រាបវារៈចិត្ត ដោយព្រះញាណរបស់ព្រះអង្គ នូវការត្រិះរិះរបស់ព្រាហ្មណ៍ និងគហបតីទាំងនោះ ទើបទ្រង់បានត្រាស់នឹងឧរុវេលកស្សបៈដោយព្រះគាថាថា

អ្នកនៅក្នុងឧរុវេលា ( មកយូរហើយ ) ស្គមស្ងួក ( ព្រោះតែការបួស ) ជាអ្នកពោលប្រៀនប្រដៅ ( ប្រជាជន ) ដោយទោសយ៉ាងណា ទើបលះភ្លើង (កន្លែងបូជា) ចោល ម្នាលកស្សបៈ តថាគត

សួរសេចក្តីនេះនឹងអ្នក ដូចម្តេចអ្នកទើបលះការបូជាភ្លើងចោល ។

ចំណែកព្រះថេរៈ ( ឧរុវេលកស្សបៈ ) ដឹងនូវបំណងរបស់ព្រះមានព្រះភាគ ទើបពោលនូវព្រះគាថានេះតបទៅវិញថា

**យញ្ញទាំងឡាយ រមែងពោលសរសើរនូវ រូប សំឡេង ក្លិន រស និងស្ត្រីដែលខ្លួនប្រាថ្នា ខ្ញុំព្រះអង្គដឹងថា នេះជាមន្ទិលក្នុងឧបធិទាំងឡាយ ព្រោះដូច្នោះ ខ្ញុំព្រះអង្គ ទើបមិនត្រេកអរក្នុងការបួងសួង និងការបូជា ដូចនេះ ។**

ដើម្បីនឹងប្រកាសភាពដែលខ្លួនជាសាវ័ក ទើបបង្អោនសិរសាទៀបព្រះបាទរបស់ព្រះតថាគត ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសម្ពុទ្ធ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័កដូច្នោះហើយ ក៏ហោះឡើងទៅឰដ៏អាកាស ៧ ដង គឺកម្ពស់មួយដូវត្នោត ពីរដូវត្នោត ដរាបដល់ ៧ ដូវត្នោត ហើយចុះមកថ្វាយបង្គំព្រះតថាគត រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ មហាជនបានឃើញបាដិហារិយ៍ដូច្នោះហើយ នាំគ្នាពោលសរសើរព្រះគុណរបស់ព្រះលោកនាថថា គួរឲ្យអស្ចារ្យណាស់ ព្រះពុទ្ធទ្រង់មានអានុភាពច្រើន សូម្បីព្រះឧរុវេលកស្សបៈជាអ្នកមានទិដ្ឋិរឹងត្អឹង ដោយសម្គាល់ខ្លួនថា ជាព្រះអរហន្ត ក៏ត្រូវ

ព្រះតថាគតទម្លាយសំណាញ់ គឺទិដ្ឋិទាំងអស់នោះហើយដែរ ។ ព្រះមុនីត្រាស់ថា តថាគតទូន្មានឧរុវេលកស្សបៈ ពុំមែនត្រឹមតែពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតឧរុវេលកស្សបៈនេះ ក៏ត្រូវតថាគតទូន្មានមកហើយដូចគ្នាដែរ ហើយទ្រង់ត្រាស់មហានារទជាតក ដើម្បីសម្តែងឡើងឲ្យឃើញ ឬឲ្យជ្រាបនូវរឿងរ៉ាវទាំងអស់នោះ បន្ទាប់មក ទ្រង់ប្រកាសសច្ចធម៌ ព្រះបាទពិម្ពិសារ ក៏បានតាំងនៅក្នុងសោតាបត្តិផលព្រមទាំងបរិស័ទ ១១ ម៉ឺននាក់ ។ រីឯបរិស័ទមួយម៉ឺននាក់ទៀត បានប្រកាសខ្លួនជាឧបាសក អ្នកដល់នូវព្រះត្រៃសរណគមន៍ជាទីពឹង ជាទីរឭកចាប់ពីថ្ងៃនេះតទៅ ។ ព្រះរាជាកាលបានសម្រេចសោតាបត្តិផលហើយ ព្រះអង្គក៏ទ្រង់អារាធនាព្រះលោកនាយក ដើម្បីទទួលភត្តក្នុងថ្ងៃស្អែក ព្រះជិនស្រីទ្រង់ទទួលដោយតុណ្ហីភាព ព្រះរាជាកាលបានជ្រាបថា ព្រះលោកនាថទទួលនិមន្តហើយ ស្តេចក្រោកចាកអាសនៈធ្វើប្រទក្សិណព្រះទសពល រួចហើយ ស្តេចក៏យាងចៀសចេញទៅ ។ លុះដល់ថ្ងៃស្អែកឡើង មហាជននៅក្នុងក្រុងរាជគ្រឹះ ដែលមានចំនួន ១៨ កោដិ ទាំងមហាជន ដែលបានឃើញព្រះមានជោគ និងទាំងមហាជន ដែលមិនទាន់បានឃើញព្រះសម្មាសម្ពុទ្ធ ទាំងប្រុស ទាំងស្រី

សុទ្ធតែជាអ្នកមានសេចក្ដីប្រាថ្នាចង់ឃើញព្រះទសពល ទើបបានដើរប្រជ្រៀតគ្នា ចូលទៅកាន់លដ្ឋិវ័នអំពីព្រឹកព្រលឹម ចម្ងាយផ្លូវ ៣ គាវុត ឥតមានកន្លែងចន្លោះទាល់តែសោះ លដ្ឋិវ័នុទ្យានពាសពេញដេរដាសសព្វទិស ទៅដោយមហាជន ។ មហាជនបាននាំគ្នាសម្លឹងមើលអត្តភាពដែលដល់នូវភាពស្អាត ដោយព្រះរូបឆោមរបស់ព្រះភគវា មិនអាចធ្វើឲ្យឆ្អែតក្នុងការបានឃើញព្រះអង្គឡើយ ។ ក្នុងឋានៈទាំងឡាយ សូម្បីឃើញដូចនេះ គប្បីពណ៌នាភាពស្រស់ស្អាតនៃព្រះរូបកាយ សូម្បីទាំងអស់ដែលជាប្រភេទលក្ខណៈ និងអនុព្យញ្ជនៈរបស់ព្រះតថាគត ឈ្មោះថា *វណ្ណរូប* ( ការពណ៌នាអំពីរូបកាយ ) ។ មហាជនដែលសម្លឹងមើលព្រះសរីរៈរបស់ព្រះវិជិតមារ ដែលដល់នូវភាពស្អាតដោយអាការយ៉ាងនេះ សូម្បីកិក្ខុមួយរូបមិនមានឱកាសនឹងចេញពីឧទ្យាននោះ ពីព្រោះផ្លូវចង្អៀត ។ បានឮថា ថ្ងៃនោះ ព្រះមុនីអាចដាច់ព្រះក្រយាហារបាន ការដាច់ព្រះក្រយាហារនោះ ពុំបានមានឡើយ ព្រោះហេតុនោះ អាសនៈដែលសក្កទេវរាជគង់ ទើបសម្ដែងអាការក្ដៅឡើង សក្កទេវរាជក៏បានរំពឹងឡើងថា តើមានហេតុអ្វី បានជាអាសនៈរបស់យើងក្ដៅ ទ្រង់បានជ្រាបហេតុនោះហើយ ទើបក្លែងភេទជាមាណពតូច បានមកពោល

សរសើរគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ចូលមកក្នុងទីចំពោះព្រះភក្រ្ត នៃព្រះលោកនាថៗបានឱកាសដោយទេវានុភាព ស្តេចនាំទៅខាងមុខ ពោលគុណរបស់ព្រះសាស្តា ដោយព្រះគាថាទាំងនេះថា

ព្រះមានព្រះភាគ មានវណ្ណៈស្អាតដូចជាមាស ដែលទ្រង់ហ្វឹកហាត់ដោយល្អហើយ ស្តេចបានយាងចូលទៅកាន់ក្រុងរាជគ្រឹះ ព្រមដោយបុរាណជដិល អ្នកហ្វឹកហាត់ខ្លួនបានល្អដែរហើយ ថែមទាំងជាអ្នករួចផុតទៀតផង ។ព្រះមានព្រះភាគ មានវណ្ណៈស្អាតដូចជាមាស ទ្រង់រួចផុតហើយ ស្តេចយាងចូលទៅកាន់ក្រុងរាជគ្រឹះ ព្រមដោយបុរាណជដិល អ្នកហ្វឹកហាត់ខ្លួនបានល្អដែរហើយ ថែមទាំងជាអ្នករួចផុតទៀតផង ។ ព្រះមានព្រះភាគ មានវណ្ណៈស្អាត ដូចជាមាស ទ្រង់ឆ្លងផុតហើយ ព្រះមានព្រះភាគអង្គនោះ មានធម៌ជាគ្រឿងនៅ ១០ មានកម្លាំង ១០ ទ្រង់ដឹងច្បាស់នូវធម៌ ១០ និងប្រកបដោយព្រះគុណ ១០ មានបរិវារ ១០០០ ស្តេចយាងចូលទៅកាន់ក្រុងរាជគ្រឹះ ។

លំដាប់នោះ មហាជនបានឃើញភាពសង្ហា នៃរូបកាយរបស់មាណពតូចនោះហើយ បាននាំគ្នាគិតថា មាណពតូចនេះ មានរូបសង្ហាណាស់ មាណពតូចនេះ យើងមិនធ្លាប់ដែលបានឃើញ ទើបពោលថា

មាណពតូចនេះមកពីទីណា ឬមាណពតូចនេះ ជាកូនចៅនរណា ។ មាណពតូចបានឮដូច្នោះហើយ ទើបពោលគាថាថា

*ព្រះសុគតជាម្ចាស់អង្គណា ទ្រង់ហ្វឹកហាត់ព្រះអង្គបានក្នុងទីទាំងពួង ទ្រង់ប្រសើរបំផុត មិនមានបុគ្គលប្រៀប ជាព្រះអរហន្តក្នុងលោក ខ្ញុំជាអ្នកបម្រើរបស់ព្រះសុគតជាម្ចាស់អង្គនោះ ។*

គ្រានោះ ព្រះសាស្តា ទ្រង់មានឱកាសស្តេចយាងទៅកាន់ព្រះរាជនិវេសន៍ ដែលសក្កទេវរាជទ្រង់ធ្វើហើយ ព្រះសមុទ្ទទ្រង់ហែហមដោយភិក្ខុ ១០០០ រូប ។ ព្រះរាជាកាលព្រះសយម្ភូស្តេចយាងទៅដល់បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចប្រព្រឹត្តទៅ ដោយវៀរចាកព្រះរតនត្រ័យទាំង ៣ បានទេ ខ្ញុំព្រះអង្គនឹងមកគាល់ព្រះភគវាក្នុងវេលាខ្លះ មិនមែនវេលាខ្លះ ក៏ឈ្មោះថា លដ្ឋិវនុទ្យានឆ្ងាយពេក ប៉ុន្តែឧទ្យានឈ្មោះវេឡុវ័នរបស់ខ្ញុំព្រះអង្គនេះ មិនឆ្ងាយពេក មិនជិតពេក ជាទីល្មមទៅមកបានដោយងាយ សមគួរដល់ព្រះពុទ្ធ ខ្ញុំព្រះអង្គ សូមថ្វាយនូវឧទ្យានវេឡុវ័ននេះ ហើយទ្រង់យកឃ្លោកទឹក ដែលមានសម្បុរដូចជាកែវមណីអប់ដោយផ្កា និងគ្រឿងក្រអូប កាលទ្រង់នឹងបរិច្ចាគ

ឧទ្យានវេឡុវ័ន ទើបទ្រង់ប្រួចទឹកដាក់លើព្រះហស្តរបស់ព្រះសាស្តា ក្នុងខណៈដែលទ្រង់ទទួលអារាម ។ គ្រានោះ មហាប្រឹថពីបានកម្រើកញាប់ញ័រ ដែលជាហេតុឲ្យដឹងថា ឫសកែវរបស់ព្រះពុទ្ធសាសនាបានប្រតិស្ឋានហើយ ។ ពិតណាស់ ក្នុងជម្ពូទ្វីប លើកលែងវេឡុវ័នចេញ ឈ្មោះថា សេនាសនៈដទៃ ដែលព្រះសម្ពុទ្ធទ្រង់ទទួលហើយ ដែលផែនដីកម្រើកញាប់ញ័រដូចនោះ រមែងមិនមាន ។ លុះព្រះសាស្តាទ្រង់ទទួលវេឡុវនារាមហើយ ព្រះលោកនាថបានធ្វើការអនុមោទនាគាថាដល់ព្រះរាជា ហើយព្រះសាស្តាក្រោកចាកអាសនៈ ហែហមដោយភិក្ខុសង្ឃ ស្តេចយាងចូលទៅកាន់ឧទ្យានវេឡុវ័ន ។

សម័យនោះឯង មានបរិព្វាជកពីរនាក់ គឺឧបតិស្សៈ និងកោលិតៈ នៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ស្វែងរកអមតធម៌ ។ បណ្តាបរិព្វាជកទាំងពីរនាក់នោះ ឧបតិស្សៈបានជួបព្រះអស្សជិត្ថេរចូលទៅបិណ្ឌបាតក្នុងស្រុក ឃើញដូច្នោះហើយ ក៏មានចិត្តជ្រះថ្លាឡើង រហូតដល់បានសួរដឹងរឿងរ៉ាវ ថែមទាំងបានស្តាប់ព្រះគាថាថា

យេ ធម្មា ហេតុប្បភវា ធម៌ទាំងឡាយណា កើតឡើងអំពីហេតុដូចនេះ ។

លុះចប់ព្រះគាថានេះ ឧបតិស្សៈ ក៏បានតាំងនៅក្នុងសោតាបត្តិផល ថែមទាំងនាំព្រះគាថានោះឯង ទៅពោលឲ្យកោលិតៈដែលជាសម្លាញ់របស់ខ្លួនបានស្តាប់ដែរ ចំណែកកោលិតបរិព្វាជក កាលដែលបានស្តាប់រួចហើយ ក៏បានតាំងនៅក្នុងសោតាបត្តិផលដូចគ្នា ។ សូម្បីសម្លាញ់ទាំងពីរនោះ ពេលដែលខ្លួនតាំងនៅក្នុងសោតាបត្តិផលហើយ បានលាសញ្ជ័យបរិព្វាជក ទៅបួសនៅក្នុងសម្នាក់ព្រះសាស្តា ព្រមដោយបរិវាររបស់ខ្លួន ។ បណ្តាសម្លាញ់ទាំងពីរនាក់នោះ ព្រះកោលិតៈឧសម្បទារួចបាន ៧ ថ្ងៃ ក៏សម្រេចជាព្រះអរហន្ត រីឯព្រះឧបតិស្សៈបានសម្រេចជាព្រះអរហន្ត ដោយកាលកន្លងទៅកន្លះខែ បន្ទាប់អំពីឧបសម្បទាហើយ ។ ព្រះលោកនាថ ទ្រង់ប្រកាសតែងតាំងព្រះថេរៈទាំងពីរទុកក្នុងតំណែងជាអគ្គសាវក គឺក្នុងថ្ងៃដែលព្រះសារីបុត្រ បានសម្រេចជាព្រះអរហន្តនោះឯង ទាំងជាថ្ងៃដែលទ្រង់ធ្វើសាវកសន្និបាតទៀតផង ។

នាកាលព្រះតថាគត គង់នៅក្នុងវេឡុវនារាមនោះឯង ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានព្រះសណ្តាប់ដំណឹងថា បុត្ររបស់យើងប្រព្រឹត្តទុក្ករកិរិយាអស់ ៦ ឆ្នាំ ឥឡូវនេះ បានសម្រេចសម្ពោធិញ្ញាណហើយ ថែមទាំងប្រកាសធម្មចក្រដ៏បវរ អាស្រ័យនៅទៀបក្រុងរាជគ្រឹះ នៅក្នុង

វេឡុវនារាម ទើបត្រាស់ហៅអាមាត្យម្នាក់មក ទ្រង់ត្រាស់ថា អ្នកចូរនាំបុរស ១០០០ នាក់ជាបរិវារ ធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ ហើយពោលតាមពាក្យរបស់យើងយ៉ាងនេះថា ព្រះបាទសុទ្ធោទនមហារាជ ដែលត្រូវជាព្រះបិតារបស់ព្រះអង្គ មានព្រះរាជបំណងចង់ជួបព្រះអង្គ ហេតុដូច្នេះ សូមព្រះមានព្រះភាគ ស្តេចយាងទៅកាន់ក្រុងកបិលពស្តុ អាមាត្យនោះក៏បានទទួលតាមព្រះរាជឱង្ការ ដោយបាននាំបរិវារ ១០០០ នាក់ទៅកាន់ក្រុងរាជគ្រឹះ ដែលមានចម្ងាយផ្លូវ ៦០ យោជន៍ លុះទៅដល់ហើយ ក៏បាននាំគ្នាចូលទៅឈរខាងចុងបរិស័ទទាំង ៤ របស់ព្រះភគវា ហើយស្តាប់ព្រះធម៌ទេសនា អាមាត្យនោះបានគិតថា ព្រះរាជឱង្ការរបស់ព្រះរាជា ដែលបញ្ជូនមកលើកទុកសិនចុះ ហើយស្ថិតនៅខាងចុងបំផុតនៃបរិស័ទ បាននាំគ្នាស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា កាលចប់ព្រះធម៌ទេសនា បានសម្រេចនូវព្រះអរហត្ត ព្រមទាំងបរិវារ ១០០០ នាក់ហើយ ទើបនាំគ្នាទូលសូមបព្វជ្ជា ព្រះមានជោគទ្រង់លាតព្រះហស្តត្រាស់ថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ ។ ក្នុងខណៈនោះឯង មនុស្សទាំងឡាយនោះ ក៏ដល់នូវភាវៈជាភិក្ខុ ដោយមានបាត្រ និងចីវរសម្រេចដោយឫទ្ធិ ដូចជាព្រះថេរៈមានវស្សា ៦០ ដូច្នោះដែរ ។ ធម្មតាព្រះអរិយៈ

ទាំងឡាយ រមែងមានខ្លួនជាកណ្តាល ចាប់តាំងអំពីដែលបានសម្រេចនូវអរហត្ត ព្រោះដូច្នោះ ទើបមិនបានក្រាបទូលបណ្តាំ ដែលព្រះរាជាទ្រង់បញ្ជូនមក ។ ព្រះរាជាបានត្រាស់ថា អាមាត្យដែលបញ្ជូនទៅហើយក៏មិនទាន់មក ដំណឹងអ្វីក៏ទ្រង់មិនបានជ្រាបទៀត ព្រះរាជាទ្រង់ត្រាស់ទៀតថា នែអាមាត្យអ្នកចូរទៅ ដូចដែលយើងប្រាប់អ្នកមុននោះឯង សូម្បីអាមាត្យទាំងនោះទៅហើយ ក៏បានសម្រេចនូវអរហត្ត ព្រមទាំងបរិស័ទដោយន័យមុននោះឯង ក៏បាននៅស្ងៀម ។ ព្រះរាជាទ្រង់បញ្ជូនអាមាត្យដល់ទៅ ៩ នាក់ ដែលមានបរិវារម្នាក់ៗ ១០០០ ទៅជាមួយដោយទំនងនោះឯង ។ អាមាត្យគ្រប់គ្នាញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេចហើយក៏បាននៅស្ងៀម ស្ថិតនៅក្នុងក្រុងរាជគ្រឹះ ។ ព្រះរាជាទ្រង់មិនជ្រាបដំណឹងអ្វីសោះ ទើបទ្រង់ត្រិះរិះថា ជនមានប្រមាណប៉ុណ្ណេះ មិននាំដំណឹងត្រឡប់មកវិញសោះ ព្រោះមិនមានសេចក្តីស្រឡាញ់ចំពោះយើង តើនរណាហ្ន៎ នឹងជាអ្នកធ្វើតាមពាក្យរបស់យើង កាលបើពិចារណាមើលទៅ ក៏បានឃើញកាឡុទាយីអាមាត្យ ។ បានឮថា កាឡុទាយីនោះជាអាមាត្យ ជាអ្នកចាត់ចែងរាជកិច្ចទាំងពួង មានសភាពស្និទ្ធស្នាលជាមួយនឹងព្រះរាជា ទាំងជាអ្នកកើតក្នុងថ្ងៃជាមួយនឹងព្រះពោធិសត្វ

ទៀតផង ។ លំដាប់នោះ ព្រះរាជាត្រាស់ហៅកាឡុទាយីអាមាត្យនោះមកថា នែបាកាឡុទាយី យើងប្រាថ្នានឹងឃើញបុត្ររបស់យើង ទើបបញ្ជូនបុរសដល់ទៅ ៩០០៩ នាក់ សូម្បីបុរសតែម្នាក់នឹងមកប្រាប់ដំណឹងក៏ពុំមានដែរ អន្តរាយនៃជីវិតរបស់យើងដឹងបានដោយលំបាកណាស់ យើងមានជីវិតរស់នៅប្រាថ្នានឹងឃើញបុត្ររបស់យើង អ្នកនឹងអាចឬទេហ្ន៎ ដែលធ្វើឲ្យយើងបានឃើញបុត្ររបស់យើង ។ ចំណែកកាឡុទាយីអាមាត្យបានក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងអាច ប្រសិនបើខ្ញុំព្រះអង្គបានបព្វជ្ជានោះ ។ ព្រះរាជាត្រាស់ថា នែបា អ្នកនឹងបានបួស ឬមិនបានបួសក៏ដោយ ចូរនាំបុត្រមកឲ្យយើងឃើញផង ។ កាឡុទាយីនោះទទួលព្រះរាជឱង្ការហើយ ធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ កាលទៅដល់ក៏បានទៅឈរនៅខាងចុងបរិស័ទ ក្នុងពេលដែលព្រះលោកនាថទ្រង់សម្តែងព្រះធម៌ លុះចប់ព្រះធម៌ហើយ លោកព្រមទាំងបរិវារក៏បានសម្រេចព្រះអរហត្ត ថែមទាំងជាអ្នកស្ថិតនៅក្នុងភាវៈជាឯហិភិក្ខុ ។

ចំណែកឯព្រះលោកនាថ បានជាព្រះពុទ្ធហើយ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ចាំវស្សាលើកដំបូង កាលបវារណាចេញ

វស្សាហើយ ស្តេចយាងទៅកាន់តំបន់ឧរុវេលា ដោយទ្រង់គង់នៅក្នុងតំបន់ឧរុវេលានោះ រហូតអស់ ៣ ខែ ទ្រង់ណែនាំទូន្មានជដិល ៣ នាក់បងប្អូន មានភិក្ខុ ១០០០ ជាបរិវារ ក្នុងថ្ងៃពេញបូណ៌មី ខែបុស្ស ស្តេចយាងចូលទៅកាន់ក្រុងរាជគ្រឹះ គង់នៅពីរខែ ។ ដោយលំដាប់កាលមានប្រមាណប៉ុណ្ណោះ ជាពេល ៥ ខែ ចំពោះព្រះសម្ពុទ្ធ ស្តេចយាងចេញចាកក្រុងពារាណសី ហេមន្តរដូវកន្លងទៅហើយ ចាប់តាំងអំពីថ្ងៃដែលព្រះកាឡុទាយិត្ថេរមកហើយ វេលាបានកន្លងទៅ ៧-៨ ថ្ងៃ ក្នុងថ្ងៃពេញបូណ៌មី ខែបុស្ស ព្រះកាឡុទាយីនោះគិតថា ហេមន្តរដូវក៏កន្លងទៅហើយ រដូវវស្សាកំពុងឈានចូលមក ពួកកសិករជកស្ទួងហើយ ធ្វើឲ្យផ្លូវទីត្រង់ចំពោះមុខសើម ផែនដីដេរដាសទៅដោយស្មៅមានពណ៌ខៀវស្រស់ ដងព្រៃក៏មានផ្កាឈើរីកស្គុសស្គាយ ផ្លូវសមរម្យដល់ការដែលធ្វើដំណើរ កាលនេះ ជាកាលដែលព្រះសម្ពុទ្ធ ស្តេចយាងទៅធ្វើការសង្គ្រោះដល់ពួកព្រះញាតិ ។ លំដាប់នោះ ព្រះកាឡុទាយីចូលទៅគាល់ព្រះភគវា ពោលសរសើរនូវផ្លូវទៅកាន់នគរកបិលពស្តុ ដើម្បីត្រូវការឲ្យព្រះមានជោគ ស្តេចយាងទៅកាន់រាជត្រកូល ដោយគាថា ៦០ ថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ដើមឈើទាំងឡាយមានផ្កាក្រហម រីកស្គុសស្គាយ មានផ្លែពេញដើម ជ្រុះស្លឹក ហើយដើមឈើទាំងនោះ ភ្លឺដូចជាមានអណ្តាតភ្លើង ភ្លឺចិញ្ចាចឡើង បពិត្រព្រះមហាវីរៈ ដល់សម័យដែលសមគួរ ដល់ពេលដែលព្រះអង្គស្តេចយាងទៅកាន់នគរកបិលពស្តុ ដោយស្ថានទីមិនត្រជាក់ពេក មិនក្តៅពេក មិនលំបាកនិងមិនខ្វះខាត ផ្ទៃភូមិភាគក៏មានស្មៅ ស្បូវភ្លាំងដ៏ខៀវស្រស់ បពិត្រព្រះមហាមុនី កាលនេះ ជាកាលសមគួរហើយ ដែលព្រះអង្គ ស្តេចយាងទៅ ។

លំដាប់នោះ ព្រះសាស្តា ត្រាស់នឹងព្រះកាឡុទាយីថា នែឧទាយី ព្រោះហេតុអ្វីហ្ន៎ ទើបអ្នកពិពណ៌នាទៅដោយសំឡេងដ៏ពីរោះយ៉ាងនេះ ព្រះកាឡុទាយីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទសុទ្ធោទនៈជាព្រះរាជបិតារបស់ព្រះអង្គ មានសេចក្តីប្រាថ្នានឹងជួបព្រះអង្គ សូមព្រះអង្គមេត្តាធ្វើការសង្គ្រោះពួកព្រះញាតិទាំងឡាយផងចុះ ព្រះសាស្តាត្រាស់ថា ប្រពៃហើយឧទាយី តថាគតនឹងធ្វើការសង្គ្រោះដល់ពពួកព្រះញាតិ អ្នកចូរប្រាប់ដល់ពួកភិក្ខុទាំងឡាយផងចុះ ។ ព្រះថេរៈក៏បានប្រាប់ដល់ពួកភិក្ខុទាំងឡាយ តាមពាក្យដែលព្រះអង្គត្រាស់ ។

ព្រះសាស្តា ទ្រង់ហែហមដោយពួកភិក្ខុជាព្រះខីណាស្រពចំនួនពីរម៉ឺនរូប គឺភិក្ខុជាកុលបុត្រអ្នកស្រុកអង្គៈ និងដែនមគធៈមួយម៉ឺនរូប ភិក្ខុជាកុលបុត្រ អ្នកក្រុងនគរកបិលពស្តុមួយម៉ឺនរូប ស្តេចយាងចេញពីក្រុងរាជគ្រឹះ ពុទ្ធដំណើរមួយថ្ងៃៗ ១ យោជន៍ ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះតម្រិះថា ស្តេចនឹងចេញចាកក្រុងរាជគ្រឹះ ទៅដល់ក្រុងកបិលពស្តុចម្ងាយផ្លូវ ៦០ យោជន៍ ដោយធ្វើដំណើររយៈពេល ២ ខែ ទើបស្តេចចារិកទៅដោយមិនប្រញាប់ប្រញាល់ឡើយ ចំណែកព្រះថេរៈគិតថានឹងក្រាបទូលសេចក្តីដែលព្រះលោកនាថ ស្តេចយាងចេញមកហើយទើបហោះទៅតាមអាកាស ទៅប្រាកដក្នុងរាជនិវេសន៍របស់ព្រះរាជា ៗព្រះរាជាទ្រង់ទតឃើញព្រះថេរៈមកភ្លាម ទ្រង់ក៏សព្វព្រះរាជហឫទ័យនិមន្តព្រះថេរៈឲ្យគង់លើបល្ល័ង្ក ដែលមានតម្លៃច្រើន ព្រះរាជាបាននាំយកបាត្រដែលពេញដោយភោជន មានរសដ៏ប្រសើរផ្សេងៗ ដែលគេចាត់ចែងត្រៀមទុក ដើម្បីព្រះអង្គហើយ ប្រគេនទៅដល់ព្រះថេរៈៗក្រោកឡើងសម្តែងអាការនឹងនិមន្តចេញទៅ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់គង់សិនចុះ ព្រះថេរៈទូលថា មហាបពិត្រ អាត្មានឹងទៅកាន់សម្នាក់ព្រះសាស្តា ហើយនឹងឆាន់ ៗព្រះរាជាត្រាស់ថា ព្រះភគវា

នៅទីណាលោកម្ចាស់ ព្រះថេរៈទូលថា មហាបពិត្រ ព្រះទសពល មានភិក្ខុពីរម៉ឺនរូបជាបរិវារ ស្តេចយាងចារិកមក ដើម្បីនឹងជួបព្រះអង្គ ព្រះរាជាទ្រង់មានព្រះហឫទ័យសប្បាយ បានត្រាស់ថា លោកម្ចាស់ ឆាន់ភត្តាហារនេះហើយ សូមនាំបិណ្ឌបាតពីព្រះរាជនិវេសន៍នេះ ទៅថ្វាយដល់ព្រះឱរសនោះ ដរាបព្រះរាជឱរសរបស់ញោមមកដល់ព្រះនគរនេះ ។ ព្រះថេរៈទទួលហើយ ព្រះរាជាអង្គាសព្រះថេរៈហើយៗ អប់បាត្រដោយលម្អិត មានគ្រឿងក្រអូបជាដើម ដាក់ពេញដោយភោជនដ៏ឧត្តម ហើយប្រគេនដល់ដៃរបស់ព្រះថេរៈ ដោយត្រាស់ថា សូមលោកម្ចាស់ ថ្វាយព្រះតថាគត ។ ព្រះថេរៈកាលបើជន ក្នុងវាំងកំពុងតែមើលនោះឯង បានបោះបាត្រឡើងទៅលើអាកាស ចំណែកខ្លួនឯងក៏ហោះឡើងទៅកាន់អាកាស ទ្របាត្រនាំយកទៅដាក់ចំពោះព្រះភក្ត្រ នៃព្រះទសពល ព្រះលោកនាថទ្រង់ក៏សោយបិណ្ឌបាតនោះ ។ ព្រះថេរៈបាននាំបិណ្ឌបាតមកជារៀងរាល់ថ្ងៃដោយឧបាយនេះ សូម្បីព្រះលោកនាយកក៏សោយបិណ្ឌបាត ដែលព្រះរាជាថ្វាយតែប៉ុណ្ណោះ ក្នុងវេលាធ្វើដំណើរ ។ ក្នុងវេលាព្រះអង្គធ្វើភត្តកិច្ចរាល់ៗ ថ្ងៃ សូម្បីព្រះថេរៈក៏ពោលថា ថ្ងៃនេះព្រះសាស្តា ស្តេចយាងមកអស់រយៈផ្លូវមានប្រមាណប៉ុណ្ណោះ ក៏បាន

ញ៉ាំងរាជត្រកូលទាំងអស់ឲ្យមានសេចក្ដីជ្រះថ្លាឡើង ចំពោះព្រះភគវា ដោយវៀរការបានឃើញព្រះលោកនាថ ដោយធម្មីកថា សម្បយុត្ត ដោយពុទ្ធគុណ ។ ដោយហេតុនោះឯង ព្រះសក្យមុនី ទើបស្ថាបនា ព្រះកាឡុទាយិត្ថេរ ទុកក្នុងតំណែងជាឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ កាឡុទាយីនេះ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់ តថាគត ផ្នែកខាងញ៉ាំងត្រកូលឲ្យជ្រះថ្លា ។

ចំណែកស្ដេចសក្យៈទាំងឡាយ កាលព្រះមានជោគស្ដេចយាង មកដោយលំដាប់ហើយ បានប្រឹក្សាគ្នាថា ពួកយើងនឹងឃើញព្រះញាតិ ដ៏ប្រសើររបស់ពួកយើង ទើបប្រជុំគ្នាពិចារណារកទីកន្លែងប្រថាប់របស់ ព្រះមហាវីរបុរស បានកំណត់គ្នាថា អារាមរបស់ស្ដេចនិគ្រោធសក្យៈ គួរជាទីរីករាយ ទើបឲ្យធ្វើការជួសជុលគ្រប់យ៉ាង ក្នុងអារាមនោះឡើង វិញ ក្នុងការទទួលព្រះសម្ពុទ្ធនោះ បាននាំគ្នាកាន់ផ្កាកម្រង និងគ្រឿង ក្រអូបជាដើម ថែមទាំងបានបញ្ជូនរាជកុមារ និងរាជកុមារីខ្លះ ដែល វ័យកំលោះក្រមុំខ្លះ ដែលស្អិតស្អាង ដោយគ្រឿងប្រដាប់គ្រប់យ៉ាង ឲ្យទៅទទួលមុនគេ បន្ទាប់អំពីនោះ ទើបបញ្ជូនរាជកុមារ និងរាជធីតា ទាំងនោះ ជាអ្នកទៅអារាធនាព្រះភគវា ទៅកាន់និគ្រោធារាមនោះ ។

ក្នុងនិគ្រោធារាមនោះ ព្រះលោកនាយក ព្រះអង្គស្តេចយាងចូលទៅ ហែហមដោយព្រះខីណាស្រពពីរម៉ឺនរូប គង់នៅលើបវរពុទ្ធាសនៈ ដែលគេរៀបចំទុកហើយ ។ ធម្មតាស្តេចសក្យៈទាំងឡាយ មានជាតិមានះ គឺប្រកាន់ខ្លួនថា ខ្លួនចាស់ជាងព្រះអង្គ ទើបមិនបានថ្វាយបង្គំព្រះភគវា ដោយយល់ថា ព្រះសិទ្ធត្ថកុមារ មានវ័យក្មេងជាងយើង ជាព្រះកនិដ្ឋា ជាព្រះភាគិនេយ្យ ជាព្រះឱរស ជាព្រះនត្តារបស់យើងទាំងឡាយ ទើបត្រាស់នឹងរាជកុមារទាំងឡាយ ដែលនៅកំលោះៗ ទាំងនោះថា អ្នកទាំងឡាយចូរទៅថ្វាយបង្គំព្រះមានព្រះភាគ ពួកយើងនឹងអង្គុយនៅពីខាងក្រោយពួកអ្នកទាំងឡាយ ។

កាលស្តេចសក្យៈទាំងនោះ មិនថ្វាយបង្គំ គង់ហើយយ៉ាងនេះ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលអធ្យាស្រ័យ របស់ស្តេចសក្យៈទាំងនោះ ហើយទ្រង់ត្រិះរិះថា ព្រះញាតិទាំងឡាយ មិនថ្វាយបង្គំតថាគត ណ្ហើយចុះ តថាគតនឹងឲ្យព្រះញាតិទាំងនេះថ្វាយបង្គំ ទើបទ្រង់ចូលចតុត្ថជ្ឈានមានអភិញ្ញាជាបាទ ចេញចាកឈានហើយ ហោះទៅលើអាកាស ដូចរោយធូលីព្រះបាទដាក់លើព្រះសិរសារបស់ស្តេចសក្យៈទាំងនោះ ព្រះមុនីបានសម្តែងបាដិហារិយ៍ ដូចគ្នានឹងយមកប្បាដិហារិយ៍

នៅទៀបគល់នៃដើម គណ្ឌាមពព្រឹក្ស ព្រះរាជាទ្រង់ឃើញភាពអស្ចារ្យ នោះហើយ ទើបត្រាស់ថា បពិត្រព្រះសម្ពុទ្ធ ក្នុងថ្ងៃដែលព្រះអង្គប្រសូត ខ្ញុំព្រះអង្គបានឃើញព្រះបាទរបស់ព្រះអង្គ ដែលខ្ញុំព្រះអង្គនាំចូលទៅឲ្យថ្វាយបង្គំកាឡទេវិលតាបស ត្រឡប់ជាព្រះបាទរបស់ព្រះទសពល ទៅប្រតិស្ឋាននៅលើក្បាលរបស់កាឡទេវិលតាបសទៅវិញ ខ្ញុំព្រះអង្គបានឃើញហេតុដ៏អស្ចារ្យដូច្នេះហើយ ក៏បានថ្វាយបង្គំព្រះលោកនាថនុ៎ះជាការថ្វាយបង្គំលើកដំបូងរបស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃវប្បមង្គល ក៏បានឃើញភាពមិនផ្លាស់ប្តូរ នៃស្រមោលម្លប់ដើមព្រីងរបស់ព្រះមានជោគដែលទ្រង់ផ្ទំលើទីសយនាដែលប្រកបដោយសិរី ក្នុងមណ្ឌបនាក្រោមម្លប់ដើមព្រីង ឃើញដូច្នោះហើយ ក៏បានថ្វាយបង្គំព្រះលោកនាយកនុ៎ះជាការថ្វាយបង្គំលើកទី ២ ឥឡូវនេះ បានឃើញបាដិហារិយ៍នេះដែលមិនធ្លាប់ឃើញ ទើបថ្វាយបង្គំព្រះសក្យមុនី នេះជាការថ្វាយបង្គំលើកទី ៣ របស់ខ្ញុំព្រះអង្គ ។ កាលព្រះរាជាថ្វាយបង្គំ សូម្បីស្តេចសក្យៈមួយអង្គ ឈ្មោះថា អ្នកមិនថ្វាយបង្គំព្រះមានជោគនោះមិនមានឡើយ ស្តេចសក្យៈទាំងពួងនាំគ្នាថ្វាយបង្គំទាំងអស់គ្នា ព្រះភគវាឲ្យព្រះញាតិទាំងឡាយថ្វាយបង្គំដោយប្រការដូច្នេះឯង ទើបស្តេចចុះចាកអាកាស

មកគង់លើពុទ្ធាសនៈដែលគេក្រាលទុកនោះ កាលព្រះសាស្តាទ្រង់គង់រួចហើយ សមាគមព្រះញាតិដែលដល់នូវកាពខ្ពង់ខ្ពស់ ទើបបានមានឡើង ។ ស្តេចសក្យៈទាំងពួង មានព្រះទ័យសោមនស្ស ក៏អង្គុយចុះហើយ ។ លំដាប់នោះ មហាមេឃបានញុំាងភ្លៀងបោក្ខរព័ស្សឲ្យធ្លាក់ចុះទឹកមានពណ៌ក្រហមហូរចុះទៅខាងក្រោម បើអ្នកណាប្រាថ្នានឹងទទឹកទើបបានទទឹក ភ្លៀងបោក្ខព័ស្សនោះ សូម្បីមួយដំណក់ធ្លាក់ចុះមកលើរាងកាយ របស់អ្នកដែលមិនប្រាថ្នាដើម្បីទទឹក ក៏មិនទទឹក ។ ស្តេចសក្យៈទាំងពួងនោះ បានឃើញហេតុអស្ចារ្យដូច្នោះ មិនធ្លាប់មានមកហើយទើបនាំគ្នានិយាយថា ឱហ្ន៎ ! គួរឲ្យអស្ចារ្យណាស់ ឱហ្ន៎ ! មិនធ្លាប់មានមកទាល់តែសោះ ព្រះមានជោគត្រាស់ថា ភ្លៀងបោក្ខរព័ស្សធ្លាក់ចុះមកក្នុងសមាគមនៃព្រះញាតិរបស់តថាគត ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនដែរ សូម្បីក្នុងអតីតកាលក៏មាន ទើបព្រះសម្ពុទ្ធទ្រង់ត្រាស់**វេស្សន្តរជាតក** អំពីហេតុដែលកើតឡើងនោះ លុះចប់ព្រះធម៌ទេសនាស្តេចសក្យៈទាំងពួង ក៏បានក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះអង្គចៀសចេញទៅ ។ ព្រះរាជា ឬមហាអាមាត្យរបស់ព្រះអង្គ សូម្បីតែមួយអង្គនាំគ្នាក្រាបទូលថា សូមព្រះភគវាទទួលភិក្ខារបស់ខ្ញុំព្រះអង្គ

ទាំងឡាយក្នុងថ្ងៃស្អែកនេះទៀតក៏ទេ ដូច្នេះហើយ ទើបស្តេចយាង ចៀសចេញទៅ ដោយមិនមានអ្នកណាមួយនិមន្តព្រះអង្គទុកឡើយ ។

លុះដល់ថ្ងៃស្អែកឡើង ព្រះសាស្តា ទ្រង់មានភិក្ខុសង្ឃពីរម៉ឺន រូបជាបរិវារ ស្តេចយាងចូលទៅកាន់ក្រុងកបិលពស្តុ ក្នុងវេលាភិក្ខា ត្រាច់ទៅដើម្បីបិណ្ឌបាត ។ មិនមាននរណានឹងទៅនិមន្ត ឬទទួលបាត្រ របស់ព្រះមានព្រះភាគៗ ទ្រង់ប្រថាប់ឈរត្រង់សសរខឿន ដោយទ្រង់ មានព្រះតម្រិះថា ព្រះពុទ្ធក្នុងកាលមុនទាំងឡាយ ស្តេចត្រាច់បិណ្ឌបាត ក្នុងនគរនៃរាជត្រកូលយ៉ាងដូចម្តេចហ្ន៎ ព្រះលោកនាយកបានជ្រាបថា ព្រះពុទ្ធពីដើមរមែងត្រាច់ទៅតាមលំដាប់ត្រកូល ដើម្បីបិណ្ឌបាតជាវត្ត ជ្រាបដូច្នេះហើយ ក៏ទ្រង់ត្រាច់ចរទៅតាមលំដាប់ផ្ទះរបស់ឥស្សរជន ដើម្បីបិណ្ឌបាត ឬស្តេចត្រាច់ចារិកទៅតាមលំដាប់ប្រកផ្ទះ នេះជាវង្ស របស់ព្រះពុទ្ធទាំងឡាយ នេះជាប្រពៃណីរបស់តថាគត សូម្បីតែតថាគត ក៏គួរបដិបត្តិដូចនេះ នឹងបំពេញវត្តដូច្នេះតទៅ ទើបស្តេចយាងទៅ បិណ្ឌបាតតាមលំដាប់ប្រកផ្ទះ តាំងអំពីផ្ទះខាងដើមតទៅ ។ គ្រានោះ មហាជនក្នុងនគរពោលថា បានឮថា សិទ្ធត្ថកុមារទ្រង់ជាស្តេចយាងទៅ ដើម្បីដុំបាយ ទើបបើកបង្អួចផ្សេងៗ ខាងលើប្រាសាទជាន់ទី ២ និង

ជាន់ទី ៣ ជាដើម ដើម្បីនាំគ្នាមើលព្រះអង្គ ។

ចំណែកព្រះនាងទេវីរាហុលមាតា ទ្រង់ព្រះតម្រិះ ដោយន័យថា ព្រះអយ្យបុត្រ ស្តេចយាងទៅដោយគង់លើ.រ.មាសជាដើម ដោយរាជានុភាពធំយ៉ាងក្រៃលែងក្នុងព្រះនគរនេះឯង ឥឡូវនេះ កោរសក់ពុកមាត់ ពុកចង្កា ទើបទ្រង់បើកសីហបញ្ជរទតមើល បានឃើញព្រះមានព្រះភាគ ទ្រង់យាងទៅតាមផ្លូវក្នុងព្រះនគរ មានព្រះកាយរុងរឿងដោយអសីត្យានុព្យញ្ជនៈ ដោយពុទ្ធសិរី ដែលរកឧបមាមិនបានប្រដាប់ដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ក៏ដោយអនុព្យញ្ជនៈ ៨០ ដែលព័ទ្ធព័ទ្ធជុំវិញដោយរស្មីប្រមាណមួយព្យាម ទើបទ្រង់សរសើរតាំងអំពីព្រះឧណ្ហីស រហូតដល់ផ្ទៃនៃព្រះបាទ ដោយបានពោលគាថាឈ្មោះថា នរសីហៈ ៨ ប្រការ មានជាអាទិ៍យ៉ាងនេះថា

ព្រះនរសីហៈ មានព្រះកេសាទន់ខ្មៅស្រិល មានផ្ទៃនៃព្រះបាទប្រាសចាកមន្ទិល ដូចជាព្រះអាទិត្យមានព្រះនាសិកកោងវែងសមរម្យជ្រួតជ្រាបទៅដោយព្រះបណ្តាញនៃព្រះរស្មី ដូចនេះ ។

ហើយទើបក្រាបទូលដល់ព្រះរាជាថា ព្រះឱរសរបស់ព្រះអង្គស្តេចយាងទៅដើម្បីដុំបាយ ព្រះរាជាក៏ស្ទុតព្រះរាជហឫទ័យ ទ្រង់ម្នីម្នា

ចុះចាកប្រាសាទ ទៅកាន់សម្នាក់ព្រះភគវា ប្រថាប់ឈរនៅពីខាងមុខព្រះភក្ត្ររបស់ព្រះមានជោគ ហើយត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបព្រះសក្យមុនីទ្រង់ធ្វើឲ្យខ្ញុំព្រះអង្គខ្មាសគេ ដើម្បីអ្វីទើបស្តេចយាងទៅដើម្បីដុំបាយ ដូចម្តេចព្រះលោកនាយក ទើបធ្វើសេចក្តីសម្គាល់ថា ភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណោះ ខ្ញុំព្រះអង្គមិនអាចថ្វាយភត្តាហារដល់ភិក្ខុទាំងអស់នេះឬ ? ព្រះសាស្តាត្រាស់តបថា មហាបពិត្រ ការត្រាច់បិណ្ឌបាតនេះ ជាវង្សនៃតថាគត ពុំមែនជាវង្សនៃខត្តិយជាតិទាំងពួងទេ ដ្បិតថា ធម្មតាព្រះសម្ពុទ្ធទាំងឡាយ រមែងចិញ្ចឹមជីវិតដោយការត្រាច់បិណ្ឌបាតជាវត្តដូច្នេះ ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ មានវង្សជាក្សត្រពុំមែនឬ ក្នុងវង្សក្សត្រនោះសោត សូម្បីក្សត្រមួយព្រះអង្គយាងទៅដើម្បីភិក្ខា រមែងមិនមាន ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ឈ្មោះថា វង្សនេះជាវង្សរបស់ព្រះអង្គ ។ តែឈ្មោះថា ពុទ្ធវង្សនេះ គឺជាវង្សរបស់ព្រះពុទ្ធទីបង្ករ ព្រះកោណ្ឌញ្ញៈ ព្រះកស្សបៈ ជាវង្សនៃតថាគត និងព្រះទសពលដទៃៗ រាប់បានច្រើនពាន់ បានសម្រេចការចិញ្ចឹមជីវិតដោយការយាងទៅបិណ្ឌបាតតែប៉ុណ្ណោះ ដោយព្រះអង្គប្រថាប់ឈរ

ក្នុងរវាងផ្លូវនោះឯង ត្រាស់ព្រះគាថានេះថា

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេក ជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

ក្នុងពេលដែលចប់ព្រះគាថានោះ ព្រះរាជាក៏បានតាំងនៅក្នុង សោតាបត្តិផល និងបានស្តាប់គាថានេះថា

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិត ឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងនៅជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

បានតាំងនៅក្នុងសកទាគាមិផល លុះបានស្តាប់ធម្មបាលជាតក បានតាំងនៅក្នុងអនាគាមិផល ។ ក្នុងសម័យជិតនឹងសោយទិវង្គត ទ្រង់ផ្ទំ លើព្រះក្រឡាបន្ទំ ដែលប្រកបដោយសិរី ខាងក្រោមស្វេតច្ឆត្រ បានសម្រេចនូវអរហត្តផល ។ ក្នុងការប្រកបនូវសេចក្តីព្យាយាម ដោយ ការរស់នៅក្នុងព្រៃ មិនបានមានដល់ព្រះរាជា ។ គ្រាទ្រង់ធ្វើឲ្យជាក់ច្បាស់ ចំពោះព្រះសោតាបត្តិផលប៉ុណ្ណោះ ទ្រង់ទទួលបាត្ររបស់ព្រះសាស្តា ទ្រង់អារាធនានិមន្តព្រះមានជោគ ព្រមទាំងភិក្ខុសង្ឃ ឲ្យស្តេចឡើងកាន់

មហាប្រាសាទ ព្រះរាជាទ្រង់អង្គាសដោយខាទនីយៈ និងភោជនីយាហារ ដ៏ប្រណីត ។ ក្នុងវេលាខាងក្រោយភត្តកិច្ច នាងស្នំទាំងពួង លើកលែងតែរាហុលមាតា នាំគ្នាទៅថ្វាយបង្គំព្រះសម្ពុទ្ធ ។ រាហុលមាតានោះ សូម្បីជនជាបរិវារពោលថា សូមព្រះនាងស្តេចយាងទៅថ្វាយបង្គំព្រះអយ្យបុត្រ ក៏ត្រាស់ថា បើគុណរបស់យើងមាននៅយ៉ាងនោះ ព្រះអយ្យបុត្រ នឹងស្តេចយាងមកកាន់សម្នាក់របស់យើង ដោយព្រះអង្គឯង យើងនឹងថ្វាយបង្គំព្រះអយ្យបុត្រនោះ ចំពោះតែទ្រង់ស្តេចយាងមកប៉ុណ្ណោះ លុះត្រាស់ដូច្នេះហើយ ព្រះនាងមិនបានស្តេចយាងទៅថ្វាយបង្គំឡើយ ព្រះសាស្តាទ្រង់ឲ្យព្រះរាជាកាន់បាត្រ ហើយស្តេចយាងទៅកាន់បន្ទប់ដ៏មានសិរីនៃរាហុលមាតា ព្រមទាំងអគ្គសាវ័កទាំងពីររូប ហើយត្រាស់ថា រាហុលមាតាកាលបើថ្វាយបង្គំតាមការពេញចិត្ត មិនគប្បីពោលពាក្យអ្វីៗ ហើយគង់លើអាសនៈដែលគេក្រាលទុកនោះ ។ រាហុលមាតាស្តេចយាងមកដោយឆាប់ ចាប់.កព្រះបាទទាំងពីរ ននៀលព្រះកេសលើខ្នងព្រះបាទ ថ្វាយបង្គំតាមអធ្យាស្រ័យ ព្រះរាជាទ្រង់ត្រាស់អំពីគុណសម្បត្តិ ដែលមានការស្រឡាញ់ និងការគោរពរបស់រាហុលមាតា ចំពោះព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ធីតារបស់ខ្ញុំព្រះអង្គ បានឮដំណឹងថា ព្រះអង្គ

ស្បៀកដណ្តប់សំពត់កាសាវៈ តាំងអំពីនោះ ព្រះនាងក៏ទ្រទ្រង់សំពត់កាសាវៈដែរ បានឮដំណឹងថា ព្រះអង្គមានភត្តតែម្តង ព្រះនាងក៏មានភត្តតែម្តងដែរ បានឮដំណឹងថា ព្រះអង្គទ្រង់លះបង់ទីអង្គុយ ទីដេកធំ ព្រះនាងក៏ទ្រង់ផ្ទំចំពោះគ្រែតូចៗ បានឮដំណឹងថា ព្រះអង្គទ្រង់លះបង់ចោលចំពោះគ្រឿងក្រអូប និងផ្កាកម្រងជាដើម ព្រះនាងក៏វៀរស្រឡះចំពោះរបស់ទាំងអស់នោះដែរ កាលព្រះញាតិទ្រង់បញ្ជូនដំណឹងមកថា យើងទាំងឡាយនឹងស្តីដណ្តឹងនាង ធ្វើជាព្រះអគ្គមហេសី ទ្រង់បដិសេធទាំងអស់ បពិត្រព្រះមានព្រះភាគ ធីតារបស់ខ្ញុំព្រះអង្គបរិបូណ៌ទៅដោយគុណសម្បត្តិយ៉ាងនេះឯង ។ ព្រះបរមសាស្តាត្រាស់ថា មហាបពិត្រ ប្រការដែលព្រះរាជធីតារបស់ព្រះអង្គ ស្មោះត្រង់ក្នុងពេលឥឡូវនេះ ទាំងខ្លួននាងជាអ្នកមានញាណចាស់ក្លាហើយនោះ មិនអស្ចារ្យទេ ក្នុងកាលមុនរាជធីតានេះ មានការរស់នៅតាមជើងភ្នំ ក៏អាចថែរក្សាខ្លួនបានក្នុងកាលញាណនៅមិនទាន់ចាស់ក្លា ដូចនេះហើយ ទ្រង់បន្ទោបង់សេចក្តីសោកសៅរបស់ព្រះរាជធីតា ( នាងពិម្ពា ) ព្រះអង្គទ្រង់ត្រាស់ **ចន្ទកិន្នរីជាតក** ដោយពិស្តារ លុះចប់ព្រះធម៌ទេសនា ព្រះនាងពិម្ពាបានសម្រេចសោតាបត្តិផល ហើយក្រោកចាកអាសនៈ ស្តេចយាង

ចៀសចេញទៅ ។

នៅថ្ងៃទី ៤ កាលកំពុងធ្វើវិវាហមង្គល ព្រះសាស្តាស្តេចយាង ចូលទៅកាន់ព្រះរាជដំណាក់អភិសេករបស់ព្រះនន្ទ ដំណើរដែលព្រះមុនី ស្តេចយាងចូលទៅកាន់ព្រះរាជដំណាក់ របស់ព្រះនន្ទរាជកុមារនោះ ទ្រង់ឲ្យព្រះនន្ទកាន់បាត្រ ដោយព្រះលោកនាថមានព្រះរាជបំណងនឹង ឲ្យព្រះនន្ទបួស លុះត្រាស់មង្គលកថាចប់ហើយ ព្រះអង្គក៏ស្តេចយាង ក្រោកឡើងពីអាសនៈ ស្តេចយាងចៀសចេញទៅ ។ គ្រានោះ នាង ជនបទកល្យាណីបានឃើញព្រះនន្ទកំពុងស្តេចយាងទៅ ទើបទូលផ្តាំថា បពិត្រព្រះអយ្យបុត្រ ព្រះអង្គប្រញាប់យាងត្រឡប់មកវិញណា ហើយ ព្រះនាងទ្រង់អើតព្រះសិរសា ក្រឡេកមើលមកតាមបង្អួច ចំណែក ព្រះនន្ទនោះ មិនអាចទូលព្រះមានព្រះភាគថា សូមព្រះអង្គទទួលយក បាត្រទៅ ។ ព្រះនន្ទក៏ស្តេចយាងទៅតាមព្រះលោកនាយក ដរាបដល់ និគ្រោធារាម ។ ព្រះសម្ពុទ្ធទ្រង់សួរព្រះនន្ទថា នែនន្ទ អ្នកបួសឬទេ ? ព្រះនន្ទនោះមិនប្រាថ្នាក្នុងការបួសទេ ប៉ុន្តែមិនហ៊ានប្រកែក បានក្រាបទូល ព្រះពុទ្ធអង្គថា បួស ព្រះបរមសាស្តាទ្រង់បំបួសព្រះនន្ទក្នុងថ្ងៃនោះទៅ ព្រះភគវាស្តេចយាងចូលទៅកាន់ **កបិលពស្តុបុរី** ទ្រង់ឲ្យព្រះនន្ទបួស

ដោយប្រការដូច្នេះឯង ។

លុះដល់ថ្ងៃទី ៧ រាហុលមាតាតាក់តែងរាហុលកុមារ ហើយបញ្ជូនឲ្យទៅគាល់ព្រះសម្មាសម្ពុទ្ធ ដោយព្រះតម្រាស់ថា បុត្រ អ្នកចូរមើលព្រះមហាសមណៈ ដែលមានរូបដូចជាព្រហ្ម មានពណ៌ដូចជាមាស ហែហមទៅដោយភិក្ខុសង្ឃពីរម៉ឺនរូប ព្រះមហាសមណៈនោះ ជាបិតារបស់បុត្រ ព្រះមហាសមណៈនោះមានកំណប់ទ្រព្យធំ ៤ រណ្តៅ ចាប់តាំងអំពីព្រះមហាសមណៈនោះចេញទៅបួសហើយ មាតាមិនឃើញកំណប់ទ្រព្យទាំងនោះឡើយ អ្នកចូរទៅសូមមត៌កនឹងព្រះមហាសមណៈនោះថា បពិត្រព្រះបិតា ខ្ញុំព្រះអង្គជាព្រះរាជកុមារព្រះអង្គ កាលបើខ្ញុំព្រះអង្គបានទទួលអភិសេកហើយ នឹងបានជាស្តេចចក្រពត្តិ ខ្ញុំព្រះអង្គត្រូវការទ្រព្យ សូមព្រះអង្គប្រទានទ្រព្យដល់ខ្ញុំព្រះអង្គ ព្រោះបុត្រជាម្ចាស់ទ្រព្យដែលជារបស់ព្រះបិតា ។ ព្រះរាហុលស្តេចយាងទៅកាន់សម្នាក់នៃព្រះសម្ពុទ្ធ គ្រាន់បានជាទីស្រឡាញ់ចំពោះព្រះបិតា មានចិត្តរីករាយណាស់ ក្រាបទូលថា បពិត្រព្រះសមណៈ ម្លប់របស់ព្រះអង្គជាសុខ ហើយបានឈរត្រាស់ពាក្យយ៉ាងដទៃ ដែលសមគួរដល់ព្រះអង្គជាច្រើន ។ ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ព្រះអង្គទ្រង់ធ្វើការអនុមោទនា

ហើយស្តេចក្រោកចាកអាសនៈចៀសចេញទៅ ។ ចំណែកព្រះរាហុល ស្តេចយាងតាមជាប់ព្រះភគវាទៅដោយត្រាស់ថា បពិត្រព្រះសមណៈ សូមព្រះអង្គប្រទានមត៌កដល់ខ្ញុំព្រះអង្គ ។ ព្រះលោកនាថ ទ្រង់មិនឲ្យព្រះរាហុលត្រឡប់មកវិញ ជនជាបរិវារ មិនអាចដើម្បីនឹងញុំាងព្រះរាហុលយាងទៅ ព្រមជាមួយនឹងព្រះសាស្តាឲ្យត្រឡប់មកវិញបាន ។ ព្រះរាហុលនោះ ស្តេចបានយាងទៅកាន់និគ្រោធារាម ព្រមជាមួយនឹងព្រះវិជិតមារ ដោយប្រការដូច្នេះ ។ ព្រះមហាវីរបុរស ស្តេចយាងទៅ ទ្រង់ព្រះតម្រិះថា ព្រះកុមារនេះប្រាថ្នាទ្រព្យដែលជារបស់បិតា ដែលប្រព្រឹត្តទៅក្នុងវដ្តៈ មានសភាពចង្អៀងចង្អល់ ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានចំពោះពោធិមណ្ឌល ដល់ព្រះរាជកុមារនេះ តថាគតធ្វើឲ្យជាម្ចាស់នៃទ្រព្យមត៌ក ដែលជាលោកុត្តរៈ ហើយត្រាស់ហៅព្រះសារីបុត្រមកថា ម្នាលសារីបុត្រ ប្រសិនបើយ៉ាងនោះ អ្នកចូរឲ្យរាហុលកុមារបួស ។ កាលព្រះរាហុលបួសរួចហើយ ទុក្ខមានប្រមាណយ៉ាងក្រៃលែង បានកើតឡើងដល់ព្រះបាទសុទ្ធោទនៈ ។ កាលបើទ្រង់មិនអាចនឹងអត់សង្កត់នូវសេចក្តីទុក្ខនោះបាន ទើបទ្រង់ទូលឲ្យព្រះសាស្តាទ្រង់ជ្រាប ។ ហើយព្រះរាជា

ទូលសូមពរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាសថា ព្រះពុទ្ធទាំងឡាយ មិនគប្បីបំបួសកុលបុត្រ ដែលមាតាបិតាមិនទាន់អនុញ្ញាតទេ ។ ព្រះសម្ពុទ្ធទ្រង់ទទួលព្រះតម្រាស់នោះរបស់ព្រះរាជា ។ ក្នុងថ្ងៃស្អែក ពេលដែលព្រះភគវា ស្តេចយាងចូលទៅទទួលចង្ហាន់ក្នុងព្រះរាជនិវេសន៍ កាលព្រះរាជាទ្រង់គង់ក្នុងទីដ៏សមគួរហើយ បានត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលដែលព្រះអង្គបំពេញនូវទុក្ករកិរិយានោះ មានទេវតាមួយអង្គ ចូលមករកខ្ញុំព្រះអង្គ ពោលថា ព្រះឱរសរបស់ព្រះអង្គ ទ្រង់ធ្វើកាលកិរិយាទៅហើយ ខ្ញុំព្រះអង្គមិនជឿពាក្យរបស់ទេវតានោះទេ បានត្រាស់បតទៅទេវតានោះវិញថា បុត្ររបស់យើង មិនទាន់សម្រេចនូវពោធិញ្ញាណ នឹងមិនធ្វើកាលកិរិយាឡើយ ទើបព្រះអង្គត្រាស់ថា ឥឡូវនេះ មហាបពិត្រ ទ្រង់មិនជឿសូម្បីក្នុងកាលមុន មានមនុស្សយកឆ្អឹងមកបង្ហាញ ពោលថា បុត្ររបស់អ្នកស្លាប់ហើយ មហាបពិត្រក៏ពុំបានជឿដែរ ហើយព្រះសម្ពុទ្ធទ្រង់ត្រាស់ **មហាធម្មបាលជាតក** ដើម្បីសម្តែងឲ្យឃើញច្បាស់ចំពោះរឿងដែលធ្លាប់កើតមកហើយនោះ ក្នុងពេលចប់ព្រះធម៌ទេសនា ព្រះរាជាក៏បានតាំងនៅក្នុងអនាគាមិផល ។ ព្រះមានព្រះភាគ ទ្រង់ឲ្យ

ព្រះបិតាតាំងនៅក្នុងផលទាំង ៣ ដោយប្រការដូច្នេះហើយ ព្រះសាស្ដា ព្រះអង្គហែហមទៅដោយភិក្ខុសង្ឃ ស្ដេចយាងចេញពីក្រុងកបិលពស្ដុ ទៅកាន់ក្រុងរាជគ្រឹះវិញទៀត ទ្រង់គង់ប្រថាប់នៅក្នុងព្រៃសីតវ័ន ។

សម័យនោះ **អនាថបិណ្ឌិកសេដ្ឋី** នាំរទេះ ៥០០ ផ្ទុកទៅដោយទំនិញ ទៅកាន់ផ្ទះរបស់លោកសេដ្ឋី ដែលជាសម្លាញ់នឹងខ្លួន នៅក្នុងក្រុងរាជគ្រឹះ បានឮមកថា ព្រះភគវាស្ដេចឧប្បត្តិឡើងក្នុងលោកហើយ ព្រះអង្គនៅក្នុងក្រុងរាជគ្រឹះ នាព្រៃសីតវ័ន ពេលជិតភ្លឺ បានចូលទៅគាល់ព្រះសាស្ដា បានស្ដាប់ធម៌ហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃទី ២ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានរូបហើយ បានសូមឲ្យព្រះសាស្ដាទ្រង់ទទួលបេ្ដជ្ញា ដើម្បីស្ដេចយាងទៅកាន់ក្រុងសាវត្ថី ។ ក្នុងរវាងផ្លូវបានឲ្យទ្រព្យមួយសែនកហាបណៈកសាងវិហារ ( ក្នុងចម្ងាយផ្លូវមួយយោជន៍ ១ កន្លែង ) ហើយទិញឧទ្យានរបស់ស្ដេចជេត ដោយទឹកប្រាក់ ១៨ កោដិ ដោយយកប្រាក់ទៅក្រាលទិញដី ហើយធ្វើការកសាងរួចស្រេច គឺឲ្យកសាងព្រះគន្ធកុដិ ដើម្បីព្រះសក្យមុនី ត្រង់កណ្ដាល ថែមទាំងឲ្យកសាងវិហារ ដែលជាទីរីករាយជុំវិញព្រះគន្ធកុដិនោះ ក្នុងភូមិភាគដែលគួររីករាយ ដោយ

ការបរិច្ចាគទ្រព្យ ១៨ កោដិ គឺឲ្យកសាងសេនាសនៈ ដូចជាកុដិមួយខ្នង កុដិពីរខ្នង សាលាធ្មសភា និងបាំរំជាដើម ស្រះបោក្ខរណី ទីចង្ក្រម ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ដោយជាកុដិសម្រាប់អាស្រ័យនៅចំពោះតែមួយអង្គៗ តាមលំដាប់ៗ ដើម្បីព្រះថេរៈធំៗ ៨០ រូប ហើយបញ្ជូនទូតទៅដើម្បីត្រូវការឲ្យព្រះភគវាស្តេចយាងមក ។ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យទូតនោះហើយ ព្រះអង្គដែលមានភិក្ខុសង្ឃជាច្រើនហែហម ស្តេចយាងចេញចាកក្រុងរាជគ្រឹះ មកកាន់ក្រុងសាវត្ថី ដោយលំដាប់ ក៏បានមកដល់ក្រុងសាវត្ថី ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី បានរៀបចំការធ្វើព្រះវិហារ ក្នុងថ្ងៃដែលព្រះសម្ពុទ្ធស្តេចយាងចូលទៅក្នុងវត្តជេតពន បានតាក់តែងប្រដាប់ប្រដាបុត្រដោយគ្រឿងអលង្ការជាច្រើន ហើយបញ្ជូនទៅព្រមគ្នានឹងកុមារ ៥០០ នាក់ ។ បុត្ររបស់សេដ្ឋី ព្រមទាំងបរិវារនោះ កាន់ទង់ ៥០០ ដោយសំពត់ ៥ ពណ៌ បាននៅខាងមុខៗ ព្រះកក្រ្កនៃព្រះលោកនាយក ។ ខាងក្រោយនៃកុមារទាំងនោះ មានសេដ្ឋីធីតា ២ នាក់ គឺ **នាងសុភទ្ទា** និង **នាងចូឡសុភទ្ទា** ព្រមជាមួយនឹងកុមារី ៥០០ នាក់ កាន់ក្អមទឹកដែលពេញទៅដោយទឹកដើរចេញទៅ ។ ខាងក្រោយនៃកុមារីទាំងនោះ

កិរិយារបស់សេដ្ឋី ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ព្រម ជាមួយនឹងស្ត្រី ៥០០ នាក់ កាន់ភាជនៈពេញទៅដោយអាហារ នៅពី ខាងក្រោយនៃមនុស្សទាំងអស់ អនាថបិណ្ឌិកសេដ្ឋីបានស្លៀកសំពត់ថ្មី ព្រមជាមួយនឹងសេដ្ឋី ៥០០ នាក់ទៀត ដែលជាអ្នកស្លៀកសំពត់ថ្មី ដូចគ្នា ដើម្បីទៅទទួលព្រះសាស្តា ។ ព្រះលោកនាថ ទ្រង់ឲ្យឧបាសក បរិស័ទនៅពីខាងមុខ ហែហមដោយភិក្ខុសង្ឃពួកធំ ទ្រង់ធ្វើចន្លោះព្រៃ ឲ្យដូចជាពណ៌ក្រហមព្រឿងៗ ដែលចាក់ស្រោចដោយរសទឹកមាស ដោយព្រះរស្មីនៃព្រះសរីរៈរបស់ព្រះអង្គ ស្តេចចូលទៅកាន់វត្តជេតពន ដោយពុទ្ធដំណើរ ដែលតជាប់គ្នាដោយពុទ្ធសិរី ដែលរកវត្ថុអ្វីប្រៀបផ្ទឹម ពុំបាន ។ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋីទូលសួរព្រះសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបដិបត្តិក្នុងវិហារនេះ យ៉ាងណា ? ព្រះភគវាត្រាស់ថា នែគហបតី ប្រសិនបើយ៉ាងនោះ ចូរវេរថ្វាយដល់ ភិក្ខុសង្ឃ ដែលនិមន្តមកនោះ នូវវិហារនេះចុះ អនាថបិណ្ឌិកសេដ្ឋី ទទួលព្រះពុទ្ធដីកានៃព្រះវិជិតមារ ហើយបានកាន់ឃ្នោកមាសប្រុចទឹក ដាក់លើព្រះហស្តនៃព្រះលោកនាថ ហើយពោលថ្វាយដោយពាក្យថា ខ្ញុំព្រះអង្គសូមថ្វាយវត្តជេតពននេះ ដល់ភិក្ខុសង្ឃ ដែលនិមន្តមកអំពី

ទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ។ ព្រះសយម្ភូទ្រង់ទទួលវិហារហើយ កាលនឹងទ្រង់ធ្វើការអនុមោទនា បានត្រាស់អានិសង្សនៃការថ្វាយវិហារយ៉ាងនេះថា

សេនាសនៈ រមែងការពារនូវត្រជាក់ និងកម្តៅ និងរមែងការពារនូវសម្ផស្ស រពោម មូស ទឹកសន្សើម និងភ្លៀង ខ្យល់ និងកម្តៅដែលកើតឡើងហើយ រមែងបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយ ការថ្វាយវិហារដល់សង្ឃ ដើម្បីសេចក្តីសុខ ដើម្បីការពិចារណា និងដើម្បីការធ្វើឲ្យជាក់ច្បាស់ ព្រះពុទ្ធទាំងឡាយសរសើរថា ជាទានដ៏ប្រសើរ ។ ព្រោះហេតុនោះឯង បណ្ឌិតកាលបើសម្លឹងឃើញប្រយោជន៍នៃខ្លួន គប្បីកសាងវិហារដ៏រីករាយ វេរប្រគេនភិក្ខុទាំងឡាយ ដែលលោកជាពហូសូតនៅចុះ ។ មួយទៀត គប្បីប្រគេនបាយ ទឹក សំពត់ និងសេនាសនៈដល់ភិក្ខុទាំងនោះ ដោយទឹកចិត្តដ៏ជ្រះថ្លាចំពោះលោកអ្នកស្មោះត្រង់ លោកអ្នកដឹងធម៌ឯណាក្នុងលោកនេះហើយ នឹងជាអ្នកមិនមានអាសវៈ បរិនិព្វាន លោករមែងសម្តែងព្រះធម៌នោះ ដែលជាគ្រឿងបន្ទោបង់នូវទុក្ខទាំងពួងដល់គេ ។

ចាប់ផ្តើមពីថ្ងៃទីពីរទៅ អនាថបិណ្ឌិកសេដ្ឋីផ្តើមការឆ្លងវិហារ ។

ការធ្វើវិហាររបស់មហាឧបាសិកាវិសាខា ៤ ខែ ។ តែការធ្វើវិហារ របស់អនាថបិណ្ឌិកសេដ្ឋី ៩ ខែទើបស្រេច អស់ប្រាក់ ១៨ កោដិ ទិញដី ១៨ កោដិ កសាងទីសេនាសនៈអស់ ១៨ កោដិ សរុបប្រាក់ ដែលលោកអនាថបិណ្ឌិកសេដ្ឋីបរិច្ចាគទ្រព្យអស់ ៥៤ កោដិ ចំពោះ វត្តជេតពន ដោយប្រការដូច្នេះ ។

ក្នុងអតីតកាល ក្នុងសម័យនៃព្រះវិបស្សីសម្ពុទ្ធ សេដ្ឋីឈ្មោះថា **បុនព្វសុមិត្ត** ទិញដីដែលក្រាលដោយឥដ្ឋមាស ហើយឲ្យកសាងសង្ឃារាម ប្រមាណមួយយោជន៍ ។ក្នុងសម័យនៃព្រះសិខីសម្ពុទ្ធ សេដ្ឋីឈ្មោះថា **សិរីវឌ្ឍ** ទិញដីដែលក្រាលដោយបណ្ដាញមាស ហើយឲ្យកសាង សង្ឃារាម ៣ គាវុត ។ ក្នុងសម័យនៃព្រះវេស្សភូសម្ពុទ្ធ សេដ្ឋីឈ្មោះថា **សោត្ថិយៈ** ទិញដីដែលក្រាលដោយស្នាមជើងដំរីមាស ហើយឲ្យកសាង សង្ឃារាមប្រមាណកន្លះយោជន៍ ។ ក្នុងសម័យនៃព្រះកកុសន្ធោសម្ពុទ្ធ សេដ្ឋីឈ្មោះថា **អច្ចុតៈ** ទិញដីដែលក្រាលដោយឥដ្ឋមាស ហើយឲ្យកសាង សង្ឃារាមប្រមាណមួយគាវុត ។ ក្នុងសម័យនៃព្រះកោនាគមនោសម្ពុទ្ធ សេដ្ឋីឈ្មោះថា **ឧគ្គៈ** ទិញដីដែលក្រាលដោយឃ្មោកមាស ហើយឲ្យ កសាងសង្ឃារាមប្រមាណកន្លះគាវុត ។ ក្នុងសម័យនៃព្រះកស្សបសម្ពុទ្ធ

សេដ្ឋីឈ្មោះថា **សុមង្គល** ទិញដីដែលក្រាលដោយឃ្មោកមាស ហើយឲ្យកសាងសង្ឃារាមប្រមាណ ១៦ ករីស ។ តែក្នុងសម័យព្រះភគវា នៃយើងនេះ សេដ្ឋីឈ្មោះថា **អនាថបិណ្ឌិក** ទិញដីដែលក្រាលដោយកហាបណៈចំនួន ១៨ កោដិ ហើយឲ្យកសាងសង្ឃារាមប្រមាណ ៨ ករីស ។ បានឮថា ទីនោះជាកន្លែងដែលព្រះមានព្រះភាគគ្រប់ព្រះអង្គមិនដែលលះបង់ឡើយ ។ ចាប់តាំងអំពីទ្រង់សម្រេចសព្វញ្ញុតញ្ញាណនៅក្រោមដើម **មហាពោធិព្រឹក្ស** រហូតដល់ **ក្រុងកុសិនារា** ជាកន្លែងដែលព្រះអង្គបរិនិព្វាន ព្រះមានព្រះភាគប្រថាប់គង់នៅក្នុងទីកន្លែងណាៗ ទីកន្លែងនោះ ឈ្មោះថា **សន្តិកេនិទាន** ដោយប្រការដូច្នេះ ខ្ញុំបានពណ៌នាជាតកទាំងពួង ដោយអំណាចសន្តិកេនិទានយ៉ាងនោះឯង ។

( ចប់ និទានកថា ដោយប្រការដូច្នេះ )

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអាសាឍ ព.ស ២៥៥៣

**ដោយសមាគមធម្មទានអរិយវង្ស យស់ សុផាត**

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានកុំព្យូទ័រជាដើម ក្នុងកិច្ចការទារជាធម្មទាន

❋ ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បូ ម៉ាឡា ព្រមទាំងបុត្រ

ឧបាសក បូ ស៊ីផូ ឧបាសិកា ចែ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បូ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បូ ដារី

កញ្ញា អ៊ឹង មុយហៀក

❋ **ពុទ្ធសាសនបណ្ឌិត** អ្នកគ្រូ ម៉ម សុខហេង ព្រមទាំងពុទ្ធបរិស័ទខេត្តសៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន់

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឱ ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

❋ ឧបាសក ឡាំ ធៀន ឧបាសិកា សីន ចាន់ថា

លោក លឹម សេងយូ អ្នកស្រី ឡាំ ចាន់សុភី

លោក ឡាំ ចាន់ណា អ្នកស្រី ទូច ចាន់សាក់គ្រីយ៉ា ( ហៅអាមុំ )

លោក ឡាំ ដារ៉ាវណ្ណ កញ្ញា ឡាំ ចាន់រ៉ារី ( ហៅស្រីម៉ៅ )

❋ ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ួន ព្រមទាំងបុត្រ

ញោម ឥម្មន្ទីនិងធូ ញោម ហាន ញោម រ៉ន ញោម ភ័ណ្ឌ ញោមសុមនា
ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា នា ញោម ឆាង
ញោម ធឹង ឡេង ញោម អៀម ញោម ភួង ញោម អ៊ុំភា ញោម សុភា
ញោម វល័ក្ខ ញោម ឆាលី លីណា ញោម ថាក ញោម ផារិន
ញោម ឈឿន ញោម ឡាង ញោម ស៊ិន ញោម ភាព សារឿន
ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា

❋ ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី
លោក ដែង រស្មី និងអ្នកស្រី ជុង ភុយយ៉ា ព្រមទាំងបុត្រ

❋ ឧបាសក អ៊ឹង ហ្គេចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ
លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ
លោក ភូ ពុយ អ្នកស្រី អ៊ឹង ណងពិន ព្រមទាំងបុត្រ
លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ
លោក ប៊ី ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ
ឧបាសិកា ជា នាង និងស្វាមី ពមទាំងបុត្រ

❋ ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ
ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ
ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ ឧបាសិកា សាម៉ុល គីមធន និងអ្នកម្តាយ
ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ
លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អឿន ភី

អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ + ហ៊ី ជាង + ជា មុយហាង គុយ លឹម + សេង មុយនី + ចៅ ជីវ ស៊ុយលៀប + ថៃ អេង + គឹម ធី ខៀវ វ៉ន + គឹម នឿង + យាយ ឆឹង + គួង ភាង + សើន គា + សឿង គឹម អាង + សេង ឆេង + ផាន់ វ៉ាន់ + យាយ រ៉ុំ + យាយ ហ៊ឹង + ឡាំម៉ាលី ផាន សុផាត + យាយ ម៉ៅ + ពៅ + ឈួន + ក. កាវ៉ាឡែន + ថៃ ង៉ា សាមណេរ អ៊ុំ វីរៈ + លោកគ្រូ រី រុត្ន + អ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា ថៃ ង៉ាថ្មគោល + អ្នកស្រី លេង យ៉ុង + តី លី + នាង ឈៀត + ហ៊ឹង នាង មឿន + អួន ប៉ុច + ឡាត វ៉ាន់យិន + ម៉ម សុខហេង + គឹម ឡេង តាំង រេន + យុន + យាយ ធុច + យាយ ឃន + ហ៊ន ស៊ម + អឿន ភី វ៉ាន់ ស៊ុនឡាយ + ផល្លី និងសវាមី + ឡុង សារី + ជា សុខហ៊ាង + គុយ លឹម សេង ទូច + ស៊ីវ ទី + ណោ ហ្គេចណៃ + វ៉ាន់ សុផានី + សា រឿន + សំ គី ចាន់ ណាវ៉ា + ធាវ៉ា + ឃៀត និងស្វាមី + ហួត អេង + អារ សុវណ្ណី ណា ស៊ុ + យាយ នៅ + ឈុន គាវ + យាយ ឪ + សំ វ៉ាន់នី + គឹម អ៊ី អៀប សាន្ទួន + យាយ ហៀន + យាយ ឡាំ + ភេន សេងមុំ + ស ខាន់ថង ស៊ី ណាត + ឃឿន + ចាន់ នី + ផន សារ៉ន + កោ ហុង ។

# នាមពុទ្ធបរិស័ទជួយចំណាយប្រាក់កាស ក្នុងកិច្ចការខារធម្មទាន

| | |
|---|---|
| ឧបាសក រៀម ឈីន | ឧបាសិកា ប៊ូ ម៉ុន |
| ឧបាសក ញ៉ែម មឿន | ឧបាសិកា រៀម ថុល ព្រមទាំងកូនចៅ |
| ឧបាសក អ៊ឹង ប៊ុនហួរ | ឧបាសិកា បូ ម៉ាឡា ព្រមទាំងកូនចៅ |
| ឧបាសក នាង រ៉ា | ឧបាសិកា តែម ធារីម ព្រមទាំងបុត្រ |
| ឧបាសក សៅ ស៊ុន្ទរា | ឧបាសិកា ប៊ុន មុំ ព្រមទាំងបុត្រ |
| ឧបាសក ណូ ស្វែង | ឧបាសិកា សោម គឹមលួន ព្រមទាំងបុត្រ |
| ឧបាសិកា ង៉ិន យ៉ុន | អ្នកស្រី សួស សុខា ព្រមទាំងបុត្រ |
| ឧបាសិកា សោម គឹមលឿម | និងស្វាមី ព្រមទាំងបុត្រ |
| ឧបាសិកា គឹម ឆវី | និងស្វាមី ព្រមទាំងបុត្រ |
| ឧបាសិកា ទាវ គឹម យក់ | ឧបាសិកា អ៊ឹម គឹមជីវ |
| ឧបាសិកា គី វណ្ណហាក់ | ឧបាសិកា ឡាំ ម៉ាលី |
| ឧបាសិកា ហួត អេង | ឧបាសិកា ឡោ សាយហ្គិច |
| ឧបាសិកា ង៉ែត យូអេង | ព្រមទាំងបុត្រ |
| ឧបាសិកា អ៊ុក នៅ | ព្រមទាំងបុត្រ |
| ឧបាសិកា សឿង | ព្រមទាំងបុត្រ |

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការឧបត្ថម្ភធម្មទាន

| | |
|---|---|
| ១ ឧបាសក ប៉េង តាំងហៃ | ឧបាសិកា ហ៊ូ គីមហៀក |
| ២ ឧបាសក ឡាយ សុខុម | ឧបាសក ម៉ៅ ផុន |
| ៣ ឧបាសិកា បូ ម៉ាឡា | កញ្ញា បូ ដារី |
| ៤ ឧបាសិកា ង៉ែត យូអេង | កញ្ញា អ៊ឹង មុយហៀក |
| ៥ ឧបាសក លឹម ខូង | ឧបាសិកា កែវ អួន |
| ៦ ឧបាសិកា កែវ កល្យាណ | ឧបាសិកា សុខ សុទ្ធី |
| ៧ ឧបាសក សីន ចន្ថា | លោក ឡាំ ដារ៉ាវណ្ណ |
| ៨ ឧបាសិកា នេត្រ នរិន្ទ | ឧបាសិកា ទន់ |
| ៩ ឧបាសិកា ឱម លក្ខណា | ឧបាសិកា ហេង ចន្ទបុញ្ញវតី |
| ១០ ឧបាសិកា អ៊ឹង រិទ្ធារី | ឧបាសក អ៊ុន សេរី |
| ១១ ឧបាសិកា គី យក់បួយ | ឧបាសិកា ឈុន ណាត |
| ១២ ឧបាសិកា រៀម ថុល | ឧបាសិកា ម៉ៅ នី |
| ១៣ ឧបាសក សន ឈៀត | ឧបាសក ឡាន សុខុម |
| ១៤ ឧបាសិកា គី វណ្ណហាក់ | ឧបាសិកា ប៉ាន ណម |
| ១៥ ឧបាសិកា ស្ងួន កល្យាណ | ឧបាសិកា ភួង ភក្តី |
| ១៦ ឧបាសក អ៊ឹម រ៉ៃយ៉ា | ឧបាសក កុយ សាមន |

# នាមពុទ្ធបរិស័ទដែលមានសទ្ធា
# បរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

ល.រ

| | | |
|---|---|---|
| 001 | លោកគ្រូបណ្ឌិត អឿ សៅ ..................... | ១៥០ $ |
| 00២ | ឧ.សិ អ៊ីង រិទ្ធារី ឧ.ស ប៊ូ ហោនាង + បុត្រ ......... | ២០០ $ |
| 00៣ | ឧ.ស មុត មឿន ឧ.សិ អ៊ិត យ៉ន + បុត្រ ........... | ២០០ $ |
| 00៤ | ឧ.ស អៀប ហៃសាន និងភរិយា និងបុត្រ ............ | ១៧០ $ |
| 00៥ | ឧ.ស លីម ប៉េងជាវ ឧ.សិ អ៊ុង គឹមគី + បុត្រ ...... | ១៥០ $ |
| 00៦ | ឧ.ស បេង ឡាំងគី និងគ្រួសារ ពិន ហេង + បុត្រ. | ១៥០ $ |
| 00៧ | ឧ.ស ម៉ៅ វង្ស ឧ.សិ ឆាន់ កាន់ជួង + បុត្រ ......... | ១០០ $ |
| 00៨ | ឧ.សិ ឆាន់ ហៃគីង ព្រមទាំងបុត្រធីតា ................ | ១០០ $ |
| 00៩ | ឧ.ស កឿត វ៉ាន ឧ.សិ ហ៊ូ អ ................. | ១០០ $ |
| 0១០ | ឧ.សិ ប៉ុក យឿន និងស្វាមី ព្រមទាំងបុត្រ ........... | ១០០ $ |
| 0១១ | ឧ.ស មុត មឿន ឧ.សិ អ៊ិត យ៉ន + បុត្រ ........... | ១០០ $ |
| 0១២ | ឧ.ស ពេជ្រ យ៉ុន ឧ.សិ ពេជ្រ យ៉ែម + បុត្រ ...... | ៦០ $ |
| 0១៣ | ឧ.ស យិម សំណាង ឧ.សិ យឹម ចាន់ថូ + បុត្រ ... | ៦០ $ |
| 0១៤ | ឧ.សិ សេក ធវី + សុគន្ធី + ធឿត + ចៅ ......... | ៥០ $ |
| 0១៥ | ឧ.ស យន ធារី ឧ.សិ សេក ចាន់ខេមា+មល្លិកា+អមរា | ៥០ $ |
| 0១៦ | ឧ.ស ម៉ាង មេង ឧ.សិ ទេព លក្ខណា + បុត្រធីតា .. | ៥០ $ |

| | | | |
|---|---|---|---|
| ០១៧ | ឧ.សិ ចាន់ រ៉ាវី ព្រមទាំងបុត្រធីតា | .......... | ៥០ $ |
| ០១៨ | ឧ.សិ យក់ ស៊ីម៉ូរ៉ា ព្រមទាំងបុត្រធីតា | ........... | ៥០ $ |
| ០១៩ | ឧ.សិ លាង ញ៉ ព្រមទាំងបុត្រធីតា | ........... | ៥០ $ |
| ០២០ | ឧ.សិ តាំង លេខគៀវ ព្រមទាំងបុត្រធីតា | ........... | ៥០ $ |
| ០២១ | ឧ.ស សៅ ហ៊ាន ឧ.សិ មាស ម៉ូលិកា + បុត្រ .. | | ៥០ $ |
| ០២២ | ឧ.សិ រ៉ាន់ ស៊ុន ព្រមទាំងបុត្រ | ............. | ៥០ $ |
| ០២៣ | ឧ.សិ លីប៉ូលីមស៊ីមប៉ូ ព្រមទាំងបុត្រ | ............. | ៤៥ $ |
| ០២៤ | ឧ.សិ សួន លាង ព្រមទាំងបុត្រ | ............. | ៤៥ $ |
| ០២៥ | ឧ.សិ លី បេន ព្រមងទាំងបុត្រ | ............. | ៤០ $ |
| ០២៦ | ឧ.សិ ខៀវ ណាត ព្រមទាំងបុត្រ | ............. | ៣០ $ |
| ០២៧ | ឧ.ស ហេម ហឿន ឧ.សិ ផាន់ ទូច + បុត្រ .......... | | ៣០ $ |
| ០២៨ | ឧ.សិ ផេង នាង ព្រមទាំងបុត្រ | .......... | ២០ $ |
| ០២៩ | ឧ.សិ ឡាច រ៉ុំ ព្រមទាំងបុត្រធីតា | .......... | ២០ $ |
| ០៣០ | ឧ.សិ ទឹម ហ៊ាន ព្រមទាំងបុត្រធីតា | .......... | ២០ $ |
| ០៣១ | ឧ.សិ ពុធ សេង ព្រមទាំងបុត្រធីតា | .......... | ២០ $ |
| ០៣២ | ឧ.សិ លី គី ឧ.ស ស៊ុន ថា + បុត្រធីតា | .......... | ២០ $ |
| ០៣៣ | ឧ.សិ វុណា ចរណៃ ព្រមទាំងបុត្រធីតា | .......... | ២០ $ |
| ០៣៤ | ឧ.សិ អ៊ី លេនសឿន ព្រមទាំងបុត្រធីតា | .......... | ២០ $ |
| ០៣៥ | ឧ.សិ ង៉ាន មុំ ឧ.ស ឈាង ឆេង +បុត្រធីតា ....... | | ២០ $ |

| | | |
|---|---|---|
| ០៣៦ | ឧ.ស អៀម វ៉ន ឧ.សិ សុខ សៅរិន ........... | ២០ $ |
| ០៣៧ | ឧ.ស និន ហាក់ ឧ.សិ លុយ ចាន់ថន +បុត្រធីតា ... | ២០ $ |
| ០៣៨ | ឧ.សិ គីម ឈាង ព្រមទាំងបុត្រធីតា ................ | ២០ $ |
| ០៣៩ | ឧ.សិ ឈោ គីមហោ និងបុត្រធីតា ................ | ២០ $ |
| ០៤០ | ឧ.សិ ថោង បូនី និងស្វាមី ព្រមទាំងបុត្រ ................ | ២០ $ |
| ០៤១ | កុមារី ឃីម អមរា ............. | ២០ $ |
| ០៤២ | ឧ.សិ ឡុង សេងហ៊ុន ឧ.ស សួស ចាន់ធី ............. | ២០ $ |
| ០៤៣ | ឧ.សិ លី ចាន់ស៊ីវ៉ាន និងស្វាមី ព្រមទាំងបុត្រ ........ | ១៥ $ |
| ០៤៤ | ឧ.ស សេង នឹម ព្រមទាំងបុត្រធីតា ............. | ១៥ $ |
| ០៤៥ | ឧ.ស ផាត សាវឿយ ព្រមទាំងបុត្រធីតា ............ | ១៥ $ |
| ០៤៦ | ឧ.សិ វ៉ាត អម ព្រមទាំងបុត្រធីតា ............. | ១៤ $ |
| ០៤៧ | ឧ.សិ ឈុន អៀង និងស្វាមី ព្រមទាំងបុត្រធីតា ...... | ១៤ $ |
| ០៤៨ | ឧ.ស ទឹម ឡាប ឧ.សិ ចាន់ នេត្រ + បុត្រធីតា ....... | ១០ $ |
| ០៤៩ | ឧ.ស សៀង ខេមរវុធ ព្រមទាំងបុត្រធីតា ......... | ១០ $ |
| ០៥០ | ឧ.សិ តាន់ វ៉ាន់ណា ព្រមទាំងបុត្រ ............ | ១០ $ |
| ០៥១ | ឧ.ស ម៉ម សុជាត និងភរិយា ព្រមទាំងបុត្រ ......... | ១០ $ |
| ០៥២ | ឧ.សិ ដួន ធី និងបុត្រធីតា ........................... | ១០ $ |

តម្លៃបោះពុម្ពក្នុង ១៧០០ ក្បាល = ២៥១៤ $

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទមានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនង តាមរយៈលេខទូរស័ព្ទ ០១២ ៣០៥ ៧៦៦ នេះក៏បាន ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ ៖

**-ជីវប្រវត្តិរបស់ពុទ្ធសាវិកា ( ភិក្ខុនី )** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-ជីវប្រវត្តិពុទ្ធឧបាសក** មាន ៥ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៥ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ សព្វថ្ងៃនេះបានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

-ធម៌សូធ្យនមស្ការ បែបសម័យទំនើប សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៤៥០ ទំព័រជាង ។

-ពុទ្ធប្បវត្តិ សព្វថ្ងៃនេះបានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៣៤៦ ទំព័រ ។

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពតែប៉ុណ្ណោះ ។

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស សព្វថ្ងៃនេះ កំពុងតែវាយកុំព្យូទ័រ ប្រហែលជាមាន ៤-៥ ភាគដែរ ។

-គម្ពីរសារត្ថសង្គហៈ ហើយសព្វថ្ងៃនេះ បានធ្វើរួចជាស្ថាពរ គឺវាយកុំព្យូទ័ររួចជាស្រេចអស់ហើយទាំង ៣ ភាគ ដែលមានកម្រាស់

រហូតទៅដល់ ៤០០ ទំព័រជាង ។

-មានបំណងនិងរៀបចំធ្វើអដ្ឋកថាដែល ៩១ ក្បាលទៀត

-អភិធម្មមត្ថសង្គហៈ និង បរមត្ថទីបនីដីកា

បោះពុម្ពជាធម្មទាន ១៧00 ក្បាល

ក្នុងតម្លៃ ២៥១៨ ដុល្លារ

រោងពុម្ព ភ្នំពេញ

TEL : 012597431

ពុទ្ធបរិវត្តិកថា -៣៤៦-

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ

## ខ្ញុំព្រះករុណា អាត្មាភាព

## ✍ យង់ សុផាត ✍

| | |
|---|---|
| ១ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ១ |
| ២ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ២ |
| ៣ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ៣ |
| ៤ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ៤ |
| ៥ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ៥ |
| ៦ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ៦ |
| ៧ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ៧ |
| ៨ | ជីវប្រវត្តិព្រះអសីតិមហាសាវ័ក ភាគ ៨ |
| ៩ | ជីវប្រវត្តិពុទ្ធសាវិកា ភាគ ១ |
| ១០ | វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស |
| ១១ | វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សាមាធិនិទ្ទេស ភាគ ១ |

**សូមអនុមោទនាចម្មទាន !**








ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគត
ប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយ
មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ
ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តី
មិនប្រមាទចុះ ។